ក្រសួងបរិស្ថាន ត្រូវរៀបចំប្រកាសស្តីពីគោលការណ៍ណែនាំ លើការគ្រប់គ្រងសំណល់ប្រកបដោយគ្រោះថ្នាក់ ដើម្បីធានាបាននូវការគ្រប់គ្រងប្រកបដោយសុវត្ថិភាព។

មាត្រា១៣.-

ម្ចាស់សំណល់ត្រូវទទួលខុសត្រូវក្នុងការទុកដាក់ ឬស្តុកទុកជាបណ្តោះអាសន្ននូវសំណល់ប្រកបដោយគ្រោះថ្នាក់របស់ខ្លួន តាមលក្ខណៈបច្ចេកទេសសមស្រប និងមានសុវត្ថិភាព។

មាត្រា១៤.-

ម្ចាស់សំណល់ត្រូវធ្វើ និងធ្វើរៀងរាល់បីខែម្តងទៅក្រសួងបរិស្ថាននូវរបាយការណ៍ដែលទាក់ទងនឹងសំណល់ប្រកបដោយគ្រោះថ្នាក់នៅក្នុងមូលដ្ឋានរបស់ខ្លួន រួមមាន៖

ក-ប្រភេទ និងបរិមាណសំណល់

ខ-វិធីសាស្ត្រក្នុងការទុកដាក់ ឬស្តុកទុកជាបណ្តោះអាសន្ន

គ-វិធីសាស្ត្រក្នុងការសំអាតសំណល់ ឬបំបាត់សំណល់។

មាត្រា១៥.-

ការទុកដាក់ ស្តុក ដឹកជញ្ជូន និងការបោះចោល ឬដាក់ចោលសំណល់ប្រកបដោយគ្រោះថ្នាក់ត្រូវអនុវត្តដាច់ដោយឡែកពីសំរាមធម្មតា ដែលនឹងមានចែងនៅក្នុងប្រកាសរបស់ក្រសួងបរិស្ថាន។ ហាមឃាត់ជា

ដាច់ខាតការបោះចោល ឬការចាក់ចោលសំណល់ប្រកបដោយគ្រោះថ្នាក់នៅតាមទីសាធារណៈ ប្រព័ន្ធលូសាធារណៈ ប្រភព ឬបណ្តាញផ្លូវទឹក តំបន់ជនបទ និងតំបន់ព្រៃភ្នំ។

មាត្រា១៧.-

ការដឹកជញ្ជូន ឬសាងសង់ទីកន្លែងចាក់ ឬទីកន្លែងស្តុកសំណល់ប្រកបដោយគ្រោះថ្នាក់ដែលមានប្រភពពីរោងចក្រសហគ្រាស និងមូលដ្ឋានផលិតកម្ម ត្រូវមានការអនុញ្ញាតពីក្រសួងបរិស្ថានជាមុន។

មាត្រា១៨.-

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវទីកន្លែងចាក់ ឬស្តុកសំណល់ប្រកបដោយគ្រោះថ្នាក់ ត្រូវធ្វើ និងធ្វើរៀងរាល់បីខែម្តងទៅក្រសួងបរិស្ថាន នូវរបាយការណ៍ដែលទាក់ទងទៅនឹងសំណល់ដែលបានដឹកយកមកចាក់ចោល ឬស្តុកនៅកន្លែងរបស់ខ្លួន រួមមាន៖

ក-ប្រភេទ និងបរិមាណសំណល់

ខ-ប្រភពដើមរបស់សំណល់

គ-ការដឹកជញ្ជូន និងមធ្យោបាយវេចខ្ចប់

ឃ-ដំណើរការ និងការគ្រប់គ្រងសំណល់នៅក្នុងទីកន្លែងរបស់ខ្លួន។

មាត្រា១៩.-

ការវិនិយោគលើការធ្វើប្រព្រឹត្តកម្មសំអាត ឬដុតសំណល់ប្រកបដោយគ្រោះថ្នាក់ ត្រូវមានការឯកភាពពីក្រសួងបរិស្ថានជាមុនសិន។

មាត្រា២២.-

ការត្រួតពិនិត្យលើការវេចខ្ចប់ ទុកដាក់ ស្តុក ដឹកជញ្ជូន កែច្នៃ ដុត ធ្វើប្រព្រឹត្តកម្មសំអាតជាតិពុល និងការចាក់ចោលសំណល់ប្រកបដោយគ្រោះថ្នាក់ គឺជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន។

មាត្រា២៦.-

ក្នុងករណីមានពាក្យបណ្តឹង ឬសេចក្តីរាយការណ៍ថា មានស្តុកទុក ឬការចាក់ចោលនូវសំណល់ប្រកបដោយគ្រោះថ្នាក់បណ្តាលឲ្យប៉ះពាល់ទៅដល់សុខភាពមនុស្ស សត្វ ឬទ្រព្យសម្បត្តិសាធារណៈ ឬបង្កឲ្យមានការបំពុលបរិស្ថាន ក្រសួងបរិស្ថានត្រូវចុះធ្វើអធិការកិច្ចជាបន្ទាន់ ហើយត្រូវជូនពត៌មានទៅបណ្តាស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន។

តារាងឧបសម្ព័ន្ធ ប្រភេទសំណល់ប្រកបដោយគ្រោះថ្នាក់

...

៣-សំណល់ភក់ដែលបង្កើតឡើងដោយរោងចក្រប្រព្រឹត្តកម្មសំអាតសំណល់រាវ និងទឹកលូ

...

៨-សំណល់ប្រេងឥន្ធនៈ និងប្រេងម៉ាស៊ីន

៩-សំណល់ដែលមានផ្ទុកជាតិអាស៊ីត

១០-សំណល់ដែលមានផ្ទុកជាតិបាស

...

Draft

១២-លំអងផ្សែង និងធូលីដែលកើតមានក្នុងករណីសំអាតផ្សែងបញ្ចេញពីមូលដ្ឋានផលិតកម្ម

...

៣.៣.៣ អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេង (២០០០)

អនុក្រឹត្យលេខ ៤២ អនក្រ.បក ស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេង ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០ បានចែងថា៖

មាត្រា២.-

អនុក្រឹត្យនេះមានវិសាលភាពអនុវត្ត និងចាត់វិធានការចំពោះរាល់ប្រភពបំពុលចល័ត និងអចល័ត ទាំងឡាយដែលបង្កឲ្យមានការបំពុលខ្យល់ និងការរំខានដោយសម្លេងនៅក្នុងបរិយាកាស។

មាត្រា៣.-

និយមន័យពាក្យបច្ចេកទេសដែលប្រើក្នុងអនុក្រឹត្យនេះត្រូវបានបកស្រាយដូចតទៅ៖

ក-ប្រភពបំពុលចែកចេញជាពីរគឺ៖

-ប្រភពចល័ត៖ គឺជាប្រភពដែលស្ថិតនៅទីតាំងមិនអចិន្ត្រៃយ៍ ជាអាទិ៍មាន៖ យន្តហោះ នាវាដឹកជញ្ជូន យានយន្ត គ្រឿងយន្ត និងគ្រឿងបំពងសម្លេងគ្រប់ប្រភេទ។

-ប្រភពអចល័ត៖ គឺជាប្រភពដែលស្ថិតនៅលើទីតាំងអចិន្ត្រៃយ៍មួយកន្លែង ជាអាទិ៍មាន៖ រោងចក្រ សហគ្រាស ឃ្លាំងស្តុកសម្ភារៈ ការដ្ឋានសំណង់ ឡដុតសំរាម គ្រឿងបំពងសម្លេង សិប្បកម្ម និងកសិដ្ឋាន គ្រប់ប្រភេទ។

ខ-សារធាតុបំពុល គឺសំដៅលើផ្សែង លំអងផ្សែង ធូលី ផេះ ភាគល្អិតនៃសំណល់ ឧស្ម័ន ចំហាយទឹក អ័ព្ទ ក្លិន និងសារធាតុវិទ្យុសកម្ម។

គ-សារធាតុឆេះ គឺសំដៅទៅលើប្រេងឥន្ធនៈ ធ្យូងថ្ម ឧស្ម័នធម្មជាតិ អុស ធ្យូង ឬសារធាតុគីមីផ្សេងៗ ទៀត ដែលមានប្រតិកម្មចំហេះ

ឃ-កម្រិតកំណត់ស្តង់ដារ គឺជាកម្រិតកំណត់កំហាប់អតិបរមានៃសារធាតុបំពុល ដែលអាចអនុញ្ញាត មាននៅក្នុងមជ្ឈដ្ឋានបរិស្ថាន ឬដែលអាចអនុញ្ញាតឲ្យបញ្ចេញពីប្រភពបំពុលចូលទៅក្នុងបរិស្ថាន។

មាត្រា៤.-

កម្រិតកំណត់ស្តង់ដារគុណភាពខ្យល់ មានចែងនៅក្នុងតារាងឧបសម្ព័ន្ធ១ និងកម្រិតកំណត់ស្តង់ដារ អតិបរមានៃសារធាតុប្រកបដោយគ្រោះថ្នាក់ ដែលអនុញ្ញាតឲ្យមាននៅក្នុងខ្យល់មានចែងនៅក្នុងតារាង ឧបសម្ព័ន្ធ២។

មាត្រា៨.-

ហាមឃាត់ដាច់ខាតនូវការបញ្ចេញសារធាតុបំពុលទៅក្នុងបរិយាកាស ដែលមិនឆ្លើយតបទៅនឹង កម្រិតកំណត់ស្តង់ដារ ដូចមានចែងក្នុងតារាងឧបសម្ព័ន្ធ៣ និងឧបសម្ព័ន្ធ៤។

មាត្រា៩.-

ហាមដាច់ខាតនូវការបង្កឲ្យមានសំលេង ដែលមិនឆ្លើយតបទៅនឹងកម្រិតកំណត់ស្តង់ដារដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធ៥ ឧបសម្ព័ន្ធ៦ ឧបសម្ព័ន្ធ៧។

មាត្រា១២.-

ហាមដាច់ខាតការបង្ហូរ ឬការធ្វើឲ្យលេចធ្លាយសារធាតុឆេះ ប្រេងឥន្ធនៈ ធាតុវិទ្យុសកម្ម ឬសារធាតុគីមីផ្សេងៗទៀតចូលក្នុងបរិយាកាស ទឹក និងដី។

មាត្រា១៣.-

ការបញ្ចេញសារធាតុបំពុល និងសំលេងចូលទៅក្នុងបរិយាកាសពីប្រភពអចល័ត ត្រូវសុំការអនុញ្ញាតពីក្រសួងបរិស្ថាន និងត្រូវធ្វើសេចក្តីចំលងនៃពាក្យសុំនោះទៅក្រសួងស្ថាប័នពាក់ព័ន្ធ។

មាត្រា១៥.-

ការសុំអនុញ្ញាតលើការបញ្ចេញសារធាតុបំពុល និងសំលេងដូចមានចែងក្នុងមាត្រា១៣នៃអនុក្រឹត្យនេះ នឹងត្រូវអនុវត្តទៅលើប្រភពបំពុលទាំងគម្រោងថ្មី និងសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការលើកលែងតែគម្រោងដែលមានរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានរួចហើយ។

មាត្រា១៦.-

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលដូចមានចែងក្នុងមាត្រា១៣នៃអនុក្រឹត្យនេះ ត្រូវដាក់ពាក្យសុំការអនុញ្ញាតមកក្រសួងបរិស្ថាន៖ ឲ្យបានមុន៤០ថ្ងៃនៃការចាប់ផ្តើមដំណើរការសម្រាប់គម្រោងនៅភ្នំពេញ។ ឲ្យបានមុន៦០ថ្ងៃនៃការចាប់ផ្តើមដំណើរការសម្រាប់គម្រោងនៅតាមខេត្ត-ក្រុង។

មាត្រា១៧.-

ការត្រួតពិនិត្យនូវបរិមាណជាតិពុលក្នុងសារធាតុឆេះ ការបញ្ចេញសារធាតុបំពុលខ្យល់ និងសម្លេងពីប្រភពអចល័តជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន។

មាត្រា១៨.-

ការត្រួតពិនិត្យនូវការបញ្ចេញឧស្ម័ន និងសម្លេងពីប្រភពចល័ត ជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថានដោយមានកិច្ចសហការពីក្រសួងស្ថាប័នពាក់ព័ន្ធ។ ចំពោះនីតិវិធីក្នុងការត្រួតពិនិត្យនេះ ត្រូវកំណត់ដោយប្រកាសរួមរបស់អន្តរក្រសួង។

មាត្រា១៩.-

ក្រសួងបរិស្ថានត្រូវរៀបចំគោលការណ៍ណែនាំបច្ចេកទេស ស្តីពីវិធីសាស្ត្រត្រួតពិនិត្យប្រភពបំពុល វិធីសាស្ត្រកំណត់ទីតាំងយកគំរូតាង និងវិធីសាស្ត្រវិភាគគុណភាពខ្យល់ និងសម្លេង។

មាត្រា២៤.-

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវទាំងអស់ត្រូវ៖

-ទទួលខុសត្រូវក្នុងការដំឡើង ឬបំពាក់ឧបករណ៍ច្រោះសំអាតសារធាតុបំពុល និងឧការណ៍ សម្រាប់កាត់បន្ថយសម្លេង ដើម្បីឲ្យឆ្លើយតបនឹងកម្រិតកំណត់ស្តង់ដារ។

-ទទួលខុសត្រូវក្នុងការដំឡើងគ្រឿងបរិក្ខារវាស់ស្ទង់សារធាតុបំពុល ដែលបញ្ចេញពីប្រភពបំពុលរបស់ខ្លួន និងត្រូវរក្សាលទ្ធផលទុកជាឯកសារ ហើយត្រូវធ្វើរបាយការណ៍មកក្រសួងបរិស្ថានរៀងរាល់ ៣ខែម្តង។

-ជ្រើសរើសអ្នកជំនាញបរិស្ថានចំនួននមួយរូប ជាអ្នកទទួលខុសត្រូវក្នុងកិច្ចសម្របសម្រួលការងារបរិស្ថាន និងរៀបចំផែនការការពារបរិស្ថានក្នុងមូលដ្ឋានរបស់ខ្លួន ដែលក្រសួងបរិស្ថានអាចផ្តល់ការបណ្តុះបណ្តាលតាមសំណូមពររបស់ម្ចាស់កម្មសិទ្ធិ។

មាត្រា២៥.-

ក្នុងករណីដែលរកឃើញថា ការបញ្ចេញសារធាតុបំពុលខ្យល់ និងសម្លេងពីប្រភពណាមួយពុំបានឆ្លើយតបទៅនឹងកម្រិតកំណត់ស្តង់ដារដូចមានចែងក្នុងមាត្រា៥ មាត្រា៧នៃអនុក្រឹត្យនេះ ក្រសួងបរិស្ថានត្រូវ៖ ក-ចេញបញ្ជាជាលាយលក្ខណ៍អក្សរតម្រូវឲ្យម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលនោះ ផ្អាកសកម្មភាពរបស់ខ្លួនជាបណ្តោះអាសន្ន រហូតដល់បទល្មើសនោះត្រូវបានកែប្រែ ប្រសិនបើសកម្មភាពល្មើសបង្កឲ្យមានគ្រោះថ្នាក់ដល់សុខភាពសាធារណៈ ឬប៉ះពាល់ដល់គុណភាពបរិស្ថាន។

មាត្រា៣០.-

ករណីមានពាក្យបណ្តឹង ឬសេចក្តីរាយការណ៍ថាប្រភពបំពុលណាមួយបានបញ្ចេញសារធាតុបំពុលខ្យល់ ឬសម្លេង ឬរំញ័របង្កឲ្យមានគ្រោះថ្នាក់ដល់សុខភាព ឬទ្រព្យសម្បត្តិសាធារណៈ ក្រសួងបរិស្ថានដោយសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធមានសិទ្ធិធ្វើអធិការកិច្ចនៅក្នុងបរិវេណប្រភពបំពុលនោះ និងយកគំរូតាងមកធ្វើការវិភាគ។

តារាង ៣.១៖ កម្រិតកំណត់ស្តង់ដារគុណភាពខ្យល់

ល.រ	ប៉ារ៉ាម៉ែត្រ	រយៈពេល ១ម៉ោង ជាមធ្យម mg/m^3	រយៈពេល៨ម៉ោង ជាមធ្យម mg/m^3	រយៈពេល២៤ម៉ោង ជាមធ្យម mg/m^3	រយៈពេល ១ឆ្នាំ ជាមធ្យម mg/m^3
១	កាបូនអុកស៊ីត CO	៤០	២០		
២	អាសូតឌីអុកស៊ីត NO_2	០,៣		០,១០	
៣	ស្ពានធ័រឌីអុកស៊ីត SO_2	០,៥		០,៣០	០,១០
៤	អូសូន O_3	០,២			
៥	សំណ Pb			០.០០៥	
៦	សារធាតុរឹងអណ្តែតក្នុង ខ្យល់ TSP			០,៣៣	០,១០

កំណត់សំគាល់

-កម្រិតកំណត់ស្តង់ដារនេះ អនុវត្តសម្រាប់ធ្វើការវាយតម្លៃគុណភាពខ្យល់ទូទៅ និងអង្កេតតាមដានស្ថានភាពនៃការបំពុលខ្យល់

-វិធីសាស្ត្រនៃការវិភាគគុណភាពខ្យល់នឹងត្រូវកំណត់តាមគោលការណ៍ណែនាំរបស់ក្រសួងបរិស្ថាន

-TSP – Total Suspended Particulate

តារាង ៣.២៖ កម្រិតកំណត់ស្តង់ដារសំលេងអតិបរមាដែលអនុញ្ញាតនៅតំបន់សាធារណៈ និងតំបន់ លំនៅដ្ឋាន

ល.រ	ទីតាំង ម៉ោង ១៨ល្ងាច	អំឡុងពេល		
		ពីម៉ោង ៦ព្រឹក ដល់ម៉ោង ២២យប់	ពីម៉ោង ១៨ល្ងាច ដល់ម៉ោង ៦ព្រឹក	ពីម៉ោង ២២យប់
១	តំបន់ស្ងប់ស្ងៀម –មន្ទីរពេទ្យ –បណ្ណាល័យ –សាលារៀន –មត្តេយ្យសាលា	៤៥	៤០	៣៥
២	តំបន់លំនៅដ្ឋាន –សណ្ឋាគារ, ទីកន្លែង រដ្ឋបាល –ភូមិគ្រឹះ, ផ្ទះល្វែង	៦០	៥០	៤៥
៣	តំបន់ពាណិជ្ជកម្ម, សេវាកម្ម និងចម្រុះ	៧០	៦៥	៥០
៤	ឧស្សាហកម្មធន់ស្រាលលាយ ចម្រុះនៅក្នុងតំបន់លំនៅដ្ឋាន	៧៥	៧០	៥០

កំណត់សំគាល់

កម្រិតកំណត់ស្តង់ដារនេះអនុវត្តសម្រាប់ការត្រួតពិនិត្យកម្រិតសំលេងពីប្រភព ឬសកម្មភាពណាមួយ ដែលបញ្ចេញសំលេងចូលក្នុងតំបន់សាធារណៈ និងតំបន់លំនៅដ្ឋាន។

៣.៣.៨ អនុក្រឹត្យស្តីពីការបំពុលទឹក

អនុក្រឹត្យលេខ ២៧អនក្រ.បក ស្តីពីការត្រួតពិនិត្យការបំពុលទឹក បានអនុម័តនៅថ្ងៃទី០៦ ខែមេសា ឆ្នាំ១៩៩៩។ មាត្រា១ អនុក្រឹត្យនេះ មានគោលដៅកំណត់ការត្រួតពិនិត្យការបំពុលទឹក ដើម្បីទប់ស្កាត់ និង កាត់បន្ថយការបំពុលទឹកនៅតាមតំបន់ទឹកសាធារណៈ សំដៅធានាបានការការពារសុខភាពមនុស្ស និងការ

Draft

អភិរក្សជីវៈចម្រុះ។ មាត្រា២ អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះរាល់ប្រភពបំពុល និងរាល់សកម្មភាពទាំងឡាយដែលបង្កឲ្យមានការបំពុលទឹកនៅតាមតំបន់ទឹកសាធារណៈ។

ដូច្នេះរាល់សកម្មភាពរបស់គម្រោង ត្រូវអនុវត្តតាមការកំណត់នូវស្តង់ដារការបំពុលទឹក នៃអនុក្រឹត្យនេះដែលមានភ្ជាប់ឧបសម្ព័ន្ធចំនួន ០៥រួមមាន៖

-ឧបសម្ព័ន្ធ១៖ ប្រភេទសារធាតុប្រកបដោយគ្រោះថ្នាក់

-ឧបសម្ព័ន្ធ២៖ កម្រិតស្តង់ដារនៃការបញ្ចេញសំណល់រាវពីប្រភពបំពុលចូលទៅក្នុងតំបន់ទឹកសាធារណៈ ឬទៅក្នុងប្រព័ន្ធបណ្តាញលូ

-ឧបសម្ព័ន្ធ៣៖

ប្រភេទនៃសារធាតុពុលដែលតម្រូវឲ្យមានការអនុញ្ញាតពីក្រសួងបរិស្ថាននិងបញ្ចេញចោលនូវសំណល់រាវរបស់ខ្លួនឬដឹកទៅទីដ៏ទៃ។

-ឧបសម្ព័ន្ធ៤៖

កម្រិតកំណត់ស្តង់ដារគុណភាពទឹកនៅតាមតំបន់ទីសាធារណៈសម្រាប់អភិរក្សជីវៈចម្រុះក្នុងទឹក

-ឧបសម្ព័ន្ធ៥៖

កម្រិតកំណត់ស្តង់ដារគុណភាពទឹកនៅតាមតំបន់សាធារណៈសម្រាប់ការពារសុខភាពសាធារណៈ។

ទាក់ទងនឹងអនុក្រឹត្យនេះ គឺតម្រូវឲ្យម្ចាស់គម្រោងត្រូវមានការត្រួតពិនិត្យការបំពុលទឹកពីតំបន់ខ្លួនឯង ដើម្បីទប់ស្កាត់និងការកាត់បន្ថយការបំពុលទឹកទៅតំបន់ទីទៃក្នុងគោលដៅថែរក្សាការពារសុខុមាលភាពមនុស្ស និងការអភិរក្សជីវៈចម្រុះ។

៣.៤ ប្រកាសជាតិសំខាន់ៗដែលពាក់ព័ន្ធ

៣.៤.១ ប្រកាសអន្តរក្រសួងមហាផ្ទៃ-បរិស្ថានស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងនៅក្នុងខេត្តក្រុង នៃព្រះរាជាណាចក្រកម្ពុជា (២០០៣)

ប្រកាសអន្តរក្រសួងមហាផ្ទៃ-បរិស្ថាន លេខ៨០ប្រក.មផ-បស្ថ ចុះថ្ងៃទី២៥ កុម្ភៈ ឆ្នាំ២០០៣ ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងនៅក្នុងខេត្តក្រុងនៃព្រះរាជាណាចក្រកម្ពុជា បានចែងថា៖

មាត្រា៤.-

ការបោះចោល ឬចាក់ចោលសំរាម សំណល់រឹងរាយប៉ាយតាមដងផ្លូវ ទីសាធារណៈ ទីប្រជុំជន ទីផ្សារ កន្លែងកំសាន្ត មណ្ឌលទេសចរណ៍ រមណីយដ្ឋាន បូជនីយដ្ឋាន ទីវាលស្រែចំការ តំបន់ការពារ តំបន់ព្រៃភ្នំ តំបន់ឆ្នេរ ច្រាំងទន្លេ ប្រភពទឹកប្រើប្រាស់ ផ្លូវនាវាចរ ប្រព័ន្ធបង្ហូរទឹកលូ ប្រព័ន្ធប្រឡាយកសិកម្មត្រូវហាមឃាត់ជាដាច់ខាត។

មាត្រា៩.-

ការដុតសំរាម សំណល់រឹងគ្រប់ប្រភេទ ទោះស្ថិតក្នុងទីលាន ឬរណ្តៅចាក់សំរាម សំណល់រឹងក្តីត្រូវហាមឃាត់ជាដាច់ខាត។

៣.៤.២ ប្រកាសស្តីពីគោលការណ៍ណែនាំទូទៅក្នុងការធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញ (២០០៩)

ប្រកាសរបស់ក្រសួងបរិស្ថានលេខ២៧៦ប្រក.បស្ថ ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០០៩ ស្តីពីគោលការណ៍ណែនាំទូទៅក្នុងការធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញ បានកំណត់ថា៖

ប្រការ២.-

ម្ចាស់គម្រោងជាបុគ្គលឯកជន ជាក្រុមហ៊ុនឯកជន ជាក្រុមហ៊ុនចំរុះរដ្ឋ ឬក្រុមហ៊ុនរដ្ឋ ជាក្រសួងស្ថាប័នរដ្ឋ ត្រូវរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ពេញលេញ លើគម្រោងស្នើឡើង ព្រមទាំងសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការ ដូចមានចែងក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ៧២អនក្រ.បក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៩ ស្តីពី «កិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន» ដើម្បីដាក់ជូនក្រសួងបរិស្ថានពិនិត្យ និងផ្តល់យោបល់ លើកលែងតែគម្រោងដែលមានលក្ខណៈពិសេស និងចាំបាច់បន្ទាន់ដែលសម្រេចដោយរាជរដ្ឋាភិបាល។

ប្រការ៤.-

ម្ចាស់គម្រោងដូចមានចែងនៅក្នុងប្រការ២ និង៣ខាងលើ អាចប្រើប្រាស់សេវាកម្មរបស់ក្រុមហ៊ុនទីប្រឹក្សា ដែលជាអ្នកទទួលខុសត្រូវផ្ទាល់ក្នុងការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ដោយគោរពទៅតាមគោលការណ៍ណែនាំទូទៅនេះ។

ប្រការ៦.-

ក្រុមហ៊ុនទីប្រឹក្សាដូចមានចែងក្នុងប្រការ៤ ត្រូវមានលក្ខណៈសម្បត្តិសមត្ថភាពជំនាញគ្រប់គ្រាន់ក្នុងការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ មានចុះបញ្ជីការនៅក្រសួងពាណិជ្ជកម្ម និងមានការទទួលស្គាល់ពីក្រសួងបរិស្ថាន។

ប្រការ៧.-

នាយកដ្ឋានអង្កេត ពិនិត្យការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឬមន្ទីរបរិស្ថានរាជធានីខេត្ត ត្រូវពិនិត្យ និងផ្តល់យោបល់លើទីតាំងគម្រោង ដូចមានចែងនៅក្នុងប្រការ២ និង៣ខាងលើ ដើម្បីកំណត់ឲ្យបានច្បាស់លាស់ថា គម្រោងនេះគួរតំរូវឲ្យរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ។

ប្រការ១៥.-

ម្ចាស់គម្រោងត្រូវមានកាតព្វកិច្ចបង់មូលនិធិទាយជ្ជទានបរិស្ថាន សម្រាប់កិច្ចការពារបរិស្ថានទៅតាមកិច្ចសន្យាការពារបរិស្ថានរបស់ក្រុមហ៊ុន។

Draft

ជំពូក ៤
ការពិពណ៌នាអំពីគម្រោង

Draft

ជំពូក ៤
ការពិពណ៌នាអំពីគម្រោង

៤.១ រចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រុមហ៊ុន

ខាងក្រោមគឺជារចនាសម្ព័ន្ធសម្រាប់គ្រប់គ្រងក្រុមហ៊ុន (ខេមបូឌា) ហ្វីប៊ឺរ អុបទិក ខមញ្ញូនីខេសិន ណេតវើក។ ហើយមកដល់បច្ចុប្បន្នក្រុមហ៊ុនមានបុគ្គលិកបម្រើការទាំងខ្មែរ និងបរទេសប្រហែលចំនួន ១៨០នាក់ដែលបានចុះបញ្ជីនូវក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។



រូបភាព ៤.១៖ រចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រុមហ៊ុន

៤.២ រយៈពេលវិនិយោគនិងគុណភាពខ្សែកាប្លីអុបទិក

តាមការលក្ខន្តិក:របស់ក្រុមហ៊ុនត្រង់ប្រការ៥បានបង្ហាញថា រយៈពេលវិនិយោគនៅព្រះរាជាណាចក្រកម្ពុជាមានរយៈពេល ៩៩ឆ្នាំ និងរយៈពេលនៃគុណភាពប្រើប្រាស់ខ្សែកាប្លីអុបទិកមានពី ៣០-៤៤ឆ្នាំ(មើលឧបសម្ព័ន្ធទី១)។

៤.៣ គោលការណ៍ណែនាំសម្រាប់សាងសង់គម្រោងកប់ខ្សែកាប្លឺអុបទិកផ្ទាល់ឆ្ពោះបំពង់និងមានបំពង់

៤.៣.១ គោលការណ៍ណែនាំសម្រាប់សាងសង់គម្រោងកប់ខ្សែកាប្លឺអុបទិកផ្ទាល់ឆ្ពោះបំពង់

១. គោលការណ៍ណែនាំសម្រាប់សាងសង់គម្រោងកប់ខ្សែកាប្លឺអុបទិកផ្ទាល់ឆ្ពោះបំពង់



Draft

៤.៣.២ គោលការណ៍ណែនាំសាងសង់គម្រោងកប់ខ្សែកាប្លីអុបទិកដាក់ចំពង់

២.គោលការណ៍ណែនាំសាងសង់គម្រោងកប់ខ្សែកាប្លីអុបទិកដាក់ចំពង់



Draft

៤.៤ ផែនការមេរបស់ក្រុមហ៊ុនបណ្តាញខ្សែកាប្លីអុបទិចកម្ពុជា

៤.៤.១ ផែនការមេ

ក្រុមហ៊ុនCFOCN បានវិនិយោគនៅក្នុងគម្រោងសាងសង់បណ្តាញទំនាក់ទំនងខ្សែកាប្លីអុបទិកនៅកម្ពុជា។ គម្រោងនេះត្រូវបានចាត់ថ្នាក់ជា៣ដំណាក់កាលនៃការអនុវត្តន៍។

- ដំណាក់កាលទី១: ២០០៧-២០១៤ បានសំរេច ៧,៤២៩គម
- ដំណាក់កាលទី២: ២០១៥បានគ្រោងនិងស្ថិតក្រោមការសាងសង់ ១,០៨៥គម
- ដំណាក់កាលទី៣: គម្រោងសាងសង់ក្នុងថ្ងៃអនាគត ផ្អែកទៅលើតម្រូវការអភិវឌ្ឍន៍អាជីវកម្ម

ប្រាក់វិនិយោគសរុបរបស់គម្រោងនេះមានចំនួន១១០លានដុល្លារអាមេរិក ដែលត្រូវបានទទួលស្គាល់ដោយRGCតាមរយៈក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា(CDC), ក្រសួងប្រៃសនីយ៍និងទូរគមនាគមន៍(MPTC), ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MEF), និងក្រសួងពាណិជ្ជកម្ម (MoC)។

តារាង ៤.១៖ ការរីកចម្រើននៃ CFOCN ទំនាក់ទំនងបណ្តាញខ្សែកាប្លីអុបទិកជាតិ

ដំណាក់កាល	ការជីកកប់ខ្សែកាប្លីផ្ទាល់ (គម)	តំបន់ជីកកប់ជាក់ទុយោខ្សែកាប្លី (គម)		សរុប (គម)
		ភ្នំពេញ	ក្រុងផ្សេងៗ	
២០០៧-២០១៤	៦៨៧៧	៣១៤	២៣៨	៧៤២៩
២០១៥	៩៦៣	៤២	៨០	១០៨៥
សរុប	៧៨៤០	៦៣៥៦	៣១៨	៨៥១៤

កំណត់សំគាល់: សូមមើលក្នុងឧបសម្ព័ន្ធខាងក្រោម

ដូចដែលបានបង្ហាញនៅតារាងខាងលើនេះ គម្រោងបណ្តាញទំនាក់ទំនងខ្សែកាប្លីអុបទិកកម្ពុជា គឺត្រូវការអនុវត្តទៅតាម អនុលោមជាមួយនឹងគម្រោងសាងសង់ និងតម្រូវការទីផ្សារ។ព័ត៌មានលម្អិតនៃសកម្មភាពរបស់គម្រោងនឹងត្រូវបានបកស្រាយនៅខាងក្រោមនេះ។

៤.៤.២ តារាងជោគជ័យ និងលទ្ធផល

ក្នុងរយៈពេល៨ឆ្នាំនៃការសាងសង់ខ្សែកាប្លីអុបទិក (ពីឆ្នាំ២០០៧ដល់បច្ចុប្បន្ន) ក្រុមហ៊ុនCFCON បានសម្រេចនូវគោលបំណងរបស់ខ្លួនដោយបញ្ចប់ការសាងសង់ខ្សែកាប្លីអុបទិកប្រវែង ៧,៤២៩គម ដែលគ្របដណ្តប់នៅទូទាំងប្រទេស ខេត្តនិងក្រុង។ ខ្សែកាប្លីអុបទិកកម្ពុជាត្រូវបានសាងសង់ដោយមានបង្គប់ខ្សែកាប្លីអុបទិកដោយផ្ទាល់ ក្នុងនោះដោយមានកប់បំពង់ខ្សែកាប្លីអុបទិក នេះជាការបញ្ជាក់ទៅតាមផែនការពីឆ្នាំ ២០០៧ ដល់ឆ្នាំ ២០១៤ ដោយបានបង្ហាញនៅក្នុង**តារាង ៤.១**។

៤.៤.៣ លទ្ធភាពទទួលបណ្តាញ

ខ្សែកាប្លីអុបទិកបានកប់ដោយផ្ទាល់ទៅនឹងតំបន់Metro ហើយនិងខ្សែកាប្លីអុបទិកដែលបានកប់ជាបំពង់,ក្រុមហ៊ុន CFOCN បានសាងសង់បណ្តាញតភ្ជាប់ដោយដំណើរការចូលពាក់ព័ន្ធទៅនឹងអ្នកប្រើប្រាស់។ ការដំណើរការសាងសង់បណ្តាញ ដោយត្រូវប្រើបច្ចេកទេស"standard duct + simplified duct + wall-suspending cable" ដើម្បីកាត់បន្ថយការប្រើប្រាស់ ខ្សែពីលើអាកាសដោយមានវិសាលភាពដ៏ធំមួយ។ មកដល់បច្ចុប្បន្នដំណើរការបណ្តាញសាងសង់ ដោយក្រុមហ៊ុនCFOCN បានពង្រីកខ្លួនគ្របដណ្តប់តាមបណ្តាខេត្តនិងទីក្រុងចំនួន១៣នៅក្នុងប្រទេសកម្ពុជា។

ខាងក្រោមនេះ ជាបង្គោលថ្ម សូមមើលរូបខាងក្រោម៖



រូបភាព ៤.២៖ បង្គោលថ្ម (១០០មានបង្គោលថ្ម១) ប្រាប់ពីទីកន្លែងនៃខ្សែកាប្លីអុបទិក (ឆ្វេង), បង្គោលថ្មដាក់លេខទំនាក់ទំនងក្រុមហ៊ុន (ស្តាំ).



រូបភាព ៤.៣៖ អធិការកិច្ចដោយអាជ្ញាធរមូលដ្ឋាន លើការសាងសង់ខ្សែកាប្លីអុបទិក

៤.៤.៤ វិសាលភាពនៃគម្រោងវិនិយោគអភិវឌ្ឍន៍

នៅថ្ងៃអនាគតក្រុមហ៊ុននឹងគិតគូរពីការសាងសង់ខ្សែកាប្លីអុបទិកនៅតាមផ្លូវជាតិ ដែលមានតម្រូវការខ្ពស់និងបណ្តាញផ្លូវស្ពានដែលមានស្រាប់។ ដើម្បីជៀសវាងទៅលើបញ្ហាដែលនឹង កើតមានឡើងនាពេលសាងសង់ខ្សែកាប្លីអុបទិកនោះ ក្រុមហ៊ុន CFOCN បានរកឃើញដំណោះស្រាយមួយចំនួនដូចជា៖

១) ដើម្បីកាត់បន្ថយការរំខានទៅលើអាជីវកម្មរបស់ប្រជាជនក្នុងមូលដ្ឋានដោយក្រុមហ៊ុនបានផ្តល់ដំណឹងជាមុន ដោយសុំការយោគយល់ និងការសហការពីប្រជាជនមូលដ្ឋានទាំងអស់។

២) ការបង្កប់ខ្សែកាប្លីអុបទិក ត្រូវបានធ្វើនៅពេលល្ងាចដើម្បីអោយប្រជាជនមូលដ្ឋានងាយស្រួលក្នុងការចេញចូលធ្វើដំណើរទៅកាន់ផ្ទះ។

៣) ក្រុមហ៊ុនមានអ្នកបច្ចេកទេសដែលប្រចាំការនៅជិតគម្រោងសាងសង់តាមផ្លូវដើម្បីធានាថានឹងគ្មានការកាត់ផ្តាច់ខ្សែកាប្លីអុបទិកដែលបានកប់នៅក្នុងដី។

៤) ក្រុមហ៊ុនបានទុកលេខទូរសព្ទ័នៅលើកន្លែងផ្សេងៗដើម្បីអោយប្រជាជនមូលដ្ឋានងាយស្រួលក្នុងការផ្តល់ដំណឹងទៅក្រុមហ៊ុនដោយជៀសវាងក្នុងការជីកស្រះ ឬការសាងសង់ហេដ្ឋារចនាសម្ពន្ធ័ផ្សេងៗដែលអាចនឹងប៉ះពាល់ដល់ខ្សែកាប្លីអុបទិកដែលកប់នៅក្នុងដី។

៥) ការកប់ខ្សែកាប្លីអុបទិកនៅក្នុងដីមានការសហការកិច្ចព្រមព្រៀងដោយម្ចាស់ដីដើម្បីធានាថា ការសាងសង់ដោយម្ចាស់ដីនឹងមិនមានការប៉ះពាល់ដល់ការបង្កប់ខ្សែកាប្លីអុបទិក ឬ ម្ចាស់ដីអាចផ្តល់ដំណឹងជាមុនដល់ក្រុមហ៊ុនដើម្បីជួយសម្រួលដល់ការសាងសង់។

៤.៤.៤ ការវាយតំលៃតំបន់គម្រោង

ការវាយតម្លៃពីការប៉ះពាល់បរិស្ថានត្រូវបានចែកចេញជា៥ក្រុមគោលដៅសូមមើលផែនទីខាងក្រោមដែលរួមមាន៖

- ក្រុមគោលដៅទី១មាន៥ខេត្ត ដែលមានខ្សែកាប្លីអុបទិកប្រវែងសរុប១,៤៥២គម ដែលស្ថិតនៅក្នុងខេត្តកំពង់ស្ពឺ ខេត្តកែប ខេត្តកំពត ខេត្តព្រះសីហនុនិង ខេត្តកោះកុង។
- ក្រុមគោលដៅទី២មាន៤ខេត្ត ដែលមានខ្សែកាប្លីអុបទិកប្រវែងសរុប៩៩៥គម ដែលស្ថិតនៅក្នុងខេត្តតាកែវ ខេត្តកណ្តាល ខេត្តព្រៃវែងនិងខេត្តស្វាយរៀង។
- ក្រុមគោលដៅទី៣មាន៥ខេត្ត ដែលមានខ្សែកាប្លីអុបទិកប្រវែងសរុប២,០៨៤គម ដែលស្ថិតនៅក្នុងខេត្តកំពង់ចាម ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តរតនគិរី និង ខេត្តមណ្ឌលគិរី។
- ក្រុមគោលដៅទី៤មាន៥ខេត្ត ដែលមានខ្សែកាប្លីអុបទិកប្រវែងសរុប១,៥២៧គម ដែលស្ថិតនៅក្នុងរាជធានីភ្នំពេញ ខេត្តកំពង់ធំ ខេត្តសៀមរាប ខេត្តឧត្តរមានជ័យ និងខេត្តព្រះវិហារ។
- ក្រុមគោលដៅទី៥មាន៥ខេត្ត ដែលមានខ្សែកាប្លីអុបទិកប្រវែងសរុប១,៥២៧គម ដែលស្ថិតនៅក្នុងខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ និង ខេត្តប៉ៃលិន។



ផែនទី ៤.១៖ ផែនទីបណ្តាញខ្សែកាប្លីអុបទិកមេទូទាំងប្រទេសកម្ពុជា(1)

៤.៥ ប្រវត្តិគម្រោង និងបទពិសោធន៍របស់ក្រុមហ៊ុន

បន្ទាប់ពី 20 ឆ្នាំនៃការ ប្រតិបត្តិការ ទទួលបានជោគជ័យ នៅក្នុងទីផ្សារ បច្ចេកវិទ្យាព័ត៌មាន Cambodia Fiber Optic Cable Network CFOCN ឥឡូវនេះ បានបង្កើតសាខារបស់ខ្លួននៅកម្ពុជា នៅខែ មេសា ឆ្នាំ 2006 CFOCN បានចុះកិច្ចព្រមព្រៀងជាមួយ រាជរដ្ឋាភិបាលកម្ពុជាដែល តំណាងដោយក្រសួង ប្រៃសណីយ៍និងទូរគមនាគមន៍ (MPTC) , ក្រុមប្រឹក្សាសម្រាប់ការអភិវឌ្ឍន៍កម្ពុជា (CDC) របស់ក្រសួង ពាណិជ្ជកម្ម (MOC) និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MEF) ក្រសួងក្នុង ខែមេសា 06 ឆ្នាំ 2007 ដើម្បីទទួលបានការអនុម័ត សម្រាប់ ការវិនិយោគនៅក្នុងខ្សែកាបអុបទិក និងហេដ្ឋារចនាសម្ព័ន្ធដែលពាក់ព័ន្ធ ការសាងសង់ទាំងអស់ទូទាំងប្រទេសដែលក្នុងនោះរបស់CDCក៏បានប្រកាសនៅថ្ងៃទី 04 ខែឧសភា ឆ្នាំ 2007 គោលបំណង វិនិយោគនៅក្នុងប្រទេសកម្ពុជា គឺដើម្បីពង្រីកនិងកែលម្អសេវាបច្ចេកវិទ្យាទំនាក់ទំនង និង ពង្រឹងភាពជាដៃគូទ្វេភាគីដែលរយៈពេលវែងរវាងប្រទេសកម្ពុជា និងប្រទេសចិន ដូច្នេះជាការជំរុញឱ្យមាន ការអភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជា និងប្រទេសចិន។

ក្នុងរយៈពេល ៧ឆ្នាំ (២០០៨ រហូតដល់បច្ចុប្បន្ន) នៃការសាងសង់ខ្សែកាប្លីអុបទិកនៅកម្ពុជា CFOCN បានសាងសង់ខ្សែកាប្លីប្រវែង៦១៣០គមឬ៥៣% នៃគម្រោងផ្លូវសរុបប្រវែង ១០៩៤០គម យោង តាមគម្រោងឆ្នាំ២០១៣។ សព្វថ្ងៃនេះ CFOCN កំពុងអនុវត្តគម្រោងសាងសង់ប្រវែង ២០០០គម យោង តាមគម្រោងឆ្នាំ ២០១៤។ បន្ទាប់មកទៀត ក្រុមហ៊ុននឹងគិតគូរពីការសាងសង់ខ្សែកាប្លីអុបទិកតាមផ្លូវជាតិ

ដែលមានតម្រូវការខ្លាំង និងសាងសង់លើផ្លូវ និងស្ពានដែលមានស្រាប់ផ្អែកទៅលើគម្រោង ៣ ទៅ ៥ឆ្នាំ ដែលត្រូវការបញ្ចប់ប្រវែង ២៨១០គម។

៤.៦ ផែនការ និងសកម្មភាពការងារសាងសង់របស់គម្រោង

៤.៦.១ ប្រភេទខ្សែកាប្លីអុបទិក

ក្រុមហ៊ុនបានផ្តល់យោបល់ពីប្រភេទខ្សែកាប្លីអុបទិក GYTA53 ថាឲ្យកប់ផ្ទាល់ដាពិសេស សម្រាប់ភាពរឹងមាំនៃខ្សែកាប្លីអុបទិករបស់គម្រោង ឯសរសៃ G652D ត្រូវបានក្រុមហ៊ុនផ្តល់យោបល់ ថាជាសរសៃសំខាន់ ពីព្រោះសរសៃ G652D ត្រូវបានគេប្រើប្រាស់យ៉ាងទូលំទូលាយជាមួយបច្ចកវិទ្យាដ៏ល្អ មានភាពងាយស្រួល សម្រាប់ការសាងសង់ និងការថែទាំ ហើយមានតំលៃសមរម្យ។



រូបភាព ៤.៤៖ ដ្យាក្រាមរចនាសម្ព័ន្ធស្រទាប់ខ្សែកាប្លីអុបទិក

ក្រុមហ៊ុន CFOCN ធ្វើការពង្រាយសេវាកម្មចែកចាយខ្សែកាប្លីអុបទិក ដល់ក្រុនហ៊ុនអតិថិជនប្រើប្រាស់យ៉ាងទូលំទូលាយចំនួន៣សំខាន់ៗគឺ៖ ២៤ ក្រុមហ៊ុនស្នូល, ៤៨ ក្រុមហ៊ុនស្នូល និង៧២ ក្រុមហ៊ុនស្នូល តាមរយៈការបញ្ជូនសេវាកម្មតាមខ្សែកាប្លីអុបទិក។ បន្ទប់បរិក្ខាប្រើប្រាស់សម្រាប់ចែកចាយរបាយសេវាកម្មខ្សែកាប្លីអុបទិក ទៅដល់ក្រុមហ៊ុនអតិថិជន។ មានក្រុមហ៊ុនអតិថិជន ២របស់ក្រុមហ៊ុន CFOCNគឺ ក្រុមហ៊ុនផ្តល់សេវាកម្មអ៊ីនធើណេត និងក្រុមហ៊ុនផ្តល់ការប្រើប្រាស់ទូរស័ព្ទ។ រចាយផ្តល់សេវាកម្មក្រុមហ៊ុន ផ្តល់សេវាកម្មប្រើប្រាស់អ៊ីនធើណេត និងក្រុមហ៊ុនផ្តល់ការប្រើប្រាស់ទូរស័ព្ទបានផ្តល់សេវាកម្មឲ្យអ្នកប្រើ ប្រាស់ចុងក្រោយដោយរាប់បញ្ចូលក្រុមហ៊ុនឯកជន ឬក្រុមហ៊ុនពាណិជ្ជកម្ម។ នៅក្នុងការប្រតិបត្តិការមាន បន្ទប់បរិក្ខាមួយសម្រាប់ផ្តល់រយៈចំងាយ ១០០គម។ ខ្សែកាប្លីនេះមានតំណ ១ សម្រាប់ ៣គម។

ការផ្តល់ទូរស័ព្ទចល័តមាន រលកស៊ីញាល់ដោយខ្លួនវា ឬផ្តល់របាយសេវាកម្មទៅដល់អ្នកប្រើប្រាស់ផ្ទាល់។ ការតំឡើងសេវាកម្មនៅក្នុងទីក្រុងមាន ២ លក្ខខណ្ឌ គឺ ៣គមសម្រាប់ទីក្រុង ឬ ១០គម សម្រាប់នៅក្រៅក្រុង។

តារាង ៤.២៖ បញ្ជាក់ពីសសៃរខ្សែកាប្លីអុទិក (G.652D fiber)

ឈ្មោះ	ការបញ្ជាក់ការពិពណ៌នា		ទិន្នន័យ
			G.652D
លក្ខណៈអុបទិក	Attenuation	@1310nm	≤0.35dB/km
		@1383nm	≤0.35dB/km
		@1550nm	≤0.22dB/km
		@1625nm	≤0.30dB/km
	Variety attenuation of wavelength	1285~1330nm @1310 nm	≤0.05 dB/km
		1525~1575nm @1550 nm	≤0.05 dB/km
	Wavelength chromatic zero dispersion		1300~1324nm
	Zero chromatic dispersion slope		≤0.092ps/(nm^2.km)
	Chromaticdispersion	@1310nm	≤3.5 ps/nm.km
		@1550nm	≤18 ps/nm.km
	Polarization mode dispersion (PMD)		≤0.2ps/$km^{1/2}$
	Cablecutoff wavelength (λcc)		≤1260nm
	Effective group refraction index	@1310nm	1.4675
		@1550nm	1.4681
លក្ខណៈ ភូមិសាស្ត្រ	Mode field diameter	@1310nm	9.2±0.6μm
		@1550nm	10.4±0.8μm
	Envelope diameter		125±1μm
	Envelopenon-circularity		≤1.0%
	Coating layer diameter		245±7μm
	Envelope/ /Coatingconcentricityerror		≤12.0μm
	core/packageconcentricityerror		≤0.8μm
	Warping degree (radius)		≥4.0m
លក្ខណៈមេកានិច	Screeningstrain		≥1.0%

Draft

	Coatingadhesion	1.3~8.9N



រូបភាព ៤.៥៖ របាយទីតាំងខ្សែកាប្លីអុបទិកសម្រាប់ក្រុមហ៊ុនចែកចាយសេវាសែកម្មអ៊ីនធើណេត និងអ្នកប្រើប្រាស់ផ្ទាល់

៤.៦.២ បច្ចេកទេសកប់ខ្សែកាប្លីអុបទិក

តាមម៉ូដែលគន្លងការជីកកប់ដាក់ខ្សែកាប្លីអុបទិក, ក្នុងនោះមាន ការកប់ផ្ទាល់នៅតាមដងផ្លូវជាតិ នានារបស់ខេត្ត និងក្រុងនីមួយៗ (ការដាក់ដាក់ទុយោត្រូវបានប្រើប្រាស់សម្រាប់ជាយក្រុង ឬជនបទដែលមានចំនួនប្រជាជនច្រើន) ការកប់ដាក់ទុយោនៅទីប្រជុំជនត្រូវបានប្រើប្រាស់ជារបៀបនៃការសាងសង់នៅពេលដែលមានផ្លូវ ឬស្ពានឆ្លងកាត់។

ទីតាំង និងប្រភេទដីគឺ ជាកត្តាធ្វើការកំណត់ តើគួរធ្វើការជីករបៀបណាសម្រាប់កប់ខ្សែកាប្លីអុបទិក។ ជម្រៅនៃការជីកជាទូទៅមាន ជម្រៅចន្លោះពី ០.៨មទៅ១.៣ម អស្រ័យលើទីតាំងខុសៗគ្នា។ ទោះបីយ៉ាងណាក៏ដោយ នៅតំបន់មានថ្ម, ការកប់ខ្សែកាប្លីអាចកប់ក្នុងជម្រៅចន្លោះពី ០.៤មទៅ០.៦ម សម្រាប់ការការពារសម្ភារៈ ដើម្បីជៀសវាងការមិនភ្ជាប់គ្នា។ ខាងក្រោមនេះជាតារាងសង្ខេបការជីកកប់ខ្សែកាប្លីនៅតាម ទីតាំងខុសៗគ្នា។

តារាង ៤.៣៖ ជម្រៅនៃការជីកកប់ខ្សែកាប្លីអុបទិក

ល.រ	ផ្នែកគន្លងកប់ និងប្រភេទដី	ជម្រៅនៃការកប់ផ្ទាល់ (ម)	ជម្រៅនៃការកប់ទុយោផ្ទាល់ (ម)
១	ដីធម្មតា	≥1.3 (ការជីកដោយគ្រឿងចក្រ)	≥1.0
២	ដីធម្មតា	≥1.2 (ការជីកដោយមនុស្ស)	
៣	ថ្ម និងដីល្បាយ, គ្រួស និងផូស៊ីលជាដើម	≥1.0	≥0.8

៤	ថ្ម និង ដីខ្សាច់	≥0.8	≥0.6
៥	ជាយក្រុង និងទីក្រុងតូចៗ	≥1.2	≥1.0
៦	មជ្ឈមណ្ឌលផ្សារ, ផ្លូវសំខាន់ៗ	≥1.0	≥0.8
៧	ប្រសព្វផ្លូវរទេះភ្លើង, ផ្លូវប្រសព្វនៃផ្លូវជាតិ	≥1.2 (ការខួងដោយគ្រឿងម៉ាស៊ីន)	≥1.0
៩	ទន្លេ	≥1.3	
១០	ផ្លូវថ្មើរជើងតាមមហាវិថី	-	≥0.8



រូបភាព ៤.៦៖ ដ្យាក្រាមពន្យល់ពីការជីកដោយគ្រឿងចក្រ



រូបភាព ៤.៧៖ ដ្យាក្រាមពន្យល់ពីការជីកដោយមនុស្ស



រូបភាព ៤.៨៖ ដ្យាក្រាមពន្យល់ពីការជីកដាក់ដោយប្រព័ន្ធទុយោ



រូបភាព ៤.៩៖ ការជីកដាក់បំពង់រវាងការកប់ផ្ទាល់ និងការដាក់បំពង់, ត្រូវបានប្រើប្រាស់តាមជាយក្រុង និងជនបទ



រូបភាព ៤.១០៖ ម៉ូដែលសម្រាប់ការការពារខ្សែកាប្លីអុបទិក

៤.៦.៣ ការជីកដោយដៃនៅតាមផ្លូវ



រូបភាព ៤.១១៖ គន្លងជីកជាក់បំពង់កាត់តាមផ្លូវសំខាន់

Draft



Duct Crossing Bridge Diagram



(1) The Section Drawing for Duct Along The Bridge

(1) The Section Diagram for Bridge Bracket

រូបភាព ៤.១២៖ ដ្យាក្រាមពន្យល់ពីការសាងសង់ខ្សែកាប្លីអុបទិកកាត់តាមស្ពាន

Draft

៤.៧ អតិថិជនទិញសេវាកម្មខ្សែកាបអុបទិកពី ក្រុមហ៊ុន CFOCN

មកដល់បច្ចុប្បន្ននេះក្រុមហ៊ុន CFOCNបានផ្តល់សេវាកម្មខ្សែកាប្លុីអុបទិកដល់សំខាន់អតិថិជនចំនួន ២គឺ៖ ១៣ក្រុមហ៊ុនផ្តល់សេវាកម្មអ៊ុិន និងចំនួន ៩ ក្រុមហ៊ុនទូរស័ព្ទចល័តដូចដែលបានបង្ហាញក្នុងតារាង ៤.៤ ដូចខាងក្រោម។

តារាង ៤.៤៖ អតិថិជនរបស់ក្រុមហ៊ុន CFOCN បច្ចុប្បន្ន

ល.រ	ក្រុមហ៊ុន	ផ្លាកក្រុមហ៊ុន	ល.រ	ក្រុមហ៊ុន	ផ្លាកក្រុមហ៊ុន
អតិថិជនផ្តល់សេវាកម្ម (Internet Service Providers)					
១	Cambodia Telecom		២	Opennet	
៣	Digi		៤	Mekongnet	
៥	Online		៦	CB	
៧	City Link		៨	EZECOM	
៩	S.I NET		១០	CHUANWEI	
១១	Tecotech		១២	NTC	
១៣	Wicam				
ក្រុមហ៊ុនទូរស័ព្ទ (Mobile Operators)					
១៤	Smart		១៥	Metfone	
១៦	Mobitel		១៧	Excell	
១៨	Beeline		១៩	Xinwe Telecom	
២០	qb				

៤.៨ ផែនការគ្រប់គ្រងកាកសំណល់

កង្វក់នៃសំរាម កើតឡើងច្រើនដោយសារតែការជីកដី និងធ្វើការដំឡើងនៅកន្លែងដូចជា កន្លែងមានសម្រាម, កន្លែងមានភក់, កន្លែងមានផ្លាស្ទិច, កន្លែងមានសំបកដប ឬកន្លែងដែលមានគំនរប្រអប់បាយថ្ងៃត្រង់នៃកម្មករ ឬកន្លែងគំនរសំរាមដែលឡានដឹកសំរាមចាក់ចោល។ សំណល់រឹងកើតមាននៅពេលដែល ខ្សែដែលបានដាក់ចាប់ផ្តើមដំណើរការ, ជីក, ការសាងសង់លូ និងសំណល់ផ្សេងៗទៀតកើតមានក្នុងកំឡុងពេល

ដែលធ្វើការ។ សម្ភារៈទាំងនេះបង្កើតនូវបរិស្ថាន ដែលគ្មានសោភ័ណ្ឌភាព និងរំខានដល់ទស្សនីយភាពរបស់អ្នកដំណើរ ឬអ្នកតាំងលំនៅ ហើយចុងបញ្ចប់បរិស្ថានធម្មជាតិប្រែក្លាយទៅជាមានការបំពុល។

វិធានការកាត់បន្ថយ៖

- នៅរាល់សំណល់រឹងដែលកើតមានត្រូវប្រមូល, រើស និងរៀបចំអោយមានត្រឹមត្រូវ
- ចំពោះគម្រោងវិនិយោគមួយដែលបានផ្តោតសំខាន់ទៅលើផែនការគ្រប់គ្រងកាកសំណល់ នោះកាកសំណល់ទាំងអស់នឹងត្រូវបានរៀបចំជាស្រេចក្នុងកំឡុងពេលធ្វើការវិនិយោគគម្រោង
- នៅថ្ងៃបញ្ចប់ការងារត្រូវតែរៀបចំ និងសំអាតកាកសំណល់ក្នុងតំបន់ដែលធ្វើការវិនិយោគ (ទាំងសំណល់រឹង និងសំណល់រាវ)
- ត្រូវផ្តត់ផ្គង់ឧបករណ៍ផ្ទុកកាកសំណល់ឲ្យបានគ្រប់គ្រាន់ដូចជា ធុងសំរាម ឬថង់ដាក់សំរាម ដើម្បីងាយស្រួលក្នុងការប្រមូលកាកសំណល់ និងយកវាទៅចោលនៅជិតកន្លែងដាក់សំរាម ជៀសវៀងការដុត ឬកប់កាកសំណល់នៅក្នុងតំបន់ធ្វើការវិនិយោគ
- ត្រូវបង្ហាត់កម្មករពីរបៀបទុកដាក់កាកសំណល់ឲ្យបានត្រឹមត្រូ(ទាំងសំណល់រឹង និងសំណល់រាវ)វ នៅមុនថ្ងៃបញ្ចប់ការងារ

វិធានការត្រួតពិនិត្យ៖

វិធានការនេះត្រូវធ្វើការអង្កេត និងត្រួតពិនិត្យ កាកសំណល់ពុលដែលកើតមាន ដើម្បីជៀសវាងផលប៉ះពាល់ក្នុងពេលធ្វើការវិនិយោគគម្រោង។ វិធានការត្រួតពិនិត្យកាកសមនល់ពុលត្រូវបានប្រតិបត្តិ ដោយម្ចាស់គម្រោងជាមួយនិងដៃគូសំខាន់ ឬអ្នកដែលទាក់ទង។

តារាង ៤.៥៖ ផែនការគ្រប់គ្រងកាកសំណល់

វិធានការកាត់បន្ថយ	ការកំណត់	ទីតាំង	គោលបំណងនៃការពិនិត្យ	ប្រេកង់	បុគ្គលក្នុងបន្ទុក	ការប៉ាន់ស្មានតំលៃ
១. ត្រូវផ្តត់ផ្គង់ឧបករណ៍ផ្ទុកកាកសំណល់ឲ្យបានគ្រប់គ្រាន់ដូចជា ធុងសំរាម ឬថង់ដាក់សំរាម ដើម្បីងាយស្រួលក្នុងការប្រមូលកាកសំណល់ និងយកវាទៅចោលនៅជិតកន្លែងដាក់សំរាម ជៀសវៀងការដុត ឬកប់កាកសំណល់នៅក្នុងតំបន់ធ្វើការវិនិ យោគ ២. ត្រូវយកជិតទុកដាក់ក្នុងការយកសំរាមចេញពីតំបន់វិនិយោគក្នុងកំឡុងពេលធ្វើការវិនិយោគ	១. ត្រូវរៀបចំ ឬគ្រប់គ្រងឲ្យបានត្រឹមត្រូវជាមួយនិងកាកសំណល់ ២. ត្រូវសំអាតកន្លែងសាងសង់ឲ្យបានស្អាត	នៅក្នុងតំបន់គោលដៅ	១. ត្រូវរំលឹកការត្រួតពិនិត្យដល់ម្ចាស់គម្រោង ២. ការអង្កេតនៅទីវាល	ជារៀងរាល់សប្តាហ៍	ម្ចាស់គម្រោង	ផ្អែកទៅលើការចំណាយជាក់ស្តែង

៤.៩ ទូរគមនាគមន៍

- **ទូរគមនាគមន៍៖** សំដៅវិទ្យាសាស្ត្រ និងបច្ចេកទេសវិទ្យាក្នុងការបញ្ជូននិងទទួល សំឡេង ទិន្នន័យ ស៊ីញ៉ាល់ រូបភាព ឬប្រភេទព័ត៌មានដទៃទៀត តាមរយៈការប្រើប្រាស់ថាមពលអេឡិច ត្រូម៉ាញេទិច ក្រោមទម្រង់ វិទ្យុ អគ្គិសនី ពន្លឺឬទម្រង់ ដទៃទៀត។



រូបភាព ៤.១៣៖ អ្នកផ្ញើ ស៊ីញ៉ាល់ និងអ្នកទទួល

- **អត្ថន័យពាក្យគមនាគមន៍៖**

- **គមនាគមន៍៖** "ការទៅនិងការមក, ដំណើរទៅនឹងដំណើរមក"(វចនានុក្រមសម្តេចសង្ឃ ជួន ណាត)

ក្នុងន័យបច្ចេកទេស៖

គមនាគមន៍៖"ការសុន្ទនាទៅវិញទៅមក ដែលអ្នកនិយាយបានបញ្ចេញសំឡេង ឬសញ្ញាហៅថាការ បញ្ជូនស៊ីញ៉ាល់ឆ្លងតាមកាត់មជ្ឈមដ្ឋានបរិយាកាសទៅដល់អ្នកស្តាប់ ឬអ្នកទទួល"

ទូរគមនាគមន៍៖"ការបញ្ជូនស៊ីញ៉ាល់តាមរយៈមជ្ឈដ្ឋានបញ្ជូនស៊ីញ៉ាល់ ពីកន្លែងមួយទៅកន្លែងមួយ ផ្សេងទៀត"

- **ការបញ្ជូនទិន្នន័យ(Data Communications)**

ការបញ្ចូលទិន្នន័យ៖ គឺសំដៅលើការផ្ទើសារឌីជីថល ដោយប្រើបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន។ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានដែលត្រូវបានប្រើនៅក្នុងការបញ្ចូនទិន្នន័យរួមទាំងខ្សែ, សរសៃអុបទិក និងប្រេកង់វិទ្យុ។



រូបភាព ៤.១៤៖ ការបញ្ចូលទិន្នន័យ

៤.១០ ធាតុផ្សំនៃសប្រព័ន្ធទូរគមនាគមន៍

- **គ្រឿងបរិក្ខារទូរគមនាគមន៍**

សំដៅដល់សម្ភារបរិក្ខា ឬឧបករណ៍ ឬគ្រឿងបង្គុំ ឬឋបនីយភ័ណ្ឌ ដែលត្រូវ ដែលត្រូវបានផលិត និង /ឬនាំចេញ-នាំចូល មកប្រើប្រាស់ក្នុងប្រព័ន្ធទូរគមនាគមន៍ និង ICT។



រូបភាព ៤.១៥៖ គ្រឿងបរិក្ខារទូរគមនាគមន៍(រ៤ថ 6)

៤.១១ ប្រភេទនៃមជ្ឈដ្ឋានបម្លងស៊ីញ៉ាល់

- **ខ្សែកាប្លីវេញជាគូ** (Twisted pair wire cable)
  - ជាប្រភេទខ្សែលោហៈ ដែលវេញជាគូ។ ហើយរវាងខ្សែនីមួយៗ រុំស្រោបដោយសំបកអ៊ីសូឡង់។
  - គេប្រើវានៅក្នុង ការផ្តល់សេវាទូរស័ព្ទខ្សែជាប្រពៃណី និងប្រើដើម្បីភ្ជាប់រវាងគ្រឿងបង្គុំរបស់កុំព្យូទ័រ។



រូបភាព ៤.១៦៖ ខ្សែកាប្លឺវេញជាគូ

- **ខ្សែកាប្លឺ Coaxial (Coaxial Cable)**
  - ❖ រួមផ្សំដោយខ្សែចម្លងនៅចំស្នូលកណ្តាល រុំព័ទ្ធដោយ វត្តុធាត់ អ៊ីសូឡង់មិនចម្លងចរន្ត
  - ❖ នៅពីខាងក្រៅវត្តុធាតុអ៊ីសូឡង់នេះគឺជាស្រទាប់សរសៃរលោហៈ ចំណែកស្រទាប់ខាងក្រៅគឺជាសំបកការពារ
  - ❖ ខ្សែកាប្លឺ Coaxial មានលទ្ធភាពបញ្ជូនអត្រាទិន្នន័យ ល្អជាងខ្សែគូ។



រូបភាព ៤.១៧៖ ខ្សែកាប្លឺ (រ៤៥ 7)

- **ខ្សែកាប្លឺអុបទិក**
  - ❖ ជាខ្សែកាប្លឺដែលផ្គុំកសរសៃអុបទិកមួយ ឬច្រើន
  - ❖ សរសៃអុបទិកនេះ ផ្លូវសម្រាប់ដាលនៃបាច់ពន្លឺ
  - ❖ អាចប្រើសម្រាប់ផ្តល់បញ្ជូន សំឡេងទិន្នន័យ និងរូបភាព បានយ៉ាងប្រសើរ





Draft



រូបភាព ៤.១៨៖ ខ្សែកាប្លី

- **មីក្រូវ៉ែ (Microwave)**
  - ❖ ត្រូវតម្លើងឧបករណ៍បរិក្ខារនៅត្រង់ទីតាំងខ្ពស់ដើម្បីអង់តែន Microwave អាចទាក់ទងស៊ីញ៉ាល់ទៅវិញទៅមកបានតាមគន្លងស៊ីញ៉ាល់(Line-of-sight) ដោយគ្មានឧបស័គ្គរារាំង
  - ❖ ការប្រើប្រាស់ Microwave

ព័ត៌មានត្រូវបំលែងទៅជាស៊ីញ៉ាល់ រួចបញ្ជូនក្នុងបរិយាកាស(ខ្យល់)ទៅអ្នកទទួល។ អ្នកទទួលបានបំលែងទៅព័ត៌មានដូចដើមវិញ (មើលរូបភាព៤.៧)។

គន្លងស៊ីញ៉ាល់





រូបភាព ៤.១៩៖ គន្លងស៊ីញ៉ាល់

- **ការបញ្ជូនស៊ីញ៉ាល់តាមផ្តាយរណប**
  - ❖ ការទាក់ទងព័ត៌មានតាមប្រព័ន្ធ ផ្តាយរណបគឺជាទម្រង់នៃការបញ្ជូន-ព័ត៌មានដោយប្រើស្ថានីយ៍ផ្សាយបន្តដែលទទួលស៊ីញ៉ាល់ពីទីតាំងមួយនៃផែនដី រួចផ្សាយបន្ត (relay) ទៅកន្លែងនៃផែនដី ប្រព័ន្ធនេះក៏ប្រើស៊ីញ៉ាល់ជា Microwaveដែរ។



រូបភាព ៤.២០៖ ការបញ្ជូនស៊ីញ៉ាល់តាមផ្កាយរណប

- **ការបញ្ជូនស៊ីញ៉ាល់តាម Cellular (ប្រព័ន្ធទូរស័ព្ទដៃ)**
  - ❖ ស៊ីញ៉ាល់ពីមួយត្រូវបាបញ្ជូនទៅខាងទទួលឆ្លងកាត់បណ្តាញធម្មតា



រូបភាព ៤.២១៖ ការបញ្ជូនស៊ីញ៉ាល់តាម Cellular

- **ការបញ្ជូនស៊ីញ៉ាល់តាម Infrared**
  - ❖ ការបញ្ជូនស៊ីញ៉ាល់ក្នុងលំហបិទជិតៗ ដោយរកពន្លឺ(light waves)
    - ▪ ទាមទារឲ្យមានគន្លងស៊ីញ៉ាល់ល្អ ហើយមានចម្ងាយជិតៗប៉ុណ្ណោះ
    - ▪ ត្រូវបានប្រើដើម្បីភ្ជាប់រវាងបរិក្ខារកំព្យូទ័រ ដូចជាកុំព្យូទ័រយួរដៃជាដើម



រូបភាព ៤.២២៖ ការបញ្ជូនស៊ីញ៉ាល់តាម Infrared

៤.១២ ការបញ្ជាក់ថាមិនមានផលប៉ះពាល់បណ្តាលមកពីខ្សែកាប្លីអុបទិក

តាមសេចក្តីជូនដំណឹងរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍លេខ: ៤៧៣ បទ បានបញ្ជាក់ថា បច្ចុប្បន្ននេះដោយបច្ចេកវិទ្យាប្រព័ន្ធទូរគមនាគមន៍មានការរីកចំរើនទូទាំងសកលលោក ពិសេសអត្រាអ្នកប្រើប្រាស់ប្រព័ន្ធទូរស័ព្ទចល័តនៅប្រទេសកម្ពុជាមានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ដែលធ្វើឲ្យក្រុមហ៊ុនបម្រើសេវាកម្មទូរស័ព្ទចល័តចាំបាច់ត្រូវពង្រីកបណ្តាសេវាគ្របដណ្តប់ ដោយកសាងបង្គោលអង់តែនទាំងនៅលើដំបូលអគារ និងក្នុងបរិវេណសមស្រប។

ការសិក្សាស្រាវជ្រាវបានពន្យល់ថា នៅពេលមនុស្សទទួលរងការផ្សាយនៃរលកអាកាសវិទ្យុពីទូរស័ព្ទចល័តក្តី ឬពីអង់តែនក្តី ថាមពលកាគច្រើនរត់ជុំវិញ ហើយមានខ្លះជ្រាបចូលក្នុងជាលិកាស្រទាប់ខាងក្រៅនៃខ្លួនមនុស្ស។ នៅក្នុងខ្លួនមនុស្សសារធាតុមួយចំនួនដូចជាជាតិទឹកចាប់ផ្តើមកម្រើកឬ រលាយសារវត្តមាននៃដែនអេឡិចត្រូម៉ាញ៉េទិច។ ប៉ុន្តែថាមពលដែលបានបង្កើតឡើងដោយប្រព័ន្ធទូរស័ព្ទចល័តដូចជាវិទ្យុ BASE STATION MICROWAVES និងឧបករណ៍ប្រើប្រាស់ហ្វ្រេកង់ដ៏ទៃទៀត វាមានកម្រិតទាបណាស់ ហើយការបង្កើនកំដៅជាលិកាដែលបណ្តាលមកពីការជ្រាបចូលនៃរលកអាកាសវិទ្យុមានកម្រិតទាបបំផុត មិនអាចបង្កគ្រោះថ្នាក់ដល់សុខភាពមនុស្សទេ។

តាមការស្រាវជ្រាវបន្ថែម របស់អង្គការសុខភាពពិភពលោក(WHO)និង អាជ្ញាធរសុខភាពផ្សេងទៀតជាច្រើនក៏បានបញ្ជាក់យ៉ាងច្បាស់ថា ការប្រើប្រាស់ប្រព័ន្ធទូរស័ព្ទចល័តមិនបានផ្តល់ផលអាក្រក់ដល់សុខភាពទេ(មើលក្នុងឧបសម្ព័ន្ធ១)។

ជំពូក ៥
ការពិពណ៌នាអំពីធនធានបរិស្ថាន
ដែលមានស្រាប់

Draft

ជំពូក ៥
ការពិពណ៌នាអំពីធនធានបរិស្ថានដែលមានស្រាប់

៥.១ សេចក្តីផ្តើម

ការសិក្សាអំពីស្ថានភាពធនធានបរិស្ថានមានស្រាប់ មានធនធានរូបសាស្ត្រ ធនធានជីវសាស្ត្រ និងធនធានសេដ្ឋកិច្ច-សង្គម ក្នុងទីតាំងគម្រោងវិនិយោគ នឹងផ្តល់ជាព័ត៌មាន ទិន្នន័យគ្រប់ជ្រុងជ្រោយ ដែលជាមូលដ្ឋានសម្រាប់រាជរដ្ឋាភិ បាល ក្នុងនោះមានក្រសួងបរិស្ថានជាស្ថាប័នដំនាញ ធ្វើការថ្លឹងថ្លែងអំពីហេតុប៉ះពាល់ដល់ធនធានបរិស្ថាន ក្នុងតំបន់គម្រោង និងផលប្រយោជន៍ដែលទទួលបានគម្រោងវិនិយោគ ព្រមទាំងឈានដល់ការសម្រេចចិត្តក្នុងការផ្តល់សិទ្ធិវិនិយោគ ឬសម្រេចផ្អាក ឬបញ្ឈប់ការវិនិយោគខ្សែកាប្លីអុបទិក ក្នុងករណីរកឃើញថា ទំហំនៃហេតុផលប៉ះពាល់អវិជ្ជមានមានច្រើនលើសលប់លើផលប្រយោជន៍ដែលទទួលបាន។ លទ្ធផលនៃការសិក្សាដែលត្រូវបានរកឃើញនេះ នឹងក្លាយជាមគ្គុទេសន៍នាំផ្លូវទៅរកហេតុផលប៉ះពាល់ដែលបានបញ្ចប់រួចរាល់ នៅក្នុងទីតាំងការវិនិយោគ ហើយនឹងឈានដល់ការរៀបចំវិធានការកាត់បន្ថយ និងផែនការគ្រប់គ្រងបរិស្ថាន ប្រកបដោយប្រសិទ្ធភាព ដើម្បីកាត់បន្ថយហេតុប៉ះពាល់អវិជ្ជមានឲ្យសល់ក្នុងកម្រិតអប្បបរមា ហើយសម្រាប់ដំណាក់កាលប្រតិបត្តិការគម្រោងតែប៉ុណ្ណោះ។

៥.២ ធនធានរូបសាស្ត្រ

៥.២.១ លក្ខណៈសណ្ឋានដី ប្រទេសដី និងតូគព្ភសាស្ត្រ

៥.២.១.១ លក្ខណៈសណ្ឋានដី

តំបន់ធំៗនៃសណ្ឋានដីគឺគេអាចចែកសណ្ឋានដីប្រទេសកម្ពុជា ជា៣ផ្នែកធំៗគឺទំនាបកណ្តាល ប្រជុំក្ំ និង ខ្ពង់រាប ហើយតំបន់ឈូងសមុទ្រ។

ក. ទំនាបកណ្តាល (la plaine central)

ផ្នែកកណ្តាលនប្រទេសកម្ពុជា ជាទំនាបមួយយ៉ាងធំធេងដែលមានរយៈកំពស់មធ្យម និងមានចំណោតយ៉ាងខ្សោយបន្តិចម្តងៗពីជើងទៅត្បូង។ ទំនាបនេះសណ្តូកបន្តពីទំនាបថៃ ពីទិសពាយ័ព្យទៅទិសអគ្នេយ៍រហូតដល់ព្រំដែនវៀតណាមផ្នែកខាងត្បូង។ ដីទំនាបកណ្តាលនេះហើយដែលមានបណ្តុំប្រជាជននិងសកម្មភាពសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា។

ទំនាបបឹង គឺជាទំនាបដែលស្ថិតនៅជុំវិញបឹងទន្លេសាប មានព្រំប្រទល់ខាងជើងទល់និងខ្ពង់រាបខាងជើងចាប់ពីរយៈកំពស់ពី ២៤ម ទៅ ២០០ម ខាងលិចនិង ខាងត្បូងទល់និងតំបន់កូនភ្នំដែលនៅតាមជើងជួរភ្នំក្រវ៉ាញ។ ទំនាបនេះមានចំណោត និងទទឹងមិនទៀងទាត់។ គេសង្កេតឃើញផ្នែកទំនាបពីរកន្លែង យ៉ាងរាបហើយធំ គឺមួយនៅខាងលិចដែលមានប្រវែងទទឹងមធ្យម ៨០គម"បាត់ដំបង" និងមួយទៀតនៅស្រុកពួកនិងស្រុកក្រឡាញ់សៀមរាប។ ក្រៅពីពីរកន្លែងនេះ មានកន្លែងតូចៗជាច្រើនទៀត ជាពិសេសមួយនៅខាងជើងសៀមរាបផ្នែកកណ្តាល ទទឹង៣០គម និងមួយទៀតនៅខាងត្បូងស្រុកបាកាន ពោធិសាត់ ទទឹង៣០គម ដែរ។ មកដល់កំពង់លួង ទំនាបនេះនៅសល់ទទឹងតែ ១៥គម ប៉ុណ្ណោះ។ ទំនាបទន្លេសាបចែកជាបីផ្នែក៖

ផ្នែកទី១: ទំនប់លិចទឹក គឺជាផ្នែដែលនៅជាប់មាត់បឹងសំបូរទៅដោយព្រៃលិចទឹក ឬព្រៃរនាមដែលជាជំរកត្រីពងនៅរដូវវស្សា។

ផ្នែកទី២: ទំនាបទាប ជាប់និងផ្នែកទី១ដែរ ជាផ្នែលិចទឹករដូវវស្សានិងវាលភក់សំបូរកូនបឹងនិងស្ទឹង ទំនាបនេះមានសារៈសំខាន់ក្នុងវិសយ័កសិកម្ម ខាងស្រូវឡើងទឹក។

ផ្នែកទី៣: ទំនាបខ្ពស់ ជាវាលស្រែលួលល្វែ លើកលែងតែដើមត្នោត និងកូនភ្នំខ្លះ។ បន្តពីវាលស្រែមានព្រៃរបោះខាងលិចនិងព្រៃក្រាស់ខាងកើត។

ដូចនេះ ទំនាបនេះពទ្ធ័ជុំវិញបឹងទន្លេសាប គឺជាតំបន់វាលស្រែនៃ ខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង សៀមរាប និងខេត្តកំពង់ឆ្នាំង។

ទំនាបទន្លេបួនមុខ: គឺជាទំនាបដែលនៅសងខាងទន្លេ៤មុខ។ ទំនាបនេះមានផ្នែធំធេង និងចំណោតនៅផ្នែកខាងកើតទន្លេ ដូចជាទំនាបខេត្តព្រៃវែងនិងស្វាយរៀង។ ចំណែកផ្នែកខាងលិចទន្លេមានផ្នែតូចចង្អៀតហើយងើបយ៉ាងខ្ពស់ទៅរកជួរភ្នំក្រវ៉ាញ ដូចជានៅកំពង់លួង "ទំនាបមានទទឹងមធ្យម ១៥គម ប៉ុណ្ណោះ" ហើយនិង ១៣គម នៅខាងត្បូងតាខ្មៅ។

គេចែកសណ្ឋានដីទំនាបទន្លេជា៣ផ្នែកគឺ:

ផ្នែកទី១: ជាភូមិភាគល្បាប់ម័ដ្ឋ គឺជាផ្នែដីដែលនៅជាប់មាត់ទន្លេមាត់បឹងនិងជាយកោះ។ ភូមិភាគល្បាប់ម័ដ្ឋនេះ មានទទឹងពី ១០ទៅរាប់រយម៉ែត្រ ដែលជាដីមានជីជាតិសំរាប់ដំណាំចំការដូចជាកប្បាស់ មន ត្រុំ ថ្នាំជក់ និងបន្លែគ្រប់មុខ។ គឺភូមិភាគនេះហើយដែលមានប្រជាជនរស់នៅ កុះករជាងភូមិភាគឯទៀតៗ។

ផ្នែកទី២: ជាភូមិភាគលិចទឹកដែលពទ្ធ័ពីក្រៅភូមិភាគល្បាប់ម័ដ្ឋ។ ភូមិភាគនេះ មួយភាគធំត្រូវលិចនៅរដូវវស្សា គឺជាភូមិភាគសំបូរបឹង វាលភក់ ព្រៃកនិង អូរ។ គេឃើញប្រជាជរស់នៅក្រៃលែដែរ ព្រោះសំបូរត្រីធ្វើអាហារ និងមានកន្លែងប្រកបរបរកសិកម្មបានគ្រប់គ្រាន់ផងដែរ។

ផ្នែកទី៣: គឺជាវាលស្រែធំល្វឹងល្វើយមើលដាច់កន្ទុយភ្នែក ដែលបន្តពីភូមិភាគលិចទឹករហូតដល់ជើងភ្នំផ្នែកខាង និង រហូតដល់ព្រំដែនវៀតណាម "ផ្នែកខាងត្បូងនិងខាងកើត" ។

សេចក្តីសន្និដ្ឋាន: ការសិក្សាពីទំនាបកណ្តាលនៃប្រទេសកម្ពុជាបានបញ្ជាក់ឲ្យឃើញថា ទំនាបជាមណ្ឌលដែលបំពេញមុខងារយ៉ាងសំខាន់ក្នុងវិស័យកសិកម្ម ព្រមទាំងជាមណ្ឌលផ្តល់ត្រីយ៉ាងច្រើនសន្ធឹកសន្ធាប់ ទៀតផង។ ក្នុងតំបន់កណ្តាលទាំងមូល គេពុំឃើញមានភ្នំ ឬខ្ពង់រាបអ្វីធំដុំទេ គឺមានតែកូនភ្នំតូចៗឯណោះមួយ ឯណោះមួយ ដូចជាភ្នំនៅស្រុកបាទីខេត្តតាកែវ ភ្នំ"បាភ្នំ" នៅខេត្តសៀមរាប ភ្នំ"កង្រី" នៅកំពង់ឆ្នាំងតំបន់វាលស្រែធំល្វឹងល្វើយច្រើនមានក្នុងខេត្តបាត់ដំបង់ កំពង់ធំ កំពង់ចាម តាកែវ ព្រៃវែង ស្វាយរៀង។

ខ. ប្រជុំភ្នំ និងខ្ពស់រាប (les massife et les plateau): ដើម្បីងាយស្រួលក្នុងការសិក្សា គេចែកមណ្ឌលនេះជាផ្នែកតូច ៗ ទៀតគឺជួរភ្នំក្រវ៉ាញ តំបន់កូនភ្នំជួរភ្នំដងរែក និងតំបន់ខ្ពង់រាប។

១- ជួរភ្នំក្រវ៉ាញ: ជួរភ្នំក្រវ៉ាញស្ថិតនៅប៉ែកនិរតី នៃប្រទេសសណ្តោកតាមបណ្តោយឆ្នេរសមុទ្រ។

គេអាចសន្និដ្ឋានបានថា ជួរភ្នំក្រវ៉ាញ មានកំណើតក្នុងសម័យពំនើងផ្តត់ "អេស៊ីញៀង" ហើយក្លាយទៅជាទំនាបសំណឹក ដែលត្រូវគ្របដណ្តប់ដោយកំទេចកំណកនៅសក័ទី២។ ហេតុនេះហើយបានជាបាតភ្នំទាំងនោះសុទ្ធសឹងប្រកបទៅដោយថ្មក្រានីត គ្របដណ្តប់ពីក្រៅដោយថ្មក្រៃ លាយខ្សាច់យ៉ាងក្រាស់។ វិវត្តន៍

នៃសកម្មភាពសំណឹក បានស៊ីផ្តាច់ជួរភ្នំនេះ ជាខ្ពង់រាប ដែលមានមុខចំណោត "ភ្នំបូកគោ" ឬជាភ្នំដាច់ ពុ ពីគ្នាដែលគេអាចចែកជួរភ្នំក្រវ៉ាញជាបីផ្នែកគឺ៖

-ជួរភ្នំក្រវ៉ាញខាងលិច៖ សណ្តោកពីប៉ៃលិន រហូតដល់ស្ទឹងពោធិសាត់។ កំពូលភ្នំតូចៗ ដែលមាននៅក្នុងតំបន់នោះគឺ ភ្នំតាជិត"១.១១៤ម" ភ្នំទឹកព្រិល"១.១២៣ម " ភ្នំបូស"១.៣៣៧ម " ភ្នំធំ"១.២៥៨ម' ភ្នំខ្មោច"១.៤២៥" និងភ្នំទំព័រ"១.៥៦៣ម" ដែលជាភ្នំខ្ពស់ជាងគេក្នុងតំបន់នេះ។

-ជួរភ្នំក្រវ៉ាញកណ្តាល៖ ជាប្រជុំភ្នំមួយដ៏ធំ ដែលមានផ្នែករាងទេរ ពីមោងទៅកោះកុង។ ប៉ែកខាងលិចមានភ្នំសំកុះ"១.០០០ម" ដូចជាភ្នំប៉ាន"១.៤០០ម" ភ្នំបាកាន"១.២២០ម" និងភ្នំខ្នងត្រពាំង"១.១៧២ម'។

-ជួរភ្នំក្រវ៉ាញខាងកើត៖ ដែលចែកជាបីក្រុមទៀតគឺ៖

ប្រជុំភ្នំខ្ចោល៖ នៅចន្លោះខេត្តពោធិ៍សាត់ និង ខេត្តកំពង់ស្ពឺ គឺនៅខាងលិចខេត្តកំពង់ឆ្នាំង។ គឺនៅទីនេះហើយដែលមាន ភ្នំខ្ពស់ជាងគេនៃប្រទេសកម្ពុជា ឈ្មោះ" ភ្នំវ៉ាល "១៨១៣ម"។

ប្រជុំភ្នំអូម្ល៖ នៅចន្លោះស្រែអំពិល និង ខេត្តកំពង់ស្ពឺ ដែលមានរយៈកំពស់មិនលើសពី ១០០ម ឡើយដូចជាខ្ពង់រាបគីរីរម្យ "៧០០ម"ជាដើម។

ប្រជុំដំរីៈ នៅជាប់ពីប្រជុំភ្នំអូរម្ល ដោយច្រកពេជ្រនិលដែលកាត់ដោយផ្លូវជាតិលេខ៤ គឺផ្លូវពីភ្នំពេញទៅកំពង់សោម ខាងត្បូងផុតប្រជុំភ្នំនេះ បញ្ចាប់ដោយមុខចំណោតនៃភ្នំបូកគោ"១.០៧៥ម"។ ជួរភ្នំក្រវ៉ាញជាជញ្ជាំងខណ្ឌទំនាបកណ្តាល និងតំបន់សមុទ្រអាចប្រព្រឹត្តទៅបានតាមច្រកសំខាន់ៗ ៣គឺ ច្រកពេជ្រនិលពីកំពង់ស្ពឺទៅស្រែអំបិល ច្រកតាសីពីស្រែអំបិលទៅពោធិ៍សាត់ និងច្រកវាលវែង ពីមោងទៅកោះកុង។ តំបន់ជួរភ្នំក្រវ៉ាញនេះ ពុំទាន់បានទទួលការត្រួសត្រាយ ឬ របុករបកឲ្យបានជិតដល់ទេ។ ដោយស្ថិតនៅចំខ្យល់មូសុងវស្សា តំបន់នេះទទួលទឹកភ្លៀងច្រើនជាងគេ មានព្រៃក្រាស់តែពិបាកចេញចូលដោយខ្វះគមនាគមន៍។ ព្រៃតំបន់នេះមានលក្ខណៈជាព្រៃ ត្រូពិច ដែលមានរុក្ខជាតិគ្រប់ប្រភេទដុះប្រជ្រៀតគ្នា ហើយជាប្រភពទឹក នៃស្ទឹងទាំងឡាយផង ព្រមទាំងសំបូរទៅដោយសត្វតូច ធំ។

ខ្ពស់រាបខៀសល់។ ក្រៅពីនេះតាមសន្ធស្សន៍ នៃការស្រាវជ្រាវរ៉ែដែរ ធ្យូងថ្មមានប្រទេសកម្ពុជា។ សព្វថ្ងៃនេះ សិប្បករកម្ពុជា យើងទាញយករ៉ែខ្លះ ពីតំបន់នេះមករចនាជាគ្រឿងឡើយ។ ខ្ពង់រាបដូចជាថ្លើមថ្មជាដើម។ ដោយខ្វះគមនាគមន៍ តំបន់នេះ មានប្រជាជនរស់នៅតិចតួច "ពរ ស្លួច"ដោយបរបាញ់សត្វ បេះផ្លែឈើ និងធ្វើកសិកម្មព្រៃដុត។

២. តំបន់កូនភ្នំ

គឺតំបន់នៅជុំវិញភ្នំក្រវ៉ាញ ដែលមានកូនភ្នំនៅជាប់ពីគ្នាមានរយៈកំពស់មិនលើសពី ៨០០ម ទេ ហើយមានទំរង់ជាថ្មក្រៃ ថ្មស៊ីស ថ្មកំបោរ ។ គេចែកតំបន់កូនភ្នំនេះជា៦ក្រុម គឺតំបន់កូនភ្នំនៅតាមមាត់សមុទ្រ តំបន់កូនភ្នំខាងលិចខេត្តបាត់តំបង ដែលសន្ធឹងពីអូរជ្រៅមកមោង តំបន់កូនភ្នំចន្លោះខេត្តកំពង់ស្ពឺ និងកំពត និងតំបន់កូនភ្នំចន្លោះខេត្តកំពតនិងខេត្តតាកែវ ដែលមានកំពស់ពី១០០ទៅ៣០០ម ដូចជាភ្នំស៊ីសូផុន ភ្នំសំពៅ"បាត់ដំបង" ពោធិសាត់ ភ្នំក្រាំងលាវ កំពង់ឆ្នាំង ភ្នំព្រៃ កំពង់ស្ពឺ ភ្នំទ្វារ ភ្នំទូកមាស កំពត។

៣.ជួរភ្នំដងរ៉ែក

ជួរភ្នំដងរ៉ែកស្ថិតនៅតាមព្រំដែនខាងជើងកម្ពុជា-ថៃ។ ជួរភ្នំនេះសណ្តូកពីលិចទៅកើត គឺចាប់ពីជ្រលងទន្លេមេគង្គទៅជ្រលងទន្លេមេណាមនៃប្រទេសថៃ។ តាមពិតជួរភ្នំដងរ៉ែកមិនមែនជាជួរភ្នំទេ គឺជាគែមខាងត្បូងនៃខ្ពង់រាបនគរាជ ដែលស្ថិតនៅក្នុងភូមិភាគខាងកើតនៃប្រទេសថៃ។ ជួរភ្នំនេះជាជញ្ជាំងសិលាក្រៃដែលមានមុខចំណោតយ៉ាងខ្លាំងមកប្រទេសកម្ពុជា និងមានប្រវែងបណ្តោយ៣០០ម និងមានរយៈកំពស់ចុះជាលំដាប់ពីកើតទៅលិច គឺពី ៧០០ ទៅ ២០០ម។ កំពូលខ្ពស់ៗរាប់ពីកើតទៅលិចមានភ្នំដងរ៉ែក**៧៥៧ម**។ ទោះបីជួរភ្នំនេះជាជញ្ជាំងខណ្ឌប្រទេសកម្ពុជានិងថៃក៏ដោយ ក៏គេអាចធ្វើការឆ្លងកាត់បានដោយច្រកភ្នំជាច្រើន។ ច្រកសំខាន់ៗគឺច្រកអន្សែ ច្រកដូនតាប៉ាយ ច្រកដូនឌី ច្រកតាព្រហ្ម និងច្រកកូន។ ជួរភ្នំដងរ៉ែកជាតំបន់ព្រៃរបោះប្រកបទៅដោយឈើមានតំលៃៗ និងសំបូរទៅដោយសត្វព្រៃដូចជួរភ្នំក្រវ៉ាញដែរដែលសុទ្ធជាតំបន់មានសារៈសំខាន់ដល់សេដ្ឋកិច្ចជាតិ។ ម៉្យាងទៀត នៅតាមជើងភ្នំដងរ៉ែកមានមនុស្សតិចណាស់ប្រហែល៣នាក់ តំបន់ព្រៃក្រាស់ អ្នកស្រុក សំរ៉ែ ច្រើនធ្វើដំណាំព្រៃដុត បេះផ្លែឈើព្រៃ និង បរបាញ់សត្វ។

៤.តំបន់ខ្ពង់រាប

តំបន់ខ្ពង់រាប មាននៅប៉ែកខាងជើង ប៉ែកខាងកើត និងប៉ែកឦសាន។ ដើម្បីងាយស្រួលក្នុងការសិក្សាកគេអាចចែកតំបន់នេះជាពីរក្រុមគឺ៖

ខ្ពង់រាបខាងជើង ជាតំបន់ខ្ពស់ ដែលបន្តពីភ្នំដងរ៉ែក មកភ្ជាប់ទំនាបកណ្តាល ស្ថិតនៅក្នុងខេត្តសៀមរាប និង ខេត្តកំពង់ធំ។ ខ្ពង់រាបនេះគ្របដណ្តប់ដោយល្បាប់ចាស់ឆ្លាស់គ្នា និងថ្មបាយក្រៀម ដែលសំបូរទៅដោយព្រៃរបោះ។ នៅតាមទ្រនុងកណ្តាលនៃខ្ពង់រាប មានកូនភ្នំជាច់ៗពីគ្នា ដូចជាភ្នំត្បែង ភ្នំចុងកាល់ ភ្នំគូលែន ភ្នំសន្ទុក ។ល។ ក្រៅពីព្រៃរបោះ និងកូនភ្នំ ផ្ទៃដីខ្ពង់រាប មួយភាគជាដីសំរាប់ដាំដំណាំ។

ខ្ពង់រាបខាងកើត និង ឧត្តរសាន ជាតំបន់ដែលបន្តពីជ្រលងទន្លេមេគង្គ រហូតដល់ព្រំប្រទល់ប្រទេសវៀតណាម។ គេចែកតំបន់នេះ ជាបួនផ្នែកគឺ៖

ខ្ពង់រាបក្រចេះ និងខេត្តស្ទឹងត្រែង ដែលមានលក្ខណៈដូចគ្នានិងខ្ពង់រាបខាងជើងដែរ តែនៅដាច់ពីខ្ពង់រាបនេះដោយសារជ្រលងទន្លេមេគង្គគឺជាតំបន់ល្បាប់ចាស់ប្រកបដោយព្រៃរបោះ ហើយមិនសូវសំបូរកូនភ្នំទេ។

ខ្ពង់រាបខេត្តកំពង់ចាម ជាខ្ពង់រាបមួយមានផ្ទៃយ៉ាងទេទៅទិសឧត្តរសាន ហើយរយៈកំពស់២០០ម។ ប៉ែកខាងនិរតី ខ្ពង់រាបនេះសន្ទឹងមកជាប់ និងទំនាបកណ្តាល។ ខ្ពង់រាបខេត្តកំពង់ចាមមានផ្ទៃរាបស្មើគ្របដណ្តប់ដោយល្បាប់ចាស់ និងថ្មបាសាល់ដែលមានស្រទាប់លើពុកផុយក្លាយទៅជាដីក្រហមទៅហើយ។ គេសង្កេតឃើញមានទួលថ្មបាសាល់ចំនួន៤ កន្លែង ដែលសព្វថ្ងៃជាចំការធំ ពិសេសចំការកៅស៊ូគឺ ចំការលើមេមត់ ស្វាយ និងដំបៅ។

ខ្ពង់រាបខេត្តរតនគិរី ដែលបន្តពីខ្ពង់រាបកន្ទុំនៃប្រទេសវៀតណាម។ ខ្ពង់រាបនេះខ័ណ្ឌប្រទេសកម្ពុជាពីប្រទេសឡាវផង និង ប្រទេសវៀតណាមផង គឺជាតំបន់ដែលពុំសូវមានគេស្គាល់ឡើយ។ ខ្ពង់រាបនេះស្ថិតនៅចន្លោះជ្រលងទន្លេសាប ទន្លេស្រែពក និង ព្រំប្រទល់វៀតណាម។ វាមានលក្ខណៈជាទំនាបថ្មក្រៃ និងខ្ពង់រាបថ្មបាសាល់ ដែលមានរយៈកំពស់៣០០ម ហើយគេនិយមហៅថា"ខ្ពង់រាបបរកែវ"។ ខ្ពង់រាបបរកែវជាកន្លែងភ្នំ

ភ្លើងចាស់ ព្រោះទីនោះមានកំអែភ្នំភ្លើង មានដីក្រហម មានផេះភ្នំភ្លើង នេះបានក្លាយទៅជាបឹងយក្សឡាម"ជាដើម"។ កំពូលភ្នំភ្លើងដែលមាននៅក្នុងតំបន់ខ្ពង់រាបនេះ គឺភ្នំ "ពោងពាយ" ៨១៦ម ភ្នំក្រង់ ៨១២ម ភ្នំរាំង ៧០១ម។ លក្ខណៈសម្បត្តិធម្មជាតិ នៅក្នុងតំបន់ខ្ពង់រាប ខាងជើង និងត្តសាន ជាតំបន់ព្រៃដូចជាតំបន់ភ្នំក្រវ៉ាញដែរ ដែលជាព្រៃក្រាស់ ផ្តល់ពូជឈើល្អសំរាប់សំណង់នានា តុ និងទូរ។

ខ្ពង់រាបខេត្តមណ្ឌលគិរី ជាខ្ពង់រាបបន្តពីខ្ពង់រាប ដាកឡាត់ នៃប្រទេសវៀតណាម។ ខ្ពង់រាបខេត្តមណ្ឌលគិរីមានវាលថ្មក្រៃ ដែលងើបឡើងពីតែមទន្លេមេគង្គទៅខ្ពង់រាបឆ្លងលើ ដែលមានរយៈកំពស់ប្រហែលនិងខ្ពង់រាបរតនគិរីដែរ។ ខ្ពង់រាបឆ្លងលើ គ្រប់ដណ្តប់ដោយថ្មបាសាល់ ដែលមានមួយភាគបានក្លាយជាដីក្រហម។ ដោយឥទ្ធិពលសំណឹក ខ្ពង់រាបនេះ មានផ្ទៃមិនសូវរាបស្មើទេ គឺមានរាងកំពូលដូចបាល់ឡុង ស្ថិតនៅជាបន្តបន្ទាប់គ្នា។ មានតែកំពូលមួយទេដែលមានកំពស់ដល់ទៅ ១.១០៣ ម គឺភ្នំព្រះបាទ។ ព្រៃរបោះ និងស្បូវដុះពីលើនៅពាសពេញព្រមទាំងមានសត្វច្រើនយ៉ាង ដូចជាអំបូរគោព្រៃ ខ្ទីង រមាស ខ្លាធំ ទន្សោង ខ្លាឃ្មុំ ជ័រី ។ល។ នៅតំបន់ខ្ពង់រាបខាងកើត ក្រៅពីភូមិស្រុក មានកុលសម្ព័ន្ធ ខា ស្មៀង និង ព្នង រស់នៅ។ តំបន់ខ្ពង់រាបទាំងនេះផ្តល់ប្រយោជន៍ដ៏សំខាន់ ចំពោះសេដ្ឋកិច្ចជាច្រើនៈឈើគ្រប់មុខ ដីក្រហម ត្បូង រ៉ែ។

៥. តំបន់ឆ្នេរសមុទ្រ

គឺជាតំបន់ដែលស្ថិតនៅប៉ែកនិរតីនៃប្រទេស។ គេអាចចែកតំបន់នេះជា ៣ផ្នែកគឺៈ

- **ទំនាបឆ្នេរ** (PLAINE CÔTIÈRE)

គឺតំបន់ចន្លោះឆ្នេរសមុទ្រ និងជួរភ្នំក្រវ៉ាញ។ ទំនាប់នេះមានរយៈកំពស់ងើបឡើងឆាប់រហ័សពីឆ្នេរទៅនិងជើងភ្នំ ហើលដែលសំបូរទៅដោយកូនភ្នំ និងផ្លូវទឹក ដែលហូរធ្លាក់ចុះពីជួរភ្នំក្រវ៉ាញទោះបីមានរយៈកំពស់ងើបឡើងឆាប់រហ័សនិងទទួលសំណឹកយ៉ាងខ្លាំងក៏ដោយ ក៏តំបន់នេះនៅតែមាន សារៈសំខាន់ដល់សេដ្ឋកិច្ចជាតិខ្លះដែរ ព្រោះគេអាចធ្វើចំការដំណាំធំ ដូចជា ចំការដូង ចំការម្រេច ចំការទូរេន ហើយនិងចំការកៅស៊ូ នៅជិតកំពង់សោម។ ក្រៅពីនេះទំនាបឆ្នេរច្រើនតែសំបូរទៅដោយព្រៃកោងកាងដែលផ្តល់ថាមពលពិសេសមួយដែរ ក្នុងការចំអិនម្ហូបអាហារ។

- **ឆ្នេរសមុទ្រ** (les sôtes)

ប្រទេសកម្ពុជាមានឆ្នេរសមុទ្រវែង ៤៤០ គម ដែលលាតសន្ធឹងពីខេត្តកោះកុងរហូតដល់ ខេត្តកំពត។ ឆ្នេរនេះ មានឆ្នេរសភាព រឆេញរឆុញខ្លាំងណាស់ដែរ ដែលមានស្នើរកោះពីរយ៉ាងធំនៅដាច់ពីគ្នា ដោយឆកកំពង់សោម គឺស្នើរកោះវាលរេញ នោងស្នើរកោះស្មាច់។ គេចែកស្នើរកោះប្រទេសកម្ពុជា ជា៥ផ្នែក គឺពីពាយព្យទៅអគ្នេយ៍ ដែលមានៈ ពីព្រំប្រទល់ថៃត្រង់ចាំយាម ទៅទល់និងព្រែកគគីរ ឆ្នេរតំបន់នេះទាបមានវាលភក់ និងព្រៃកោងកាង ហើយនិងមានភូមិអ្នកនេសាទជាច្រើន ដូចជា ថ្នល់ក្របី បឹងក្រសោបកោះកាពិ។ ល។ ព្រែកគគីរ ទៅទល់និងជ្រោយសូរិយវង្ស ឆ្នេរសមុទ្រស្ថិតនៅក្បែរជើងភ្នំ និងចំផ្លូវខ្យល់មូសុងបក់ ដែលបណ្តាលអោយឆ្នេរមានសភាពរឆេញរឆុញខ្លាំង និងពុំសូវមានមនុស្សរស់នៅទេ។ ឆក BAIE កំពង់សោម សំបូរព្រៃតែគ្មានមនុស្សរស់នៅទេ។ នៅខាងឆកនេះមានជ្រោយសុរិយវង្ស និងជ្រោយថ្មសដែលមានភូមិអ្នកនេសាទនៅត្រង់ ចំលងគោ។ នៅខាងកើតឆកកំពង់សោមមានជ្រោយវាលរេញ ដែលមានកំពង់ផែកំពង់សោម។ ឆកកំពង់សោមមានប្រវែង ៣០គម ហើយចាប់រាក់បន្តិចម្តង ដោយសារល្បាប់ដែលព្រែកទាំងមូលហូរនាំ

ចូលមក។ ពីកំពង់សោមទៅឆកទឹកសាប មានឆ្នេរខ្សាច់ជាច្រើនប្រកបដោយដើមស្វាយ។ នៅចំកណ្តាលវាលឆ្នេរនេះមានឆកវាមដែលជាជំរកយ៉ាងល្អ សំរាប់កំពង់ផែ។ ពីឆកទឹកសាបទៅហាទៀង មាត់សមុទ្រមានរាងផតចូលក្នុងដោយសារឆកទឹកសាប និងឆកវាលរេញ។ ឆ្នេរតំបន់នេះមានផ្ទៃរាប ហើយពោរពេញទៅដោយវាលភក់ក្បែរមុខចំណោត FALAISE បូកគោ ឆ្នេរមានរាងជាឆ្នូ សំបូរទៅដោយដើមកោងកាង(LES PALÉTUVIERS) ខាងកើតពាមសមុទ្រLÉSTUAIRE DE DE LA RIVIERE នៃស្ទឹងកំពតគឺឆ្នេរខ្សាច់ដែលមានស្ថានីយងូតទឹក កែប UNE STATION BALANÉAIRE។

- **ឈូងសមុទ្រ (GOLFE DU KAMPUCHEA)**

ឈូងសមុទ្រខ្មែរពុំសូវជ្រៅប៉ុន្មានទេ ហើយមានបាតរាបស្មើរ ជំរៅមធ្យម មាន៥០គម ហើយជំរៅអតិបរិមាមានមិនលើសពី៧៥ម ឡើយ។ ឈូងសមុទ្រនេះខ័ណ្ឌប្រទេសកម្ពុជាពីឧបទ្វីប ម៉ាឡាកា។ ទោះបីឈូងសមុទ្រនេះមានជំរៅមិនសូវជ្រៅក៏ដោយ ក៏នាវាសមុទ្រធំ បានចូលមកដល់កំផែកំពង់សោមបានដោយងាយដែរ។ ម៉្យាងទៀតឈូងសមុទ្រនេះ សំបូរកោះណាស់ កោះដែលជាកម្មសិទ្ធិរបស់ប្រទេសកម្ពុជា គឺ៖

កោះកុងខាងជើងពាមសមុទ្រព្រៃកតាតីគឺ ប្លុកដីដែលមិនបានទទួលសំរុតបាតសមុទ្រ ដូចជាកោះព័រ កោះកាពិ កោះចៅលាវ កោះស្តេត និងកោះមូល។ កោះកុងជាកោះធំជាងគេនៃប្រទេសកម្ពុជា ដែលមានទំហំប្រហែល ៨០គម^{2} គឺជាកូនភ្នំមួយមានកំពស់ ៤១០ម ដែលដាច់ចេញពីទ្វីបដោយបំណាក់បាតសមុទ្រ។ ប៉ែកខាងលិច កោះកុងបែរមុខទៅរកខ្សល់មូសុងនីរតី បណ្តាលឲ្យកោះនេះមានរាង រឆេញរឆុញប្រកបទៅដោយផ្នាំងថ្ម ដែលស្ទើរតែចូលពុំចុះ។ ផ្ទុយទៅវិញឆ្នេរខាងកើតគេចផុតពីខ្សល់មូសុងដែលមានប្រជាជនរស់នៅ និងមានចំការដំណាំយ៉ាងច្រើន។ ក្រុមកោះដែលនៅចន្លោះកោះកុង និងជ្រោយស្មាច់ គឺជាកូនកោះមួយជួរប្រកបដោយថ្ម។ កោះដែលនៅមុខឆក កំពង់សោម មានកោះរង់ និងកោះរង់សន្លឹម។ កោះនៅឯនាយស្ទើរកោះវាលរេញមានបួនក្រុមគឺក្រុមទី១ នៅពីមុខកំពង់ផែកំពង់សោមមានកោះពស់ ក្រុមទី២ នៅមុខរាមមានកោះតាកៀវ កោះឫស្សី កោះត្រែះ កោះចន្លុះ និងកោះស្រមោច ក្រុមទី៣ មានកោះត្រង់ កោះថ្មី និងកោះសេះ ក្រុមទី៤គឺកោះដែលនៅលំហូរ ឈូងសមុទ្រមានកោះតាង កោះអន្លើយ៍ កោះព្រីង កោះវៀ និង កោះវ៉ែ។ ជាចុងក្រោយបង្អស់ នៅខាងត្បូងស្ថានីយកែប មានកោះស្វាយ កោះទន្សាយ កោះត្បាល់ កោះអង្គុញ កោះសេះ និងកោះឫស្សី កោះទាំងអស់នេះមានប្រជាជនរស់នៅតិចតួចណាស់ព្រមទាំងប្រកបដោយស្រែស្តុកដែលគេពុំទាន់បានទាញយកផលនៅឡើយ។ ប៉ុន្តែសព្វថ្ងៃនេះ កោះមួយភាគធំជាមជ្ឈមណ្ឌលនេសាទយ៉ាងសំខាន់នៅជួរដែល ខ្សល់មូសុងបក់ពីទិសឥសាន្ត។

៥.២.១.២ ប្រភេទដី

ក. ប្រភេទដីទូទៅនៅប្រទេសកម្ពុជា

ប្រទេសកម្ពុជាមានផ្ទៃដីចំនួន ១៨១,០៣៥គម^{2}។ ហើយ Dr. Crocker, ១៩៦៣ មានប្រភេទដីចំនួន ១៦ប្រភេទ គឺ Red yellow podzols (ដីខ្សាច់ជ្រៅអាស៊ីត 'ប៉ុតសូលីត') ដែលមានផ្ទៃដី ២២,៧៦៣ គម^{2}= ១២.៥៥%, Larosols(ដីក្រហមលើ បាសាល្ត៍) ដែលមានផ្ទៃដី ៧,១២៣គម^{2}= ៣.៩៣, Planosols(ដីជាំទឹកប្រភេទ 'ប្លាណូសុល') ដែលមានផ្ទៃដី ១,៦៦៦គម^{2}= ០.៩២%, Plinthite

podzols(ដីជាំទឹកប្រភេទ 'ឥដ្ឋមានឡាតេរីត') ដែលមានផ្ទៃដី ១៧,១៤៧គម^{២}= ៩.៤៧%, Culturak hydromorphics('ដីស្រែ' រចរិលលើល្បាប់ចាស់) ដែលមានផ្ទៃដី ១២,៨៩៦គម^{២}= ៧.១៣%, Grey hydromorphics(ដីឥដ្ឋខ្មៅជាំទឹក) ដែលមាន១៧,២៥២គម^{២}= ៩.៥៣%, Plenthitic hydromorphics('ឡាតេរីតជាំទឹកជានិច្ចកាល') ដែលមានផ្ទៃដី ១,២៧៥គម^{២}= ០.៧១%, Brown hydromorphics(ដីឥដ្ឋស្រែ 'ប្រភេទបាត់ដំបង') ដែលមានផ្ទៃដី ៦,៧០១គម^{២}= ៣.៧២%, Alumisols(ដីខ្មៅអណ្តែត) ដែលមានផ្ទៃដី ២,៧៨២គម^{២}= ១.៥៣%, Regurs(ដីឥដ្ឋហើមប្រភេទ 'រ៉ែគ្លា') ដែលមានផ្ទៃដី ៦,៥៧០គម^{២}= ៣.៦៣%, Acid lithosols (ដីរាក់គ្រួសអាស៊ីត) ដែលមានផ្ទៃដី ៤៥,២៧១គម^{២}= ២៥.០០%, Basic lithosols(ដីរាក់គ្រួសបាសាល្ត៍) ដែលមានផ្ទៃដី ៣,៤១៨គម^{២}= ១.៩០%, Alluvial soils(ដីល្បាប់កណ្តោង) ដែលមានផ្ទៃដី ១៧,០៦៤គម^{២}=៩.៤៣%, Brown alluvials(ដីល្បាប់ល្បាយ) ដែលមានផ្ទៃដី ២,៧៥៤គម^{២}= ១.៥៣%, Lacustrine alluvials(ដីល្បាប់ឥដ្ឋ(វាលភក់)) ដែលមានផ្ទៃដី ១០,៣៧៣គម^{២}= ៥.៧៣%, Coastal complex(ល្បាប់ សមុទ្រ) ដែលមានផ្ទៃដី ២,២២៩គម^{២}= ១.២៣% (សូមមើលឧបសម្ព័ន្ធ២ តារាង១.១)។ តាមផែនទីក្នុងឧបសម្ព័ន្ធ២ តារាង១.២លទ្ធផលសិក្សាប្រភេទដីនៅតាមតំបន់ការបញ្ចប់ប្រភេទដីនៅទីតាំងខ្សែកាបអុបទិចមានដូចខាងក្រោម៖

ក. ប្រភេទដីនៅឃុំដូនយ៉ាយ និងឃុំសត្វពង ស្រុកឈូក ខេត្តកំពត មាន១ប្រភេទគឺ Cultural hydromorphics('ដីស្រែ' រចរិលលើល្បាប់ចាស់)។

ខ. ប្រភេទដីនៅឃុំកំពង់ពពិល ស្រុកពារាំង ខេត្ត ព្រៃវែង មាន១ប្រភេទគឺ Alluvial Lithosols។

គ. ប្រភេទដីនៅឃុំស្វាយឃ្លាំង ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ មាន១ប្រភេទគឺ Great Lake។

ឃ. ប្រភេទដីនៅឃុំសណ្តាន់ និងឃុំមានរិទ្ធ ស្រុកសណ្តាន់ ខេត្តកំពង់ធំ មាន១ប្រភេទគឺ Alluvial Lithosols។

ង. ប្រភេទដីនៅសង្កាត់ព្រៃញី សាលាក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ មាន៣ប្រភេទគឺ Grey hydromorphics (ដីឥដ្ឋខ្មៅជាំទឹក), Cultural hydromorphics('ដីស្រែ' រចរិលលើល្បាប់ចាស់), Alluvial Lithosols។

៥.២.១.៣ ភូគព្ភសាស្ត្រ

ប្រវត្តិធរណីនៃសណ្ឋានដីប្រទេសកម្ពុជា(Histoire géologique du relief de Kampuchea)កំណកំណើនសណ្ឋានដីប្រទេសកម្ពុជា គឺជាលទ្ធផលនៃវិវត្តន៍ធរណីកាលមួយយ៉ាងវែងដែលគេអាចបញ្ជាក់ត្រួសៗដូចតទៅ៖ មុនស័កទី១)Ere primaire) ភូមិភាគនេះ បានទទួលពំនើងផ្នត់ កាលេដូញាង (plissement calédonien) ដែលបណ្តាលឲ្យមានរំលេចក្រានីតជាច្រើនអន្លើ។ នៅស័កទី១ ពំនើងផ្នត់ថ្មីមួយទៀតដែលមានលំនាំទិសដូចមុន បានចាប់ផ្តើមឡើង គឺពំនើងផ្នត់ អ៊ែស៊ីញាង (plissement hercynien)។ តែផ្ទៃដីពំនើងផ្នត់ នេះ បានក្លាយទៅជាទំនាបសំណឹក(plaine d'érosion) នៅចុងស័កទី១ ។ នៅស័កទី២ (Ere secondaire) ដែលជាសម័យកំណកកំទេចសិលាកំបោរ(Sédimentation calcaire និង ជាសម័យ រង្វាតសមុទ្រ(transgression marine) ផ្ទៃដីទាំងអស់ត្រូវបានលិចកប់ក្រោមទឹក និង ក្រោមកំណកសិលា ក្រៃ។

ដូចនោះ ផ្ទៃដីប្រៀបបានទៅ និងរណ្តៅមួយយ៉ាងជ្រៅ។ ចាប់ពីសក័ទី៣ (Ere tertiare) មក ភូមិភាគនេះ ប្រហែលបានទទួលចលនាក្នុងជំរៅដីយ៉ាងញឹកញាប់ ជាហេតុបណ្តាលឲ្យមានទ្រនុង និងសំរុត លេចជាមុខចំណោតឡើង(escarpement) ។ បន្ទាប់មក មុខចំណោតក៏ត្រូវរិចរិលទៅដោយសារសំណឹក និង រំហូរថ្មបាសាល់មកលើ។ ឧទាហរណ៍ៈ ភ្នំក្រានីតនៅក្នុងស្រុកបាទី សំណឹកស៊ីផ្តាច់ផ្ទាំងសិលាក្រែ ដូចមាននៅភ្នំក្រវ៉ាញ ភ្នំដងរ៉ែក និងខ្ពង់រាបឥ្សសានជាតឹកតាងស្រាប់។ នៅសក័ទី៤ (Ere quaternaire) ចលនាធរណីខាងលើនេះ ជាចលនារុញឡើងលើយ៉ាងយឺត ស្របជាមួយ និងតំហយទឹកសមុទ្រ (regression marine) បណ្តាលឲ្យលេចរហូតដល់ឃើញល្បាប់ក្បែរល្បាប់ថ្មី គឺវាលទំនាបកណ្តាលសព្វថ្ងៃនេះ។ ការសិក្សាវិវត្តន៍ទំរង់ដីប្រទេសកម្ពុជាទាំងមូល បានបង្ហាញឲ្យដឹងថា ដំណើរសំណឹកនិងកំណើតកំណកំទេច តែងមាននៅគ្រប់សម័យធរណីទាំងអស់ដូចជាកំណើតស្រទាប់ដីឥដ្ឋសម័យ "ស្ហ៉ាស៊ិច"Jurassique យ៉ាងក្រាស់និងបំណក់ (faille)បំពេញដោយកំទេចថ្មនៃទន្លេមេគង្គតាំងពីមុនសក័ទី៣ និង ជាមេរៀនរហូតមក។ គឺបាតុភូតទាំងអស់នេះ ហើយដែលកសាងសណ្ឋានដីប្រទេសកម្ពុជាសព្វថ្ងៃនេះ។ ឧទាហរណ៍ៈ នៅប្រជុំភ្នំក្រវ៉ាញនិងនៅភូមិភាគខាងកើត សំណឹកបានស៊ីផ្តាច់ខ្ពង់រាប បណ្តាលឲ្យមានមុខចំណោតខ្ពស់"ភ្នំ"ជាច្រើនអន្លើ ដូចជាភ្នំបូកគោដែលនៅជួរភ្នំដំរីជាដើម។ ដំណាក់កាលពុកផុយនៃសិលាទាំងឡាយ ដោយសារអាកាសធាតុក្តៅហើយសើមនេះ ទើបគ្រប់យ៉ាងប្រព្រឹត្តទៅច្រើនកន្លែង។ ការពុកផុយខ្លាំងហើយអាប់បែបនេះ បង្កើតឲ្យមានដី"ថ្មបាយក្រៀម"នៅលើផ្ទៃដីមួយភាគធំដែលជួនកាលជាទីសំបូរជាតិដែក ដូចជាកំពង់ធំ និង សៀមរាបជាដើម។ នៅរដូវវស្សា ទឹកភ្លៀងបានហូរនាំកំទេចសិលាពុកផុយទាំងនោះទៅចាក់គរនៅបាតបឹង បាតសមុត្រនិង បាតទន្លេ បណ្តាលឲ្យរាក់បន្តិចម្តងៗ ក្លាយទៅជាវាលភក់ ឬវាយទំនាប ឬដីសណ្តា។ សព្វថ្ងៃនេះទន្លេមេគង្គបានដឹកជញ្ជូនទៅចាក់គរនៅតាមពាមសមុទ្រ នូវកំទេចថ្មក្រួស ខ្សាច់ បណ្តាលឲ្យមានដីសណ្តាដុះពី ១០០ម ទៅ១៥០ម ក្នុងមួយឆ្នាំៗ។ ចំណែកនៅតាមឈូងសមុទ្រសកម្មភាពទឹកស្ទឹងដែលហូរធ្លាក់ចុះពីភ្នំក្រវ៉ាញ បានធ្វើឲ្យឆ្នេរសមុទ្រយើងរាក់បន្តិចម្តងៗដែរ នៅត្រង់ម្តុំភូមិភាគកំពត និងកំពង់សោម។

៤.២.២ អាកាសធាតុ

អាកាសធាតុ ជាស្ថានភាពបរិយាកាសរបស់តំបន់មួយក្នុងពេលវេលាមួយជាក់លាក់។ ធាតុផ្សំនៃអាកាសធាតុ មានដូចជាៈ សីតុណ្ហភាព កម្រិតទឹកភ្លៀង សំណើម ទិសខ្យល់ និងល្បឿនខ្យល់បក់។ មិនត្រឹមតែប៉ុណ្ណោះទេប្រព័ន្ធអាកាសធាតុនេះវាមានឥទ្ធិពលយ៉ាងខ្លាំងទៅលើប្រព័ន្ធអេកូស៊ីក្នុងតំបន់ មួយ។

អាកាសធាតុប្រទេសកម្ពុជាយើង ក៏ដូចជាប្រទេសជិតខាងនៅអាស៊ីអាគ្នេយ៍ដែរ គឺទទួលរងនូវឥទ្ធិពលពីរបបខ្យល់មូសុង និងអាកាសធាតុតំបន់ត្រូពិក ដែលជាអាកាសធាតុក្តៅហើយសើម ហើយមានពន្លឺព្រះអាទិត្យពេញលេញ និងភ្លៀងធ្លាក់គ្រប់គ្រាន់ លក្ខណៈល្អនេះបានអំណោយផលដល់ការរស់នៅរបស់មនុស្សសត្ធ និងរុក្ខជាតិ។ ការប្រែប្រួលនូវស្ថានភាពអាកាសធាតុនៅក្នុងតំបន់នោះ៖

៥.២.២.១ អាកាសធាតុនៅខេត្តកំពត

ក. សីតុណ្ហភាពមធ្យមអតិបរមា និងអប្បរមាប្រចាំឆ្នាំនៅខេត្តកំពត៖

តាមក្រាហ្វិក ៥.១ បង្ហាញពីសីតុណ្ហភាពមធ្យមអតិបរមា និងអប្បរមាប្រចាំឆ្នាំនៅខេត្តកំពតគឺ៖ នៅឆ្នាំ២០១០មានសីតុណ្ហភាពអប្បរមា ២២ °C និងសីតុណ្ហភាពអតិបរមា ៣៥ °C, នៅឆ្នាំ២០១១មានសីតុណ្ហភាពអប្បរមា ២២ °C និងសីតុណ្ហភាពអតិបរមា ៣៣ °C, នៅឆ្នាំ២០១២មានសីតុណ្ហភាពអប្បរមា ២៣ °C និងសីតុណ្ហភាពអតិបរមា ៣៥ °C, នៅឆ្នាំ២០១៣មានសីតុណ្ហភាពអប្បរមា ២៥ °C និងសីតុណ្ហភាពអតិបរមា ៣២ °C និងនៅឆ្នាំ២០១៤មានសីតុណ្ហភាពអប្បរមា ២៦ °C និងសីតុណ្ហភាពអតិបរមា ៣៣ °C។ ដូចនេះ សីតុណ្ហភាពអប្បរមាទាបជាងគេគឺនៅ ឆ្នាំ២០១០និងឆ្នាំ២០១១, សីតុណ្ហភាពអប្បរមាខ្ពស់ជាងគេគឺនៅ ឆ្នាំ២០១៤, សីតុណ្ហភាពអតិបរមាទាបជាងគេគឺនៅ ឆ្នាំ២០១៣, សីតុណ្ហភាពអតិបរមាខ្ពស់ជាងគេគឺនៅ ឆ្នាំ២០១០និងឆ្នាំ២០១២ (ក្រ.ធ.ទ.ឧ)។



ក្រាហ្វិក ៥.១៖ សីតុណ្ហភាពមធ្យមអតិបរមា និងអប្បរមាប្រចាំឆ្នាំនៅខេត្តកំពត

ខ. កំពស់ទឹកភ្លៀងប្រចាំឆ្នាំនៅខេត្តកំពត

តាមក្រាហ្វិក ៥.២៖ បង្ហាញថាកំពស់ទឹកភ្លៀងប្រចាំឆ្នាំនៅខេត្តកំពតគឺ

នៅឆ្នាំ២០១០ មានកំពស់ទឹកភ្លៀង ១៤១៩មម, នៅឆ្នាំ២០១១ មានកំពស់ទឹកភ្លៀង ១៧៣៨មម, នៅឆ្នាំ២០១២ មានកំពស់ទឹកភ្លៀង ១៣៩៥មម, នៅឆ្នាំ២០១៣ មានកំពស់ទឹកភ្លៀង ១៦៤៤មម និងនៅឆ្នាំ២០១៤ មានកំពស់ទឹកភ្លៀង ១១៧៤មម។ ដូចនេះ កំពស់ទឹកភ្លៀងខ្ពស់ជាងគេគឺនៅ ឆ្នាំ២០១១ និងកំពស់ទឹកភ្លៀងទាបជាងគេគឺនៅ ឆ្នាំ២០១២ (ក្រ.ធ.ទ.ឧ)។

Draft



ក្រាហ្វិក ៥.២៖ កំពស់ទឹកភ្លៀងប្រចាំឆ្នាំនៅខេត្តកំពត

គ. ល្បឿនខ្យល់មធ្យមអតិបរមា និងអប្បរមាប្រចាំឆ្នាំនៅខេត្តកំពត

តាមតារាង ៥.១ ខាងក្រោម បង្ហាញថាល្បឿនខ្យល់មធ្យមអតិបរមា និងអប្បរមាប្រចាំឆ្នាំនៅខេត្តកំពតគឺ៖ នៅឆ្នាំ២០១០មានល្បឿនខ្យល់អប្បរមា ២ម/វិ, ល្បឿនខ្យល់អតិបរមា ១៤ម/វិ, នៅឆ្នាំ២០១១មានល្បឿនខ្យល់អប្បរមា ៨ម/វិ, ល្បឿនខ្យល់អតិបរមា ១៩ម/វិ, នៅឆ្នាំ២០១២មានល្បឿនខ្យល់អប្បរមា ៧ម/វិ, ល្បឿនខ្យល់អតិបរមា ១៥ម/វិ, នៅឆ្នាំ២០១៣មានល្បឿនខ្យល់អប្បរមា ៥ម/វិ, ល្បឿនខ្យល់អតិបរមា ១៦ម/វិ និងនៅឆ្នាំ២០១៤មានល្បឿនខ្យល់អប្បរមា ៨ម/វិ, ល្បឿនខ្យល់អតិបរមា ១៥ម/វិ។ ដូចនេះ ល្បឿនខ្យល់អប្បរមាទាបជាងគេគឺនៅ ឆ្នាំ២០១០, ល្បឿនខ្យល់អប្បរមាខ្ពស់ជាងគេគឺនៅ ឆ្នាំ២០១១និងឆ្នាំ២០១៤, ល្បឿនខ្យល់អតិបរមាទាបជាងគេគឺនៅ ឆ្នាំ២០១១ និងល្បឿនខ្យល់អតិបរមាខ្ពស់ជាងគេគឺនៅ ឆ្នាំ២០១០ (ក្រ.ធ.ទ.ឧ)។

តារាង ៥.១៖ ល្បឿន និងទិសដៅខ្យល់មធ្យមអតិបរមា និងអប្បរមាប្រចាំឆ្នាំនៅខេត្តកំពត

ល្បឿនខ្យល់ (ម/វិ)Wind Speed														
ខេត្តកំពត														
Month	Jan	Feb	Mar	Apr	May	Jun	Jul	Aug	Sep	Oct	Nov	Dec	**Max**	**Min**
2010	NE	SE	NE	S	SE	W	SW	SW	NW	N	E	N	**14**	**2**
	4	2	4	3	8	8	10	6	14	7	6	6		
2011	NE	SE	NE	S	SE	W	SW	SW	NW	N	E	N	**19**	**8**
	10.0	10.0	10.0	8.0	17.0	18.0	19.0	12.0	12.0	16.0	13.0	12.0		
2012	NE	SE	NE	S	SE	W	SW	SW	NW	N	E	N	**15**	**7**

	7.0	8.0	13.0	14.0	15.0	12.0	10.0	10.0	10.0	10.0	8.0	10.0		
2013	NE	SE	NE	S	SE	W	SW	SW	NW	N	E	N	**16**	**5**
	8.0	5.0	9.0	10.0	9.0	10.0	10.0	10.0	16.0	9.0	8.0	8.0		
2014	NE	SE	NE	S	SE	W	SW	SW	NW	N	E	N	**15**	**8**
	11	10	13	14	15	13	12	11	12	8	8	10		

៥.២.២.២ អាកាសធាតុនៅខេត្តព្រៃវែង

ក. សីតុណ្ហភាពមធ្យមអតិបរមា និងអប្បរមាប្រចាំឆ្នាំនៅខេត្តព្រៃវែង

តាមក្រាហ្វិក ៥.៣៖ បង្ហាញថាសីតុណ្ហភាពមធ្យមអតិបរមា និងអប្បរមាប្រចាំឆ្នាំនៅខេត្តព្រៃវែងគឺ៖ នៅឆ្នាំ២០១០មានសីតុណ្ហភាពអប្បរមា ២៣ ° C និងសីតុណ្ហភាណអតិបរមា ៣៤ ° C, នៅឆ្នាំ ២០១១មានសីតុណ្ហភាពអប្បរមា ២៣ °C និងសីតុណ្ហភាណអតិបរមា ៣៣ °C, នៅឆ្នាំ២០១២មានសីតុណ្ហ ភាពអប្បរមា ២៤ °C និងសីតុណ្ហភាណអតិបរមា ៣៤ °C, នៅឆ្នាំ២០១៣មានសីតុណ្ហភាពអប្បរមា ២៣ °C និងសីតុណ្ហភាណអតិបរមា ៣៤ °C និងនៅឆ្នាំ២០១៤មានសីតុណ្ហភាពអប្បរមា ២៣ °C និងសីតុណ្ហភាណ អតិបរមា ៣៦ °C។ ដូចនេះ សីតុណ្ហភាពអប្បរមាទាបជាងគឺនៅ ឆ្នាំ២០១០, ឆ្នាំ២០១១, ឆ្នាំ២០១៣ និងឆ្នាំ ២០១៤, សីតុណ្ហភាពអប្បរមាខ្ពស់ជាងគឺនៅ ឆ្នាំ២០១២, សីតុណ្ហភាពអតិបរមាទាបជាងគឺនៅ ឆ្នាំ២០១២ និងសីតុណ្ហភាពអតិបរមាខ្ពស់ជាងគឺនៅ ឆ្នាំ២០១៤ (ក្រ.ធ.ទ.ឧ)។



ក្រាហ្វិក ៥.៣៖ សីតុណ្ហភាពមធ្យមអតិបរមា និងអប្បរមាប្រចាំឆ្នាំនៅខេត្តព្រៃវែង

Draft

ខ. កំពស់ទឹកភ្លៀងប្រចាំឆ្នាំនៅខេត្តព្រៃវែង

តាមក្រាហ្វិក ៥.៤ បង្ហាញថាកំពស់ទឹកភ្លៀងប្រចាំឆ្នាំនៅខេត្តព្រៃវែងគឺ៖ នៅឆ្នាំ២០១០ មានកំពស់ទឹកភ្លៀង ១៨៨៨មម, នៅឆ្នាំ២០១១ មានកំពស់ទឹកភ្លៀង ១៣៧១មម, នៅឆ្នាំ២០១២ មានកំពស់ទឹកភ្លៀង ១៨១៤មម, នៅឆ្នាំ២០១៣ មានកំពស់ទឹកភ្លៀង ១៦១១មម និងនៅឆ្នាំ២០១៤ មានកំពស់ទឹកភ្លៀង ១៤១៤មម។ ដូចនេះ កំពស់ទឹកភ្លៀងទាបជាងគេគឺនៅ ឆ្នាំ២០១១ និងកំពស់ទឹកភ្លៀងខ្ពស់ជាងគេគឺនៅ ឆ្នាំ ២០១០ (ក្រ.ធ.ទ.ឧ)។



ក្រាហ្វិក ៥.៤៖ កំពស់ទឹកភ្លៀងប្រចាំឆ្នាំនៅខេត្តព្រៃវែង

៥.២.២.៣ អាកាសធាតុនៅខេត្តត្បូងឃ្មុំ

ក. សីតុណ្ហភាពមធ្យមអតិបរមា និងអប្បរមានប្រចាំឆ្នាំនៅខេត្តត្បូងឃ្មុំ

តាមក្រាហ្វិក ៥.៥ បង្ហាញថាសីតុណ្ហភាពមធ្យមអតិបរមា និងអប្បរមានប្រចាំឆ្នាំនៅខេត្តត្បូងឃ្មុំគឺ៖ នៅឆ្នាំ២០១០ មានសីតុណ្ហភាពអប្បរមា ២១°C និងសីតុណ្ហភាពអតិបរមា ៣៥°C, នៅឆ្នាំ២០១១ មានសីតុណ្ហភាពអប្បរមា ២២ °C និងសីតុណ្ហភាពអតិបរមា ៣៤ °C, នៅឆ្នាំ២០១២ មានសីតុណ្ហភាពអប្បរមា ២២°C និងសីតុណ្ហភាពអតិបរមា ៣៥°C, នៅឆ្នាំ២០១៣ មានសីតុណ្ហភាពអប្បរមា ២២°C និងសីតុណ្ហភាពអតិបរមា ៣៥ °C និងនៅឆ្នាំ២០១៤ មានសីតុណ្ហភាពអប្បរមា ២២ °C និងសីតុណ្ហភាពអតិបរមា ៣៥°C។ ដូចនេះ សីតុណ្ហភាពអប្បរមាទាបគឺនៅ ឆ្នាំ២០១១, ឆ្នាំ២០១២, ឆ្នាំ២០១៣ និងឆ្នាំ២០១៤, សីតុណ្ហភាពអប្បរមាខ្ពស់ជាងគេគឺនៅ ឆ្នាំ២០១០, សីតុណ្ហភាពអតិបរមាទាបគឺនៅ ឆ្នាំ២០១១ និងសីតុណ្ហភាពអតិបរមាខ្ពស់ជាងគេគឺនៅ ឆ្នាំ២០១០, ឆ្នាំ២០១២, ឆ្នាំ២០១៣ និងឆ្នាំ២០១៤ (ក្រ.ធ.ទ.ឧ)។

Draft



ក្រាហ្វិក ៥.៥៖ សីតុណ្ហភាពមធ្យមអតិបរមា និងអប្បរមាប្រចាំឆ្នាំនៅខេត្តត្បូងឃ្មុំ

ខ. កំពស់ទឹកភ្លៀងប្រចាំឆ្នាំនៅខេត្តត្បូងឃ្មុំ

តាមក្រាហ្វិក ៥.៦ បង្ហាញថាកំពស់ទឹកភ្លៀងប្រចាំឆ្នាំនៅខេត្តត្បូងឃ្មុំគឺ៖ នៅឆ្នាំ២០១០ មានកំពស់ទឹកភ្លៀង ១៧៧០មម, នៅឆ្នាំ២០១១ មានកំពស់ទឹកភ្លៀង ១៣៨២មម, នៅឆ្នាំ២០១២ មានកំពស់ទឹកភ្លៀង ១៧០០មម, នៅឆ្នាំ២០១៣ មានកំពស់ទឹកភ្លៀង ១៤៦៧មម និងនៅឆ្នាំ២០១០ មានកំពស់ទឹកភ្លៀង ១៣២២មម។ ដូចនេះ កំពស់ទឹកភ្លៀងទាបជាងគេគឺនៅ ឆ្នាំ២០១៤ និងកំពស់ទឹកភ្លៀងខ្ពស់ជាងគេគឺនៅ ឆ្នាំ២០១០ (ក្រ.ធ.ទ.ខ)។



ក្រាហ្វិក ៥.៦៖ កំពស់ទឹកភ្លៀងប្រចាំឆ្នាំនៅខេត្តត្បូងឃ្មុំ

Draft

គ សំណើមមធ្យមប្រចាំឆ្នាំនៅខេត្តត្បូងឃ្មុំ

តាមក្រាហ្វិក ៥.៧ បង្ហាញថាសំណើមមធ្យមប្រចាំឆ្នាំនៅខេត្តត្បូងឃ្មុំគឺ៖ នៅឆ្នាំ២០១០ មានសំណើម ៨០%, នៅឆ្នាំ២០១១ មានសំណើម ៧៨%, នៅឆ្នាំ២០១២ មានសំណើម ៧៨%, នៅឆ្នាំ ២០១៣ មានសំណើម ៧៧% និងនៅឆ្នាំ២០១៤ មានសំណើម ៦៤%។ ដូចនេះ សំណើមទាបជាងគេគឺ នៅ ឆ្នាំ២០១៤ និងសំណើមខ្ពស់ជាងគេគឺនៅ ឆ្នាំ២០១០ (ក្រ.ធ.ទ.ឧ)។



ក្រាហ្វិក ៥.៧៖ សំណើមមធ្យមប្រចាំឆ្នាំនៅខេត្តត្បូងឃ្មុំ

ឃ. ល្បឿនខ្យល់មធ្យមអតិបរមា និងអប្បរមាប្រចាំឆ្នាំនៅខេត្តត្បូងឃ្មុំ

តាមតារាង ៥.២ ខាងក្រោម បង្ហាញថាល្បឿនខ្យល់មធ្យមអតិបរមា និងអប្បរមាប្រចាំឆ្នាំនៅខេត្តត្បូងឃ្មុំគឺ៖ នៅឆ្នាំ២០១០ មានល្បឿនខ្យល់អប្បរមា ៨ម/វិ, ល្បឿនខ្យល់អតិបរមា ១៨ម/វិ, នៅឆ្នាំ២០១១ មានល្បឿនខ្យល់អប្បរមា ៨ម/វិ, ល្បឿនខ្យល់អតិបរមា ១៨ម/វិ, នៅឆ្នាំ២០១២ មានល្បឿនខ្យល់អប្បរមា ៦ ម/វិ, ល្បឿនខ្យល់អតិបរមា ២០ម/វិ, នៅឆ្នាំ២០១៣ មានល្បឿនខ្យល់អប្បរមា ៨ម/វិ, ល្បឿនខ្យល់អតិបរមា ២០ម/វិ និងនៅឆ្នាំ២០១៤ មានល្បឿនខ្យល់អប្បរមា ៦ម/វិ, ល្បឿនខ្យល់អតិបរមា ២០ម/វិ។ ដូចនេះ ល្បឿនខ្យល់អប្បរមាទាបជាងគេគឺនៅ ឆ្នាំ២០១២និងឆ្នាំ២០១៤, ល្បឿនខ្យល់អប្បរមាខ្ពស់ជាងគេគឺនៅ ឆ្នាំ ២០១០, ឆ្នាំ២០១១និងឆ្នាំ២០១៣, ល្បឿនខ្យល់អតិបរមាទាបជាងគេគឺនៅ ឆ្នាំ២០១០និងឆ្នាំ២០១១, ល្បឿនខ្យល់អតិបរមាខ្ពស់ជាងគេគឺនៅ ឆ្នាំ២០១២, ឆ្នាំ២០១៣និងឆ្នាំ២០១៤ (ក្រ.ធ.ទ.ឧ)។

Draft

តារាង ៥.២៖ ល្បឿន និងទិសដៅខ្យល់មធ្យមអតិបរមា និងអប្បរមាប្រចាំឆ្នាំនៅខេត្តត្បូងឃ្មុំ

ល្បឿនខ្យល់ (ម/វិ)													
ខេត្តត្បូងឃ្មុំ													
Month	Jan	Feb	Mar	Apr	May	Jun	Jul	Aug	Sep	Oct	Nov	Dec	Max	Min
2010	NE	SE	NE	S	SE	W	SW	SW	NW	N	E	N	18	8
	11.0	8.0	10.0	18.0	12.0	18.0	14	12.0	12.0	14.0	14.0	16.0		
2011	NE	SE	NE	S	SE	W	SW	SW	NW	N	E	N	18	8
	11.0	11.0	10.0	18.0	18.0	16.0	12	9.0	10.0	8.0	11.0	12.0		
2012	NE	SE	NE	S	SE	W	SW	SW	NW	N	E	N	20	6
	10	8	11	20	10	12	16	16	6	10	9	10		
2013	NE	SE	NE	S	SE	W	SW	SW	NW	N	E	N	20	8
	12.0	11.0	18.0	16.0	16.0	20.0	12.0	15	8	9	11	12		
2014	NE	SE	NE	S	SE	W	SW	SW	NW	N	E	N	20	6
	8.0	6.0	16.0	10.0	20.0	12.0	20.0	10.0	12.0	16.0	10.0	11.0		

៥.២.២.៤ អាកាសធាតុនៅខេត្តកំពង់ធំ

ក. សីតុណ្ហភាពមធ្យមអតិបរមា និងអប្បរមាប្រចាំឆ្នាំនៅខេត្តកំពង់ធំ

តាមក្រាហ្វិក ៥.៨ បង្ហាញថាសីតុណ្ហភាពមធ្យមអតិបរមា និងអប្បរមាប្រចាំឆ្នាំនៅខេត្តកំពង់ធំគឺ៖ នៅឆ្នាំ២០១០ មានសីតុណ្ហភាពអប្បរមា ២១ °C,មានសីតុណ្ហភាពអតិបរមា ៣៤ °C, នៅឆ្នាំ២០១១ មានសីតុណ្ហភាពអប្បរមា ២១ °C,មានសីតុណ្ហភាពអតិបរមា ៣២ °C, នៅឆ្នាំ២០១២ មានសីតុណ្ហភាពអប្បរមា ២៣ °C,មានសីតុណ្ហភាពអតិបរមា ៣៥ °C, នៅឆ្នាំ២០១៣ មានសីតុណ្ហភាពអប្បរមា ២២ °C,មានសីតុណ្ហភាពអតិបរមា ៣៣ °C និងនៅឆ្នាំ២០១៤ មានសីតុណ្ហភាពអប្បរមា ២២ °C,មានសីតុណ្ហភាពអតិបរមា ៣៣ °C។ ដូចនេះ សីតុណ្ហភាពអប្បរមាទាបជាងគេគឺនៅ ឆ្នាំ២០១០និងឆ្នាំ២០១១, សីតុណ្ហភាពអប្បរមាខ្ពស់ជាងគេគឺនៅ ឆ្នាំ២០១២, សីតុណ្ហភាពអតិបរមាទាបជាងគេគឺនៅ ឆ្នាំ២០១១ និងសីតុណ្ហភាពអតិបរមាខ្ពស់ជាងគេគឺនៅ ឆ្នាំ២០១២ (ក្រ.ធ.ទ.ឧ)។

Draft



ក្រាហ្វិក ៥.៨៖ សីតុណ្ហភាពមធ្យមអតិបរមា និងអប្បរមាប្រចាំឆ្នាំនៅខេត្តកំពង់ធំ

ខ. កំពស់ទឹកភ្លៀងប្រចាំឆ្នាំនៅខេត្តកំពង់ធំ

តាមក្រាហ្វិក ៥.៩ បង្ហាញថាកំពស់ទឹកភ្លៀងប្រចាំឆ្នាំនៅខេត្តកំពង់ធំគឺ៖ នៅឆ្នាំ២០១០ មានកំពស់ទឹកភ្លៀង ១៤១៩មម, នៅឆ្នាំ២០១១ មានកំពស់ទឹកភ្លៀង ១៧៣៨មម, នៅឆ្នាំ២០១២ មានកំពស់ទឹកភ្លៀង ១៣៩៥មម, នៅឆ្នាំ២០១៣ មានកំពស់ទឹកភ្លៀង ១៦៤៤មម និងនៅឆ្នាំ២០១៤ មានកំពស់ទឹកភ្លៀង ១១៧៤មម។ ដូចនេះ កំពស់ទឹកភ្លៀងទាបជាងគេគឺនៅ ឆ្នាំ២០១៤ និងកំពស់ទឹកភ្លៀងខ្ពស់ជាងគេគឺនៅ ឆ្នាំ ២០១១ (ក្រ.ធ.ទ.ឧ)។



ក្រាហ្វិក ៥.៩៖ កំពស់ទឹកភ្លៀងប្រចាំឆ្នាំនៅខេត្តកំពង់ធំ

៥.២.២.៥ អាកាសធាតុនៅខេត្តពោធិ៍សាត់

ក. សីតុណ្ហភាពមធ្យមអតិបរមា និងអប្បរមាប្រចាំឆ្នាំនៅខេត្តពោធិ៍សាត់

តាមក្រាហ្វិក ៥.១០ បង្ហាញថាសីតុណ្ហភាពមធ្យមអតិបរមា និងអប្បរមាប្រចាំឆ្នាំនៅខេត្តពោធិ៍សាត់គឺ៖ នៅឆ្នាំ២០១០ មានសីតុណ្ហភាពអប្បរមា ២២ °C, សីតុណ្ហភាពអតិបរមា ៣៣ °C, នៅឆ្នាំ២០១១ មានសីតុណ្ហភាពអប្បរមា ២១ °C, សីតុណ្ហភាពអតិបរមា ៣៥ °C, នៅឆ្នាំ២០១២ មានសីតុណ្ហភាពអប្បរមា ២០ °C, សីតុណ្ហភាពអតិបរមា ៣៦ °C, នៅឆ្នាំ២០១៣ មានសីតុណ្ហភាពអប្បរមា ២១ °C, សីតុណ្ហភាពអតិបរមា ៣៦ °C និងនៅឆ្នាំ២០១៤ មានសីតុណ្ហភាពអប្បរមា ២២ °C, សីតុណ្ហភាពអតិបរមា ៣៦ °C។ ដូចនេះ សីតុណ្ហភាពអប្បរមាទាបជាងគេគឺនៅ ឆ្នាំ២០១២, សីតុណ្ហភាពអប្បរមាខ្ពស់ជាងគេគឺនៅ ឆ្នាំ២០១០ និងឆ្នាំ២០១៤, សីតុណ្ហភាពអតិរមាទាបជាងគេគឺនៅ ឆ្នាំ២០១៣ និងសីតុណ្ហភាពអតិរមាខ្ពស់ជាងគេគឺនៅ ឆ្នាំ២០១២, ឆ្នាំ២០១៣ និងឆ្នាំ២០១៤ (ក្រ.ធ.ទ.ឧ)។



ក្រាហ្វិក ៥.១០៖ សីតុណ្ហភាពមធ្យមអតិបរមា និងអប្បរមាប្រចាំឆ្នាំនៅខេត្តពោធិ៍សាត់

ខ. កំពស់ទឹកភ្លៀងមធ្យមប្រចាំឆ្នាំនៅខេត្តពោធិ៍សាត់

តាមក្រាហ្វិក ៥.១១ បង្ហាញថាកំពស់ទឹកភ្លៀងមធ្យមប្រចាំឆ្នាំនៅខេត្តពោធិ៍សាត់គឺ៖ នៅឆ្នាំ២០១០ មានកំពស់ទឹកភ្លៀង ១៨៧៦មម, នៅឆ្នាំ២០១១ មានកំពស់ទឹកភ្លៀង ១៤៨៨មម, នៅឆ្នាំ២០១២ មានកំពស់ទឹកភ្លៀង ១៦៤០មម, នៅឆ្នាំ២០១៣ មានកំពស់ទឹកភ្លៀង ១៥៨៤មម និងនៅឆ្នាំ២០១៤ មានកំពស់ទឹកភ្លៀង ១២៨៥មម។ ដូចនេះ កំពស់ទឹកភ្លៀងទាបជាងគេគឺនៅ ឆ្នាំ២០១៤ និងកំពស់ទឹកភ្លៀងខ្ពស់ជាងគេគឺនៅ ឆ្នាំ២០១១ (ក្រ.ធ.ទ.ឧ)។

Draft



ក្រាហ្វិក ៥.១១៖ កំពស់ទឹកភ្លៀងប្រចាំឆ្នាំនៅខេត្តពោធិ៍សាត់

៥.៣ ធនធានជីវសាស្ត្រ (រុក្ខជាតិ និងសត្វព្រៃ)

ក្រោយពីបានចុះសិក្សាធ្វើការកត់ត្រា និងអត្តសញ្ញាណកម្មរុក្ខជាតិតាមពំនុះកាត់ទទឹង ១00% នៅតាមទីតាំងសំណាក៖

- ផ្នែកផ្លូវលេខ ១៣៥ បានបញ្ចប់ការបសាងសង់បណ្តាញខ្សែកាប្លីអុបទិកស្ថិតនៅខាងឆ្វេង ឬស្តាំផ្លូវតាមទិសត្បូងទៅជើងក្នុងឃុំដូនយ៉ុយ និងសត្វពង ស្រុកឈូកខេត្តកំពតដែលមានទទឹង ២៥ ម ចំងាយពីអ័ក្សទ្រូងផ្លូវ និងមានប្រវែង ១0,៣ គម មានផ្ទៃសិក្សា ២៥,៧៥ ហត ។
- ផ្នែកផ្លូវជាតិលេខ ៨ បានបញ្ចប់ការសាងសង់បណ្តាញខ្សែកាប្លីអុបទិកស្ថិតនៅខាងឆ្វេងម្ខាងផ្លូវតាមទិសជើងទៅត្បូងក្នុងឃុំកំពង់ពពិលស្រុកខេត្តពារាំងខេត្តព្រៃវែងដែលមានទទឹង ២៥ម ចំងាយពីអ័ក្សទ្រូងផ្លូវ និងមានប្រវែង ៣,៧ គម មានផ្ទៃសិក្សា ៩,២៥ ហត ។
- ផ្នែកផ្លូវជាតិលេខ ៣0៨ បានបញ្ចប់ការសាងសង់បណ្តាញខ្សែកាប្លីអុបទិកស្ថិតនៅខាងស្តាំម្ខាងផ្លូវតាមទិសជើងទៅត្បូងក្នុងឃុំស្វាយឃ្លាំងស្រុកក្រូចឆ្មារខេត្តត្បូងឃ្មុំ ដែលមានទទឹង ២៥មចំងាយពីអ័ក្សទ្រូងផ្លូវ និងមានប្រវែង ២,២៦ គម មានផ្ទៃសិក្សា ៥,៦៥ ហត ។
- ផ្នែកផ្លូវលេខ ២១៩ បានបញ្ចប់ការសាងសង់បណ្តាញខ្សែកាប្លីអុបទិកស្ថិតនៅខាងឆ្វេងម្ខាងផ្លូវតាមទិសជើងទៅត្បូងក្នុងឃុំសណ្តាន់ និងឃុំមានរិទ្ធិស្រុកសណ្តាន់ខេត្តកំពង់ធំ ដែលមានទទឹង ២៥ម ចំងាយពីអ័ក្សទ្រូងផ្លូវ និងមានប្រវែង ៤,២ គម មានផ្ទៃសិក្សា ១0,៥ ហត ។
- ផ្នែកផ្លូវជាតិលេខ៥ បានបញ្ចប់ការសាងសង់បណ្តាញខ្សែកាប្លីអុបទិកស្ថិតនៅខាងស្តាំម្ខាងផ្លូវតាមទិសជើងទៅត្បូងក្នុងឃុំព្រៃញីសាលាក្រុងពោធិ៍សាត់ខេត្តពោធិ៍សាត់ ដែលមានទទឹង ២៥ម ចំងាយពីអ័ក្សទ្រូងផ្លូវ និងមានប្រវែង ៧,៧ គម មានផ្ទៃសិក្សា ១៩,២៥ ហត ។

Draft

- ដោយផ្នែកដីសិក្សាទាំង៥ទីតាំងជាលំនៅដ្ឋាន ស្រែ ចំការ។ ចំពោះសត្វក្រុមការងារធ្វើការសេកាសន៍ ប្រជុំពិភាក្សាជាមួយចាស់ព្រឹទ្ធាចារ្យ ប្រជាជនមូលដ្ឋាន អាជ្ញាធរដែនដី និងការពិនិត្យជាក់ស្តែងដែលបានលទ្ធផលដូចខាងក្រោម។

៤.៣.១ ប្រភេទរុក្ខជាតិនៅផ្នែកផ្លូវលេខ ១៣៨ក្នុងឃុំដូនយ៉ីយ និងសត្វពង ស្រុកឈូកខេត្តកំពត

តាមតារាង១.៣ ក្នុងឧបសម្ព័ន្ធទី២ ខាងក្រោមបានបង្ហាញថាលទ្ធផលពីប្រភេទរុក្ខជាតិបានមកពីការសិក្សានៅនៅឃុំដូនយ៉ីយ និងសត្វពង ស្រុកឈូកខេត្តកំពត ចំនួនសរុប៣០ប្រភេទរុក្ខជាតិ មានចំនួន៨ប្រភេទរុក្ខជាតិដាំជាដំណាំហូបផ្លែនៅលើចំណីផ្លូវ ចំនួន៨ប្រភេទរុក្ខជាតិដាំលំអតាមផ្លូវ ឬទប់ការហូរច្រោះផ្លូវនៅលើចំណីផ្លូវ ចំនួន៧ប្រភេទរុក្ខជាតិដុះនៅលើចំណីផ្លូវ និងចំនួន៧ប្រភេទរុក្ខជាតិដាំជាដំណាំនៅលើចំណីផ្លូវ។ ក្នុងចំណោមសរុបចំនួន៣០ប្រភេទរុក្ខជាតិមានតែចំនួន៤ប្រភេទរុក្ខជាតិ(ឫស្សី អាកាស្យាស្លឹកតូច ស្មៅដើងក្រាស់ និងត្រែង)ជាCL ចំនួន១ប្រភេទរុក្ខជាតិ(ស្វាយ)ជាDD និងប្រភេទរុក្ខជាតិ(ឈើទាលទឹក)ជាEn ក្នុង **IUCN RED LIST** ឆ្នាំ ២០១៥ ហើយមានឈើប្រណិត១ប្រភេទ(អង្គាញ់)តាមចំណាត់ថ្នាក់ឈើពាណិជ្ជកម្មកម្ពុជា។

៤.៣.២ ប្រភេទសត្វ នៅផ្នែកផ្លូវលេខ ១៣៨ក្នុងឃុំដូនយ៉ីយ និងសត្វពង ស្រុកឈូកខេត្តកំពត

តាមតារាង១.៤ ក្នុងឧបសម្ព័ន្ធទី២ ខាងក្រោម បានបង្ហាញថាលទ្ធផលពីប្រភេទសត្វសរុបចំនួន ៣៣ បានមកពីការសិក្សានៅក្នុងឃុំដូនយ៉ីយ និងសត្វពង ស្រុកឈូកខេត្តកំពតមាន៖

១)ថ្នាក់បក្សីសត្វសរុបមានចំនួន៩ប្រភេទ ហើយក្នុងនោះមានចំនួន៨ប្រភេទ(ចាបស្រុក,គ្រលឹងគ្រលោង, សារិកាកែវ, លលក, ក្លែងស្រាក់, កញ្ជ្រៀច, មៀម, លលកខ្មោច)ជា LC, មាន ចំនួន១ប្រភេទ(ពពូល) ជាVu ស្ថិតនៅក្នុង IUCN RED LIST ឆ្នាំ ២០១៥។

២) ថ្នាក់ល្មូនសត្វសរុបមានចំនួន៩ប្រភេទ ហើយក្នុងនោះមានចំនួន២ប្រភេទ (ពស់ប្រលិត ថ្លែន) ជា LC ស្ថិតនៅក្នុង IUCN RED LIST ឆ្នាំ ២០១៥។

៣)ថ្នាក់ថនិកសត្វសរុបមានចំនួន២ប្រភេទ ហើយក្នុងនោះមានចំនួន២ប្រភេទ (កណ្តុរប្រេង ស្គារ) ជា LC ស្ថិតនៅក្នុង IUCN RED LIST ឆ្នាំ ២០១៥។

៤)ថ្នាក់មណ្ឌុកសត្វ សរុបមានចំនួន៣ប្រភេទ ហើយក្នុងនោះមានចំនួន៣ប្រភេទ(គង្កង់ ហ៊ីង និងកង្កែប)ជា LC ឯចំនួន១ប្រភេទ(កង្កែប)ជា En ស្ថិតនៅក្នុង IUCN RED LIST ឆ្នាំ ២០១៥។

៥)ថ្នាក់កុម្ភសត្វសរុបមានចំនួន១ប្រភេទ ហើយក្នុងនោះមានចំនួន១ប្រភេទ(ក្តាមស្រែ)ជា DD ស្ថិតនៅក្នុង IUCN RED LIST ឆ្នាំ ២០១៥,

៦)ថ្នាក់មច្ឆាសត្វសរុបមានចំនួន៩ប្រភេទ ហើយក្នុងនោះមានចំនួន៣ប្រភេទ (ត្រីផ្ទក់ ត្រីកន្ត្រុបអន្ទង់) ជា LC, មានចំនួន១ប្រភេទ (ត្រីក្រឹមភ្លុក)ជា Vu, មានចំនួន១ប្រភេទ (ត្រីក្រាញ់)ជា DD ស្ថិតនៅក្នុង IUCN RED LIST ឆ្នាំ ២០១៥។

៤.៣.៣ ប្រភេទរុក្ខជាតិនៅផ្នែកផ្លូវជាតិលេខ ៨ក្នុងឃុំកំពង់ពពិល ស្រុកពារាំង ខេត្តព្រៃវែង

តាមតារាង១.៥ ក្នុងឧបសម្ព័ន្ធទី២ លទ្ធផលពីប្រភេទរុក្ខជាតិបានមកពីការសិក្សានៅឃុំកំពង់ពពិល ស្រុកពារាំង ខេត្តព្រៃវែងខាងក្រោមបានបង្ហាញថាចំនួន៧ប្រភេទរុក្ខជាតិដាំជាដំណាំហូបផ្លែនៅលើចំណីផ្លូវ ចំនួន៧ប្រភេទរុក្ខជាតិដាំលំអតាមផ្លូវ ឬទប់ការហូរច្រោះផ្លូវនៅលើចំណីផ្លូវ ចំនួន៨ប្រភេទរុក្ខជាតិដុះនៅលើចំណីផ្លូវ និងចំនួន៨ប្រភេទរុក្ខជាតិដាំជាដំណាំនៅលើចំណីផ្លូវ។ ក្នុងចំណោមសរុបចំនួន២២ប្រភេទរុក្ខជាតិមានតែចំនួន៤ប្រភេទរុក្ខជាតិ(អាកាស្យាស្លឹកតូច ឫស្សី ត្រែង និងស្មៅជើងក្រាស់)ជាCL ចំនួន១ប្រភេទរុក្ខជាតិ(ស្វាយ)ជាDD ក្នុង IUCN RED LIST ឆ្នាំ ២០១៥ ហើយមានឈើប្រណិត១ប្រភេទ(អង្គាញ់) និងឈើលេខ៣មាន១ប្រភេទ(កំពឹងរាជ)តាមចំណាត់ថ្នាក់ឈើពាណិជ្ជកម្មកម្ពុជា។

៤.៣.៤ ប្រភេទសត្វបានមកពីការសិក្សានៅឃុំកំពង់ពពិល ស្រុកពារាំង ខេត្តព្រៃវែង

តាមតារាង១.៦ ក្នុងឧបសម្ព័ន្ធទី២ ខាងក្រោម បានបង្ហាញថាលទ្ធផលពីប្រភេទសត្វសរុបចំនួន ៣១ បានមកពីការសិក្សានៅឃុំកំពង់ពពិល ស្រុកពារាំង ខេត្តព្រៃវែងមាន៖

១)ថ្នាក់បក្សីសត្វសរុបមានចំនួន៨ប្រភេទ ហើយក្នុងនោះមានចំនួន២ប្រភេទ(ពស់វែកក្របី ពស់សង់សឿ)ជាLC ស្ថិតនៅក្នុង IUCN RED LIST ឆ្នាំ ២០១៥។

២) ថ្នាក់ល្មូនសត្វសរុបមានចំនួន៨ប្រភេទ ហើយក្នុងនោះចំនួនមាន២ប្រភេទ (ពស់វែកនាម និងពស់ថ្លាន់តូច) ជា V ឯ២ប្រភេទ (ពស់វែកក្របី និងត្រកួត) ជា LC ស្ថិតនៅក្នុង IUCN RED LIST ឆ្នាំ ២០១៥។

៣)ថ្នាក់ថនិកសត្វសរុបមានចំនួន១ប្រភេទ ដែលមិនស្ថិតនៅក្នុង IUCN RED LIST ឆ្នាំ ២០១៥។

៤)ថ្នាក់មណ្ឌុកសត្វសរុបមានចំនួន៥ប្រភេទ ហើយក្នុងនោះមានចំនួន៣ប្រភេទ(គឹងក់ ហ៊ឹង កញ្ជោញចេក)ជា LC ឯចំនួន១ប្រភេទ(កង្កែបអូកតូច)ជា NT ស្ថិតនៅក្នុង IUCN RED LIST ឆ្នាំ ២០១៥។

៥)ថ្នាក់កុម្ភសត្វមានចំនួន១ប្រភេទ(ក្តាមស្រែ)ជា DD ស្ថិតនៅក្នុង IUCN RED LIST ឆ្នាំ ២០១៥,

៦)ថ្នាក់មច្ឆាសត្វសរុបមានចំនួន៨ប្រភេទ ហើយក្នុងនោះមានចំនួន២ប្រភេទ(ត្រីផ្នក់ ត្រីក្រឹមទន្សាយ)ជា LC , មានចំនួន១ប្រភេទ(ត្រីក្រាញ់)ជា DD, មានចំនួន១ប្រភេទ(ត្រីក្រម៉ម)ជាNT ស្ថិតនៅក្នុង IUCN RED LIST ឆ្នាំ ២០១៥។

៤.៣.៤ ប្រភេទរុក្ខជាតិនៅផ្នែកផ្លូវជាតិលេខ ៣០៨ ក្នុងឃុំស្វាយឃ្លាំង ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម

តាមតារាង១.៧ ក្នុងឧបសម្ព័ន្ធទី២ លទ្ធផលពីប្រភេទរុក្ខជាតិបានមកពីការសិក្សានៅឃុំកំពង់ពពិល ស្រុកពារាំង ខេត្តព្រៃវែងខាងក្រោមបានបង្ហាញថាចំនួន៦ប្រភេទរុក្ខជាតិដាំជាដំណាំហូបផ្លែនៅលើចំណីផ្លូវ ចំនួន៦ប្រភេទរុក្ខជាតិដាំលំអតាមផ្លូវ ឬទប់ការហូរច្រោះផ្លូវនៅលើចំណីផ្លូវ ចំនួន៤ប្រភេទរុក្ខជាតិដុះនៅលើចំណីផ្លូវ និងចំនួន៥ប្រភេទរុក្ខជាតិដាំជាដំណាំនៅលើចំណីផ្លូវ។ ក្នុងចំណោមសរុបចំនួន២២ប្រភេទរុក្ខជាតិមានតែចំនួន៣ប្រភេទរុក្ខជាតិ(អាកាស្យាស្លឹកតូច ឫស្សី និងស្មៅជើងក្រាស់)ជាCL ចំនួន១ប្រភេទរុក្ខជាតិ

(ស្វាយ)ជាDD ក្នុង IUCN RED LIST ឆ្នាំ ២០១៥ ហើយមានឈើប្រណិត១ប្រភេទ(អង្គាញ់) និងឈើលេខ៣មាន១ប្រភេទ(កំពឹងរាជ)តាមចំណាត់ថ្នាក់ឈើពាណិជ្ជកម្មកម្ពុជា។

៤.៣.៦ ប្រភេទសត្វបានមកពីការសិក្សានៅឃុំស្វាយឃ្លាំង ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម

តាមតារាង១.៨ ក្នុងឧបសម្ព័ន្ធទី២ ខាងក្រោម បានបង្ហាញថាលទ្ធផលពីប្រភេទសត្វសរុបចំនួន ៣៣ បានមកពីការសិក្សានៅឃុំស្វាយស ស្រុកក្រគរខេត្តពោធិ៍មានៈ

១)ថ្នាក់បក្សីសត្វចំនួន១៣ប្រភេទ ហើយមាន២ប្រភេទ(កេងកងធំ, ប្រចៀវ)ជា(nt), មាន៩ប្រភេទ(ទីទុយ, មាន់ព្រៃ, ជ្រើងអង្កាម, មៀម, ក្ងោក, លលក, លលកទ្រាំង, ក្អែក និងខ្លែងស្រាក់)ជា LC និងមាន១ប្រភេទ(ពពូល)ជា V ស្ថិតនៅក្នុង IUCN RED LIST ឆ្នាំ ២០១៥។

២) ថ្នាក់លូនសត្វចំនួន១០ប្រភេទក្នុងនោះមាន២ប្រភេទ (ពស់វែកនាម និងពស់ថ្លាន់តូច) ជា V ឯ២ប្រភេទ (ពស់វែកក្របី និងត្រកួត) ជា LC ស្ថិតនៅក្នុង IUCN RED LIST ឆ្នាំ ២០១៥។

៣)ថ្នាក់ថនិកសត្វចំនួន៣ប្រភេទក្នុងនោះមាន២ប្រភេទ(ស្ការ និងទន្សាយគល់)ជាLC ឯ១ប្រភេទ(កំប្រុកធំ)ជា nt ស្ថិតនៅក្នុង IUCN RED LIST ឆ្នាំ ២០១៥។

៤)ថ្នាក់មណ្ឌុកសត្វ ចំនួន៥ប្រភេទក្នុងនោះមាន៣ប្រភេទ(គីង្គក់ ហ៊ីង កញ្ជោញចេក និងក្រឡួនតន)ជា LC ឯចំនួន១ប្រភេទ(កង្កែបអូកតូច)ជា En ស្ថិតនៅក្នុង IUCN RED LIST ឆ្នាំ ២០១៥។

៥)ថ្នាក់កុម្ភសត្វមានចំនួន១ប្រភេទ(ក្តាមស្រែ)ជា DD ស្ថិតនៅក្នុង IUCN RED LIST ឆ្នាំ ២០១៥, ៦)ថ្នាក់មច្ឆាសត្វចំនួន៧ប្រភេទ ក្នុងនោះមាន៥ប្រភេទ(ត្រីលិញ ត្រីផ្នក់ ត្រីអណ្តែង ត្រីឆ្លូញ និងត្រីរ៉ស់)ជា CL ឯ១ប្រភេទ(ត្រីក្រាញ់)ជា DD ស្ថិតនៅក្នុង IUCN RED LIST ឆ្នាំ ២០១៥។

៤.៣.៧ ប្រភេទរុក្ខជាតិនៅផ្នែកផ្លូវជាតិលេខ ២១៩ក្នុងឃុំសណ្តាន់ និងឃុំមានវិទ្ធិ ស្រុកសណ្តាន់ ខេត្តកំពង់ធំ

តាមតារាង១.៩ ក្នុងឧបសម្ព័ន្ធទី២ លទ្ធផលពីប្រភេទរុក្ខជាតិបានមកពីការសិក្សានៅឃុំសណ្តាន់ និងឃុំមានវិទ្ធិ ស្រុកសណ្តាន់ ខេត្តកំពង់ធំ ខាងក្រោមបានបង្ហាញថាចំនួន៨ប្រភេទរុក្ខជាតិដាំជាដំណាំហូបផ្លែនៅលើចំណីផ្លូវ ចំនួន១០ប្រភេទរុក្ខជាតិដាំលំអតាមផ្លូវ ឬទប់ការហូរច្រោះផ្លូវនៅលើចំណីផ្លូវ ចំនួន៥ប្រភេទរុក្ខជាតិដុះនៅលើចំណីផ្លូវ និងចំនួន៨ប្រភេទរុក្ខជាតិដាំជាដំណាំនៅលើចំណីផ្លូវ។ ក្នុងចំណោមសរុបចំនួន ២៧ប្រភេទរុក្ខជាតិមានតែចំនួន៨ប្រភេទរុក្ខជាតិ(អាកាស្យាស្លឹកតូច ឫស្សីស្រុក ត្រែង និងស្មៅដើងក្រាស់)ជាCL, មានចំនួន១ប្រភេទរុក្ខជាតិ(ស្វាយ)ជាDD, មានចំនួន១ប្រភេទរុក្ខជាតិ(ឈើទាលទឹក)ជា En, មានចំនួន១ប្រភេទរុក្ខជាតិ(គគីរម្សៅ)ជាVu ក្នុង IUCN RED LIST ឆ្នាំ ២០១៥ ហើយមានឈើប្រណិត១ប្រភេទ(អង្គាញ់), ឈើលេខ១មាន១ប្រភេទ(គគីរម្សៅ) និងឈើលេខ២មាន១ប្រភេទ(ឈើទាលទឹក) តាមចំណាត់ថ្នាក់ឈើពាណិជ្ជកម្មកម្ពុជា។

៤.៣.៨ ប្រភេទសត្វបានមកពីការសិក្សានៅឃុំសណ្តាន់ និងឃុំមានរិទ្ធិ ស្រុកសណ្តាន់ ខេត្តកំពង់ធំ

តាមតារាង១.១០ ក្នុងឧបសម្ព័ន្ធទី២ បានបង្ហាញថាលទ្ធផលពីប្រភេទសត្វសរុបចំនួន៣៨ បានមកពីការសិក្សានៅឃុំសណ្តាន់ និងឃុំមានរិទ្ធិ ស្រុកសណ្តាន់ ខេត្តកំពង់ធំមាន៖

១)ថ្នាក់បក្សីសត្វសរុបមានចំនួន១២ប្រភេទ ហើយក្នុងនោះមានចំនួន៩ប្រភេទ(លលក លលកទ្រាំង ប្រវឹក មាន់ព្រៃ ទុង គ្រលឹងគ្រលោង ទីទុយ មៀម ក្អែក)ជា LC, មានចំនួន២ប្រភេទ(ពពូល ត្រដក់តូច)ជា Vu និងមានចំនួន១ប្រភេទ(ក្ងោក)ជា En ស្ថិតនៅក្នុង IUCN RED LIST ឆ្នាំ ២០១៥។

២) ថ្នាក់លូនសត្វសរុបមានចំនួន៩ប្រភេទ ហើយក្នុងនោះមានចំនួន២ប្រភេទ (ពស់វែកក្របី ពស់ពង្កាក់ខៀវក្អែកក្រហមធំ)ជា LC , មានចំនួន២ប្រភេទ (ពស់វែកដំបូក ពស់ថ្លាន់តូច)ជា Vu ស្ថិតនៅក្នុង IUCN RED LIST ឆ្នាំ ២០១៥។

៣)ថ្នាក់ថនិកសត្វសរុបមានចំនួន៥ប្រភេទ ហើយក្នុងនោះមានចំនួន៣ប្រភេទ(ស្គារ និងទន្សាយគល់កំប្រុកពោះប្រផេះ)ជាLC ស្ថិតនៅក្នុង IUCN RED LIST ឆ្នាំ ២០១៥។

៤)ថ្នាក់មណ្ឌុកសត្វសរុបមានចំនួន៥ប្រភេទ ហើយក្នុងនោះមានចំនួន៣ប្រភេទ(គីង្គក់ ហ៊ឹង ក ញ្ជេញចេក)ជា LC, មានចំនួន១ប្រភេទ(កង្កែបអូកតូច)ជាNT ស្ថិតនៅក្នុង IUCN RED LIST ឆ្នាំ ២០១៥។

៥)ថ្នាក់កុម្ភសត្វសរុបមានចំនួន១ប្រភេទ(ក្តាមស្រែ)ជា DD ស្ថិតនៅក្នុង IUCN RED LIST ឆ្នាំ ២០១៥,

៦)ថ្នាក់មច្ឆាសត្វចំនួន៦ប្រភេទ ហើយក្នុងនោះមានចំនួន៣ប្រភេទ(ត្រីលិញ ត្រីផ្នក់ ត្រីកញ្ជនជ័យ) ជា LC, មានចំនួន១ប្រភេទ(ត្រីក្រម៉ែម)ជាNT ស្ថិតនៅក្នុង IUCN RED LIST ឆ្នាំ ២០១៥។

៤.៣.៩ ប្រភេទរុក្ខជាតិនៅផ្នែកផ្លូវជាតិលេខ ៨ក្នុងឃុំព្រៃញី សាលាក្រុងពោធិ៍សាត ខេត្តពោធិ៍សាត់

តាមតារាង១.១១ ក្នុងឧបសម្ព័ន្ធទី២ លទ្ធផលពីប្រភេទរុក្ខជាតិបានមកពីការសិក្សានៅឃុំព្រៃញី សាលាក្រុងពោធិ៍សាត ខេត្តពោធិ៍សាត់ ខាងក្រោមបានបង្ហាញថាចំនួន៩ប្រភេទរុក្ខជាតិដាំជាដំណាំហូបផ្លែនៅលើចំណីផ្លូវ ចំនួន៨ប្រភេទរុក្ខជាតិដាំលំអតាមផ្លូវ ឬទប់ការហូរច្រោះផ្លូវនៅលើចំណីផ្លូវ ចំនួន៦ប្រភេទរុក្ខជាតិដុះនៅលើចំណីផ្លូវ និងចំនួន៩ប្រភេទរុក្ខជាតិដាំជាដំណាំនៅលើចំណីផ្លូវ។ ក្នុងចំណោមសរុបចំនួន៣២ប្រភេទរុក្ខជាតិមានតែចំនួន៤ប្រភេទរុក្ខជាតិ(អាកាស្យាស្លឹកតូច ឫស្សីស្រុក ត្រែង និងស្មៅជើងក្រាស់)ជា LC, មានចំនួន១ប្រភេទរុក្ខជាតិ(ស្វាយ)ជាDD និងមានចំនួន១ប្រភេទ(ក្របៅ)ជា Vu ក្នុង **IUCN RED LIST** ឆ្នាំ ២០១៥ ហើយមានឈើប្រណិត១ប្រភេទ(អង្គាញ់) និងឈើលេខ៣មាន១ប្រភេទ(កំពឹងរាជ) តាមចំណាត់ថ្នាក់ឈើពាណិជ្ជកម្មកម្ពុជា។

៤.៣.១០ ប្រភេទសត្វបានមកពីការសិក្សានៅឃុំព្រៃញី សាលាក្រុងពោធិ៍សាត ខេត្តពោធិ៍សាត់

តាមតារាង១.១២ ក្នុងឧបសម្ព័ន្ធទី២ ខាងក្រោម បានបង្ហាញថាលទ្ធផលពីប្រភេទសត្វសរុបចំនួន ៣១ បានមកពីការសិក្សានៅឃុំព្រៃញី សាលាក្រុងពោធិ៍ខេត្តពោធិ៍មាន៖

១)ថ្នាក់បក្សីសត្វសរុបមានចំនួន៩ប្រភេទ ហើយក្នុងនោះមានចំនួន៨ប្រភេទ(លលក លលកទ្រាំង ប្រវឹក មាន់ព្រៃ គ្រលឹងគ្រលោង ទីទុយ មៀម ក្អែក)ជា LC, មានចំនួន១ប្រភេទ(ពពូល)ជាVu ស្ថិតនៅក្នុង IUCN RED LIST ឆ្នាំ ២០១៥។

២) ថ្នាក់ល្មូនសត្វសរុបមានចំនួន៦ប្រភេទ ហើយក្នុងនោះមានចំនួន២ប្រភេទ (ពស់វែកក្របី ពស់ពង្កាក់ខៀវក្នែកក្រហមធំ)ជា LC , មានចំនួន១ប្រភេទ (ពស់វែកដំបូក) ជាVu ស្ថិតនៅក្នុង IUCN RED LIST ឆ្នាំ ២០១៥។

៣)ថ្នាក់ថនិកសត្វសរុបមានចំនួន៤ប្រភេទ ហើយក្នុងនោះមានចំនួន២ប្រភេទ(កំប្រុកពោះប្រផេះស្គារ)ជាLC ស្ថិតនៅក្នុង IUCN RED LIST ឆ្នាំ ២០១៥។

៤)ថ្នាក់មណ្ឌុកសត្វសរុបមានចំនួន៥ប្រភេទ ហើយក្នុងនោះមានចំនួន៣ប្រភេទ(គីង្គក់ ហ៊ឹង កញ្ជេញចេក)ជា LC, មានចំនួន១ប្រភេទ(កង្កែបអូកតូច)ជាNT ស្ថិតនៅក្នុង IUCN RED LIST ឆ្នាំ ២០១៥។

៥)ថ្នាក់កុម្ភសត្វសរុបមានចំនួន១ប្រភេទ(ក្តាមស្រែ)ជា DD ស្ថិតនៅក្នុង IUCN RED LIST ឆ្នាំ ២០១៥,

៦)ថ្នាក់មច្ឆាសត្វសរុបមានចំនួន៦ប្រភេទ ហើយក្នុងនោះមានចំនួន៣ប្រភេទ(ត្រីលិញ ត្រីផ្ទក់ ត្រីកញ្ឆេនជ័យ)ជាLC, មាន១ប្រភេទ(ត្រីក្រម៉ែម)ជា NT ស្ថិតនៅក្នុង IUCN RED LIST ឆ្នាំ ២០១៥។

ដូចនេះតាមលទ្ធផលខាងលើ និងតារាង ១.១៣ក្នុងឧបសម្ព័ន្ធទី២ បានបង្ហាញថា ប្រភេទរុក្ខជាតិសរុបតាមតំបន់សិក្សាទាំង ៥កន្លែងមានចំនួនសរុប ៤១ប្រភេទ ក្នុងចំនោមនោះ មានចំនួនសរុប ១០ប្រភេទជារុក្ខជាតិដាំជាជំណាំហូបផ្លែនៅលើចំណីផ្លូវ ដែលមានចំនួន១ប្រភេទ(ស្វាយ)ជាDD ក្នុងIUCN RED LIST និងមានចំនួន១ប្រភេទ (កំពឹងរាជ)ជាឈើលេខ៣, មានចំនួនសរុប១០ប្រភេទរុក្ខជាតិដាំជាជំណាំលើចំណីផ្លូវ, មានចំនួនសរុប១២ប្រភេទរុក្ខជាតិដាំលំអតាមផ្លូវ ឬទប់ការហូរច្រោះផ្លូវនៅលើចំណីផ្លូវ ដែលមានចំនួនសរុប២ប្រភេទ (ឬស្សីស្រុក និងអាកាស្យាស្លឹកតូច) ជាLC, មានចំនួន១ប្រភេទ (គគីរម្សៅ)ជា Vu, មានចំនួន១ប្រភេទ (ឈើទាលទឹក) ជាEn ក្នុងIUCN RED LIST និងមានចំនួន១ប្រភេទ (គគីរម្សៅ)ជាឈើលេខ១, មានចំនួន១ប្រភេទ (ឈើទាលទឹក)ជាឈើលេខ២ និងមានចំនួន១ប្រភេទ (កំពឹងរាជ)ជាឈើលេខ៣, មានចំនួនសរុប៩ប្រភេទរុក្ខជាតិដុះលើចំណីផ្លូវដែលមានចំនួន២ប្រភេទ(ត្រែង និងស្មៅជើងក្រាស់)ជាLC និងមានចំនួន ១ប្រភេទ(ក្របៅ)ជាVu ក្នុងIUCN RED LIST ។ តាមតារាង ១.១៤ក្នុងឧបសម្ព័ន្ធទី២ បានបង្ហាញថាប្រភេទសត្វសរុបតាមតំបន់សិក្សាទាំង ៥កន្លែងមានចំនួន ៦២ប្រភេទ ក្នុងចំណោមនោះមានចំនួនសរុប២១ប្រភេទជាថ្នាក់បក្សីសត្វដែលមាន ២ប្រភេទ(ពពូល និងត្រដក់តូច)ជាVu, ២ប្រភេទ(ក្ងោក និងចាបព្រៃវែង)ជាEn និងមាន១៧ប្រភេទ (កញ្ជ្រៀច, កុក, ក្អែក, ខ្លែងស្រាក់, គ្រលឹងគ្រលោង, ចាបស្រុក, តារៅស្រុក, ទីទុយ, ទុង, ទោម, ប្រវឹក, មាន់ព្រៃ, មៀម, លលក, លលកខ្មោច,

លលកទ្រាំងនិងសារិកាកែវ)ជាLC ក្នុងIUCN RED LIST , មានចំនួនសរុប១៤ប្រភេទជាថ្នាក់ល្មួនសត្វ ដែលមាន២ប្រភេទ(ពស់ថ្លាន់តូច និងពស់វែកដំបូក)ជាVu និងមាន៦ប្រភេទ(ថ្លែន, ពស់ពស្លាក់ខៀវក្នែកក្រហម, ពស់ពស្លាក់, ពស់ព្រលិត, ពស់វែកក្របី និងពស់សង់សឿ)ជាLC ក្នុងIUCN RED LIST, មានចំនួនសរុប៦ប្រភេទជាឋនិកសត្វ ដែលមានមានចំនួន៣ប្រភេទ(កំប្រុកពោះប្រផេះ, ទន្សាយគល់ និងស្ការ)ជាLC ក្នុង IUCN RED LIST, មានចំនួនសរុប៦ប្រភេទជាមណ្ឌកសត្វ ដែលមានចំនួន១ប្រភេទ(កង្កែបអូកតូច)ជាNT, មានចំនួន៤ប្រភេទ(កង្កែប, កញ្ជេញចេក, គីង្គក់ និងហ៊ីង)ជាLC ក្នុងIUCN RED LIST, មានចំនួនសរុប១ប្រភេទជាកុម្ភសត្វ ដែលក្នុងនោះមានចំនួន១ប្រភេទ(ក្តាមស្រែ) ជាDD ក្នុងIUCN RED LIST, មានចំនួនសរុប១៤ប្រភេទជាមច្ឆាសត្វ ដែលក្នុងនោះមានចំនួន១ប្រភេទ(ត្រីក្រម៉ែម) ជាNT ក្នុងIUCN RED LIST, មានចំនួន២ប្រភេទ(ត្រីក្រាញ់ និងត្រីក្រឹមទន្សាយ) ជាDD ក្នុងIUCN RED LIST និងមានចំនួន៥ប្រភេទ(ត្រីកញ្ជនជ័យ, ត្រីផ្នក់, ត្រីលិញ, ត្រីកន្ត្រែប និងអន្ទង់) ជាLC ក្នុងIUCN RED LIST។

៥.៤ ធនធានសេដ្ឋកិច្ចសង្គម

៥.៤.១ សេចក្តីផ្តើម

ការសិក្សាវាយតម្លៃលើធនធានសេដ្ឋកិច្ច-សង្គមនៃគម្រោងបានកំពុងសាងសង់បណ្តាញខ្សែកាប្លីអុបទិក មានប្រវែង 1,085 គម តាមខេត្តគោលដៅទាំង៥ ដោយការសិក្សាជ្រើសរើសជាសំណាកនូវផ្នែកផ្លូវកំពុងសាងសង់បណ្តាញខ្សែកាប្លីអុបទិកស្ថិតនៅផ្លូវក្នុងស្រុកឈូកខេត្តកំពត ,ផ្លូវស្រុកខ្សាច់កណ្តាលខេត្តកណ្តាល, ផ្លូវក្នុងស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម, ផ្លូវក្នុងស្រុកសណ្តាន់ខេត្តកំពង់ធំ ,ផ្លូវក្នុងស្រុកក្រគរខេត្តពោធិ៍សាត់។ ប៉ុន្តែដោយសកម្មភាពកំពុងសាងសង់ខ្សែកាប្លីអុបទិកនៅក្នុងរដូវខែប្រាំង ហើយម្យ៉ាងទៀតបានធ្វើឡើដោយបរិស្ថានផ្តល់លក្ខខណ្ឌការងារសិក្សារបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូងនៅរដូវវស្សាដែលនៅសល់កន្លែងកំពុងសាងសង់ខ្សែកាប្លីអុបទិកតែ២ កន្លែងគត់គឺ១) ផ្លូវលេខ៣៨០ក្នុងឃុំព្រៃតាកូវស្រុកខ្សាច់កណ្តាលខេត្តកណ្តាលមានប្រវែង ២,៧ គម និង២) , ផ្លូវលេខ៥៥ក្នុងឃុំស្វាយសរស្រុកក្រគរខេត្តពោធិ៍សាត់មានប្រវែង ១៥,៥ គម។ ជាងនេះទៅទៀតក្រុមការងារសិក្សាផលប៉ះពាល់ក៏បានប្រជុំផ្សព្វផ្សាយអំពីគម្រោងដោយបានធ្វើការពន្យល់ដល់ប្រជាពលរដ្ឋ ក៏ដូចជាអជ្ញាធរ ពីបំណងរបស់គម្រោង។ ក្នុងការសាងសង់របស់គម្រោងនេះគឺត្រូវការដីចំណីផ្លូវ ២៥ម ឬ៣០មតែម្ខាងពីអ័ក្ស។ បន្ទាប់ពីការជួបប្រជុំផ្សព្វផ្សាយពីគម្រោងរួចមកក្រុមការងារក៏បានជ្រើសរើសយក១៥% នៃគ្រួសារនឹងត្រូវប៉ះពាល់ដោយសារគម្រោងសំរាប់សិក្សាសេដ្ឋកិច្ចសង្គម បានប្រមូលទិន្នន័យមានស្រាប់ពីឃុំ។ ជាងនេះទៅទៀតក្រុមការងារបានធ្វើការសម្ភាសពីចំណូលរួមក្នុងគ្រួសារ ចំណាយរួមក្នុងគ្រួសារ អ្នកប្រើប្រាស់ទាក់ទងនឹងខ្សែកាប្លីអុបទិក យោបល់លើគំរោងដែលកំពុងសាងសង់ខ្សែកាប្លីអុបទិក(លម្អិតមើលទ្ធផលខាងក្រោម)។ ការសិក្សានេះធ្វើឡើង ដើម្បីវិភាគទៅលើសេដ្ឋកិច្ចសង្គមរបស់ពួកគាត់ និងប្រៀបធៀបប៉ារ៉ាមែត្រ ដើមមួយចំនួនដែលមានស្រាប់នៅក្នុងដំណាក់កាលកំពុងសាងសង់ និងដំណាក់កាលអនុវត្តគម្រោងផងដែរ។

៥.៤.២ ការសិក្សាធនធានសេដ្ឋកិច្ចសង្គមនៅក្នុងឃុំដូនយ៉ាយ និងឃុំសត្វពង ស្រុកឈូក ខេត្តកំពត

៥.៤.២.១ ប្រជាជន និងការតាំងទីលំនៅ

ស្ថានភាពភូមិសាស្ត្រដែលមាននៅក្នុងតំបន់គម្រោង បានបញ្ចប់ការសាងសង់បណ្តាញខ្សែកាប្លីអុបទិកដែលត្រូវបានសាងសង់រួចរាល់ហើយអូសកាត់ក្នុងឃុំចំនួន ០២គឺឃុំសត្វពង និងឃុំដូនយ៉ាយ ដែលស្ថិតនៅក្នុងស្រុកឈូក ខេត្តកំពត។ ដោយផ្អែកតាមការរៀបរាប់របស់មេឃុំរួចបានឲ្យដឹងថា ប្រជាជននៅក្នុងឃុំសត្វពងមានដូចជា គ្រួសាររស់នៅអចិន្ត្រៃយ៍មានចំនួន ១៨២៤គ្រួសារ, ចំនួនគ្រួសាររស់នៅបណ្តោះអាសន្នមានចំនួន ១១គ្រួសារ, ប្រជាពលរដ្ឋដែលមានអាយុចាប់ពី១៨ឆ្នាំឡើងមានស្រី ៣៣១៤នាក់ និងប្រុសមាន ៣០២២នាក់ និងផ្ទៃដីលំនៅដ្ឋានក្នុង១គ្រួសារពី ០.២០អាទៅ១ហត។ ឯចំនួនប្រជាជននៅក្នុងឃុំដូនយ៉ាយមានដូចជា គ្រួសាររស់នៅអចិន្ត្រៃយ៍មានចំនួន ១៤៥៤គ្រួសារ, ចំនួនគ្រួសាររស់នៅបណ្តោះអាសន្នមានចំនួន ០គ្រួសារ, ប្រជាពលរដ្ឋដែលមានអាយុចាប់ពី១៨ឆ្នាំឡើងមានស្រី ២៣២៦នាក់ និងប្រុសមាន ២២១៧នាក់ និងផ្ទៃដីលំនៅដ្ឋានក្នុង១គ្រួសារពី ០.២០អាទៅ១ហត។

តារាង ៥.៣៖ បញ្ជាក់អំពីប្រជាជន និងលំនៅដ្ឋាន

ល.រ	ប្រជាជន និងលំនៅដ្ឋាន	ឃុំសត្វពង	ឃុំដូនយ៉ាយ
១	ចំនួនគ្រួសាររស់នៅអចិន្ត្រៃយ៍	**១៨២៤** គ្រួសារ	**១៤៥៤** គ្រួសារ
២	ចំនួនគ្រួសាររស់នៅបណ្តោះអាសន្ន	**១១** គ្រួសារ	០ គ្រួសារ
៣	ប្រជាពលរដ្ឋដែលមានអាយុ ចាប់ពី១៨ឆ្នាំឡើង	ស្រី **៣៣១៤** នាក់ ប្រុស **៣០២២** នាក់	ស្រី **២៣២៦** នាក់ ប្រុស **២២១៧** នាក់
៤	ផ្ទៃដីលំនៅដ្ឋានក្នុង ១គ្រួសារ	០.២០ អា ទៅ ១ហ.ត	០.២០ អា ទៅ ១ហ.ត

បញ្ជាក់៖ ទិន្នន័យបានពីឃុំសត្វពង និងឃុំដូនយ៉ាយ

៥.៤.២.២ អាជីព និងមុខរបរ

យោងតាមទិន្នន័យដែលបានបង្ហាញពីលោក ហាស់ សំអឿន មេឃុំដូនយ៉ាយ និងលោក ឃុញ ហ៊ាប មេឃុំសត្វពង បានអោយដឹងថា អាជីប និងមុខរបររបស់ប្រជាពលរដ្ឋដែលបានរស់នៅក្នុងតំបន់ទាំងពីរឃុំខាងលើនេះ មានចំនួន ៨៥% ជាកសិករ១៣ ,ជាអាជីវករ និងមន្ត្រីរាជការ២%។

៥.៤.២.៣ ការប្រើប្រាស់ដី និងការកាន់កាប់ដោយប្រជាជន

ឯការប្រើប្រាស់ដីក្នុងឃុំនិមួយៗ មានសណ្ឋានដូចតទៅ៖ ចំពោះឃុំសត្វពងមានផ្ទៃដីសរុបមានចំនួន ១១៤៥,៣៤ហត, ដីលំនៅដ្ឋានមាន ១១៣ហត, ផ្ទៃដីដំណាំរួមផ្សំមាន ៦,៣៤ហត, ដីស្រែមាន ១០១៤ហត, ដីទំនប់មាន ១៣,៨៥ហត, ដីប្រឡាយមាន ៦២,២៥ហត និងដីថ្ម‌ល់មាន ៨,៤២ហត។ ការប្រើប្រាស់ដីនៅឃុំដូនយ៉ាយមានផ្ទៃដីសរុប ១៤៤៨ហត, ដីលំនៅដ្ឋានមាន ១០៤ហត និងដីផ្សេងៗទៀតមាន ១៣៤៨ហត។ សូមមើលតារាង ៥.៤ ខាងក្រោម។

តារាង ៥.៤៖ ការប្រើប្រាស់ដី និងកាន់កាប់ដីដោយប្រជាជន

ល.រ	ផ្ទៃដី	ឃុំសត្វពង	ឃុំដូនយ៉ុយ
១	ផ្ទៃដីសរុប	១១៤៥.៣៤ ហ.ត	១៤៤៨ ហ.ត
២	ដីលំនៅដ្ឋាន	១១៣ ហ.ត	១០៤ ហ.ត
៣	ផ្ទៃដីដំណាំរួមផ្សំ	៦.៣៤ ហ.ត	១៣៤៨ ហ.ត
៤	ផ្ទៃដីស្រែ	១០១៤ ហ.ត	
៥	ដីទំនប់	១៣.៨៥ ហ.ត	
៦	ដីប្រឡាយ	៦២.២៥ ហ.ត	
៧	ដីថ្នល់	៨.៤២ ហ.ត	

បញ្ជាក់៖ ទិន្នន័យបានពីឃុំសត្វពង និងឃុំដូនយ៉ុយ

៥.៤.២.៤ ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ

យោងតាមការប្រជុំផ្សព្វផ្សាយជាមួយក្រុមការងារ និងអាជ្ញាធរមូលដ្ឋានរួចមកបាន អោយដឹងថា ចំពោះការប្រើប្រាស់ទឹក គឺប្រជាពលរដ្ឋខ្លះគាត់មានលទ្ធភាពអាចទិញទឹកស្អាតយកមកប្រើប្រាស់ប្រចាំថ្ងៃបាន និងខ្លះទៀតគាត់មិនមានលទ្ធភាពមិនអាចទិញទឹកស្អាតយកមកប្រើប្រាស់បាន គឺពួកគាត់បានសំណូមពរទៅលោក មេឃុំ ដើម្បីជួយជីកអណ្តូង រឺអណ្តូងស្នប់ សំរាប់យកទឹកមកប្រើប្រាស់ក្នុងភូមិរបស់គាត់ ហើយខ្លះទៀតគាត់បានប្រើប្រាស់ទឹកស្ទឹង ទឹកបឹង និងទឹកស្រះ ដើម្បីចិញ្ចឹមជីវភាពផ្ទាល់ខ្លួនរបស់ពួកគាត់។ ចំពោះការបរិភោគទឹកវិញគឺពួកគាត់បានដាំទឹកអោយពុះជាមុនសិន មុននិងគាត់ពិសា មិនថាទឹកម៉ាស៊ីន ទឹកស្ទឹង ទឹកបឹង និងទឹកស្រះឡើយ។

៥.៤.២.៥ ការប្រើប្រាស់ថាមពល

យោងតាមការសិក្សាបានអោយដឹងថា ការប្រើប្រាស់ថាមពលអគ្គីសនីគឺវាមានសារៈសំខាន់មួយផ្នែកដែរ សំរាប់ការបំភ្លឺតាមផ្ទះ សណ្ឋាគារ ភោជនីយ៍ដ្ឋាន រោងកុន ដងផ្លូវ និងតាមបណ្តាកន្លែងមួយចំនួនទៀតដែលត្រូវការ ។ តាមសម្តីលោក ឃុញ ហ៊ាប មេឃុំសត្វពង បានអោយដឹងថា ជាក់ស្តែងនៅក្នុងឃុំសត្វពងទាំងមូលរបស់គាត់មានថាមពលអគ្គីសនី ប្រើប្រាស់គ្រប់គ្រាន់ ចំនួន ៩០% និង ១០% ទៀតប្រើអុស ធ្យូង ។ រីឯលោក ហាស់ សំអឿន មេឃុំដូនយ៉ុយ វិញបាននិយាយថា ចំពោះប្រជាពលរដ្ឋរស់នៅក្នុងឃុំរបស់គាត់មានប្រមាណតែ ៣៤៧គ្រួសារ ប៉ុណ្ណោះដែលមានប្រើថាមពលអគ្គិសនីប្រើគ្រប់គ្រាន់ និងសល់ពីនោះមានប្រើដូចជា អុស និងធ្យូងសំរាប់ជីវភាពរស់នៅរបស់ពួកគាត់។

៥.៤.២.៦ ហេដ្ឋារចនាសម្ព័ន្ធ

បើនិយាយពីហេដ្ឋារចនាសម្ព័ន្ធ និងផ្លូវគមនាគមន៍វិញ វាជាបេះដូងមួយយ៉ាងសំខាន់សំរាប់ធ្វើចរាចរ និងប្រកបរបរចិញ្ចឹមជីវិតមិនថានៅទីណានោះទេ សូម្បីតែនៅក្នុងព្រះរាជាណាចក្រកម្ពុជាទាំងមូល ក៏ត្រូវការផ្លូវគមនាគមន៍នេះដែរ ។ ជាក់ស្តែងនៅក្នុងឃុំសត្វពងមានផ្លូវគ្រួសក្រហមចំនួន **៤ខ្សែ** និងផ្លូវកៅស៊ូ ០១ខ្សែ

ខុសពីឃុំដូនយ៉ាយមានផ្លូវកៅស៊ូ **១ខ្សែ** ផ្លូវគ្រួសក្រហម ,**១១ខ្សែ** និងផ្លូវដីចំនួន **៣ខ្សែ**។ ដូចមានក្នុងតារាង ទី ៥.៥ ខាងក្រោម៖

តារាង ៥.៥៖ បែងចែកផ្លូវគមនាគមន៍ក្នុងឃុំសត្វពង និងឃុំដូនយ៉ាយ

ល.រ	ផ្លូវគមនាគមន៍	ឃុំសត្វពង	ឃុំដូនយ៉ាយ
១	ផ្លូវកៅស៊ូ	១ ខ្សែ	១ ខ្សែ
២	ផ្លូវគ្រួសក្រហម	៤ ខ្សែ	១១ ខ្សែ
៣	ផ្លូវដី		៣ ខ្សែ

បញ្ជាក់៖ ទិន្នន័យបានពីឃុំសត្វពង និងឃុំដូនយ៉ាយ

៥.៤.២.៧ វិស័យអប់រំ និងសិក្សាធិការ

ចំពោះការអប់រំវិញ ប្រជាពលរដ្ឋទាំងអស់គួរទទួលបាននូវសិទ្ធអប់រំស្មើៗគ្នា នេះបើយោងតាមការកំណត់របស់រាជរដ្ឋាភិបាល។ នេះបើតាមការបកស្រាយរបស់លោកមេឃុំដូនយ៉ាយបានអោយដឹងថា នៅក្នុងឃុំរបស់គាត់មានសាលាបឋមសិក្សាចំនួន ២ កន្លែង និងអនុវិទ្យាល័យចំនួន ១ កន្លែង។ ចំពោះឃុំសត្វពងវិញមានសាលាបឋមសិក្សាចំនួន ៣ កន្លែង និងអនុវិទ្យាល័យ ១កន្លែង។ ហើយការអប់រំវិញគឺជាការលើកកំពស់ប្រសិទ្ធភាពរបស់ប្រជាពលរដ្ឋទាំងអស់អោយមានចំណេះដឹង។ មើលតារាង ៥.៦ខាងក្រោម៖

តារាង ៥.៦៖ បញ្ជាក់ពីចំនួនបឋមសិក្សា និងវិទ្យាល័យ

ល.រ	វិស័យអប់រំ	ឃុំសត្វពង	ឃុំដូនយ៉ាយ
១	សាលាបឋមសិក្សា	៣ កន្លែង	២ កន្លែង
២	អនុវិទ្យាល័យ	១ កន្លែង	១ កន្លែង

បញ្ជាក់៖ ទិន្នន័យបានពីឃុំសត្វពង និងឃុំដូនយ៉ាយ

៥.៤.២.៨ សុខាភិបាល និងអប់រំសុខភាព

ចំពោះវិស័យសុខាភិបាលវិញ លោកហាស់ សំអឿនមេឃុំដូនយ៉ាយបាននិយាយថានៅក្នុងឃុំរបស់គាត់មានមណ្ឌលសុខភាព ១កន្លែង និងមិនទាន់មានបុគ្គលិកគ្រប់គ្រាន់សំរាប់បម្រើការជូនប្រជាជននៅឡើយទេ។ ចំណែកឯលោក ឃុញ ហ៊ាប មេឃុំសត្វពងវិញក៏បាននិយាយដែរថានៅក្នុងឃុំរបស់គាត់មិនមានមណ្ឌលសុខភាពទេ ហើយមន្ទីរពេទ្យបង្អែកក៏គ្មានដែរ តែដល់ពេលប្រជាពលរដ្ឋត្រូវការទៅព្យាបាលម្តងៗ ត្រូវទៅព្យាបាលនៅមន្ទីរពេទ្យបង្អែកឃុំឈូក ដែលត្រូវប្រើប្រាស់រួមគ្នាជាមួយប្រជាពលរដ្ឋដែលរស់នៅទីនោះ។

៥.៤.២.៩ ជំនឿសាសនា និងវប្បធម៌ប្រជាជន

យោងតាមការសិក្សាដោយផ្ទាល់ពី ឃុំសត្វពង និងឃុំដូនយ៉ាយរួចមក បានអោយដឹងថានៅក្នុងឃុំរបស់គាត់គឺប្រជាជនភាគច្រើនក្នុងភូមិទាំងអស់ កាន់ព្រះពុទ្ធសាសនា និងក្នុងឃុំរបស់ពួកគាត់គឺមានវត្ត ០១ កន្លែងដូចគ្នាប៉ុណ្ណោះ។

៥.៤.២.១០ វិស័យទេសចរណ៍

ចំពោះវិស័យទេសចរណ៍វិញ វាមានសារៈសំខាន់ខ្លាំងណាស់សំរាប់ប្រជាជន គឺវាជួយអោយប្រជាជនមានជីវភាពធូរស្រាល រីកចំរើន និងលើកស្ទួយ ភូមិ-ឃុំអោយមានចំណូលកាន់តែប្រសើរឡើង។ ជាក់ស្តែងដូចក្នុងឃុំសត្វពង និងឃុំដូនយ៉ាយ គឺប្រជាជនបានចំណូលពីការធ្វើស្រែចំការ និងលក់ដូរតិចតួច បើនិយាយពីវិស័យទេសចរណ៍វិញគឺ ឃុំទាំងពីរនេះនៅឆ្ងាយពីផ្លូវជាតិគួរសមដែរ ហើយដីរបស់គាត់ជាដីស្រែ មិនមានដីណាអាចធ្វើជារមនីយ៍ដ្ឋានបាន ហេតុដូចនេះធ្វើអោយពួកគាត់រកចំណូលពីវិស័យទេសចរណ៍មិនបាន។

៥.៤.២.១១ ចំណូលរួមក្នុងគ្រួសារ

តាមក្រាហ្វិក ៥.១២ ខាងក្រោមនេះបានបកស្រាយអោយឃើញថា ការសិក្សាទៅលើសំណាកគ្រួសារចំនួន ៩គ្រួសារក្នុងចំណោមគ្រួសារចំនួន ៦៣គ្រួសារ ដែលជាប្រជាករដែលមានផលប៉ះពាល់នៅតាមបណ្តោយផ្លូវស្ថិតក្នុងឃុំដូនយ៉ាយ និងឃុំសត្វពង ស្រុកឈូក ខេត្តកំពត ដែលមានលទ្ធផលចំណូលរួមជាមធ្យមប្រចាំខែចំនួន ៣៧៥ដុល្លារ ក្នុងម្នាក់។ ដែលក្នុងនោះចំណូលរួមជាមធ្យម៖ ៦៤.៤៤ដុល្លារ ពីការធ្វើស្រែ, ៥.៥៦ដុល្លារ ពីការធ្វើចំការ, ១៦៦.៦៧ដុល្លារ ពីការចិញ្ចឹមសត្វ, ៧០.៨៣ដុល្លារ ពីការលក់ដូរ, ១១.១១ ដុល្លារ ពីការធ្វើពលកម្ម, ៤៣.០៦ដុល្លារ ពីប្រាក់ខែ, ៨.៣៣ដុល្លារ បានពីការធ្វើមុខរបរផ្សេងៗ។



ក្រាហ្វិក ៥.១២៖ ចំណូលរួមក្នុងគ្រួសារក្នុងមួយខែរបស់ប្រជាជននៅឃុំដូនយ៉ាយ និងឃុំសត្វពង

៥.៤.២.១២ ចំណាយរួមក្នុងគ្រួសារ

តាមក្រាហ្វិក ៥.១៣ ខាងក្រោមនេះបានបកស្រាយអោយឃើញថា ការសិក្សាទៅលើសំណាកគ្រួសារចំនួន ៩គ្រួសារក្នុងចំណោមគ្រួសារចំនួន ៦៣គ្រួសារ ដែលជាប្រជាករដែលមានផលប៉ះពាល់នៅតាមបណ្តោយផ្លូវស្ថិតក្នុងឃុំដូនយ៉យ និងឃុំសត្វពង ស្រុកឈូក ខេត្តកំពត ដែលមានលទ្ធផលចំណូលរួមជាមធ្យមប្រចាំខែចំនួន ៣៧៥ដុល្លារ ក្នុងម្នាក់។ ដែលក្នុងនោះចំណូលរួមជាមធ្យម៖ ៦៤.៤៤ដុល្លារ ពីការធ្វើស្រែ, ៥.៥៦ដុល្លារ ពីការធ្វើចំការ, ១៦៦.៦៧ដុល្លារ ពីការចិញ្ចឹមសត្វ, ៧០.៨៣ដុល្លារ ពីការលក់ដូរ, ១១.១១ដុល្លារ ពីការធ្វើពលកម្ម, ៤៣.០៦ដុល្លារ ពីប្រាក់ខែ, ៨.៣៣ដុល្លារ បានពីការធ្វើមុខរបរផ្សេងៗ។



ក្រាហ្វិក ៥.១៣៖ ចំណាយរួមក្នុងគ្រួសារក្នុងឃុំឃុំដូនយ៉យ និងឃុំសត្វពង

៥.៤.២.១៣ ស្ថិតិអ្នកប្រើប្រាស់ទាក់ទងនឹងខ្សែកាប្លីអុបទិក

តាមតារាង ៥.៧ ខាងក្រោមបានបង្ហាញថាស្ថិតិអ្នកប្រើប្រាស់ទាក់ទងនឹងខ្សែកាប្លីអុបទិកមានដូចតទៅ៖

- ក្នុងចំណោម សំណាក៩គ្រួសារ តំណាងអោយចំនួន63គ្រួសារជាប្រជាករមាន ៣៣%នៃគ្រួសារដែលត្រូវជា ៣គ្រួសារ ជាអ្នកដែលស្គាល់បច្ចេកវិទ្យា និងសេវាកម្មខ្សែកាប្លីអុបទិក។ ចំណែកឯ ៦៧% =៦គ្រួសារ ទៀតមិនមានការយល់ដឹងពីបច្ចេកវិទ្យា និងសេវាកម្មខ្សែកាប្លីអុបទិកនេះឡើយ។
- ក្នុងចំណោម សំណាក៩គ្រួសារ តំណាងអោយចំនួន៦៣គ្រួសារជាប្រជាករមាន ១០០%នៃគ្រួសារដែលត្រូវជា ៩គ្រួសារ ជាអ្នកដែលមានទូរសព្ទប្រើប្រាស់ ភ្ជាប់ប្រពន្ធ័ដូចជា Mobitel, Metphone និងSmart។
- ក្នុងចំណោម សំណាក៩គ្រួសារ តំណាងអោយចំនួន៦៣គ្រួសារជាប្រជាករមាន ៧៨%នៃគ្រួសារដែលត្រូវជា ៧គ្រួសារ ជាអ្នកដែលមានទូរទស្សន៍ប្រើប្រាស់ ភ្ជាប់ប្រពន្ធ័ DTV។ ចំណែកឯ ២២%=២ គ្រួសារ ទៀតមិនមានប្រើប្រាស់ទូរទស្សន៍នោះទេ។

- ក្នុងចំណោម សំណាក៩គ្រួសារ តំណាងអោយចំនួន៦៣គ្រួសារជាប្រជាករមាន ៤៤%នៃគ្រួសារដែលត្រូវជា ៤គ្រួសារ ជាអ្នកដែលមានអ៊ីនធើណេតប្រើប្រាស់ ដែលមានភ្ជាប់ប្រពន្ធ័តាមរយៈទូរសព្ទ័ដៃ ។ ចំណែកឯ ៥៦%=៥គ្រួសារ ទៀតមិនមានប្រើប្រាស់អ៊ីនធើណេតនោះទេ។

តារាង ៥.៧៖ ស្ថិតិអ្នកប្រើប្រាស់ទាក់ទងនឹងខ្សែកាប្លីអុបទិកក្នុងឃុំដូនយ៉ុយ និងឃុំសត្វពង

ល.រ	ការផ្សព្វផ្សាយពីខ្សែកាប្លីអុបទិក	ចំនួនគ្រួសារ	ភាគរយ
១	អ្នកដែលដឹងពីខ្សែកាប្លីអុបទិក	៣	៣៣
២	អ្នកដែលមិនដឹងពីខ្សែកាប្លីអុបទិក	៦	៦៧
	សរុប	៩	១០០
ការប្រើប្រាស់ទូរសព្ទ			
១	អ្នកដែលប្រើប្រាស់ទូរសព្ទ	៩	១០០
២	អ្នកមិនប្រើទូរសព្ទ	០	០
	សរុប	៩	១០០
ការប្រើប្រាស់ទូរទស្សន៍			
១	អ្នកប្រើប្រាស់ទូរទស្សន៍	៧	៧៨
២	អ្នកអត់ប្រើប្រាស់ទូរទស្សន៍	២	២២
	សរុប	៩	១០០
ការប្រើប្រាស់អ៊ីនធើណេត			
១	អ្នកប្រើប្រាស់អ៊ីនធើណេត	៤	៤៤
២	អ្នកមិនប្រើប្រាស់អ៊ីនធើណេត	៥	៥៦
	សរុប	៩	១០០

៥.៤.២.១៤ យោបល់របស់ប្រជាជនលើគម្រោងកំពុងសាងសង់ខ្សែកាប្លីអុបទិក

តាមរយៈការសិក្សាចុះសម្ភាសន៍ផ្ទាល់នៅថ្ងៃទី ១៩ ខែសីហា ឆ្នាំ២០១៥ លើ៩គ្រួសារសំណាក នៅក្នុងចំណោម៦៣គ្រួសារប្រជាករដែលបានប៉ះពាល់ដីលំនៅដ្ឋាន ឬចំការ នៃឃុំដូនយ៉ុយ និងឃុំសត្វពង ស្រុកឈូក ខេត្តកំពត ដែលគាត់មានយោបល់លើគម្រោងកំពុងសាងសង់ខ្សែកាប្លីអុបទិកមានដូចខាងក្រោម៖

- តាមដ្យាក្រាមផ្ទឹត ៥.១ ខាងក្រោមបានបង្ហាញអោយឃើញថា មាន ៦៧% ត្រូវជា ៦គ្រួសារពេញចិត្តនឹងគម្រោងកំពុងសាងសង់ខ្សែកាប្លីអុបទិកនេះ ព្រោះវាផ្តល់អត្ថប្រយោជន៍ដ៏ធំសម្បើមតាមរយៈការប្រើប្រាស់ទូរសព្ទ ទូរទស្សន៍ អ៊ីនធើណេត និងការមេ៉ាសុវត្ថិភាពផ្សេងៗ ដែលជាពិសេសវាជួយរួមចំណែកក្នុងការអភិវឌ្ឍន៍ធនធានមនុស្ស និងប្រទេសជាតិអោយបានដើរទាន់អរិយប្រទេសនានាក្នុងពិភពលោក។ ប៉ុន្តែមានចំនួន៣ គ្រួសារ ស្មើ នឹង ៣៣% ប៉ុណ្ណោះដែលមិនពេញចិត្តអោយមានគម្រោងសាងសង់ខ្សែកាប្លីអុបទិកនេះ ព្រោះពេលសាងសង់ដីកកប់ខ្សែកាប្លីអុបទិក រំខានដល់ការចេញចូលផ្ទះរបស់ពួកគាត់ ជាពិសេសប៉ះពាល់ដីស្រែ ចំការ និងលំនៅដ្ឋាន។ តែទោះជាយ៉ាងនេះក៏

Draft

ដោយគាត់ក៏នៅតែអនុញ្ញាតអោយធ្វើការជីកកប់ខ្សែកាប្លីអុបទិក ដោយមានការសម្របសម្រួលពីអាជ្ញាធរជាមួយនឹងប្រជាជន ទើបធ្វើអោយការសាងសង់មានភាពរលូន។

- តាមមតិយោបល់បន្ថែមរបស់ប្រជាជនទាំង៩គ្រួសារនេះមានដូចខាងក្រោម៖
  - ពេញចិត្តនឹងគម្រោងព្រោះការជីកកប់មានភាពស្អាតត្រឹមត្រូវដូចដើម សាងសង់រយៈពេលខ្លី
  - ផុងស្រែ ផុងគោ ក្របី
  - ពេញចិត្តអោយមានខ្សែកាប្លីអុបទិក ប៉ុន្តែសំណូមពរអោយមានការជីកលប់អោយបានត្រឹមត្រូវ
  - សំណូមពរអោយមានតម្លៃថោកសមរម្យ
  - សំណូមពរអោយមានការផ្តល់ពត៌មាន និងធ្វើការផ្សព្វផ្សាយអោយប្រជាជនមានការយល់ដឹងមុននឹងធ្វើការសាងសង់
  - ចង់អោយមានការអភិវឌ្ឍន៍ក្នុងភូមិ ឃុំ



ដ្យាក្រាមផ្ទៃត ៥.១៖ចិត្តពេញមិននិង ចិត្តពេញការចំពោះប្រជាជនរបស់ផ្ទាល់យោបល់អំពីមតិបង្ហាញ លើគម្រោងកំពុងសាងសង់ខ្សែកាប្លីអុបទិកនៅឃុំជួនយ៉ុយ និងឃុំសត្វពង

៥.៤.៣ ការសិក្សាធនធានសេដ្ឋកិច្ចសង្គមនៅក្នុងឃុំកំពង់ពពិល ស្រុកពារាំង ខេត្តព្រៃវែង

៥.៤.៣.១ អំពីប្រជាជន និងការតាំងលំនៅដ្ឋាន

ស្ថានភាពភូមិសាស្ត្រដែលមាននៅក្នុងតំបន់គម្រោង បណ្តាញខ្សែកាប្លីអុបទិកដែល ត្រូវបានសាងសង់រួចហើយ ដែលស្ថិតនៅក្នុងឃុំកំពង់ពពិល ស្រុកពារាំង ខេត្តព្រៃវែង។ ដោយផ្អែកតាមការរៀបរាប់របស់មេឃុំរួចមកបានអោយដឹងថា ប្រជាជនដែលរស់នៅក្នុងឃុំកំពង់ពពិល មានដូចជា គ្រួសាររស់នៅអចិន្ត្រៃយ៍

មានចំនួន ៣១៧៩គ្រួសារ, ចំនួនប្រជាជនសរុបមានចំនួន ១៥៩៦៥នាក់ និងមានផ្ទៃដីលំនៅដ្ឋានក្នុងឃុំទាំងមូលមានចំនួន ១៣៤ហត។ សូមមើលតារាង ៥.៨ខាងក្រោម។

តារាង ៥.៨៖ បញ្ជាក់អំពីប្រជាជន និងលំនៅដ្ឋាន

ល.រ	ប្រជាជន និងលំនៅដ្ឋាន	ឃុំកំពង់ពពិល
១	ចំនួនគ្រួសាររស់នៅអចិន្ត្រៃយ៍	៣១៧៩ គ្រួសារ
២	ចំនួនប្រជាជនសរុប	១៥៩៦៥ នាក់
៣	ផ្ទៃដីលំនៅដ្ឋានក្នុងឃុំទាំងមូល	១៣៤ ហ.ត

បញ្ជាក់៖ ទិន្នន័យបានពីឃុំកំពង់ពពិល

៥.៤.៣.២ អាជីប និងមុខរបរ

យោងតាមទិន្នន័យដែលបានបង្ហាញពីលោកមេឃុំកំពង់ពពិល បានឲ្យដឹងថាអាជីប និងមុខរបររបស់ប្រជាពលរដ្ឋដែលបានរស់នៅក្នុងតំបន់របស់គាត់មានចំនួន ៤០%, ធ្វើស្រែចំការ ២%, មន្ត្រី ២៣% អាជីវករ និងកម្មករ ៣៥%។

៥.៤.៣.៣ ការប្រើប្រាស់ដី និងកាន់កាប់ដីដោយប្រជាជន

ការប្រើប្រាស់ដីក្នុងឃុំព្រែកតាកូវមានចំនួន ៣ភូមិ មានសណ្ឋានដីដូចតទៅ៖ ផ្ទៃដីសរុបមានចំនួន ៤៤៩៤ហត, ដីលំនៅដ្ឋានមាន ១៣៤ហត, ផ្ទៃដីដំណាំរួមផ្សំ និងស្រែប្រាំងមាន ៥១៧ហត និងស្រែវស្សាមាន ១៨០០ហត។ សូមមើលតារាង ៥.៩ ខាងក្រោម។

តារាង ៥.៩៖ ការប្រើប្រាស់ដី និងកាន់កាប់ដីដោយប្រជាជន

ល.រ	ផ្ទៃដី	ឃុំកំពង់ពពិល
១	ផ្ទៃដីសរុប	៤៤៩៤ ហ.ត
២	ដីលំនៅដ្ឋាន	១៣៤ ហ.ត
៣	ផ្ទៃដីដំណាំរួមផ្សំ	៥១៧ ហ.ត
៤	ស្រែប្រាំង	
៥	ស្រែវស្សា	១៨០០ ហ.ត

បញ្ជាក់៖ ទិន្នន័យបានពីឃុំកំពង់ពពិល

៥.៤.៣.៤ ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ

យោងតាមការប្រជុំផ្សព្វផ្សាយជាមួយក្រុមការងារ និងអាជ្ញាធរមូលដ្ឋានរួចមកបានអោយដឹងថា ចំពោះការប្រើប្រាស់ទឹកវិញ គឺក្នុងឃុំកំពង់ពពិលទាំងមូល មានទឹកស្អាតប្រើប្រាស់ចំនួន ៧០% និង៣០% ទៀតប្រើប្រាស់អណ្តូងស្នប់ ។

៥.៤.៣.៥ អនាម័យ

ចំពោះបញ្ហាអនាម័យវិញគឺវាមាន សារៈសំខាន់ដែរក្នុងការរស់នៅដូចជា ការបន្ទោរបង់ ការលាង សម្អាតបន្លែបង្កា លាងដៃ លាងចាននិងរបស់របរមួយចំនួន ។ ក្រោយពីបានសំណេះ សំណាលជាមួយលោក មេឃុំកំពង់ពពិលរួចមក បានអោយដឹងថាក្នុងឃុំរបស់គាត់មានបង្គន់អនាម័យប្រើប្រាស់ ចំនួន ៨០ % និង មិនមានបង្គន់ប្រើប្រាស់ចំនួន ២០% ។ ចំពោះបញ្ហាសំរាមវិញតាមភូមិគឺមិនមានសេវាកម្មដឹកជញ្ជូនសំរាមទេ ដូច្នេះពួកគេមានតែធ្វើការដីកកប់ រឺដុតសំរាមនៅទីវាល និងក្បែរផ្ទះរបស់ពួកគាត់តែប៉ុណ្ណោះ។

៥.៤.៣.៦ ការប្រើប្រាស់ថាមពល

យោងតាមការសិក្សាបានអោយដឹងថា ការប្រើប្រាស់ថាមពលអគ្គីសនីគឺវាមានសារៈសំខាន់មួយផ្នែក ដែរ សំរាប់ការបំភ្លឺតាមផ្ទះ សណ្ឋាគារ ភោជនីយ៍ដ្ឋាន ដងផ្លូវ និងតាមបណ្តាកន្លែងមួយចំនួនទៀត ។ តាមស ម្តីលោក អុជ សាយ មេឃុំកំពង់ពពិល បានអោយដឹងថា ជាក់ស្តែងនៅក្នុងឃុំកំពង់ពពិល ទាំងមូលរបស់គាត់ មានថាមពលអគ្គីសនី ប្រើប្រាស់ទាំងអស់ ។

៥.៤.៣.៧ ហេដ្ឋារចនាសម្ព័ន្ធ និងផ្លូវគមនាគមន៍

បើនិយាយពីហេដ្ឋារចនាសម្ព័ន្ធ និងផ្លូវគមនាគមន៍វិញ វាជាបេះដូងមួយយ៉ាងសំខាន់សំរាប់ធ្វើចរាចរ និងប្រកបរបរចិញ្ចឹមជីវិតមិនថានៅទីណានោះទេ សូម្បីតែនៅក្នុងព្រះរាជាណាចក្រកម្ពុជាទាំងមូល ក៏ត្រូវការ ផ្លូវគមនាគមន៍នេះដែរ ។ ជាក់ស្តែងនៅក្នុងឃុំកំពង់ពពិល មានផ្លូវសរុប ចំនួន ៣ខ្សែ ធំៗ សុទ្ធតែក្រាលគ្រួស ក្រហមទាំងអស់ និងផ្លូវដីក្នុងភូមិមានជាច្រើនខ្សែផងដែរ ហើយចុងក្រោយមានផ្លូវកៅស៊ូ ១ខ្សែ ឆ្លងកាត់គឺផ្លូវ ជាតិលេខ ៨ នេះផ្ទាល់តែម្តង ។

៥.៤.៣.៨ វិស័យអប់រំ និងសិក្សាធិការ

ចំពោះការអប់រំវិញ ប្រជាពលរដ្ឋទាំងអស់គួរទទួលបាននូវសិទ្ធអប់រំស្មើៗគ្នា នេះបើយោងតាមការ កំណត់របស់រាជរដ្ឋាភិបាល។ នេះបើតាមការបកស្រាយរបស់លោកមេឃុំកំពង់ពពិល បានអោយដឹងថា នៅ ក្នុងឃុំរបស់គាត់មានសាលាបឋមសិក្សាចំនួន ៥ កន្លែង និងវិទ្យាល័យ ១ កន្លែង។ ហើយការអប់រំវិញគឺជាការ លើកកំពស់ប្រសិទ្ធភាពរបស់ប្រជាពលរដ្ឋទាំងអស់អោយមានចំណេះដឹង។ មើលតារាង ៥.១០ ខាងក្រោម៖

តារាង ៥.១០៖ បញ្ជាក់ពីចំនួនបឋមសិក្សា និងវិទ្យាល័យ

ល.រ	វិស័យអប់រំ	ឃុំកំពង់ពពិល
១	សាលាបឋមសិក្សា	៥ កន្លែង
២	វិទ្យាល័យ	១ កន្លែង

បញ្ជាក់៖ ទិន្នន័យបានពីឃុំកំពង់ពពិល

៥.៤.៣.៩ សុខាភិបាល និងអប់រំសុខភាព

ចំពោះវិស័យសុខាភិបាលវិញ លោក អុជ សាយ មេឃុំកំពង់ពពិល បាននិយាយថានៅក្នុងឃុំរបស់គាត់មានមណ្ឌលសុខភាព ១កន្លែង ។

៥.៤.៣.១០ ជំនឿសាសនា និងវប្បធម៌

យោងតាមការសិក្សាដោយផ្ទាល់ពី ឃុំកំពង់ពពិលរួចមក បានអោយដឹងថា នៅក្នុងឃុំរបស់គាត់គឺប្រជាជនភាគច្រើនក្នុងភូមិទាំងអស់ កាន់ព្រះពុទ្ធសាសនា ។

៥.៤.៣.១១ វិស័យទេសចរណ៍

ចំពោះវិស័យទេសចរណ៍វិញ វាមានសារៈសំខាន់ខ្លាំងណាស់សំរាប់ប្រជាជន គឺវាជួយអោយប្រជាជនមានជីវភាពធូរស្រាល រីកចំរើន និងលើកស្ទួយ ភូមិ-ឃុំអោយមានចំណូលកាន់តែប្រសើរឡើង។ ប៉ុន្តែជាក់ស្តែងដូចក្នុងឃុំកំពង់ពពិល គឺមិនមានតំបន់ទេសចរណ៍នោះទេ ។ ដូច្នេះធ្វើអោយប្រជាជនទាំងអស់ក្នុងភូមិ ខ្លះប្រកបរបរលក់ដូរ និងខ្លះទៀតធ្វើកម្មករតាមរោងចក្រតែប៉ុណ្ណោះ ។

៥.៤.៣.១២ ចំណូលរួមក្នុងគ្រួសារ

តាមក្រាហ្វិក ៥.១៥ ខាងក្រោមនេះបានបកស្រាយអោយឃើញថា ការសិក្សាទៅលើសំណាកគ្រួសារចំនួន ៩គ្រួសារក្នុងចំណោមគ្រួសារចំនួន ១៦៤គ្រួសារ ដែលជាប្រជាករដែលមានផលប៉ះពាល់នៅតាមបណ្តោយផ្លូវ ស្ថិតក្នុងឃុំពពិល ស្រុកពារាំង ខេត្តព្រៃវែង ដែលមានលទ្ធផលចំណូលរួមជាមធ្យមប្រចាំខែចំនួន ៤៤៥.៨២ដុល្លារ ក្នុងម្នាក់។ ដែលក្នុងនោះចំណូលរួមជាមធ្យម: ៣៩០.២៧ដុល្លារ ពីការលក់ដូរ, ៥៥.៥៥ ដុល្លារ ពីការធ្វើពលកម្ម។



ក្រាហ្វិក ៥.១៥៖ ចំណូលរួមក្នុងគ្រួសារក្នុងមួយខែរបស់ប្រជាជននៅឃុំពពិល

៥.៤.៣.១៣ ចំណាយរួមក្នុងគ្រួសារ

តាមក្រាហ្វិក ៥.១៦ ខាងក្រោមនេះបានបកស្រាយអោយឃើញថា ការសិក្សាទៅលើសំណាកគ្រួសារចំនួន ៩គ្រួសារក្នុងចំណោមគ្រួសារចំនួន ១៦៤គ្រួសារ ដែលជាប្រជាករដែលមានផលប៉ះពាល់នៅតាមបណ្តោយផ្លូវ ស្ថិតក្នុងឃុំពពិល ស្រុកពារាំង ខេត្តព្រៃវែង ដែលមានលទ្ធផលចំណាយរួមជាមធ្យមប្រចាំខែចំនួន ៤៤៤ដុល្លារ ក្នុងម្នាក់។ ដែលក្នុងនោះចំណាយរួមជាមធ្យមទៅលើ: ១៥៦.៦៧ដុល្លារ លើអាហារ, ៣៣.៤៤ ដុល្លារ លើយានយន្ត, ៨៧.៥០ដុល្លារ លើបង់ថ្លៃសាលាកូន, ៨.៣៣ដុល្លារ លើទឹក, ១៤៩.៧២ដុល្លារ លើភ្លើង, ៣.៨៩ដុល្លារ លើកាតទូរស័ព្ទ។



ក្រាហ្វិក ៥.១៦៖ ចំណាយរួមក្នុងគ្រួសារក្នុងឃុំពពិល

៥.៤.៣.១៤ ស្ថិតិអ្នកប្រើប្រាស់ទាក់ទងនឹងខ្សែកាប្លីអុបទិក

តាមតារាង ៥.១១ ខាងក្រោមបានបង្ហាញថាស្ថិតិអ្នកប្រើប្រាស់ទាក់ទងនឹងខ្សែកាប្លីអុបទិកមានដូចតទៅ៖

- ក្នុងចំណោម សំណាក៩គ្រួសារ តំណាងអោយចំនួន១៦៤គ្រួសារជាប្រជាករមាន ៣៣%នៃគ្រួសារដែលត្រូវជា ៣គ្រួសារ ជាអ្នកដែលស្គាល់បច្ចេកវិទ្យា និងសេវាកម្មខ្សែកាប្លីអុបទិក។ ចំណែកឯ ៦៧% =៦គ្រួសារ ទៀតមិនមានការយល់ដឹងពីបច្ចេកវិទ្យា និងសេវាកម្មខ្សែកាប្លីអុបទិកនេះឡើយ។
- ក្នុងចំណោម សំណាក៩គ្រួសារ តំណាងអោយចំនួន១៦៤គ្រួសារជាប្រជាករមាន ១០០%នៃគ្រួសារដែលត្រូវជា ៩គ្រួសារ ជាអ្នកដែលមានទូរសព្ទប្រើប្រាស់ ភ្ជាប់ប្រពន្ធ័ដូចជា Mobitel, Metphone និងSmart។
- ក្នុងចំណោម សំណាក៩គ្រួសារ តំណាងអោយចំនួន១៦៤គ្រួសារជាប្រជាករមាន ១០០%នៃគ្រួសារដែលត្រូវជា ៩គ្រួសារ ជាអ្នកដែលមានទូរទស្សន៍ប្រើប្រាស់ ភ្ជាប់ប្រពន្ធ័ដូចជា ប៉ុស្តសាធារណៈ និង One TV។

- ក្នុងចំណោម សំណាក៩គ្រួសារ តំណាងអោយចំនួន១៦៤គ្រួសារជាប្រជាករមាន ៨៩%នៃគ្រួសារដែលត្រូវជា ៨គ្រួសារ ជាអ្នកដែលមានអ៊ីនធើណេតប្រើប្រាស់ ដែលមានភ្ជាប់ប្រពន្ធ័តាមរយៈទូរសព្ទ័ដៃ ។ ចំណែកឯ ១១%=១គ្រួសារ ទៀតមិនមានប្រើប្រាស់អ៊ីនធើណេតនោះទេ។

តារាង ៥.១១៖ ស្ថិតិអ្នកប្រើប្រាស់ទាក់ទងនឹងខ្សែកាប្លីអុបទិកនៅក្នុងឃុំពពិល

ល.រ	ការផ្សព្វផ្សាយពីខ្សែកាប្លីអុបទិក	ចំនួនគ្រួសារ	ភាគរយ
១	អ្នកដែលដឹងពីខ្សែកាប្លីអុបទិក	៣	៣៣
២	អ្នកដែលមិនដឹងពីខ្សែកាប្លីអុបទិក	៦	៦៧
	សរុប	៩	១០០
ការប្រើប្រាស់ទូរស័ព្ទ			
១	អ្នកដែលប្រើប្រាស់ទូរសព្ទ	៩	100
២	អ្នកមិនប្រើទូរសព្ទ	០	0
	សរុប	៩	១០០
ការប្រើប្រាស់ទូរទស្សន៍			
១	អ្នកប្រើប្រាស់ទូរទស្សន៍	៩	១០០
២	អ្នកអត់ប្រើប្រាស់ទូរទស្សន៍	០	០
	សរុប	៩	១០០
ការប្រើប្រាស់អ៊ីនធើណេត			
១	អ្នកប្រើប្រាស់អ៊ីនធើណេត	៨	៨៩
២	អ្នកមិនប្រើប្រាស់អ៊ីនធើណេត	១	១១
	សរុប	៩	១០០

៥.៤.៣.១៥ យោបល់របស់ប្រជាជនលើគម្រោងកំពុងសាងសង់ខ្សែកាប្លីអុបទិក

តាមរយៈការសិក្សាចុះសម្ភាសន៍ផ្ទាល់នៅថ្ងៃទី ៣១ ខែសីហា ឆ្នាំ២០១៥ លើ៩គ្រួសារសំណាក នៅក្នុងចំណោម១៤៥គ្រួសារប្រជាករដែលបានប៉ះពាល់ដីលំនៅដ្ឋាន ឬចំការ នៃឃុំស្វាយឃ្លាំង ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ ដែលគាត់មានយោបល់លើគម្រោងកំពុងសាងសង់ខ្សែកាប្លីអុបទិកមានដូចខាងក្រោម៖

- តាមដ្យាក្រាមផ្ទៃត ៥.២ ខាងក្រោមបានបង្ហាញអោយឃើញថា មាន ១០០% ត្រូវជា ៩គ្រួសារពេញចិត្តនឹងគម្រោងកំពុងសាងសង់ខ្សែកាប្លីអុបទិកនេះ ព្រោះវាផ្តល់អត្ថប្រយោជន៍ដ៏ធំសម្បើមតាមរយៈការប្រើប្រាស់ទូរសព្ទ ទូរទស្សន៍ អ៊ីនធើណេត និងការមេ៉ាសុវត្ថិភាពផ្សេងៗ ដែលជាពិសេសវាជួយរួមចំណែកក្នុងការអភិវឌ្ឍន៍ធនធានមនុស្ស និងប្រទេសជាតិអោយបានដើរទាន់អរិយប្រទេសនានាក្នុងពិភពលោក។
- តាមមតិយោបល់បន្ថែមរបស់ប្រជាជនទាំង៩គ្រួសារនេះមានដូចខាងក្រោម៖
  - ពេញចិត្តនឹងគម្រោងព្រោះការជីកកប់មានភាពស្អាតត្រឹមត្រូវដូចដើម សាងសង់រយៈពេលខ្លី

Draft

- សំណូមពរអោយមានតម្លៃថោកសមរម្យ
- ពេញចិត្តព្រោះមិនខ្លាចឆ្លងចរន្ត
- ចង់អោយមានការអភិវឌ្ឍន៍ក្នុងភូមិ ឃុំ



ដ្យាក្រាមផ្ទៃត ៥.២៖ចិត្តពេញមិននិង ចិត្តពេញការចំពោះប្រជាជនរបស់ផ្ទាល់យោបល់អំពីមតិបង្ហាញ លើគម្រោងកំពុងសាងសង់ខ្សែកាប្លឺអុបទិកនៅឃុំពពិល

៥.៤.៤ ការសិក្សាធនធានសេដ្ឋកិច្ចសង្គមនៅក្នុងឃុំស្វាយឃ្លាំង ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ

៥.៤.៤.១ អំពីប្រជាជន និងការតាំងលំនៅដ្ឋាន

ស្ថានភាពភូមិសាស្ត្រដែលមាននៅក្នុងតំបន់គម្រោង បណ្តាញខ្សែកាប្លឺអុបទិកដែល ត្រូវបានសាងសង់រួចហើយ ដែលស្ថិតនៅក្នុងឃុំស្វាយឃ្លាំង ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ។ដោយផ្អែកតាមការរៀបរាប់របស់មេឃុំរួចមកបានអោយដឹងថា ប្រជាជនដែលរស់នៅក្នុងឃុំស្វាយឃ្លាំង មានដូចជា គ្រួសាររស់នៅអចិន្ត្រៃយ៍ មានចំនួន ១៨៨៨ គ្រួសារប្រជាព ,នាក់៩២៨៣សរុបមានចំនួនប្រជាជន ,លរដ្ឋដែលមានអាយុចាប់ពី ១៨ ឆ្នាំឡើងទៅមានចំនួន ស្រី ៣៣៨៣ នាក់ និងប្រុស ៣៣១១ នាក់ និងផ្ទៃដីលំនៅដ្ឋានក្នុងឃុំទាំងមូលមានចំនួន ១៣៦ ហិកតា។ សូមមើលតារាង ៥.១២ខាងក្រោម៖

តារាង ៥.១២៖ បញ្ជាក់អំពីប្រជាជន និងលំនៅដ្ឋាន

ល.រ	ប្រជាជន និងលំនៅដ្ឋាន	ឃុំស្វាយឃ្លាំង
១	ចំនួនគ្រួសាររស់នៅអចិន្ត្រៃយ៍	១៨៨៨ គ្រួសារ
២	ចំនួនប្រជាជនសរុប	៩២៨៣ នាក់
៣	ប្រជាពលរដ្ឋដែលមានអាយុ ចាប់ពី១៨ឆ្នាំឡើង	ស្រី ៣៣៨៣ នាក់ ប្រុស ៣៣១១ នាក់
៤	ផ្ទៃដីលំនៅដ្ឋានក្នុងឃុំទាំងមូល	១៣៦ ហ.ត

បញ្ជាក់៖ ទិន្នន័យបានពីឃុំស្វាយឃ្លាំង

៥.៤.៤.២ អាជីប និងមុខរបរ

យោងតាមទិន្នន័យដែលបានបង្ហាញពីលោក តេង យូរហ៊ីត មេឃុំស្វាយឃ្លាំង បានអោយដឹងថាអាជីប និងមុខរបររបស់ប្រជាពលរដ្ឋដែលបានរស់នៅក្នុងតំបន់របស់គាត់ មានចំនួន ៨៥% ធ្វើស្រែចំការនិង ១៥% ជាអាជីវករ ។

៥.៤.៤.៣ ការប្រើប្រាស់ដី និងកាន់កាប់ដីដោយប្រជាជន

ឯការប្រើប្រាស់ដីក្នុងឃុំស្វាយឃ្លាំងមានសណ្ឋានដីដូចតទៅ៖ ផ្ទៃដីសរុបមាន ៣៧២៨៤៣ ហត, ដីលំនៅដ្ឋានមាន ១៣៦ហត, ផ្ទៃដីដំណាំរួមផ្សំមាន ៤៩៧ហត, ផ្ទៃដីស្រែមាន ៦៣១ហត, ស្រែប្រាំងមាន ៥៨៥ហត និងស្រែវស្សាមាន៤៦ហត។ សូមមើលតារាង ៥.១៣ ខាងក្រោម។

តារាង ៥.១៣៖ ការប្រើប្រាស់ដី និងកាន់កាប់ដីដោយប្រជាជន

ល.រ	ផ្ទៃដី	ឃុំស្វាយឃ្លាំង
១	ផ្ទៃដីសរុប	៣៧២៨.៤៣ ហ.ត
២	ដីលំនៅដ្ឋាន	១៣៦ ហ.ត
៣	ផ្ទៃដីដំណាំរួមផ្សំ	៤៩៧ ហ.ត
៤	ផ្ទៃដីស្រែ	៦៣១ ហ.ត
៥	ស្រែប្រាំង	៥៨៥ ហ.ត
៦	ស្រែវស្សា	៤៦ ហ.ត

បញ្ជាក់៖ ទិន្នន័យបានពីឃុំស្វាយឃ្លាំង

៥.៤.៤.៤ ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ

យោងតាមការប្រជុំផ្សព្វផ្សាយជាមួយក្រុមការងារ និងអាជ្ញាធរមូលដ្ឋានរួចមកបានអោយដឹងថា ចំពោះការប្រើប្រាស់ទឹកវិញ គឺក្នុងឃុំស្វាយឃ្លាំងទាំងមូល គឺមានអណ្តូងទឹកនៅតាមផ្ទះទាំងអស់។

៥.៤.៤.៥ អនាម័យ

ចំពោះបញ្ហាអនាម័យវិញគឺវាមាន សារៈសំខាន់ដែរក្នុងការរស់នៅដូចជា ការបន្ទោរបង់ ការលាងសម្អាតបន្លែបង្គា លាងដៃ លាងចាននិងរបស់របរមួយចំនួន ។ ក្រោយពីបានសំណេះ សំណាលជាមួយលោកមេឃុំស្វាយឃ្លាំងរួចមក បានអោយដឹងថាក្នុងភូមិរបស់គាត់មានបង្គន់អនាម័យប្រើប្រាស់សមរម្យ សរុបមកក្នុងឃុំរបស់គាត់មានបង្គន់ប្រើប្រាស់ចំនួន ៩0 % និងមិនមានបង្គន់ប្រើប្រាស់ចំនួន ១0% ។ ចំពោះបញ្ហាសំរាមវិញតាមភូមិគឺមិនមានសេវាកម្មដឹកជញ្ជូនសំរាមទេ មានតែនៅលើដងផ្លូវជាតិតែប៉ុណ្ណោះ ដូច្នេះពួកគេមានតែធ្វើការជីកកប់ រឺដុតសំរាមនៅទីវាល និងក្បែរផ្ទះរបស់ពួកគេ។

៥.៤.៤.៦ ការប្រើប្រាស់ថាមពល

យោងតាមការសិក្សាបានអោយដឹងថា ការប្រើប្រាស់ថាមពលអគ្គីសនីគឺវាមានសារៈសំខាន់មួយផ្នែកដែរ សំរាប់ការបំភ្លឺតាមផ្ទះ សណ្ឋាគារ ភោជនីយដ្ឋាន ដងផ្លូវ និងតាមបណ្តាកន្លែងមួយចំនួនទៀត ។ តាមសម្តីលោក តេង យូហ៊ួត មេឃុំស្វាយឃ្លាំង បានអោយដឹងថា ជាក់ស្តែងនៅក្នុងឃុំស្វាយឃ្លាំង ទាំងមូលរបស់គាត់មានថាមពលអគ្គីសនី ប្រើប្រាស់គ្រប់គ្រាន់ ចំនួន ៩០% និង ១០% ទៀតប្រើអុស ធ្យូង ។

៥.៤.៤.៧ ហេដ្ឋារចនាសម្ព័ន្ធ និងផ្លូវគមនាគមន៍

បើនិយាយពីហេដ្ឋារចនាសម្ព័ន្ធ និងផ្លូវគមនាគមន៍វិញ វាជាបេះដូងមួយយ៉ាងសំខាន់សំរាប់ធ្វើចរាចរ និងប្រកបរបរចិញ្ចឹមជីវិតមិនថានៅទីណានោះទេ សូម្បីតែនៅក្នុងព្រះរាជាណាចក្រកម្ពុជាទាំងមូល ក៏ត្រូវការផ្លូវគមនាគមន៍នេះដែរ ។ ជាក់ស្តែងនៅក្នុងឃុំស្វាយឃ្លាំង មានផ្លូវសរុបទាំងអស់ ចំនួន ២០ខ្សែ ដូចជាផ្លូវបេទីមីណី ផ្លូវបេតុង ផ្លូវគ្រួសក្រហម និងផ្លូវលំធម្មតា។ ដូចមានក្នុងតារាង ៥.១៤ ខាងក្រោម៖

តារាង ៥.១៤៖ បែងចែកផ្លូវគមនាគមន៍ក្នុងឃុំស្វាយឃ្លាំង

ល.រ	ផ្លូវគមនាគមន៍	ឃុំស្វាយឃ្លាំង
១	ផ្លូវបេទីមីណី	២ ម៉ែត្រ
២	ផ្លូវបេតុង	១៦៦ ម៉ែត្រ
៣	ផ្លូវគ្រួសក្រហម	៧៤៣៩ ម៉ែត្រ
៤	ផ្លូវលំធម្មតា	២៩៧២០ ម៉ែត្រ

បញ្ជាក់៖ ទិន្នន័យបានពីឃុំស្វាយឃ្លាំង

៥.៤.៤.៨ វិស័យអប់រំ និងសិក្សាធិការ

ចំពោះការអប់រំវិញ ប្រជាពលរដ្ឋទាំងអស់គួរទទួលបាននូវសិទ្ធអប់រំស្មើៗគ្នា នេះបើយោងតាមការកំណត់របស់រាជរដ្ឋាភិបាល។ នេះបើតាមការបកស្រាយរបស់លោកមេឃុំស្វាយឃ្លាំងបានអោយដឹងថា នៅក្នុងឃុំរបស់គាត់មានសាលាមត្តេយ្យចំនួន ៥ កន្លែង សាលាបឋមសិក្សាចំនួន ៥ កន្លែង អនុវិទ្យាល័យចំនួន ១ កន្លែង និងវិទ្យាល័យ ១ កន្លែង។ ហើយការអប់រំវិញគឺជាការលើកកំពស់ប្រសិទ្ធភាពរបស់ប្រជាពលរដ្ឋទាំងអស់អោយមានចំណេះដឹង។ មើលតារាង ៥.១៥ ខាងក្រោម៖

តារាង ៥.១៥៖ បញ្ជាក់ពីចំនួនបឋមសិក្សា និងវិទ្យាល័យ

ល.រ	វិស័យអប់រំ	ឃុំស្វាយឃ្លាំង
១	សាលាមត្តេយ្យ	៥ កន្លែង
២	សាលាបឋមសិក្សា	៥ កន្លែង
៣	អនុវិទ្យាល័យ	១ កន្លែង
៤	វិទ្យាល័យ	១ កន្លែង

បញ្ជាក់៖ ទិន្នន័យបានពីឃុំស្វាយឃ្លាំង

Draft

៥.៤.៤.៩ សុខាភិបាល និងអប់រំសុខភាព

ចំពោះវិស័យសុខាភិបាលវិញ លោក តេង យូហ៊ួត មេឃុំស្វាយឃ្លាំង បាននិយាយថានៅក្នុងឃុំរបស់គាត់មានមណ្ឌលសុខភាព ១កន្លែង ។

៥.៤.៤.១០ ជំនឿសាសនា និងវប្បធម៌

យោងតាមការសិក្សាដោយផ្ទាល់ពី ឃុំស្វាយឃ្លាំងរួចមក បានអោយដឹងថា នៅក្នុងឃុំរបស់គាត់គឺប្រជាជនភាគច្រើនក្នុងភូមិទាំងអស់ កាន់ព្រះពុទ្ធសាសនា ។

៥.៤.៤.១១ វិស័យទេសចរណ៍

ចំពោះវិស័យទេសចរណ៍វិញ វាមានសារៈសំខាន់ខ្លាំងណាស់សំរាប់ប្រជាជន គឺវាជួយអោយប្រជាជនមានជីវភាពធូរស្រាល រីកចំរើន និងលើកស្ទួយ ភូមិ-ឃុំអោយមានចំណូលកាន់តែប្រសើរឡើង។ ជាក់ស្តែងដូចក្នុងឃុំស្វាយឃ្លាំង គឺប្រជាជនបានចំណូលពីការធ្វើស្រែចំការ និងលក់ដូរតិចតួច បើនិយាយពីវិស័យទេសចរណ៍វិញគឺ ឃុំនេះនៅឆ្ងាយ ហើយដីរបស់គាត់គឺជាដីស្រែចំការ ហេតុដូចនេះធ្វើអោយពួកគាត់រកចំណូលពីវិស័យទេសចរណ៍មិនបានទេ។

៥.៤.៤.១២ ចំណូលរួមក្នុងគ្រួសារ

តាមក្រាហ្វិក ៥.១៧ ខាងក្រោមនេះបានបកស្រាយអោយឃើញថា ការសិក្សាទៅលើសំណាកគ្រួសារចំនួន ២៥គ្រួសារក្នុងចំណោមគ្រួសារចំនួន ១៦៤គ្រួសារ ដែលជាប្រជាករដែលមានផលប៉ះពាល់នៅតាមបណ្តោយផ្លូវ ស្ថិតក្នុងឃុំស្វាយឃ្លាំង ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ ដែលមានលទ្ធផលចំណាយរួមជាមធ្យមប្រចាំខែចំនួន ២៤៤ដុល្លារ ក្នុងម្នាក់។ ដែលក្នុងនោះចំណាយរួមជាមធ្យមទៅលើ: ១៧៤.៥ដុល្លារ លើអាហារ, ៣៤.០៥ដុល្លារ លើយានយន្ត, ១៨.០៦ដុល្លារ លើបង់ថ្លៃសាលាកូន, ១.៥២៧ដុល្លារ លើទឹក, ១២.១៦ដុល្លារ លើភ្លើង, ៣.៨៨ដុល្លារ លើកាតទូរសព្ទ, ០.២ដុល្លារលើការចំណាយផ្សេងៗ។



ក្រាហ្វិក ៥.១៧៖ ចំណូលរួមក្នុងគ្រួសារក្នុងមួយខែរបស់ប្រជាជននៅឃុំស្វាយឃ្លាំង

៥.៤.៤.១៣ ចំណាយរួមក្នុងគ្រួសារ

តាមក្រាហ្វិក ៥.១៨ ខាងក្រោមនេះបានបកស្រាយអោយឃើញថា ការសិក្សាទៅលើសំណាកគ្រួសារចំនួន ២៥គ្រួសារក្នុងចំណោមគ្រួសារចំនួន ១៦៤គ្រួសារ ដែលជាប្រជាករដែលមានផលប៉ះពាល់នៅតាមបណ្តោយផ្លូវ ស្ថិតក្នុងឃុំស្វាយឃ្លាំង ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ ដែលមានលទ្ធផលចំណាយរួមជាមធ្យមប្រចាំខែចំនួន ២៤៤ដុល្លារ ក្នុងម្នាក់។ ដែលក្នុងនោះចំណាយរួមជាមធ្យមទៅលើ: ១៧៤.៥ដុល្លារ លើអាហារ, ៣៤.០៥ដុល្លារ លើយានយន្ត, ១៨.០៦ដុល្លារ លើបង់ថ្លៃសាលាកូន, ១.៥២៧ដុល្លារ លើទឹក, ១២.១៦ ដុល្លារ លើភ្លើង, ៣.៨៨ដុល្លារ លើកាតទូរសព្ទ, ០.២ដុល្លារលើការចំណាយផ្សេងៗ។



ក្រាហ្វិក ៥.១៨៖ ចំណាយរួមក្នុងគ្រួសារក្នុងឃុំព្រែកស្វាយឃ្លាំង

៥.៤.៤.១៤ ស្ថិតិអ្នកប្រើប្រាស់ទាក់ទងនឹងខ្សែកាប្លឺអុបទិក

តាមតារាង ៥.១៦ ខាងក្រោមបានបង្ហាញថាស្ថិតិអ្នកប្រើប្រាស់ទាក់ទងនឹងខ្សែកាប្លឺអុបទិកមានដូចតទៅ៖

- ក្នុងចំណោម សំណាក២៥គ្រួសារ តំណាងអោយចំនួន១៦៤គ្រួសារជាប្រជាករមាន ៤៤%នៃគ្រួសារដែលត្រូវជា ១១គ្រួសារ ជាអ្នកដែលស្គាល់បច្ចេកវិទ្យា និងសេវាកម្មខ្សែកាប្លឺអុបទិក។ ចំណែកឯ ៥៦%=១៤គ្រួសារ ទៀតមិនមានការយល់ដឹងពីបច្ចេកវិទ្យា និងសេវាកម្មខ្សែកាប្លឺអុបទិកនេះឡើយ។
- ក្នុងចំណោម សំណាក២៥គ្រួសារ តំណាងអោយចំនួន១៦៤គ្រួសារជាប្រជាករមាន ៩៦%នៃគ្រួសារដែលត្រូវជា ២៤គ្រួសារ ជាអ្នកដែលមានទូរសព្ទប្រើប្រាស់ ភ្ជាប់ប្រពន្ធ័ដូចជា Mobitel, Metphone និងSmart។ ចំណែកឯ ៤%=១គ្រួសារ ទៀតមិនមានប្រើប្រាស់ទូរសព្ទនោះទេ។
- ក្នុងចំណោម សំណាក២៥គ្រួសារ តំណាងអោយចំនួន១៦៤គ្រួសារជាប្រជាករមាន ៩៦%នៃគ្រួសារដែលត្រូវជា ២៤គ្រួសារ ជាអ្នកដែលមានទូរទស្សន៍ប្រើប្រាស់ ភ្ជាប់ប្រពន្ធ័ដូចជា ប៉ុស្តសាធារណៈ និង DTV។ ចំណែកឯ ៤%=១គ្រួសារ ទៀតមិនមានប្រើប្រាស់ទូរទស្សន៍នោះទេ។
- ក្នុងចំណោម សំណាក២៥គ្រួសារ តំណាងអោយចំនួន១៦៤គ្រួសារជាប្រជាករមាន ៣២%នៃគ្រួសារដែលត្រូវជា ៨គ្រួសារ ជាអ្នកដែលមានអ៊ីនធើណេតប្រើប្រាស់ ដែលមានភ្ជាប់ប្រពន្ធ័តាមរយៈទូរសព្ទ័ដៃ ។ ចំណែកឯ ៦៨%=១៧គ្រួសារ ទៀតមិនមានប្រើប្រាស់អ៊ីនធើណេតនោះទេ។

Draft

តារាង ៥.១៦៖ ស្ថិតិអ្នកប្រើប្រាស់ទាក់ទងនឹងខ្សែកាប្លីអុបទិក

ល.រ	ការផ្សព្វផ្សាយពីខ្សែកាប្លីអុបទិក	ចំនួនគ្រួសារ	ភាគរយ
១	អ្នកដែលដឹងពីខ្សែកាប្លីអុបទិក	១១	៤៤
២	អ្នកដែលមិនដឹងពីខ្សែកាប្លីអុបទិក	១៤	៥៦
	សរុប	២៥	១០០
ការប្រើប្រាស់ទូរស័ព្ទ			
១	អ្នកដែលប្រើប្រាស់ទូរសព្ទ	២៤	៩៦
២	អ្នកមិនប្រើទូរសព្ទ	១	៤
	សរុប	២៥	១០០
ការប្រើប្រាស់ទូរទស្សន៍			
១	អ្នកប្រើប្រាស់ទូរទស្សន៍	២៤	៩៦
២	អ្នកអត់ប្រើប្រាស់ទូរទស្សន៍	១	៤
	សរុប	២៥	១០០
ការប្រើប្រាស់អ៊ីនធើណេត			
១	អ្នកប្រើប្រាស់អ៊ីនធើណេត	៨	៣២
២	អ្នកមិនប្រើប្រាស់អ៊ីនធើណេត	១៧	៦៨
	សរុប	២៥	១០០

៥.៤.៤.១៥ យោបល់របស់ប្រជាជនលើគម្រោងកំពុងសាងសង់ខ្សែកាប្លីអុបទិក

តាមរយៈការសិក្សាចុះសម្ភាសន៍ផ្ទាល់នៅថ្ងៃទី ២៥ ខែសីហា ឆ្នាំ២០១៥ លើ២២គ្រួសារសំណាក នៅក្នុងចំណោម១៤៥គ្រួសារប្រជាករដែលបានប៉ះពាល់ដីលំនៅដ្ឋាន ឬចំការ នៃឃុំស្វាយឃ្លាំង ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ ដែលគាត់មានយោបល់លើគម្រោងកំពុងសាងសង់ខ្សែកាប្លីអុបទិកមានដូចខាងក្រោម៖

- តាមដ្យាក្រាមផ្ទឹត ៥.៣ ខាងក្រោមបានបង្ហាញអោយឃើញថា មាន ៩២% ត្រូវជា ២៣គ្រួសារពេញចិត្តនឹងគម្រោងកំពុងសាងសង់ខ្សែកាប្លីអុបទិកនេះ ព្រោះវាផ្តល់អត្ថប្រយោជន៍ដ៏ធំសម្បើមតាមរយៈការប្រើប្រាស់ទូរសព្ទ ទូរទស្សន៍ អ៊ីនធើណេត និងការមេ៉ាសុវត្ថិភាពផ្សេងៗ ដែលជាពិសេសវាជួយរួមចំណែកក្នុងការអភិវឌ្ឍន៍ធនធានមនុស្ស និងប្រទេសជាតិអោយបានដើរទាន់អរិយប្រទេសនានាក្នុងពិភពលោក។ ប៉ុន្តែមានចំនួន២ គ្រួសារ ស្មើ នឹង ៨% ប៉ុណ្ណោះដែលមិនពេញចិត្តអោយមានគម្រោងសាងសង់ខ្សែកាប្លីអុបទិកនេះ ព្រោះពេលសាងសង់ជីកកប់ខ្សែកាប្លីអុបទិក រំខានដល់ការចេញចូលផ្ទះរបស់ពួកគាត់ ជាពិសេសប៉ះពាល់ដីស្រែ ចំការ និងលំនៅដ្ឋាន។ តែទោះជាយ៉ាងនេះក៏ដោយគាត់ក៏នៅតែអនុញ្ញាតអោយធ្វើការជីកកប់ខ្សែកាប្លីអុបទិក ដោយមានការសម្របសម្រួលពីអាជ្ញាធរជាមួយនឹងប្រជាជន ទើបធ្វើអោយការសាងសង់មានភាពរលូន។
- តាមមតិយោបល់បន្ថែមរបស់ប្រជាជនទាំង២២គ្រួសារនេះមានដូចខាងក្រោម៖

- ពេញចិត្តនឹងគម្រោងព្រោះការជីកកប់មានភាពស្អាតត្រឹមត្រូវដូចដើម សាងសង់រយៈពេលខ្លី
- ពេញចិត្តអោយមានខ្សែកាប្លីអុបទិក ប៉ុន្តែសំណូមពរអោយមានការជីកលប់អោយបានត្រឹមត្រូវ
- សំណូមពរអោយមានតម្លៃថោកសមរម្យ
- សំណូមពរអោយមានការផ្តល់ពត៌មាន និងធ្វើការផ្សព្វផ្សាយអោយប្រជាជនមានការយល់ដឹងមុននឹងធ្វើការសាងសង់
- មិនពេញចិត្តព្រោះខ្លាចឆ្លងចរន្ត និងមិនចូលចិត្តអោយជីកដីមុខផ្ទះ ព្រោះខាងក្រុមហ៊ុនមិនបានធ្វើការកប់លប់អោយស្អាតល្អដូចដើម។
- ចង់អោយមានការអភិវឌ្ឍន៍ក្នុងភូមិ ឃុំ



ដ្យាក្រាមផ្ទៃត ៥.៣៖ ការបង្ហាញអំពីមតិអ្នកពេញចិត្ត និងមិនពេញចិត្តរបស់ប្រជាជនផ្ទាល់ចំពោះគម្រោងបញ្ចប់ការសាងសង់ខ្សែកាប្លីអុបទិកនៅឃុំស្វាយឃ្លាំង

៥.៤.៥ ការសិក្សាធនធានសេដ្ឋកិច្ចសង្គមនៅក្នុងឃុំសណ្តាន់ និងឃុំមានរិទ្ធ ស្រុកសណ្តាន់ ខេត្តកំពង់ធំ

៥.៤.៥.១ អំពីប្រជាជន និងការតាំងលំនៅដ្ឋាន

ស្ថានភាពភូមិសាស្ត្រដែលមាននៅក្នុងតំបន់គម្រោង បណ្តាញខ្សែកាប្លីអុបទិកដែលត្រូវបានសាងសង់រួចរាល់ ហើយក្នុងព្រះរាជាណាចក្រកម្ពុជាទាំងមូលត្រូវបានក្រុមហ៊ុនខ្សែកាប្លីអុបទិក អូសឆ្លងកាត់ស្ទើគ្រប់ខេត្តក្រុង ជាក់ស្តែងគឺអុសកាត់ក្នុងឃុំចំនួន ០២ គឺឃុំសណ្តាន់ និងឃុំមានរិទ្ធ ដែលស្ថិតនៅក្នុងស្រុកសណ្តាន់ ខេត្តកំពង់ធំ។ ដោយផ្អែកតាមការរៀបរាប់របស់មេឃុំនីមួយៗរួចមកបានឲ្យដឹងថា ប្រជាជននៅក្នុងឃុំសណ្តាន់មានគ្រួសាររស់នៅជាអចិន្ត្រៃសរុបចំនួន ២១៩៥គ្រួសារ, ចំនួនប្រជាជនសរុបមាន ៩៨៥៧នាក់

និងប្រជាពលរដ្ឋដែលមានអាយុចាប់ពី១៨ឆ្នាំឡើង មានស្រី ៣១៤៦នាក់ និងប្រុស ៣០៣៥នាក់។ ចំណែកប្រជាជននៅក្នុងឃុំមានរិទ្ធមានគ្រួសាររស់នៅជាអចិន្ត្រៃសរុបចំនួន ១៧២៤គ្រួសារ, ចំនួនប្រជាជនសរុបមាន ៧១៤៣នាក់ និងប្រជាពលរដ្ឋដែលមានអាយុចាប់ពី១៨ឆ្នាំឡើង មានស្រី ១៩៧២នាក់ និងប្រុស ១៦៩២ នាក់។ សូមមើលតារាង ៥.១៧ ខាងក្រោម។

តារាងទី ៥.១៧៖ បញ្ជាក់អំពីប្រជាជន និងលំនៅដ្ឋាន

ល.រ	ប្រជាជន និងលំនៅដ្ឋាន	ឃុំសណ្តាន់	ឃុំមានរិទ្ធ
១	ចំនួនគ្រួសាររស់នៅអចិន្ត្រៃយ៍	**២១៩៥** គ្រួសារ	**១៧២៣** គ្រួសារ
២	ចំនួនប្រជាជនសរុប	**៩៨៥៧** នាក់	**៧១៤៣** នាក់
៣	ប្រជាពលរដ្ឋដែលមានអាយុ ចាប់ពី១៨ឆ្នាំឡើង	ស្រី **៣១៤៦** នាក់ ប្រុស **៣០៣៥** នាក់	ស្រី **១៩៧២** នាក់ ប្រុស **១៦៩២** នាក់

បញ្ជាក់៖ ទិន្នន័យបានពីឃុំសណ្តាន់ និងឃុំមានរិទ្ធ

៥.៤.៥.២ អាជីប និងមុខរបរ

យោងតាមទិន្នន័យដែលបានបង្ហាញពីលោកមេឃុំសណ្តាន់ បានអោយដឹងថា អាជីប និងមុខរបរ របស់ប្រជាពលរដ្ឋដែលបានរស់នៅក្នុងតំបន់នេះ មានចំនួន **៨៥%** ធ្វើស្រែចំការ និង**១៥%** អាជីវករ។ចំពោះស្មៀនឃុំមានរិទ្ធ បានអោយដឹងដែរថា អាជីប និងមុខរបររបស់ប្រជាពលរដ្ឋដែលបានរស់នៅក្នុងតំបន់របរស់គាត់ មានចំនួន **៧៥%** ធ្វើស្រែចំការ **២0%** អាជីវករ និង **៥%** ជាមន្ត្រីរាជការ ។

៥.៤.៥.៣ ការប្រើប្រាស់ដី និងកាន់កាប់ដីដោយប្រជាជន

ការប្រើប្រាស់ដីក្នុងឃុំនីមួយៗ មានសណ្ឋានដូចតទៅ៖ គឺក្នុងឃុំសណ្តាន់ និងឃុំមានរិទ្ធ ការប្រើប្រាស់ដីភាគច្រើនគឺប្រជាជនប្រកបរបរធ្វើស្រែចំការ និងអាជីវករ។

៥.៤.៥.៤ ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ

យោងតាមការប្រជុំផ្សព្វផ្សាយជាមួយក្រុមការងារ និងអាជ្ញាធរមូលដ្ឋានរួចមកបានអោយដឹងថា ចំពោះការប្រើប្រាស់ទឹក គឺប្រជាពលរដ្ឋរស់នៅឃុំទាំងពីរខាងលើ គឺពួកគាត់មានអណ្តូង រីអណ្តូងស្ទប់ គ្រប់ផ្ទះទាំងអស់សំរាប់យកទឹកមកប្រើប្រាស់ក្នុងភូមិរបស់គាត់ ។ ចំពោះការបរិភោគទឹកវិញគឺពួកគាត់បានដាំទឹកអោយពុះជាមុនសិន មុននិងគាត់ពិសា មិនថាទឹកម៉ាស៊ីន ទឹកស្ទឹង ទឹកបឹង និងទឹកស្រះឡើយ។

៥.៤.៥.៥ អនាម័យ

ចំពោះបញ្ហាអនាម័យវិញគឺវាមាន សារៈសំខាន់ដែរក្នុងការរស់នៅដូចជា ការបន្ទោរបង់ ការលាងសម្អាតបន្លែបង្គា លាងដៃ លាងចាននិងរបស់របរមួយចំនួន ។ ប៉ុន្តែយើងផ្តោតសំខាន់ទៅលើសំរាម ការបន្ទោរបង់ បង្គន់ ទីវាល និងកន្លែងផ្សេងៗ ក្រោយពីបានសំណេះ សំណាលជាមួយលោកមេឃុំសណ្តាន់រួចមក

បានអោយដឹងថាក្នុងភូមិរបស់គាត់មានផ្ទះខ្លះមានបង្គន់អនាម័យប្រើប្រាស់ និងខ្លះទៀតពួកគាត់ប្រើប្រាស់ការបន្ទោរបង់នៅក្នុងព្រៃ។ រីឯក្នុងឃុំមានវិទ្ធ ស្មៀនបានបញ្ជាក់ផងដែរថាក្នុងឃុំរបស់គាត់មានបង្គន់ប្រើប្រាស់ចំនួន **៣០%** និង**៧០%** ទៀតប្រើប្រាស់តាមទំលាប់របស់ពួកគាត់គឺ ក្នុងព្រៃ និងតាមទីវាលដាច់ស្រយាល។ ចំពោះសំរាមវិញពួកគាត់មានតែធ្វើការដីកកប់ រឺដុតសំរាមនៅទីវាល និងក្បែរផ្ទះរបស់ពួកគេ។

៥.៤.៥.៦ ការប្រើប្រាស់ថាមពល

យោងតាមការសិក្សាបានអោយដឹងថា ការប្រើប្រាស់ថាមពលអគ្គីសនីគឺវាមានសារៈសំខាន់មួយផ្នែកដែរ សំរាប់ការបំភ្លឺតាមផ្ទះ សណ្ឋាគារ ភោជនីយ៍ដ្ឋាន រោងកុន ដងផ្លូវ និងតាមបណ្តាកន្លែងមួយចំនួនទៀតដែលត្រូវការ ។ តាមសម្តីលោក **បាន ហេង** មេឃុំសណ្តាន់ បានអោយដឹងថា ជាក់ស្តែងនៅក្នុងឃុំសណ្តាន់ទាំងមូលរបស់គាត់មានចំនួន **១៣** ភូមិ ហើយ **៥** ភូមិប្រើប្រាស់ថាមពលអគ្គីសនីរដ្ឋ និង **៨**ភូមិទៀតគាត់ប្រើប្រាស់ អាគុយ និងសូឡា ។ រីឯលោក **ឡោ ម៉ែងលាន** ស្មៀនឃុំ វិញ បាននិយាយផងដែរថា ចំពោះប្រជាពលរដ្ឋរស់នៅក្នុងឃុំរបស់គាត់ មាន **២ភូមិ** ប្រើភ្លើងបង្គោល និង ៦ ភូមិទៀតប្រើប្រាស់អាគុយ និងសូឡា។

៥.៤.៥.៧ ហេដ្ឋារចនាសម្ព័ន្ធ និងផ្លូវគមនាគមន៍

បើនិយាយពីហេដ្ឋារចនាសម្ព័ន្ធ និងផ្លូវគមនាគមន៍វិញ វាជាបេះដូងមួយយ៉ាងសំខាន់សំរាប់ធ្វើចរាចរ និងប្រកបរបរចិញ្ចឹមជីវិតមិនថានៅទីណានោះទេ សូម្បីតែនៅក្នុងព្រះរាជាណាចក្រកម្ពុជាទាំងមូល ក៏ត្រូវការផ្លូវគមនាគមន៍នេះដែរ ។ ជាក់ស្តែងនៅក្នុងឃុំសណ្តាន់ មានផ្លូវកៅស៊ូ **១ខ្សែ** ផ្លូវគ្រួសក្រហមចំនួន **៤ខ្សែ** ធំៗ និងផ្លូវតូចៗជាច្រើន ខុសពីឃុំមានវិទ្ធមានផ្លូវគ្រួសក្រហម ជាច្រើនខ្សែ និងផ្លូវដីចំនួន **១០ខ្សែ**។

៥.៤.៥.៨ វិស័យអប់រំ និងសិក្សាធិការ

ចំពោះការអប់រំវិញ ប្រជាពលរដ្ឋទាំងអស់គួរទទួលបាននូវសិទ្ធអប់រំស្មើៗគ្នា នេះបើយោងតាមការកំណត់របស់រាជរដ្ឋាភិបាល។ នេះបើតាមការបកស្រាយរបស់លោកមេឃុំសណ្តាន់បានអោយដឹងថា នៅក្នុងឃុំរបស់គាត់មានសាលាបឋមសិក្សាចំនួន ៨ កន្លែង និង វិទ្យាល័យចំនួន ១ កន្លែង។ ចំពោះឃុំមានវិទ្ធវិញមានសាលាបឋមសិក្សាចំនួន ៨ កន្លែងដូចគ្នា និងអនុវិទ្យាល័យ ១កន្លែងផងដែរ។ ហើយការអប់រំវិញគឺជាការលើកកំពស់ប្រសិទ្ធភាពរបស់ប្រជាពលរដ្ឋទាំងអស់អោយមានចំណេះដឹង។ មើលតារាង ៥.១៨ ខាងក្រោម៖

តារាង ៥.១៨៖ បញ្ជាក់ពីចំនួនបឋមសិក្សា និងវិទ្យាល័យ

ល.រ	វិស័យអប់រំ	ឃុំសណ្តាន់	ឃុំមានវិទ្ធ
១	សាលាបឋមសិក្សា	៨ កន្លែង	៨ កន្លែង
២	អនុវិទ្យាល័យ	០ កន្លែង	១ កន្លែង
៣	វិទ្យាល័យ	១ កន្លែង	០ កន្លែង

បញ្ជាក់៖ ទិន្នន័យបានពីឃុំសណ្តាន់ និងឃុំមានវិទ្ធ

៥.៤.៥.៩ សុខាភិបាល និងអប់រំសុខភាព

ចំពោះវិស័យសុខាភិបាលវិញ លោក **បាន ហេង** មេឃុំសណ្តាន់បាននិយាយថានៅក្នុងឃុំរបស់គាត់មានមណ្ឌលសុខភាព **១កន្លែង** និងឃុំមានវិទ្ធផ្ទាល់មិនមានមណ្ឌលសុខភាពសំរាប់ប្រើប្រាស់ទេ គឺពួកគាត់ប្រើប្រាស់ជាមួយមណ្ឌលសុខភាព ឃុំសណ្តាន់។

៥.៤.៥.១០ ជំនឿសាសនា និងវប្បធម៌

យោងតាមការសិក្សាដោយផ្ទាល់ពី ឃុំសណ្តាន់ និងឃុំមានវិទ្ធរួចមក បានអោយដឹងថា នៅក្នុងឃុំរបស់គាត់គឺប្រជាជនភាគច្រើនក្នុងភូមិទាំងអស់ កាន់ព្រះពុទ្ធសាសនា ។

៥.៤.៥.១១ វិស័យទេសចរណ៍

ចំពោះវិស័យទេសចរណ៍វិញ វាមានសារៈសំខាន់ខ្លាំងណាស់សំរាប់ប្រជាជន គឺវាជួយអោយប្រជាជនមានជីវភាពធូរស្រាល រីកចំរើន និងលើកស្ទួយ ភូមិ-ឃុំអោយមានចំណូលកាន់តែប្រសើរឡើង។ ជាក់ស្តែងដូចក្នុងឃុំសណ្តាន់ មិនមានតំបន់ទេសចរណ៍ទេ ប៉ុន្តែចំពោះឃុំមានវិទ្ធវិញគឺមានតំបន់ទេសចរមួយកន្លែងសំរាប់ប្រជាជនមកលេងកំសាន្តក្នុងរដូវ ភ្ជុំបិណ្ឌ គឺ **បឹងអូរក្រញាក់** ។

៥.៤.៥.១២ ចំណូលរួមក្នុងគ្រួសារ

តាមក្រាហ្វិក ៥.១៩ ខាងក្រោមនេះបានបកស្រាយអោយឃើញថា ការសិក្សាទៅលើសំណាកគ្រួសារចំនួន ១៨គ្រួសារក្នុងចំណោមគ្រួសារចំនួន ៩១គ្រួសារ ដែលជាប្រជាករដែលមានផលប៉ះពាល់នៅតាមបណ្តោយផ្លូវ ស្ថិតក្នុងឃុំសណ្តាន់ ឃុំមានវិទ្ធ ស្រុកសណ្តាន់ ខេត្តកំពង់ធំ ដែលមានលទ្ធផលចំណូលរួមជាមធ្យមប្រចាំខែចំនួន ១៥៨.៨១ដុល្លារ ក្នុងម្នាក់។ ដែលក្នុងនោះចំណូលរួមជាមធ្យម: ១០០.៨៩ដុល្លារ ពីការធ្វើស្រែ, ៩.៣៧ដុល្លារ ពីការចិញ្ចឹមសត្វ, ២០.៥៣ដុល្លារ ពីការលក់ដូរ, ៨.៩២ដុល្លារ ពីការធ្វើពលកម្ម, ១១.៦០ដុល្លារ ពីប្រាក់ខែ, ៧.៥០ដុល្លារ បានពីការធ្វើមុខរបរផ្សេងៗ។



ក្រាហ្វិក ៥.១៩៖ ចំណូលរួមក្នុងគ្រួសារក្នុងមួយខែរបស់ប្រជាជននៅឃុំស្វាយឃ្លាំង និងឃុំមានរិទ្ធ

៥.៤.៥.១៣ ចំណាយរួមក្នុងគ្រួសារ

តាមក្រាហ្វិក ៥.២០ ខាងក្រោមនេះបានបកស្រាយអោយឃើញថា ការសិក្សាទៅលើសំណាកគ្រួសារចំនួន ១៤គ្រួសារក្នុងចំណោមគ្រួសារចំនួន ៩១គ្រួសារ ដែលជាប្រជាករដែលមានផលប៉ះពាល់នៅតាមបណ្តោយផ្លូវ ស្ថិតក្នុងឃុំសណ្តាន់ ឃុំមានរិទ្ធ ស្រុកសណ្តាន់ ខេត្តកំពង់ធំ ដែលមានលទ្ធផលចំណូលរួមជាមធ្យមប្រចាំខែចំនួន ១១៤៩ដុល្លារ ក្នុងម្នាក់។ ដែលក្នុងនោះចំណូលរួមជាមធ្យម: ៦៩៤.៦៤ដុល្លារ ពីការធ្វើស្រែ, ១៤២.៨៦ដុល្លារ ពីការចិញ្ចឹមសត្វ, ២០៥.៣៦ដុល្លារ ពីការលក់ដូរ, ៤៦.៤៣ដុល្លារ ពីការធ្វើពលកម្ម, ៥១.៧៩ដុល្លារ ពីប្រាក់ខែ, ៧.៥០ដុល្លារ បានពីការធ្វើមុខរបរផ្សេងៗ។



ក្រាហ្វិក ៥.២០៖ ចំណាយរួមក្នុងគ្រួសារក្នុងឃុំសណ្តាន់ និងឃុំមានរិទ្ធ

៥.៤.៥.១៤ ស្ថិតិអ្នកប្រើប្រាស់ទាក់ទងនឹងខ្សែកាប្លឺអុបទិក

តាមតារាង ៥.១៩ ខាងក្រោមបានបង្ហាញថាស្ថិតិអ្នកប្រើប្រាស់ទាក់ទងនឹងខ្សែកាប្លឺអុបទិកមានដូចតទៅ៖

- ក្នុងចំណោម សំណាក១៤គ្រួសារ តំណាងអោយចំនួន៩១គ្រួសារជាប្រជាករមាន ២១%នៃគ្រួសារដែលត្រូវជា ៤គ្រួសារ ជាអ្នកដែលស្គាល់បច្ចេកវិទ្យា និងសេវាកម្មខ្សែកាប្លឺអុបទិក។ ចំណែកឯ ៧៩% =១១គ្រួសារ ទៀតមិនមានការយល់ដឹងពីបច្ចេកវិទ្យា និងសេវាកម្មខ្សែកាប្លឺអុបទិកនេះឡើយ។
- ក្នុងចំណោម សំណាក១៤គ្រួសារ តំណាងអោយចំនួន៩១គ្រួសារជាប្រជាករមាន ៩៣%នៃគ្រួសារដែលត្រូវជា ១៣គ្រួសារ ជាអ្នកដែលមានទូរសព្ទប្រើប្រាស់ ភ្ជាប់ប្រពន្ធ័ដូចជា Mobitel, Metphone និងSmart។ ចំណែកឯ ៧%=១គ្រួសារ ទៀតមិនមានប្រើប្រាស់ទូរសព្ទនោះទេ។
- ក្នុងចំណោម សំណាក១៤គ្រួសារ តំណាងអោយចំនួន៩១គ្រួសារជាប្រជាករមាន ៣៦%នៃគ្រួសារដែលត្រូវជា ៥គ្រួសារ ជាអ្នកដែលមានទូរទស្សន៍ប្រើប្រាស់ ភ្ជាប់ប្រពន្ធ័ ប៉ុស្តសាធារណៈ ។ ចំណែកឯ ៦៤%=៩គ្រួសារ ទៀតមិនមានប្រើប្រាស់ទូរទស្សន៍នោះទេ។
- ក្នុងចំណោម សំណាក១៤គ្រួសារ តំណាងអោយចំនួន៩១គ្រួសារជាប្រជាករមាន ១៤%នៃគ្រួសារដែលត្រូវជា២គ្រួសារ ជាអ្នកដែលមានអ៊ីនធើណេតប្រើប្រាស់ ដែលមានភ្ជាប់ប្រពន្ធ័តាមរយៈទូរសព្ទ័ដៃ ។ ចំណែកឯ ៨៦%=១២គ្រួសារ ទៀតមិនមានប្រើប្រាស់អ៊ីនធើណេតនោះទេ។

តារាង ៥.១៩៖ ស្ថិតិអ្នកប្រើប្រាស់ទាក់ទងនឹងខ្សែកាប្លឺអុបទិកក្នុងឃុំសណ្តាន់ និងឃុំមានរិទ្ធ

ល.រ	ការផ្សព្វផ្សាយពីខ្សែកាប្លឺអុបទិក	ចំនួនគ្រួសារ	ភាគរយ
១	អ្នកដែលដឹងពីខ្សែកាប្លឺអុបទិក	៣	២១
២	អ្នកដែលមិនដឹងពីខ្សែកាប្លឺអុបទិក	១១	៧៩
	សរុប	១៤	១០០
ការប្រើប្រាស់ទូរសព្ទ			
១	អ្នកដែលប្រើប្រាស់ទូរសព្ទ	១៣	៩៣
២	អ្នកមិនប្រើទូរសព្ទ	១	៧
	សរុប	១៤	១០០
ការប្រើប្រាស់ទូរទស្សន៍			
១	អ្នកប្រើប្រាស់ទូរទស្សន៍	៥	៣៦
២	អ្នកអត់ប្រើប្រាស់ទូរទស្សន៍	៩	៦៤
	សរុប	១៤	១០០
ការប្រើប្រាស់អ៊ីនធើណេត			
១	អ្នកប្រើប្រាស់អ៊ីនធើណេត	២	១៤
២	អ្នកមិនប្រើប្រាស់អ៊ីនធើណេត	១២	៨៦
	សរុប	១៤	១០០

៥.៤.៥.១៥ យោបល់របស់ប្រជាជនលើគម្រោងកំពុងសាងសង់ខ្សែកាប្លីអុបទិក

តាមរយៈការសិក្សាចុះសម្ភាសន៍ផ្ទាល់នៅថ្ងៃទី ២៥ ខែសីហា ឆ្នាំ២០១៥ លើ១៤គ្រួសារសំណាក នៅក្នុងចំណោម៩១ គ្រួសារប្រជាករដែលបានប៉ះពាល់ដីលំនៅដ្ឋាន ឬចំការ នៃឃុំសណ្តាន់ ឃុំមានរិទ្ធ ស្រុកសណ្តាន់ ខេត្តកំពង់ធំ ដែលគាត់មានយោបល់លើគម្រោងកំពុងសាងសង់ខ្សែកាប្លីអុបទិកមានដូចខាងក្រោម៖

- តាមដ្យាក្រាមផ្នែត ៥.៤ ខាងក្រោមបានបង្ហាញអោយឃើញថា មាន ៥០% ត្រូវជា ៧គ្រួសារពេញចិត្ត នឹងគម្រោងកំពុងសាងសង់ខ្សែកាប្លីអុបទិកនេះ ព្រោះវាផ្តល់អត្ថប្រយោជន៍ដ៏ធំសម្បើមតាមរយៈការប្រើប្រាស់ទូរសព្ទ ទូរទស្សន៍ អ៊ីនធើណេត និងការមេរ៉ាសុវត្ថិភាពផ្សេងៗ ដែលជាពិសេសវាជួយរួមចំណែកក្នុងការអភិវឌ្ឍន៍ធនធានមនុស្ស និងប្រទេសជាតិអោយបានដើរទាន់អរិយប្រទេសនានាក្នុងពិភពលោក។ ប៉ុន្តែមានចំនួន៧ គ្រួសារ ស្មើ នឹង ៥០% ដែលមិនពេញចិត្តអោយមានគម្រោងសាងសង់ខ្សែកាប្លីអុបទិកនេះ ព្រោះពេលសាងសង់ជីកកប់ខ្សែកាប្លីអុបទិក រំខានដល់ការចេញចូលផ្ទះរបស់ពួកគាត់ ជាពិសេសប៉ះពាល់ដីស្រែ ចំការ និងលំនៅដ្ឋាន។ តែទោះជាយ៉ាងនេះក៏ដោយគាត់ក៏នៅតែអនុញ្ញាតអោយធ្វើការជីកកប់ខ្សែកាប្លីអុបទិក ដោយមានការសម្របសម្រួលពីអាជ្ញាធរជាមួយនឹងប្រជាជន ទើបធ្វើអោយការសាងសង់មានភាពរលូន។



ដ្យាក្រាមផ្នែត ៥.៤៖បង្ហាញអំពីមតិយោបល់ផ្ទាល់របស់ប្រជាជនចំពោះការពេញចិត្ត និងមិនពេញចិត្តលើគម្រោងកំពុងសាងសង់ខ្សែកាប្លីអុបទិកនៅឃុំសណ្តាន់ និងឃុំមានរិទ្ធ

- តាមមតិយោបល់បន្ថែមរបស់ប្រជាជនទាំង១៤គ្រួសារនេះមានដូចខាងក្រោម៖
  - ពេញចិត្តនឹងគម្រោងព្រោះការជីកកប់មានភាពស្អាតត្រឹមត្រូវដូចដើម សាងសង់រយៈពេលខ្លី
  - ពេញចិត្តអោយមានខ្សែកាប្លីអុបទិក ប៉ុន្តែសំណូមពរអោយមានការជីកលប់អោយបានត្រឹមត្រូវ
  - សំណូមពរអោយមានតម្លៃថោកសមរម្យ

- សំណូមពរអោយមានការផ្តល់ពត៌មាន និងធ្វើការផ្សព្វផ្សាយអោយប្រជាជនមានការយល់ដឹងមុននឹងធ្វើការសាងសង់
- មិនពេញចិត្តព្រោះខ្លាចឆ្លងចរន្ត និងមិនចូលចិត្តអោយដីកដីមុខផ្ទះ ព្រោះខាងក្រុមហ៊ុនមិនបានធ្វើការកប់លប់អោយស្អាតល្អដូចដើម។
- ចង់អោយមានការអភិវឌ្ឍន៍ក្នុងភូមិ ឃុំ

៥.៤.៦ ការសិក្សាធនធានសេដ្ឋកិច្ចសង្គមនៅក្នុងសង្កាត់ព្រៃញី សាលាក្រុងអោធ៏សាត់ ខេត្តអោធ៏សាត់

៥.៤.៦.១ អំពីប្រជាជន និងការតាំងលំនៅដ្ឋាន

ស្ថានភាពភូមិសាស្ត្រដែលមាននៅក្នុងតំបន់គម្រោង បណ្តាញខ្សែកាប្លីអុបទិកដែលត្រូវបានកសាងរួចក្នុងព្រះរាជាណាចក្រកម្ពុជាទាំងមូលត្រូវបានក្រុមហ៊ុនខ្សែកាប្លីអុបទិក អូសឆ្លងកាត់ស្ទើគ្រប់ខេត្តក្រុងជាក់ស្តែងគឺអូសកាត់ក្នុងសង្កាត់ព្រៃញី ដែលស្ថិតនៅក្នុងក្រុងដូនកែវ ខេត្តពោធ៏សាត់។ ដោយផ្អែកតាមការរៀបរាប់របស់ចៅសង្កាត់រួចមកបានឲ្យដឹងថា ប្រជាជនរស់នៅក្នុងសង្កាត់ព្រៃញីមានចំនួនគ្រួសាររស់នៅអចិន្ត្រៃយ៍ចំនួន ១១៣៣គ្រួសារ, ចំនួនប្រជាជនសរុប ៥០៥៣នាក់, ប្រជាពលរដ្ឋដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ ស្រីមានចំនួន ១៦៦៨នាក់ និងប្រុស ១៥០០នាក់។ សូមមើលតារាង ៥.២០ ខាងក្រោម។

តារាង ៥.២០៖ បញ្ជាក់អំពីប្រជាជន និងលំនៅដ្ឋាន

ល.រ	ប្រជាជន និងលំនៅដ្ឋាន	សង្កាត់ព្រៃញី
១	ចំនួនគ្រួសាររស់នៅអចិន្ត្រៃយ៍	**១១៣៣** គ្រួសារ
២	ចំនួនប្រជាជនសរុប	**៥០៥៣** នាក់
៣	ប្រជាពលរដ្ឋដែលមានអាយុ ចាប់ពី១៨ឆ្នាំឡើង	ស្រី **១៦៦៨** នាក់ ប្រុស **១៥០០** នាក់

បញ្ជាក់៖ ទិន្នន័យបានពីសង្កាត់ព្រៃញី

៥.៤.៦.២ អាជីប និងមុខរបរ

យោងតាមទិន្នន័យដែលបានបង្ហាញពីចៅសង្កាត់ព្រៃញី បានអោយដឹងថា អាជីប និងមុខរបររបស់ប្រជាពលរដ្ឋដែលបានរស់នៅក្នុងតំបន់នេះ មានចំនួន **៦០%** ធ្វើស្រែចំការ **២០%** អាជីវករ និង **២០%** ទៀតជាមន្ត្រីរាជការ។

៥.៤.៦.៣ ការប្រើប្រាស់ដី និងកាន់កាប់ដីដោយប្រជាជន

ការប្រើប្រាស់ដីក្នុងសង្កាត់របស់គាត់ មានសណ្ឋានដូចតទៅ៖ គឺផ្ទៃដីសរុបរួមមាន **៨៣០** ហិកតា ក្នុងនោះមានផ្ទៃដីស្រែចំនួន **៤៦០** ហិកតា និង **៤១០** ហិកតាទៀតគឺជាផ្ទៃដីលំនៅដ្ឋាន។

៥.៤.៦.៤ ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ

យោងតាមការប្រជុំផ្សព្វផ្សាយជាមួយក្រុមការងារ និងអាជ្ញាធរមូលដ្ឋានរួចមកបានអោយដឹងថា ចំពោះការប្រើប្រាស់ទឹក គឺប្រជាពលរដ្ឋរស់នៅសង្កាត់ព្រៃញី គឺពួកគាត់មានទឹកស្អាតប្រើប្រាស់គ្រប់គ្រាន់ និងខ្លះទៀតប្រើប្រាស់ទឹកអណ្តូង និងអណ្តូងស្នប់ ។

៥.៤.៦.៥ អនាម័យ

ចំពោះបញ្ហាអនាម័យវិញគឺវាមាន សារៈសំខាន់ដែរក្នុងការរស់នៅដូចជា ការបន្ទោរបង់ ការលាងសម្អាតបន្លែបង្គា លាងដៃ លាងចាននិងរបស់របរមួយចំនួន ។ ប៉ុន្តែយើងផ្តោតសំខាន់ទៅលើសំរាម ការបន្ទោរបង់ បង្គន់ ទីវាល និងកន្លែងផ្សេងៗ ក្រោយពីបានសំណេះ សំណាលជាមួយចៅសង្កាត់ព្រៃញី រួចមក បានអោយដឹងថាក្នុងឃុំរបស់គាត់មាន បង្គន់អនាម័យប្រើប្រាស់គ្រប់គ្រាន់ គឺ **១០០%** តែម្តង។ ចំពោះសំរាមវិញ ពួកគាត់មានតែធ្វើការដឹកកប់ រឺដុតសំរាមនៅទីវាល និងក្បែរផ្ទះរបស់ពួកគេ។

៥.៤.៦.៦ ការប្រើប្រាស់ថាមពល

យោងតាមការសិក្សាបានអោយដឹងថា ការប្រើប្រាស់ថាមពលអគ្គីសនីគឺវាមានសារៈសំខាន់មួយផ្នែកដែរ សំរាប់ការបំភ្លឺតាមផ្ទះ សណ្ឋាគារ ភោជនីយ៍ដ្ឋាន រោងកុន ដងផ្លូវ និងតាមបណ្តាកន្លែងមួយចំនួនទៀតដែលត្រូវការ ។ តាមសម្តីចៅសង្កាត់ព្រៃញី បានអោយដឹងថា ក្នុងសង្កាត់ព្រៃញី ទាំងមូលរបស់គាត់មានថាមពលអគ្គីសនី ប្រើប្រាស់**១០០%** ។

៥.៤.៦.៧ ហេដ្ឋារចនាសម្ព័ន្ធ និងផ្លូវគមនាគមន៍

បើនិយាយពីហេដ្ឋារចនាសម្ព័ន្ធ និងផ្លូវគមនាគមន៍វិញ វាជាបេះដូងមួយយ៉ាងសំខាន់សំរាប់ធ្វើចរាចរ និងប្រកបរបរចិញ្ចឹមជីវិតមិនថានៅទីណានោះទេ សូម្បីតែនៅក្នុងព្រះរាជាណាចក្រកម្ពុជាទាំងមូល ក៏ត្រូវការផ្លូវគមនាគមន៍នេះដែរ ។ ជាក់ស្តែងនៅសង្កាត់ព្រៃញីនេះ មានផ្លូវគ្រួសក្រហមចំនួន **១១ខ្សែ** ធំៗ និងផ្លូវកៅស៊ូ **១ខ្សែ** ផងដែរជាក់ស្តែងគឺផ្លូវជាតិលេខ **៥** នេះតែម្តង ។

៥.៤.៦.៨ វិស័យអប់រំ និងសិក្សាធិការ

ចំពោះការអប់រំវិញ ប្រជាពលរដ្ឋទាំងអស់គួរទទួលបាននូវសិទ្ធអប់រំស្មើៗគ្នា នេះបើយោងតាមការកំណត់របស់រាជរដ្ឋាភិបាល។ នេះបើតាមការបកស្រាយរបស់ចៅសង្កាត់រងព្រៃញី បានអោយដឹងដែរថា នៅក្នុងសង្កាត់ព្រៃញី របស់គាត់មានសាលាបឋមសិក្សាចំនួន **២** កន្លែង អនុវិទ្យាល័យចំនួន **១** កន្លែង និងសាលាគរុកោសល្យ **១** កន្លែងផងដែរ។ មើលតារាង ៥.២១ខាងក្រោម៖

តារាង ៥.២១៖ បញ្ជាក់ពីចំនួនបឋមសិក្សា និងវិទ្យាល័យ

ល.រ	វិស័យអប់រំ	សង្កាត់ព្រៃញី
១	សាលាបឋមសិក្សា	២ កន្លែង
២	អនុវិទ្យាល័យ	១ កន្លែង
៣	សាលាគរុកោសល្យ	១ កន្លែង

បញ្ជាក់៖ ទិន្នន័យបានពីសង្កាត់ព្រៃញី

៥.៤.៦.៩ សុខាភិបាល និងអប់រំសុខភាព

ចំពោះវិស័យសុខាភិបាលវិញ ចៅសង្កាត់រងព្រៃញី បាននិយាយថានៅក្នុងសង្កាត់ របស់គាត់មានមណ្ឌលសុខភាព **១កន្លែង** ។

៥.៤.៦.១០ ជំនឿសាសនា និងវប្បធម៌

យោងតាមការសិក្សាដោយផ្ទាល់ពី ឃុំស្វាយសរួចមក បានអោយដឹងថា នៅក្នុងឃុំរបស់គាត់គឺប្រជាជនភាគច្រើនក្នុងភូមិទាំងអស់ កាន់ព្រះពុទ្ធសាសនា ។

៥.៤.៦.១១ វិស័យទេសចរណ៍

ចំពោះវិស័យទេសចរណ៍វិញ វាមានសារៈសំខាន់ខ្លាំងណាស់សំរាប់ប្រជាជន គឺវាជួយអោយប្រជាជនមានជីវភាពធូរស្រាល រីកចំរើន និងលើកស្ទួយ ភូមិ-ឃុំអោយមានចំណូលកាន់តែប្រសើរឡើង។ ជាក់ស្តែងគឺក្នុងសង្កាត់ព្រៃញ៊ី ទាំងមូលមិនមានតំបន់ទេសចរណ៍នោះទេ។

៥.៤.៦.១២ ចំណូលរួមក្នុងគ្រួសារ

តាមក្រាហ្វិក ៥.២១ ខាងក្រោមនេះបានបកស្រាយអោយឃើញថា ការសិក្សាទៅលើសំណាកគ្រួសារចំនួន ១៥គ្រួសារក្នុងចំណោមគ្រួសារចំនួន ៨៥គ្រួសារបតាមនៅប៉ៈពាល់ផលមានដែលប្រជាករជាដែលដៃ ពោធិសាត់ខេត្ត ក្រគរព្រៃញី ស្រុកឃុំក្នុងស្ថិត ផ្លូវណ្តោយលមានលទ្ធផលចំណូលរួមជាមធ្យមប្រចាំខែចំនួន ៣៩៣ដុល្លារ ក្នុងម្នាក់។ ដែលក្នុងនោះចំណូលរួមជាមធ្យម: ៧៤.៣៣ដុល្លារ ពីការធ្វើស្រែ, ៣៨ដុល្លារ ពីការចិញ្ចឹមសត្វ,១៤ .៦៥ដុល្លារ ពីការលក់ដូរ, ២៨.៥ដុល្លារ ពីការធ្វើពលកម្ម, ៣៩ដុល្លារ ពីប្រាក់ខែ, ៦៦.៦៧ដុល្លារ បានពីការធ្វើមុខរបរផ្សេងៗ។



ក្រាហ្វិក ៥.២១៖ ចំណូលរួមក្នុងគ្រួសារក្នុងមួយខែរបស់ប្រជាជននៅឃុំព្រៃញី

៥.៤.៦.១៣ ចំណាយរួមក្នុងគ្រួសារ

តាមក្រាហ្វិក ៥.២២ ខាងក្រោមនេះបានបកស្រាយអោយឃើញថា ការសិក្សាទៅលើសំណាកគ្រួសារចំនួន ១៥គ្រួសារក្នុងចំណោមគ្រួសារចំនួន ៨៥គ្រួសារនៅប៉ះពាល់ផលមានដែលប្រជាករជាដែលដៃ ពោធិសាត់ខេត្ត ក្រគរព្រៃញី ស្រុកឃុំក្នុងស្ថិត ផ្លូវបណ្តាយតាមលមានលទ្ធផលចំណូលរួមជាមធ្យមប្រចាំខែចំនួន ៣៩៣ដុល្លារ ក្នុងម្នាក់។ ដែលក្នុងនោះចំណូលរួមជាមធ្យម: ៧៤.៣៣ដុល្លារ ពីការធ្វើស្រែ, ៣៨ ដុល្លារ ពីការចិញ្ចឹមសត្វ,១៤ .៦៥ដុល្លារ ពីការលក់ដូរ, ២៨.៥ដុល្លារ ពីការធ្វើពលកម្ម, ៣៩ដុល្លារ ពីប្រាក់ខែ , ៦៦.៦៧ដុល្លារ បានពីការធ្វើមុខរបរផ្សេងៗ។



ក្រាហ្វិក ៥.២២៖ ចំណាយរួមក្នុងគ្រួសារក្នុងឃុំព្រៃញី

៥.៤.៦.១៤ ស្ថិតិអ្នកប្រើប្រាស់ទាក់ទងនឹងខ្សែកាប្លីអុបទិក

តាមតារាង ៥.២២ ខាងក្រោមបានបង្ហាញថាស្ថិតិអ្នកប្រើប្រាស់ទាក់ទងនឹងខ្សែកាប្លីអុបទិកមានដូចតទៅ៖

- ក្នុងចំណោម សំណាក១៥គ្រួសារ តំណាងអោយចំនួន៨៥គ្រួសារជាប្រជាករមាន ៤7%នៃគ្រួសារដែលត្រូវជា ៧គ្រួសារ ជាអ្នកដែលស្គាល់បច្ចេកវិទ្យា និងសេវាកម្មខ្សែកាប្លីអុបទិក។ ចំណែកឯ ៥3% =៨គ្រួសារ ទៀតមិនមានការយល់ដឹងពីបច្ចេកវិទ្យា និងសេវាកម្មខ្សែកាប្លីអុបទិកនេះឡើយ។
- ក្នុងចំណោម សំណាក15គ្រួសារ តំណាងអោយចំនួន៨៥គ្រួសារជាប្រជាករមាន៦៧%នៃគ្រួសារដែលត្រូវជា ១០គ្រួសារ ជាអ្នកដែលមានទូរសព្ទប្រើប្រាស់ ភ្ជាប់ប្រពន្ធ័ដូចជា Mobitel, Metphone និងSmart។ ចំណែកឯ ៣៣%=៥គ្រួសារ ទៀតមិនមានប្រើប្រាស់ទូរសព្ទនោះទេ។
- ក្នុងចំណោម សំណាក១៥គ្រួសារ តំណាងអោយចំនួន៨៥គ្រួសារជាប្រជាករមាន៦៧%នៃគ្រួសារដែលត្រូវជា ១០គ្រួសារ ជាអ្នកដែលមានទូរទស្សន៍ប្រើប្រាស់ ភ្ជាប់ប្រពន្ធ័ដូចជា ប៊ុស្តសាធារណៈ និង One TV។ ចំណែកឯ ៣៣%=៥គ្រួសារ ទៀតមិនមានប្រើប្រាស់ទូរទស្សន៍នោះទេ។
- ក្នុងចំណោម សំណាក១៥គ្រួសារ តំណាងអោយចំនួន៨៥គ្រួសារជាប្រជាករមាន ៣៣%នៃគ្រួសារដែលត្រូវជា ៨៥គ្រួសារ ជាអ្នកដែលមានអ៊ីនធើណេតប្រើប្រាស់ ដែលមានភ្ជាប់ប្រពន្ធ័តាមរយៈទូរសព្ទ័ដៃ ។ ចំណែកឯ ៦៧%=១០គ្រួសារ ទៀតមិនមានប្រើប្រាស់អ៊ីនធើណេតនោះទេ។

តារាង ៥.២២៖ ស្ថិតិអ្នកប្រើប្រាស់ទាក់ទងនឹងខ្សែកាប្លីអុបទិក

ល.រ	ការផ្សព្វផ្សាយពីខ្សែកាប្លីអុបទិក	ចំនួនគ្រួសារ	ភាគរយ
១	អ្នកដែលដឹងពីខ្សែកាប្លីអុបទិក	៧	៤៧
២	អ្នកដែលមិនដឹងពីខ្សែកាប្លីអុបទិក	៨	៥៣
	សរុប	១៥	១០០
ការប្រើប្រាស់ទូរស័ព្ទ			
១	អ្នកដែលប្រើប្រាស់ទូរសព្ទ	១០	៦៧
២	អ្នកមិនប្រើទូរសព្ទ	៥	៣៣
	សរុប	១៥	១០០
ការប្រើប្រាស់ទូរទស្សន៍			
១	អ្នកប្រើប្រាស់ទូរទស្សន៍	១០	៦៧
២	អ្នកអត់ប្រើប្រាស់ទូរទស្សន៍	៥	៣៣
	សរុប	១៥	១០០
ការប្រើប្រាស់អ៊ីនធើណេត			
១	អ្នកប្រើប្រាស់អ៊ីនធើណេត	៥	៣៣
២	អ្នកមិនប្រើប្រាស់អ៊ីនធើណេត	១០	៦៧
	សរុប	១៥	១០០

៥.៤.៦.១៥ យោបល់របស់ប្រជាជនលើគម្រោងកំពុងសាងសង់ខ្សែកាប្លីអុបទិក

តាមរយៈការសិក្សាចុះសម្ភាសន៍ផ្ទាល់នៅថ្ងៃទី ៣១ ខែសីហា ឆ្នាំ២០១៥ លើ១៥គ្រួសារសំណាក នៅក្នុងចំណោម៨៥គ្រួសារប្រជាករដែលបានប៉ះពាល់ដីលំនៅដ្ឋាន ឬចំការ នៃសង្កាត់ព្រៃញី ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ក្រោមខាងដូចមានអុបទិកខ្សែកាប្លីសាងសង់កំពុងគម្រោងលើយោបល់មានគាត់ដែល ៖

- តាមដ្យាក្រាមផ្នែត ៥.៥ ខាងក្រោមបានបង្ហាញអោយឃើញថា មាន ៨៧% ត្រូវជា ១៣គ្រួសារពេញចិត្តនឹងគម្រោងកំពុងសាងសង់ខ្សែកាប្លីអុបទិកនេះ ព្រោះវាផ្តល់អត្ថប្រយោជន៍ដ៏ធំសម្បើមតាមរយៈការប្រើប្រាស់ទូរសព្ទ ទូរទស្សន៍ អ៊ីនធើណេត និងការមេរ៉ាសុវត្ថិភាពផ្សេងៗ ដែលជាពិសេសវាជួយរួមចំណែកក្នុងការអភិវឌ្ឍន៍ធនធានមនុស្ស និងប្រទេសជាតិអោយបានដើរទាន់អរិយប្រទេសនានាក្នុងពិភពលោក។ ប៉ុន្តែមានចំនួន២ គ្រួសារ ស្មើ នឹង ១៣% ប៉ុណ្ណោះដែលមិនពេញចិត្តអោយមានគម្រោងសាងសង់ខ្សែកាប្លីអុបទិកនេះ ព្រោះពេលសាងសង់ជីកកប់ខ្សែកាប្លីអុបទិក រំខានដល់ការចេញចូលផ្ទះរបស់ពួកគាត់ ជាពិសេសប៉ះពាល់ដីស្រែ ចំការ និងលំនៅដ្ឋាន។ តែទោះជាយ៉ាងនេះក៏ដោយគាត់ក៏នៅតែអនុញ្ញាតអោយធ្វើការជីកកប់ខ្សែកាប្លីអុបទិក ដោយមានការសម្របសម្រួលពីអាជ្ញាធរជាមួយនឹងប្រជាជន ទើបធ្វើអោយការសាងសង់មានភាពរលូន។



ដ្យាក្រាមផ្នែត ៥.៥៖មតិផ្ទាល់របស់ប្រជាជនទៅលើការពេញចិត្ត និងមិនពេញចិត្តគម្រោងបានបញ្ចប់ការសាងសង់ខ្សែកាប្លីអុបទិកនៅឃុំស្វាយឃ្លាំង

- តាមមតិយោបល់បន្ថែមរបស់ប្រជាជនទាំង១៥គ្រួសារនេះមានដូចខាងក្រោម៖
  - ពេញចិត្តនឹងគម្រោងព្រោះការជីកកប់មានភាពស្អាតត្រឹមត្រូវដូចដើម សាងសង់រយៈពេលខ្លី
  - ពេញចិត្តអោយមានខ្សែកាប្លីអុបទិក ព្រោះសេវាកម្មមានល្បឿនលឿន
  - មានការធុញទ្រាន់ មិនចង់អោយមានការកប់
  - សំណូមពរអោយមានតម្លៃថោកសមរម្យ និងរហ័សឆាប់បានប្រើប្រាស់

- សំណូមពរអោយមានការផ្តល់ពត៌មាន និងធ្វើការផ្សព្វផ្សាយអោយប្រជាជនមានការយល់ដឹងមុននឹងធ្វើការសាងសង់
- ពេញចិត្ត ព្រោះវាអាចនឹងមានប្រយោជន៍ដល់ក្មេងជំនាន់ក្រោយ
- ចង់អោយមានការអភិវឌ្ឍន៍ក្នុងភូមិ ឃុំ

Draft

ជំពូក ៦
ការពិគ្រោះយោបល់ពីសាធារណៈជន

Draft

ជំពូក ៦
ការចូលរួម ការប្រឹក្សា និងការពិគ្រោះយោបល់ពីសាធារណៈជន

៦.១ សេចក្តីផ្តើម

គម្រោងវិនិយោគ សម្រាប់គម្រោងបានបញ្ចប់ការសាងសង់លើបណ្តាញខ្សែកាប្លីអុបទិកកម្ពុជា របស់ក្រុមហ៊ុន Cambodia Fiber Optic Communication Network Co., Ltd (CFOCN) បណ្តាលឱ្យមានការប៉ះពាល់ ដល់ប្រជាពលរដ្ឋ ដែល រស់នៅក្បែរតំបន់ និងធនធានធម្មជាតិដូចជា សត្វព្រៃ ព្រៃឈើ និងរុក្ខជាតិជាដើម ។ ហេតុដូច្នេះហើយបានជាចាំបាច់ត្រូវធ្វើការផ្សព្វផ្សាយព័ត៌មានដល់ អាជ្ញាធរក៏ដូចជាស្ថាប័នពាក់ព័ន្ធ និងជា ពិសេសដល់ប្រជាពលរដ្ឋតែម្តង ។ ការប្រជុំពិភាក្សាពិគ្រោះយោបល់ជាមួយស្ថាប័នពាក់ព័ន្ធ អាជ្ញាធរពាក់ព័ន្ធ និងប្រជាពលរដ្ឋជាទិន្នន័យដ៏សំខាន់ដើម្បីទទួលបាននូវមតិរិះគន់មតិយោបល់គាំទ្រ ព័ត៌មាន លំអិតពាក់ព័ន្ធ និងបរិស្ថានដែលមានស្រាប់ និងអនុសាសន៍នានា សម្រាប់ជាទុនក្នុងការវាយតម្លៃគម្រោងថាតើគម្រោងមានការអភិវឌ្ឍន៍មែន ឬមិនមែនហើយនិងអាចបញ្ជាក់ឱ្យដឹងថាប្រជាពលរដ្ឋក៏ដូចជាអាជ្ញាធរពាក់ព័ន្ធនៅក្នុងតំបន់ ថាតើពួកគាត់ពិតជាស្វាគមន៍នឹងវត្តមានគម្រោងអភិវឌ្ឍន៍នេះដែរឬយ៉ាងណា?

៦.២ គោលបំណង

គោលបំណងនៃការប្រឹក្សា និងពិគ្រោះយោបល់ពីសាធារណៈជន មានគោលបំណងដូចតទៅ៖

- ធ្វើការផ្សព្វផ្សាយដល់សាធារណជន និងអ្នកដែលពាក់ព័ន្ធនឹងគម្រោងទាំងអស់ឱ្យបានដឹងឮអំពីគោលបំណង និងដំណាក់កាលនៃការអនុវត្តគម្រោងនេះ ។
- ស្វែងរកមតិរិះគន់ សំណូមពរ បញ្ហាទំនាស់ និងរកវិធីសាស្ត្រកែលំអផ្សេងៗ របស់ពួកគាត់ទាំងនោះដើម្បីឱ្យគម្រោងទទួលបានជោគជ័យ ។
- ស្វែងរកវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន នៃគម្រោងបញ្ចប់ការសាងសង់ខ្សែកាប្លីអុបទិកនេះឱ្យកាន់តែមានប្រសិទ្ធិភាពដោយធ្វើការប្រជុំពិភាក្សាជាមួយមន្ទីរពាក់ព័ន្ធ និងមានការចូលរួមពីសំណាក់អាជ្ញាធរដែនដី និងប្រជាជនមូលដ្ឋាន ។

៦.៣ អំណត់ហេតុនៃការប្រឹក្សា ពិគ្រោះយោបល់ និងការចូលរួមរបស់សាធារណៈជន

៦.៣.១ ការពិគ្រោះយោបល់ជាមួយអាជ្ញាធរមូលដ្ឋានស្រុកឈូក ខេត្តកំពត

នៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៥ វេលាម៉ោង១៤ និង៣០នាទី នៅសាលាស្រុកឈូក ក្រុមការងារវាយ តម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង បានជួបពិភាក្សា និងពិគ្រោះយោបល់ជាមួយលោក **ឆេង វិបុល** នាយករដ្ឋបាលសាលាស្រុកឈូក លើគម្រោងបញ្ចប់ការសាងសង់ខ្សែ កាប្លីអុបទិក(CFOCN)។ នៅក្នុងកិច្ចប្រជុំនេះលោកនាយកបានលើកឡើងពីមតិយោបល់ និងសំណូមពររបស់អាជ្ញាធរដូចខាងក្រោមដូចខាងក្រោម៖

លោកពិតបានដឹងអំពីវត្តមានរបស់ក្រុមហ៊ុនបណ្តាញខ្សែកាប្លីអុបទិកកម្ពុជា (CFOCN) ដែលបានសាងសង់រួច នៅក្នុងស្រុករបស់លោកចាប់តាំងពីក្រុមហ៊ុនមកវិនិយោគដំបូងរហូតឈានដល់បញ្ចប់ការសាងសង់ ដោយក្រុមហ៊ុនតែងតែធ្វើការទំនាក់ទំនង និងជូនដំណឹងជាមុន ។ ក្រុមការងារវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង បានធ្វើការបង្ហាញក៏ដូចជាពិគ្រោះយោបល់ជាមួយអាជ្ញាធរស្រុកឈូក លោកមានការគាំទ្រ ចំពោះវត្តមានរបស់គម្រោងវិនិយោគខាងលើនេះ ហើយក៏មានការពេញចិត្តផងដែរ ព្រោះថាក្រុមហ៊ុនតែង តែធ្វើការទំនាក់ទំនង និងរាយការណ៍នៅកន្លែងដែលមានការស្មុកស្មាញក្នុងការសាងសង់ និងបានធ្វើការ សម្របសម្រួលតាំងពីអាជ្ញាធរស្រុក ឃុំ និងភូមិជានិច្ច គឺគម្រោងសាងសង់ខ្សែកាប្លីអុបទិកបានធ្វើឱ្យមានការរីកចំរើន ធ្វើឱ្យមានការងាយស្រួលដល់ប្រជាជននៅតាមជនបទក្នុងការទំនាក់ទំនង ដឹងពីព័ត៌មាន និងសេវា ផ្សេងៗជាច្រើន ។ តាងនាមឲ្យអាជ្ញាធរមូលដ្ឋានស្រុកឈូកសូមគាំទ្រលើគម្រោងបានបញ្ចប់ការសាងសង់ខ្សែកាប្លីអុបទិក១០០% ពីព្រោះគម្រោងបានបញ្ចប់ទៅដោយរលូនដោយពុំមានបញ្ហាទំនាស់ជាមួយនឹងប្រជាជន។ ហើយម៉្យាងទៀតគម្រោងនេះនឹងចូលរួមចំណែកជួយធ្វើអោយប្រជាជនទទួលបាននូវពត៌មានពីចំណេះដឹង និងចំណេះធ្វើសំរាប់កសាងជីវភាពគ្រួសារអោយកាន់តែធូរធា ហើយក៏ហ្នឹងធ្វើឲ្យស្រុករីកចម្រើនដូចនៅទីក្រុងធំៗនៅក្នុងប្រទេសកម្ពុជា។

- **សមាសភាពអ្នកចូលរួមពិភាក្សា** (សូមរួបថតក្នុងឧបសម្ព័ន្ធ)៖
  ១. លោក **ឆេង វិបុល** ជានាយករដ្ឋបាលសាលាស្រុកឈូក ខេត្តកំពត
  ២. លោក **លឹម សុជាតិ** ជាបុគ្គលិកថែទាំ និងជួសជុលខ្សែកាប្លីអុបទិក
  ៣. លោក **ឆេង** ជាបុគ្គលិកថែទាំ និងជួសជុលខ្សែកាប្លីអុបទិក
  ៤. ក្រុមការងាររបស់ក្រុមហ៊ុនPPIC
- **អង្គប្រជុំខាងលើមានខ្លឹមសារទាំងមូលដូចខាងក្រោម៖**
  - លោកបានមានប្រសាសន៍ថា បានជ្រាបពីគម្រោងតាមរយៈរបស់ក្រុមហ៊ុន Cambodia Fiber Optic Cable Network Co., Ltd (CFOCN) នេះផ្ទាល់ដោយបង្ហាញលិខិតផ្លូវច្បាប់ពីរាជរដ្ឋាភិបាល។
  - **សំណូមពរ**

– សូមក្រុមហ៊ុនធ្វើការបោះបង្គោលចំណាំត្រង់ចំណុចដែលខ្សែកាប្លីរត់ឆ្លងកាត់ផ្លូវ ឬប្រឡាយ ដើម្បីងាយស្រួលក្នុងការជូនដំណឹងទៅក្រុមហ៊ុនវិញ ពេលដែលមានការអភិវឌ្ឍន៍។
– សូមឱ្យក្រុមហ៊ុនទំនាក់ទំនងមកអាជ្ញាធរមូលដ្ឋានឱ្យបានឆាប់រហ័ស នៅពេលដែលមានសំណូមពរពីអាជ្ញាធរ។

៦.៣.២ ការពិគ្រោះយោបល់ជាមួយអាជ្ញាធរ ឃុំសត្វពង ស្រុកឈូក ខេត្តកំពត

នៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ វេលាម៉ោង១៥ និង៤០នាទីរសៀល នៅសាលាឃុំសត្វពង ក្រុមការងារវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង បានជួបពិភាក្សានិងពិគ្រោះយោបល់ជាមួយលោក **ឃុញ ហ៊ាប** មេឃុំសត្វពង លើគម្រោងបញ្ចប់ការសាងសង់ខ្សែកាប្លីអុបអិក (CFOCN) នៅក្នុង

កិច្ចប្រជុំនេះ អាជ្ញាធរឃុំបានលើកឡើងជាយោបល់ពីមតិយោបល់ និងសំណូមពរ និងចំណាប់អារម្មណ៍ដូចខាងក្រោម។

- **សមាសភាពអ្នកចូលរួមពិភាក្សា** (សូមរូបថតក្នុងឧបសម្ព័ន្ធ)៖
  ១. លោក **ឃុញ ហ៊ាប** ជាមេឃុំសត្វពង ស្រុកឈូក ខេត្តកំពត
  ២. លោក **លឹម សុជាតិ** ជាបុគ្គលិកថែទាំ និងជួសជុលខ្សែកាប្លីអុបទិក
  ៣. លោក **ឆេង** ជាបុគ្គលិកថែទាំ និងជួសជុលខ្សែកាប្លីអុបទិក
  ៤. ក្រុមការងាររបស់ក្រុមហ៊ុនPPIC
- **អង្គប្រជុំខាងលើមានខ្លឹមសារទាំងមូលដូចខាងក្រោម៖**
  - អង្គប្រជុំបានលើកឡើងថា បានដឹងពីគម្រោងតាមរយៈរបស់ក្រុមហ៊ុន Cambodia Fiber Optic Cable Network Co., Ltd (CFOCN) នេះផ្ទាល់តាមរយៈសាលាស្រុក។
  - **មតិ សំណូមពរ និងចំណាប់អារម្មណ៍ធរភូមិឃុំ**

តាមមតិលោកបានដឹងអំពីវត្តមានគម្រោងរបស់ក្រុមហ៊ុនបណ្តាញខ្សែកាប្លីអុបទិកកម្ពុជា (CFOCN) នេះចាប់ តាំងពីក្រុមហ៊ុនមកវិនិយោគដំបូងរហូតមកដល់បច្ចុប្បន្ន ប៉ុន្តែមិនបានដឹងអំពីសារៈប្រយោជន៍របស់ខ្សែកាប្លីអុបទិកថា តើអាចប្រើប្រាស់លើសេវាទូរទស្សន៍ខ្សែកាប ទូរស័ព្ទ និងសេវាអ៊ីនធឺណេតបានដែរឬទេ?

ជាមួយគ្នានេះដែរ លោកមេឃុំក៏បានគាំទ្រចំពោះគម្រោងអភិវឌ្ឍន៍នេះ ដែលធ្វើឱ្យមានភាពងាយស្រួល ក្នុងការប្រើប្រាស់ទៅអនាគត ទោះបីជាគម្រោងនេះបានបញ្ចប់ទៅដោយ ក៏ដីស្រែរបស់ប្រជាជនមានការស្រុតនៅចំណុចខ្លះៗនៅពេលដែលមានភ្លៀងធ្លាក់រួច ដែលបង្កធ្វើឱ្យពិបាកក្នុងការព្យួរ រាស់ ស្លុង និងពិបាកក្នុង ការធ្វើដំណើរខ្លះៗក៏ដោយ តែវាមិនមែនជាបញ្ហាធំដុំនោះទេ ប៉ុន្តែបញ្ហានេះមិនបានធ្វើឱ្យមានការរាំងស្ទះ ដល់ការបង្កបង្កើនផល និងការប្រកបរបររបស់ប្រជាពលរដ្ឋឡើយ ទោះបីជាកន្លងមកការអនុវត្តគម្រោងនេះ បានធ្វើឱ្យមានការប៉ះពាល់ដល់ដីស្រែ ដីចំការ ក៏ដូចជាដីលំនៅដ្ឋានរបស់ ប្រជាជន។ គ្រប់ពេលនៃការអនុវត្តរបស់ក្រុមហ៊ុន អាជ្ញាធរពិនិត្យឃើញថា ក្រុមហ៊ុនតែងតែធ្វើការសម្របសម្រួលជាមួយប្រជាពលរដ្ឋជានិច្ច។

- **សំណូមពរផ្ទាល់អាជ្ញាធរឃុំ៖**
  - សូមឱ្យក្រុមហ៊ុនធ្វើការសាងសង់ឡើងវិញ ចំពោះកន្លែងដែលមានផលប៉ះពាល់នៅពេលដែលការសាងសង់កន្លងមកមិនបានដូចសភាពដើម ។
  - សូមឲ្យក្រុមហ៊ុនចែកចាយសេវាកម្មទាក់ទងទៅនឹងខ្សែកាប្លីអុបទិកដូចជា៖ ទូរសព្ទ ទូរទស្សន៍ អ៊ីនធើណេត និងការមេ៉ាសុវត្ថិភាពឲ្យបានកាន់តែឆាប់កាន់តែល្អ។

៦.៣.៣ ការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋនៅភូមិត្រពាំងកកោះ ឃុំដូនយ៉ាយ ស្រុកឈូក ខេត្តកំពត

នៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៥ វេលាម៉ោង០៨ និង៣០នាទី នៅភូមិត្រពាំងកកោះ ក្រុមការងារវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង បានជួបពិភាក្សា និងពិគ្រោះយោបល់ជាមួយលោក **ស្វាយ**

ឡាយ មេភូមិត្រពាំងកកោះ និងប្រជាជនចំនួន ០៩នាក់ (មានភ្ជាប់ជូនបញ្ជីវត្តមានក្នុងតារាងឧសម្ព័ន្ធ) លើគម្រោងបញ្ចប់ការសាងសង់ខ្សែកាប្លីអុបអិក។ការប្រជុំនេះបានលើកឡើងជាមតិ និង សំណូមពរមួយចំនួនដូចខាងក្រោម៖

↳ មតិ(ការរីះគន់ ការព្រួយបារម្ភ ការគាំទ្រ) សំណូមពររបស់ប្រជាជន

មតិរួមរបស់ប្រជាជន បានឱ្យដឹងថាប្រជាជនបានដឹងអំពីវត្តមានរបស់ក្រុមហ៊ុនបណ្តាញខ្សែកាប្លីអុបទិកកម្ពុជា (CFOCN) ដោយលោកមេភូមិបានជូនដំណឹងតាំងពីមុនពេលដែលក្រុមហ៊ុនមកធ្វើការវិនិយោគដំបូងរហូតបញ្ចប់ការសាងសង់ ហើយក៏ដឹងអំពីសារៈប្រយោជន៍ដូចជាអាចប្រើប្រាស់បានទៅលើទូរទស្សន៍ខ្សែកាបទូរស័ព្ទ និងអ៊ីនធឺណេត។ ប្រជាពលរដ្ឋមានការគាំទ្រទាំងស្រុង ទោះបីជាការដំណើរការនៃការសាងសង់គម្រោងបានបញ្ចប់ទៅដោយធ្វើឱ្យដីស្រែរបស់គាត់មានការស្រុតនៅចំណុចខ្លះៗ នៅពេលដែលមានភ្លៀងធ្លាក់រួច មានការពិបាកក្នុងការព្យួរ និងស្ទូង។ នៅពេលមានការប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់ប្រជាជន គឺក្រុមហ៊ុនបានធ្វើការសាងសង់ ជួសជុល និងបានទូទាត់សំណងដល់ប្រជាជនវិញ ដែលការទូទាត់សំណង និងការជួសជុលវិញនេះ គឺធ្វើឡើងភ្លាមៗ ទោះបីមិនបានដូចសភាពដើមទាំងស្រុងក៏ដោយ។ ចំពោះការប៉ះពាល់ដែលមានការពាក់ព័ន្ធរវាងក្រុមហ៊ុនខ្សែកាប្លីអុបទិក (CFOCN) និងភូមិត្រពាំងកកោះ គឺការពាក់ព័ន្ធជាមួយដីស្រែ ដីចំការ ក៏ដូចជាដីលំនៅដ្ឋានរបស់ប្រជាជន។

↳ សំណូមពរផ្ទាល់របស់ប្រជាពលរដ្ឋ៖

- សូមក្រុមហ៊ុនធ្វើការផ្សព្វផ្សាយដល់ប្រជាជនពីព័ត៌មាននៃការទំនាក់ទំនង តើត្រូវធ្វើដូចម្តេចទើបអាចប្រើប្រាស់ប្រព័ន្ធខ្សែកាប្លីអុបទិកនេះបាន ។
- សូមប្រាប់ពីតម្លៃនៃការប្រើប្រាស់សេវាកម្មខ្សែកាប្លីអុបទិកនេះ និងរបៀបទំនាក់ទំនង ដើម្បីទទួលបានសេវាកម្មនេះ។
- សូមឱ្យតម្លៃនៃការប្រើប្រាស់សេវាខ្សែកាប្លីអុបទិក មានតម្លៃថោកដើម្បីឱ្យប្រជាជនមានលទ្ធភាពប្រើប្រាស់បានច្រើន ។
- សូមឱ្យមានសំណងត្រឹមត្រូវទៅតាមតម្លៃនៃការខូចខាតទ្រព្យសម្បត្តិរបស់ពួកគាត់ជាក់ស្តែង កុំធ្វើឱ្យតែបាន ។

៦.៣.៤ ការពិគ្រោះយោបល់ជាមួយអាជ្ញាធរនៅឃុំដូនយ៉ាយ ស្រុកឈូក ខេត្តកំពត

នៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ វេលាម៉ោង១៥ និង០០នាទី នៅសាលាដូនយ៉ាយ ក្រុមការងារវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង បានជួបពិភាក្សា និងពិគ្រោះយោបល់ជាមួយអាជ្ញាធរមូលដ្ឋានចំនួនចំនួន ០៣រូប រួមមាន លោក **ហាស់ សំអឿន** ជាមេឃុំដូនយ៉ាយ លោក **ហ៊ុន សារិន** ក្រុមប្រឹក្សាឃុំ និងលោក **ស្វាយ ឡាយ** មេភូមិត្រពាំងកកោះ។ នៅក្នុងកិច្ចប្រជុំនេះ អាជ្ញាធរឃុំបានលើកឡើងជាយោបល់ពីមតិយោបល់ និងសំណូមពរ និងចំណាប់អារម្មណ៍ដូចខាងក្រោម។

- **សមាសភាពអ្នកចូលរួមពិភាក្សា** (សូមរូបថតក្នុងឧបសម្ព័ន្ធ)៖

  ១. លោក **ហាស់ សំអឿន** ជាមេឃុំដូនយ៉ាយ ស្រុកឈូក ខេត្តកំពត

Draft

២. លោក **ហ៊ុន សារិន** ជាក្រុមប្រឹក្សាឃុំដូនយ៉ុយ ស្រុកឈូក ខេត្តកំពត
៣. លោក **ស្វាយ លាយ** ជាមេភូមិត្រពាំងកកោះ ឃុំដូនយ៉ុយ ស្រុកឈូក ខេត្តកំពត
៤. កញ្ញា **ញិត ស្រីណា** ជាប្រជាជនដែលរស់នៅក្នុងឃុំដូនយ៉ុយ ស្រុកឈូក ខេត្តកំពត
៥. លោក **លឹម សុជាតិ** ជាបុគ្គលិកថែទាំ និងជួសជុលខ្សែកាប្លីអុបទិក
៦. លោក **ឆេង** ជាបុគ្គលិកថែទាំ និងជួសជុលខ្សែកាប្លីអុបទិក
៧. ក្រុមការងាររបស់ក្រុមហ៊ុនPPIC

- **អង្គប្រជុំខាងលើមានខ្លឹមសារទាំងមូលដូចខាងក្រោម៖**
  - អង្គប្រជុំបានលើកឡើងថា បានដឹងពីគម្រោងតាមរយៈរបស់ក្រុមហ៊ុន Cambodia Fiber Optic Cable Network Co., Ltd (CFOCN) នេះផ្ទាល់តាមរយៈសាលាស្រុក។
  - **មតិ សំណូមពរ និងចំណាប់អារម្មណ៍ធរភូមិឃុំ**

តាមមតិរបស់អាជ្ញាធរឃុំ ក្រោយពីបានពិភាក្សា និងពិគ្រោះយោបល់រួចមក បានឱ្យដឹងថា អាជ្ញាធរឃុំបានដឹងពី វត្តមានរបស់ក្រុមហ៊ុនបណ្តាញខ្សែកាប្លីអុបទិកកម្ពុជា (CFOCN) ដែលបានសាងសង់។ អាជ្ញាធរឃុំមិនមានការជំទាស់ទេ ដោយក្រុមប្រឹក្សាឃុំ-ភូមិបានធ្វើការពិភាក្សា ថាតើមានផលប៉ះពាល់ឬអត់? ក្រោយពីមានការ ទំនាក់ទំនងរបស់ក្រុមហ៊ុនជាមួយអាជ្ញាធរឃុំ-ភូមិ ក៏ដូចជាប្រជាជនឃើញថាមិនផលប៉ះពាល់ទេ ព្រោះការបង្កប់ខ្សែកាប្លីចូលទៅក្នុងដីមានជម្រៅប្រមាណ ១,២ម៉ែត្រ គឺមិនមានផលប៉ះពាល់សម្រាប់ការបង្កបង្កើនផលទេ។ ទោះបីមានការប៉ះទៅលើផ្ទះមួយកន្លែងដែលត្រូវកាត់ផ្លូវ ក្រុមហ៊ុនបានសម្របសម្រួលភ្លាមៗ និង បានបំពេញការខូចខាតឡើងវិញដែរ។ ចំពោះការប៉ះពាល់ពាក់ព័ន្ធរវាងក្រុមហ៊ុនខ្សែកាប្លីអុបទិក (CFOCN) និងឃុំដូនយ៉ុយ គឺការពាក់ព័ន្ធជាមួយ ដីស្រែ ដីចំការ ក៏ដូចជាដីលំនៅដ្ឋានរបស់ប្រជាជន។ ភូមិត្រពាំងកកោះ មានការពាក់ព័ន្ធជាមួយគម្រោង ខ្សែកាប្លីអុបទិកខាងលើលើដីស្រែ និងផ្លូវប្រវែង៥ គីឡូម៉ែត្រ។

  - **សំណូមពរផ្ទាល់អាជ្ញាធរឃុំ៖**

- សូមក្រុមហ៊ុនធ្វើការផ្សព្វផ្សាយដល់ប្រជាជនពីព័ត៌មាននៃការទំនាក់ទំនង អាចប្រើប្រាស់ប្រព័ន្ធខ្សែកាប្លីអុបទិកនេះបាន និងដាក់សេវាកម្មអោយប្រើប្រាស់កាន់តែឆាប់កាន់តែល្អ។
- សូមប្រាប់ពីតម្លៃនៃការប្រើប្រាស់សេវាខ្សែកាប្លីអុបទិកនេះ និងរបៀបទំនាក់ទំនងដើម្បីទទួលបានការប្រើប្រាស់ ។
- សូមឱ្យតម្លៃនៃការប្រើប្រាស់សេវាខ្សែកាប្លីអុបទិកមានតម្លៃថោកដើម្បីឱ្យប្រជាជនមានលទ្ធភាពប្រើប្រាស់បានច្រើន ។

៦.៣.៤ ការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋនៅភូមិត្រពាំងអណ្តូង ឃុំសត្វពង ស្រុកឈូក ខេត្តកំពត

នៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៥ វេលាម៉ោង១០ និង០០នាទី នៅភូមិត្រពាំងអណ្តូង ក្រុមការងារសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង បានជួបពិភាក្សា និងពិគ្រោះយោបល់ជាមួយលោក **ធូរ រឹម** អនុប្រធានភូមិ និងប្រជាពលរដ្ឋចំនួន ១០នាក់ (ដូចមានភ្ជាប់បញ្ជីវត្តមានក្នុងតារាងឧបសម្ព័ន្ធ) លើ

គម្រោងបញ្ចប់ការសាងសង់ខ្សែកាប្លឹអុបទិក(CFOCN) ។ ការប្រជុំនេះបានលើកឡើងជាមតិ និង សំណូមពរមួយចំនួនដូចខាងក្រោម៖

✎ មតិ និងសំណូមពររបស់ប្រជាជន

តាមមតិរួមរបស់ប្រជាជនការពិភាក្សា និងពិគ្រោះយោបល់នេះបានឱ្យដឹង ថា ប្រជាជនមិនបានដឹងអំពីវត្តមានរបស់ក្រុមហ៊ុនបណ្តាញខ្សែកាប្លឹអុបទិកកម្ពុជា (CFOCN) ដែលបាន សាងសង់រួចនៅក្នុងភូមិរបស់ពួកគាត់នោះទេ ចាប់តាំងពីក្រុមហ៊ុនមកវិនិយោគដំបូងរហូតមកដល់បច្ចុប្បន្ន ហើយក៏មិនដឹងអំពីសារៈប្រយោជន៍ដែរ។ ប៉ុន្តែពេលដែលក្រុមការងារវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និង សង្គមដំបូង បានធ្វើការបង្ហាញក៏ដូចជាពិគ្រោះយោបល់ប្រាប់ដល់ប្រជាជនដែលបានចូលរួម គឺពួកគាត់មិន មានការជំទាស់ជាមួយការអនុវត្តគម្រោងនាពេលកន្លងមកនោះទេ ទោះបីជាការដំណើរការនៃការសាងសង់ គម្រោងបានបញ្ចប់ទៅដោយធ្វើឱ្យដីស្រែរបស់គាត់មានការស្រុតនៅចំណុចខ្លះៗ នៅពេលដែលមានភ្លៀង ធ្លាក់រួចហើយពិបាកក្នុងការញ្ជូរនិងស្ទូងក៏ដោយ ព្រោះពួកគាត់យល់ឃើញថា គម្រោងសាងសង់ខ្សែកាប្លឹ អុបទិកនឹងធ្វើឱ្យមានការរីកចំរើន និងបង្កលក្ខណៈងាយស្រួលដល់ប្រជាជននៅតាមជនបទក្នុងការទំនាក់ទំនង ដឹងពីព័ត៌មាន និងសេវាផ្សេងៗជាច្រើន។ ការអនុវត្តនាពេលកន្លងមានការពាក់ព័ន្ធជាមួយដីស្រែ ដីចំការ ក៏ដូចជាដីលំនៅដ្ឋានរបស់ប្រជាជនថែមទៀតផង។

✎ មតិ និងសំណូមពររបស់ប្រជាជន

- សូមឱ្យក្រុមហ៊ុនធ្វើការជូនដំណឹងជាមុន មុននឹងធ្វើការសាងសង់បន្ថែមទៀត ។
- សូមឱ្យក្រុមហ៊ុនធ្វើការផ្សព្វផ្សាយដល់ប្រជាជនពីព័ត៌មានដែលអាចប្រើប្រាស់ប្រព័ន្ធខ្សែកាប្លឹអុបទិកនេះ។
- សូមឱ្យក្រុមហ៊ុនបង្ហាញពីតម្លៃសេវាប្រើប្រាស់ខ្សែកាប្លឹអុបទិកនេះ ហើយក៏សុំឱ្យមានតម្លៃសេវាពិសេសដល់ប្រជាជននៅតាមជនបទ ដោយធ្វើកំណត់ឱ្យទាបជាងប្រជាជនដែលរស់នៅតាមទីក្រុង។

៦.៣.៦ ការពិគ្រោះយោបល់ជាមួយអាជ្ញាធរមូលដ្ឋានស្រុកក្រូចឆ្មា ខេត្តត្បូងឃ្មុំ

នៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៥ វេលាម៉ោង១០និង០៨នាទី នៅសាលាស្រុកក្រូចឆ្មា ក្រុមការងារវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមដំបូង បានជួបពិភាក្សានិងពិគ្រោះយោបល់ជាមួយលោកស្រី **ប៊ុន សំណាង** អភិបាលរងស្រុកក្រូចឆ្មា និងលោក **យុត ឡាដែន** ប្រធានការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុស្រុកក្រូចឆ្មា លើគម្រោងសាងសង់ខ្សែកាប្លឹអ៊ុបអិក (CFOCN)។ ។ នៅក្នុងកិច្ចប្រជុំនេះ អាជ្ញាធរស្រុកក្រូចឆ្មារបានលើកឡើងពី មតិ យោបល់និងសំណូមពររបស់អាជ្ញាធរដូចខាងក្រោម ៖៖

លោកស្រីបានដឹងពីវត្តមាននៃការវិនិយោគរបស់ក្រុមហ៊ុនបណ្តាញខ្សែកាប្លឹអុបទិកកម្ពុជា(CFOCN) តាមរយៈការស្នើសុំពីក្រុមហ៊ុនផ្ទាល់ ដោយក្រុមហ៊ុនបណ្តាញខ្សែកាប្លឹអុបទិកកម្ពុជា(CFOCN) បានជូនដំណឹងមកសាលាស្រុក។ លោកស្រីយល់ឃើញថាការសុំពិភាក្សា និងពិគ្រោះយោបល់ របស់ក្រុមការងារវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមដំបូង ហាក់បីដូចជាមានការយឺតយ៉ាវ ដោយធ្វើការសិក្សាក្រោយពី

ដំណើរការនៃការសាងសង់នៅក្នុងស្រុកត្រូវបានបញ្ចប់ ប៉ុន្តែអាជ្ញាធរស្រុកយល់ឃើញថា បើមានការប៉ះពាល់គឺគម្រោង សាងសង់នេះ មិន អាច បញ្ចប់ បាន ទេ។ ទោះយ៉ាងណាអាជ្ញាធរស្រុកគាំទ្រ និងពេញចិត្តចំពោះគម្រោងវិនិយោគនេះដែលនាំឱ្យមានការរីកចំរើន ធ្វើឱ្យមានការងាយស្រួលដល់ប្រជាជននៅតាមជនបទក្នុងការទំនាក់ទំនង ដឹងពីព័ត៌មាន និងសេវាផ្សេងៗជាច្រើន ។

- **សមាសភាពអ្នកចូលរួមពិភាក្សា** (សូមរូបថតក្នុងឧបសម្ព័ន្ធទី)៖
  ១. លោក **ឃុត ឡាដែន** ជាប្រធានការិយាល័យរដ្ឋបាល ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម
  ២. ប៊ុន សំណាង ជាអភិបាលរងស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម
  ៣. លោក **កែ លាងហ៊ាត** ជាមេក្រុមបុគ្គលិកថែទាំ និងជួសជុលខ្សែកាប្លីអុបទិក
  ៤. លោក **លាង ហេងឡុង** ជាមេរងក្រុមបុគ្គលិកថែទាំ និងជួសជុលខ្សែកាប្លីអុបទិក
  ៥. ក្រុមការងាររបស់ក្រុមហ៊ុនPPIC
- **អង្គប្រជុំខាងលើមានខ្លឹមសារទាំងមូលដូចខាងក្រោម៖**
  - លោកបានមានប្រសាសន៍ថា លោកបានជ្រាបពីគម្រោងតាមរយៈរបស់ក្រុមហ៊ុន Cambodia Fiber Optic Cable Network Co., Ltd (CFOCN) នេះផ្ទាល់ដោយបង្ហាញលិខិតផ្លូវច្បាប់ពីរាជរដ្ឋាភិបាល។
  - **មតិផ្ទាល់អាជ្ញាធរស្រុកក្រូចឆ្មារ៖**
  - **សំណូមពរ**

– សូមឱ្យក្រុមហ៊ុនខ្សែកាប្លីអុបទិកជួយបំពេញបែបបទរដ្ឋបាល ក្នុងការទំនាក់ទំនងជាមួយអាជ្ញាធរស្រុក ឃុំ ភូមិ ឱ្យបានល្អគ្រប់បែបបទរដ្ឋបាលដែលមាន។
– សូមឱ្យក្រុមហ៊ុនធ្វើការផ្សព្វផ្សាយដល់ប្រជាជន និងអាជ្ញាធរមូលដ្ឋានឱ្យបានដឹងពីដំណើរការឱ្យបានច្បាស់ ដូចជាខិតប័ណ្ណផ្សព្វផ្សាយព័ត៌មាននៅតាមទីសាធារណៈ។

៦.៣.៧ ការពិគ្រោះយោបល់ជាមួយអាជ្ញាធរឃុំស្វាយឃ្លាំង ស្រុកក្រូចឆ្មា ខេត្តត្បូងឃ្មុំ

នៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៥ វេលាម៉ោង១០ និង៣០នាទី នៅសាលាឃុំស្វាយឃ្លាំង ក្រុមការងារ វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង បានជួបពិភាក្សានិងពិគ្រោះយោបល់ជាមួយលោក **កេង យូហ៊ិត** មេឃុំស្វាយឃ្លាំង និងលោក **ញ៉ុក ណៃ** ជំទប់ទី១ឃុំស្វាយឃ្លាំង លើគម្រោងសាងសង់ខ្សែកាប្លីអុបទិក (CFOCN) ។ ក្រោយពីបានជួបពិគ្រោះយោបល់រួចមក អាជ្ញាធរឃុំបានលើកឡើងដូចខាងក្រោម៖

- **សមាសភាពអ្នកចូលរួមពិភាក្សា** (សូមរូបថតក្នុងឧបសម្ព័ន្ធទី)៖
  ១. លោក កេង យូហ៊ិត ជាមេឃុំស្វាយឃ្លាំង ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ
  ២. ក្រុមការងាររបស់ក្រុមហ៊ុនPPIC
- **អង្គប្រជុំខាងលើមានខ្លឹមសារទាំងមូលដូចខាងក្រោម៖**

- អង្គប្រជុំបានលើកឡើងថា បានដឹងពីគម្រោងតាមរយៈរបស់ក្រុមហ៊ុន Cambodia Fiber Optic Cable Network Co., Ltd (CFOCN) នេះផ្ទាល់តាមរយៈសាលាស្រុក។

- **មតិ សំណូមពរ និងចំណាប់អារម្មណ៍ពីភូមិឃុំ**

តាមមតិលោកមេឃុំ ក៏ដូចជាក្រុមប្រឹក្សាឃុំទាំងមូលមិនបានដឹងពីដំណឹងនៃការវិនិយោគរបស់ក្រុមហ៊ុនខ្សែកាប្លី អុបទិក CFOCN នៅតំបន់របស់គាត់ទេ តែនៅដែលក្រុមហ៊ុនរៀបចំធ្វើការសាងសង់ខ្សែកាប្លី គឺក្រុមហ៊ុន មានលិខិតអនុញ្ញាតិជូនដល់សាលាឃុំ ផ្ទៃដីដែលមានការប៉ះពាល់នៅក្នុងឃុំទាំងមូល គឺប៉ះតែលើដីលំនៅដ្ឋាន ដីស្រែ ប៉ុន្តែអាជ្ញាធរឃុំឃើញថា ការសាងសង់របស់ក្រុមហ៊ុនមានការបង្កប់ខ្សែកាប្លីរួចហើយមិនបានធ្វើ ការលប់ដី ឬក៏ចាក់សាបនៅពីមុខផ្ទះរបស់ប្រជាជនឱ្យបានដូចសភាពដើមឡើយទេ។ ប៉ុន្តែទោះបីជាមានការ រំខានដល់ប្រជាជនបន្តិចបន្តួចក៏ដោយ ក៏អាជ្ញាធរឃុំនៅតែមានការឯកភាព និងគាំទ្រចំពោះគម្រោងទាំងមូល ព្រោះគម្រោងនេះនឹងធ្វើឱ្យមានការរីកចំរើន និងមានការងាយស្រួលក្នុងការប្រើប្រាស់ ។

- **សំណូមពរផ្ទាល់រងស់អាជ្ញាធរឃុំ**

  - សូមឱ្យការសាងសង់ធ្វើការចាក់បំពេញដីឡើងវិញឱ្យបានល្អ និងត្រូវជូនដំណឹងមកអាជ្ញាធរភូមិឃុំ ជាមុន ទើបប្រជាជនបានដឹងពីវត្តមាននៃការសាងសង់ ។
  - សូមឱ្យក្រុមហ៊ុនធ្វើការសាងសង់ឱ្យបានឆាប់រហ័ស និងឆាប់បានដំណើរការដាក់ឱ្យប្រជាជនបានប្រើប្រាស់ ។
  - សូមឱ្យក្រុមហ៊ុន (CFOCN) ធ្វើការផ្សព្វផ្សាយព័ត៌មាននៃការប្រើប្រាស់ និងសូមសំណូមពរអោយក្រុមហ៊ុនដាក់តំលៃប្រើប្រាស់អោយបានសមរម្យអោយប្រជាជនមានលទ្ធភាពប្រើប្រាស់។

៦.៣.៨ ការពិគ្រោះយោបល់ជាមួយប្រជាជននៅភូមិទី១ ដល់ភូមិទី៦ ឃុំស្វាយឃ្លាំង ស្រុកក្រូចឆ្មា ខេត្តត្បូងឃ្មុំ

នៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៥ វេលាម៉ោង១៤និង៣០នាទី នៅសាលាឃុំដូនយ៉ុយ ក្រុមការងារវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមដំបូង បានជួបពិភាក្សា និងពិគ្រោះយោបល់ជាមួយប្រជាជននៅភូមិទី១ ដល់ភូមិទី៦ ក្នុងឃុំស្វាយឃ្លាំង ព្រមទាំងមានការចូលពីមេភូមិផងដែរ (មានភ្ជាប់ជូនបញ្ជីវត្តមាននៅក្នុងតារាងឧបសម្ព័ន្ធទី...)។ ការប្រជុំនេះបានលើកឡើងជាមតិ និងសំណូមពរមួយចំនួនដូចខាងក្រោម៖

- **មតិ សំណូមពររបស់ប្រជាជន**

ការសាងសង់របស់ក្រុមហ៊ុនបានដំណើរការដល់ភូមិទី៣ ទើបប្រជាជនបានដឹងពីវត្តមាននៃការវិនិយោគរបស់ក្រុមហ៊ុនបណ្តាញខ្សែកាប្លីអុបទិកកម្ពុជា (CFOCN) ដែលបានសាងសង់កន្លងមក នៅក្នុងភូមិរបស់ពួកគាត់នោះ។ ប៉ុន្តែប្រជាជនក្នុងភូមិដែលខ្សែកាប្លីបានឆ្លងកាត់នោះ គឺពួកគាត់មិនបានដឹងពីសារៈប្រយោជន៍នៃខ្សែកាប្លីអុបទិកទេ។ ពួកគាត់មិនមានការជំទាស់ទេ ទោះបីជាការដំណើរការនៃការសាងសង់គម្រោងបានបញ្ចប់ទៅដោយធ្វើឱ្យមានការខូចខាតដល់ដីលំនៅដ្ឋានរបស់ពួកគាត់ខ្លះៗក៏ដោយ មានការស្រុតនៅចំណុចខ្លះៗនៅពេលដែលមានភ្លៀងធ្លាក់រួច ។ ប្រជាជនមានការគាំទ្រ និងពេញចិត្តចំពោះគម្រោងសាងសង់ខ្សែកាប្លីអុបទិកព្រោះបានធ្វើឱ្យមានការរីកចំរើន ធ្វើឱ្យមានការងាយស្រួលដល់ប្រជាជននៅតាមជនបទ ក្នុងការទំនាក់ទំនង ដឹងពីព័ត៌មាន និងសេវាផ្សេងៗជាច្រើន ។

- **សំណូមពរផ្ទាល់របស់ប្រជាពលរដ្ឋ៖**

– សូមអោយមានការផ្តល់ដំណឹងជាមុន មុននឹងធ្វើការសាងសង់ និងមានការលប់ដីអោយបានល្អ ដូចដើមពេលចប់ការសាងសង់
– សូមអោយដំណើរការសេវាកម្មអោយបានឆាប់រហ័ស
– សូមឱ្យក្រុមហ៊ុន(CFOCN)ធ្វើការផ្សព្វផ្សាយព័ត៌មាននៃការប្រើប្រាស់ និងសូមឱ្យតម្លៃសេវាកម្មមានតម្លៃថោកសមរម្យដែលប្រជាជនអាចប្រើប្រាស់បាន ។

៦.៣.៩ ការពិគ្រោះយោបល់ជាមួយអាជ្ញាធរមូលដ្ឋានស្រុកសណ្តាន់ ខេត្តកំពង់ធំ

នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៥ វេលាម៉ោង១០ និង២០នាទី នៅសាលាស្រុកសណ្តាន់ ក្រុមការងារ វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង បានជួបពិភាក្សានិងពិគ្រោះយោបល់ជាមួយលោក **ប៉ែន កិន** ប្រធានក្រុមប្រឹក្សាស្រុក លើគម្រោងបញ្ចប់ការសាងសង់ខ្សែកាប្លីអ៊ុបអិក(CFOCN)។ នៅក្នុងកិច្ចប្រជុំនេះ អាជ្ញាធរស្រុកសណ្តាន់បានលើកឡើងពី មតិ យោបល់និងសំណូមពររបស់អាជ្ញាធរដូចខាងក្រោម ៖

លោកបានដឹងពីវត្តមាន នៃការវិនិយោគរបស់ក្រុមហ៊ុនបណ្តាញខ្សែកាប្លីអុបទិកកម្ពុជា (CFOCN) តាមរយៈក្រុមហ៊ុនផ្ទាល់ ដោយក្រុមហ៊ុនបណ្តាញខ្សែកាប្លីអុបទិកកម្ពុជា (CFOCN) បានជូនដំណឹងមកសាលាស្រុកពីការវិនិយោគ និងសុំការអនុញ្ញាតសាងសង់បណ្តាញខ្សែកាប្លីនេះ។ ដោយពិនិត្យឃើញថា ការវិនិយោគលើបណ្តាញខ្សែកាប្លីនេះ វាធ្វើឱ្យមានការរីកចំរើនច្រើនជាងផលប៉ះពាល់ដែលបានកើតមាននាពេលកន្លងមក ហើយភាគីក្រុមហ៊ុនបានធ្វើការសម្រួល និងជួសជុលឡើងវិញលើចំណុចដែលបានប៉ះពាល់ជាមួយប្រជាជនរួចរាល់ផងដែរ។ អាជ្ញាធរស្រុកសូមគាំទ្រ និងពេញចិត្ត ចំពោះគម្រោងវិនិយោគនេះដែលនាំឱ្យមានការរីកចំរើន ធ្វើឱ្យមានការងាយស្រួលដល់ប្រជាជននៅតាមជនបទក្នុងការទំនាក់ទំនង ដឹងពីព័ត៌មាន និងសេវាផ្សេងៗជាច្រើន ។

- **សមាសភាពអ្នកចូលរួមពិភាក្សា** (សូមរូបថតក្នុងឧបសម្ព័ន្ធទី)៖

  ១. លោក **ប៉ែន និន** ជាប្រធានក្រុមប្រឹក្សាស្រុកសណ្តាន់ ខេត្តកំពង់ធំ

  ២. ក្រុមការងាររបស់ក្រុមហ៊ុនPPIC

- **អង្គប្រជុំខាងលើមានខ្លឹមសារទាំងមូលដូចខាងក្រោម៖**

  ↳ លោកបានមានប្រសាសន៍ថា បានជ្រាបពីគម្រោងតាមរយៈរបស់ក្រុមហ៊ុន Cambodia Fiber Optic Cable Network Co., Ltd (CFOCN) នេះផ្ទាល់ដោយបង្ហាញលិខិតផ្លូវច្បាប់ពីរាជរដ្ឋាភិបាល។

  ↳ សំណូមពរ

– សូមអោយដំណើរការសេវាកម្មខ្សែកាប្លីអុបទិកអោយបានឆាប់រហ័សប្រើប្រាស់
– សូមឱ្យក្រុមហ៊ុនធ្វើការផ្សព្វផ្សាយដល់ប្រជាជន និងអាជ្ញាធរមូលដ្ឋានឱ្យបានដឹងពីដំណើរការឱ្យបានច្បាស់ដូចជាខិតប័ណ្ណផ្សព្វផ្សាយព័ត៌មាននៅតាមទីសាធារណៈ ។

- សុំឱ្យតម្លៃសមរម្យទៅលើសេវាកម្មដែលនឹងត្រូវដាក់លក់ ទៅតាមជីវភាព ប្រជាជន អាចទិញសេវាប្រើប្រាស់បាន ។

៦.៣.១០ ការពិគ្រោះយោបល់ជាមួយអាជ្ញាធរឃុំសណ្តាន់ ស្រុកសណ្តាន់ ខេត្តកំពង់ធំ

នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៥ វេលាម៉ោង១០ និង៤០នាទី នៅសាលាឃុំសណ្តាន់ ក្រុមការងារវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង បានជួបពិភាក្សា និងពិគ្រោះយោបល់ជាមួយលោក **បាន ហេង** មេឃុំសណ្តាន់ និងលោក **ហេង សុខឿន** ស្មៀនឃុំ លើគម្រោងបញ្ចប់ការសាងសង់ខ្សែកាប្លីអុបអិក (CFOCN) ។ នៅក្នុងកិច្ចប្រជុំនេះ អាជ្ញាធរឃុំបានលើកឡើងជាយោបល់ពីមតិយោបល់ និងសំណូមពរ និងចំណាប់អារម្មណ៍ដូចខាងក្រោម៖

- **សមាសភាពអ្នកចូលរួមពិភាក្សា** (សូមរូបថតក្នុងឧបសម្ព័ន្ធ)៖
  - ១. លោក **បាន ហេង ជាមេឃុំសណ្តាន់ ស្រុកសណ្តាន់ ខេត្តកំពង់ធំ**
  - **២. លោក ហេង សុខឿន ជាស្មៀនឃុំសណ្តាន់ ស្រុកសណ្តាន់ ខេត្តកំពង់ធំ**
  - ២. លោក **ហ៊ា សុផល** ជាបុគ្គលិកថែទាំ និងជួសជុលខ្សែកាប្លីអុបទិក
  - ៣. លោក **ឌី សុធារិទ្ធ** ជាបុគ្គលិកថែទាំ និងជួសជុលខ្សែកាប្លីអុបទិក
  - ៤. សៀង ប៊ុនរ៉ុង ជាបុគ្គលិកថែទាំ និងជួសជុលខ្សែកាប្លីអុបទិក
  - ៥. ម៉ែ សេងថៃ ជាបុគ្គលិកថែទាំ និងជួសជុលខ្សែកាប្លីអុបទិក
  - ៦. ក្រុមការងាររបស់ក្រុមហ៊ុនPPIC
- **អង្គប្រជុំខាងលើមានខ្លឹមសារទាំងមូលដូចខាងក្រោម៖**
  - ✍ អង្គប្រជុំបានលើកឡើងថា បានដឹងពីគម្រោងតាមរយៈរបស់ក្រុមហ៊ុន Cambodia Fiber Optic Cable Network Co., Ltd (CFOCN) នេះផ្ទាល់តាមរយៈសាលាស្រុក។
  - ✍ **មតិ សំណូមពរ និងចំណាប់អារម្មណ៍ធរភូមិឃុំសណ្តាន់ ស្រុកសណ្តាន់ ខេត្តកំពង់ធំ**

តាមមតិលោកមេឃុំ ក៏ដូចជាក្រុមប្រឹក្សាឃុំទាំងអស់បានដឹងពីដំណឹងនៃការវិនិយោគរបស់ក្រុមហ៊ុនខ្សែកាប្លីអុបទិក (CFOCN) នៅតំបន់របស់គាត់ តាមរយៈសាលាខេត្ត សាលាស្រុកបានជូនដំណឹងមកសាលាឃុំ ហើយឃុំក៏បានជូនដំណឹងដល់ប្រជាជនក្នុងភូមិនៅពេលដែលក្រុមហ៊ុនបានមកប្រាប់ពីការចាប់ផ្តើមដំណើរ។ ការសាងសង់ នេះបានធ្វើឱ្យប៉ះពាល់ដល់ដីស្រែ និងដីលំនៅដ្ឋានដែលការសាងសង់នេះកាត់ស្រែរបស់ពួកគាត់នៅរដូវប្រាំងមិនមានការធ្វើស្រែទេ។ ជារួមអាជ្ញាធរឃុំយល់ឃើញថា ការរំខានដល់ប្រជាជនបន្តិចបន្តួចវាតែងតែកើតមាននៅពេលដែលមានការអភិវឌ្ឍន៍។ អាជ្ញាធរឃុំនៅតែមានការឯកភាព និងគាំទ្រចំពោះគម្រោងនេះព្រោះថាធ្វើឱ្យមានការរីកចំរើន និងមានការងាយស្រួលក្នុងការប្រើប្រាស់ ។

✍ សំណូមពរផ្ទាល់អាជ្ញាធរឃុំសណ្តាន់៖

- សូមឱ្យក្រុមហ៊ុនធ្វើការសម្របសម្រួលជាមួយប្រជាជនភ្លាមៗនៅពេលដែលមានការសាង់សង់បន្តទៀត

- សូមឱ្យក្រុមហ៊ុន (CFOCN) ធ្វើការផ្សព្វផ្សាយព័ត៌មាននៃការប្រើប្រាស់ និងសូមតម្លៃសេវាកម្មមានតម្លៃថោកសមរម្យដែលប្រជាជនអាចប្រើប្រាស់បាន ។

៦.៣.១១ ការពិគ្រោះយោបល់ជាមួយប្រជាជននៅភូមិសណ្តាន់ ឃុំសណ្តាន់ ស្រុកសណ្តាន់ ខេត្តកំពង់ធំ

នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៥ វេលាម៉ោង១៣ និង៤៥នាទី នៅផ្ទះលោកមេភូមិសណ្តាន់ ក្រុមការងារវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង បានជួបពិភាក្សា និងពិគ្រោះយោបល់ជាមួយលោក **អ៊ុង ចន** មេភូមិសណ្តាន់ លោក **យ៉ាន វល់ក្ន** អនុប្រធានភូមិ និងមានការចូលរួមពីប្រជាពលរដ្ឋចំនួន ០៨នាក់(មានបញ្ជីវត្តមានភ្ជាប់ជូនក្នុងតារាងឧបសម្ព័ន្ធ) លើគម្រោងបញ្ចប់ការសាងសង់ខ្សែកាប្លីអុបអិក។ ការប្រជុំនេះបានលើកឡើងជាមតិ និង សំណូមពរមួយចំនួនដូចខាងក្រោម៖

↳ មតិ សំណូមពររបស់ប្រជាជន

ប្រជាជននៅក្នុងភូមិមិនបានដឹងពីវត្តនៃការវិនិយោគរបស់ក្រុមហ៊ុនខ្សែកាប្លីអុបទិក (CFOCN) ដែលបានសាងសង់នាពេលកន្លងមកទេ ហើយពួកគាត់ក៏មិនបានដឹងពីសារៈប្រយោជន៍នៃខ្សែកាប្លីអុបទិកនេះទេ។ ប៉ុន្តែ ពួកគាត់មិនមានការជំទាស់ទេ ទោះបីជាការដំណើរការនៃការសាងសង់គម្រោងបានបញ្ចប់ទៅដោយធ្វើឱ្យមានការខូចខាតដល់ដីស្រែរបស់ពួកគាត់ជាច្រើនកន្លែងក៏ដោយ និងដីលំនៅដ្ឋានដែលខ្សែកាប្លីបានកប់កាត់ធ្វើឱ្យមានការស្រុតនៅចំណុចខ្លះៗនៅពេលដែលមានភ្លៀងធ្លាក់រួច។ ពួកគាត់គាំទ្រ និងពេញចិត្តចំពោះគម្រោងសាងសង់ខ្សែកាប្លីអុបទិក ព្រោះនឹងធ្វើឱ្យមានការរីកចំរើន ធ្វើឱ្យមានការងាយស្រួលដល់ប្រជាជននៅតាមជនបទក្នុងការទំនាក់ទំនង ដឹងពីព័ត៌មាន និងសេវាផ្សេងៗជាច្រើន ។

↳ សំណូមពរផ្ទាល់របស់ប្រជាពលរដ្ឋ៖

- សូមឱ្យក្រុមហ៊ុនធ្វើការសាងសង់ឱ្យបានឆាប់រហ័ស និងឆាប់បានដំណើរការដាក់ឱ្យប្រជាជនបានប្រើប្រាស់

៦.៣.១២ ការពិគ្រោះយោបល់ជាមួយអាជ្ញាធរឃុំមានរិទ្ធ ស្រុកសណ្តាន់ ខេត្តកំពង់ធំ

នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៥ វេលាម៉ោង១១ និង៤០នាទី នៅសាលាឃុំមានរិទ្ធ ក្រុមការងារវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង បានជួបពិភាក្សា និងពិគ្រោះយោបល់ជាមួយលោក **ស្រី សៀក** ជំទប់ទី១ ឃុំមានរិទ្ធ និងលោក **ឡោ ម៉ែងលាង** ស្មៀនឃុំមានរិទ្ធ លើគម្រោងបញ្ចប់ការសាងសង់ខ្សែកាប្លីអុបអិក(CFOCN)។ នៅក្នុងកិច្ចប្រជុំនេះលោកជំទប់ឃុំ និងស្មៀនឃុំ បានមតិដូចខាងក្រោម៖

- **សមាសភាពអ្នកចូលរួមពិភាក្សា** (សូមរូបថតក្នុងឧបសម្ព័ន្ធ)៖
  ១. លោក **ស្រី សៀក** ជាមេឃុំមានរិទ្ធ ស្រុកសណ្តាន់ ខេត្តកំពង់ធំ
  ២. លោក **ឡោ ម៉ែងលាន ជាស្មៀនឃុំមានរិទ្ធ ស្រុកសណ្តាន់ ខេត្តកំពង់ធំ**
  ៣. ក្រុមការងាររបស់ក្រុមហ៊ុនPPIC
- **អង្គប្រជុំខាងលើមានខ្លឹមសារទាំងមូលដូចខាងក្រោម៖**

- អង្គប្រជុំបានលើកឡើងថា បានដឹងពីគម្រោងតាមរយៈរបស់ក្រុមហ៊ុន Cambodia Fiber Optic Cable Network Co., Ltd (CFOCN) នេះផ្ទាល់តាមរយៈសាលាស្រុក។

- **មតិ សំណូមពរ និងចំណាប់អារម្មណ៍ឃុំមានរិទ្ធ**

តាមមតិអាជ្ញាធរឃុំបានដឹងពីដំណឹងនៃការវិនិយោគរបស់ក្រុមហ៊ុនខ្សែកាប្លីអុបទិក (CFOCN) នៅតំបន់របស់គាត់តាមរយៈសាលាស្រុក ហើយនៅពេលដែលចាប់ផ្តើមសាងសង់ក្រុមហ៊ុនក៏បានជូនដំណឹងមកសាលាឃុំ ម្តងទៀតដែរ។ ផ្ទៃដីដែលមានការប៉ះពាល់នៅក្នុងឃុំទាំងមូល គឺដីស្រែ ដីលំនៅដ្ឋាន និងដីចំការ ហើយផលប៉ះពាល់ដែលកើតមាននៅពេលសាងសង់មិនសូវមានទេ ដោយសារការសាងសង់កាត់ស្រែរបស់ពួកគាត់នៅរដូវប្រាំងមិនមានការធ្វើស្រែទេ ហើយដីលំនៅដ្ឋានដីចំការមិនមានផលប៉ះពាល់ទេ។ អាជ្ញាធរឃុំមានការឯកភាព និងគាំទ្រចំពោះគម្រោងព្រោះគម្រោងនេះធ្វើឱ្យមានការរីកចំរើន មានការអភិវឌ្ឍន៍និងមានភាពងាយស្រួលក្នុងការប្រើប្រាស់ ។

- សំណូមពរផ្ទាល់របស់អាជ្ញាធរឃុំ

- សូមអោយការដំឡើងសេវាកម្មមានភាពឆាប់រហ័សបានប្រើប្រាស់។
- សូមអោយមានការផ្សព្វផ្សាយពីគុណសម្បត្តិរបស់ខ្សែកាប្លីអុបទិកទៅកាន់ប្រជាពលរដ្ឋ ក៏ដូចជារដ្ឋអំណាចមូលដ្ឋាន
- សូមឱ្យក្រុមហ៊ុន (CFOCN) ធ្វើការផ្សព្វផ្សាយព័ត៌មាននៃការប្រើប្រាស់ និងសូមឱ្យតម្លៃសេវាកម្មមានតម្លៃថោកសមរម្យដែលប្រជាជនអាចប្រើប្រាស់បាន។

៦.៣.១៣ ការពិគ្រោះយោបល់ជាមួយប្រជាជននៅភូមិត្បូងទឹក ឃុំមានរិទ្ធ ស្រុកសណ្តាន់ ខេត្តកំពង់ធំ

នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៥ វេលាម៉ោង១៤ និង៤០នាទី នៅផ្ទះលោកមេភូមិត្បូងទឹក ក្រុមការងារវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង បានជួបពិភាក្សា និងពិគ្រោះយោបល់ជាមួយលោក **នូ ចាង** មេភូមិត្បូងទឹក និងប្រជាជនចំនួន ២០នាក់(មានភ្ជាប់បញ្ជីវត្តមានក្នុងតារាង៤សម្ព័ន្ធទី....) លើគម្រោងបញ្ចប់ការសាងសង់ខ្សែកាប្លីអុបទិក(CFOCN)។ ការប្រជុំនេះបានលើកឡើងជាមតិ និងសំណូមពរមួយចំនួនដូចខាងក្រោម៖

- **មតិ និងសំណូមពររបស់ប្រជាជន**

ប្រជាជននៅក្នុងភូមិទាំងអស់ មិនបានដឹងពីវត្តមាននៃការវិនិយោគរបស់ក្រុមហ៊ុនខ្សែកាប្លីអុបទិក (CFOCN) ដែលបានសាងសង់កន្លងមកនៅក្នុងភូមិរបស់ពួកគាត់ទេ ហើយពួកគាត់ក៏មិនបានដឹងអំពីសារៈប្រយោជន៍នៃខ្សែកាប្លីអុបទិកនេះដែរ។ ពួកគាត់មិនមានការដំទាស់ទេ ទោះបីជាដំណើរការសាងសង់របស់គម្រោងបានបញ្ចប់ទៅដោយធ្វើឱ្យមានការខូចខាតដល់ដីស្រែរបស់ពួកគាត់ជាច្រើនកន្លែងក៏ដោយ និងដីលំនៅដ្ឋានដែលខ្សែកាប្លីបានកប់កាត់ធ្វើឱ្យមានការស្រុតនៅចំណុចខ្លះៗនៅពេលដែលមានភ្លៀងធ្លាក់រួច។ ប្រជាជនមានការគាំទ្រ និងពេញចិត្តចំពោះគម្រោងសាងសង់ខ្សែកាប្លីអុបទិកព្រោះបានធ្វើឱ្យមានការរីកចំរើន ធ្វើឱ្យមានការងាយស្រួលដល់ប្រជាជននៅតាមជនបទក្នុងការទំនាក់ទំនង ដឹងពីព័ត៌មាន និងសេវាផ្សេងៗជាច្រើន។

↳ មតិ និងសំណូមពររបស់ប្រជាជន

- សូមឱ្យក្រុមហ៊ុនធ្វើការសាងសង់ឱ្យបានឆាប់រហ័ស និងឆាប់បានដំណើរការដាក់ឱ្យប្រជាជនបានប្រើប្រាស់

៦.៣.១៤ ការពិគ្រោះយោបល់ជាមួយអាជ្ញាធរមូលដ្ឋាន ស្រុកពារាំង ខេត្តព្រៃវែង

នៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៥ វេលាម៉ោង០៨ និង២០នាទី នៅសាលាស្រុកពារាំង ក្រុមការងារវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង បានជួបពិភាក្សា និងពិគ្រោះយោបល់ជាមួយលោក **ហ៊ី ធួក** អភិបាលស្រុក លើគម្រោងកំពុងសាងសង់ខ្សែកាប្លីអុបទិក(CFOCN) ។ នៅក្នុងកិច្ចប្រជុំនេះ អាជ្ញាធរស្រុកក្រូចឆ្មារបានលើកឡើងពី មតិ យោបល់និងសំណូមពររបស់អាជ្ញាធរដូចខាងក្រោម៖

អាជ្ញាធរស្រុកពារាំងបានដឹងពីវត្តមាន នៃការវិនិយោគរបស់ក្រុមហ៊ុនបណ្តាញខ្សែកាប្លីអុបទិកកម្ពុជា (CFOCN) តាមរយៈក្រុមហ៊ុនផ្ទាល់ ដោយក្រុមហ៊ុនបានជូនដំណឹងមកសាលាស្រុកពីការវិនិយោគ និងការសុំការអនុញ្ញាតសាងសង់កប់បណ្តាញខ្សែកាប្លី។ អាជ្ញាធរស្រុកយល់ឃើញថា ការវិនិយោគលើបណ្តាញខ្សែកាប្លីនេះវានឹងធ្វើឱ្យមានការរីកចំរើនច្រើនជាងផលប៉ះពាល់ដែលបានកើតមានកន្លងមក ដោយភាគីក្រុមហ៊ុនបានធ្វើការសម្រួល និងបានជួសជុលឡើងវិញទៅលើចំណុចដែលបានប៉ះពាល់ជាមួយប្រជាជនរួចរាល់ផងដែរ។ អាជ្ញាធរស្រុកសូមគាំទ្រ និងពេញចិត្ត ចំពោះគម្រោងវិនិយោគនេះដែលនាំឱ្យមានការរីកចំរើន ធ្វើឱ្យមានការងាយស្រួលដល់ប្រជាជននៅតាមជនបទក្នុងការទំនាក់ទំនង ដឹងពីព័ត៌មាន និងសេវាផ្សេងៗ។

- **សមាសភាពអ្នកចូលរួមពិភាក្សា** (សូមរូបថតក្នុងឧបសម្ព័ន្ធទី)៖
  ១. លោក **ហ៊ី ធួក** ជាអភិបាលស្រុកពារាំង ខេត្តព្រៃវែង
  ២. លោក **អ៊ុច សយ** ជាមេឃុំពពិល ស្រុកពារាំង ខេត្តព្រៃវែង
  ៣. ក្រុមការងាររបស់ក្រុមហ៊ុនPPIC
- **អង្គប្រជុំខាងលើមានខ្លឹមសារទាំងមូលដូចខាងក្រោម៖**
  ↳ លោកបានមានប្រសាសន៍ថា បានជ្រាបពីគម្រោងតាមរយៈរបស់ក្រុមហ៊ុន Cambodia Fiber Optic Cable Network Co., Ltd (CFOCN) នេះផ្ទាល់ដោយបង្ហាញលិខិតផ្លូវច្បាប់ពីរាជរដ្ឋាភិបាល។
  ↳ សំណូមពរ

- សូមឱ្យក្រុមហ៊ុនជួយបំពេញបែបបទរដ្ឋបាល ក្នុងការទំនាក់ទំនងជាមួយអាជ្ញាធរ ស្រុក ឃុំ ភូមិ ក៏ដូចជាអាជ្ញាធរជំនាញ ដើម្បីឱ្យដំណើរការការងារមានភាពរលូន និងបានល្អ ។
- សូមឱ្យចុះត្រួតពិនិត្យតំបន់ដែលបានកប់ខ្សែកាប្លីរួចឱ្យបានញឹកញាប់ ដើម្បីឱ្យមានភាពងាយស្រួលក្នុងការកាត់បន្ថយផលប៉ះពាល់ដែលកើតមានឡើងដាយថាហេតុ ។

៦.៣.១៥ ការពិគ្រោះយោបល់ជាមួយអាជ្ញាធរឃុំកំពង់ពពិល ស្រុកពារាំង ខេត្តព្រៃវែង

នៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៥ វេលាម៉ោង០៩ និង៤០នាទី នៅសាលាឃុំកំពង់ពពិល ក្រុមការងារវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង បានជួបពិភាក្សា និងពិគ្រោះយោបល់ជាមួយលោក **អ៊ុច សយ** មេឃុំកំពង់ពពិល លើគម្រោងកំពុងសាងសង់ខ្សែកាប្លីអ៊ុបអិក (CFOCN) ។ នៅក្នុងកិច្ចប្រជុំនេះ អាជ្ញាធរឃុំបានលើកឡើងជាយោបល់ពីមតិយោបល់ និងសំណូមពរ និងចំណាប់អារម្មណ៍ដូចខាងក្រោម៖

- **សមាសភាពអ្នកចូលរួមពិភាក្សា** (សូមរួបថតក្នុងឧបសម្ព័ន្ធទី ??)៖
  ១. លោក **អ៊ុច សយ ជាមេឃុំកំពង់ពពិល ស្រុកពារាំង ខេត្តព្រៃវែង**
  ២. ក្រុមការងាររបស់ក្រុមហ៊ុនPPIC
- **អង្គប្រជុំខាងលើមានខ្លឹមសារទាំងមូលដូចខាងក្រោម៖**
  - អង្គប្រជុំបានលើកឡើងថា បានដឹងពីគម្រោងតាមរយៈរបស់ក្រុមហ៊ុន Cambodia Fiber Optic Cable Network Co., Ltd (CFOCN) នេះផ្ទាល់តាមរយៈសាលាស្រុក។
  - **មតិ សំណូមពរ និងចំណាប់អារម្មណ៍ធរភូមិឃុំកំពង់ពពិល**

ឃុំបានដឹងពីដំណឹងនៃការវិនិយោគរបស់ក្រុមហ៊ុនខ្សែកាប្លីអុបទិក (CFOCN) នៅតំបន់របស់គាត់តាមរយៈក្រុមហ៊ុន ហើយនៅពេលដែលចាប់ផ្តើមសាងសង់ក្រុមហ៊ុនក៏បានជូនដំណឹងមកសាលាឃុំម្តងទៀតដែរ។ ផ្ទៃដីដែលមានការប៉ះពាល់នៅក្នុងឃុំគឺ ដីស្រែស្ទើតែ៩០% និងមានដីលំនៅដ្ឋានតិចតួច ហើយផលប៉ះពាល់ដែលកើតមាននៅពេលសាងសង់នៅតាមមុខផ្ទះរបស់ប្រជាជនគឺមិនមានបញ្ហាទេ។ អាជ្ញាធរឃុំសូមឯកភាព និងគាំទ្រចំពោះគម្រោង ព្រោះគម្រោងនេះធ្វើឱ្យមានការរីកចំរើន មានការអភិវឌ្ឍន៍ និងមានការងាយស្រួលក្នុងការប្រើប្រាស់ ។

- **សំណូមពរផ្ទាល់អាជ្ញាធរឃុំ៖**

– សូមឱ្យក្រុមហ៊ុនផ្សព្វផ្សាយពីផលប៉ះពាល់នៃការកប់ខ្សែកាប
– សូមឱ្យចុះត្រួតពិនិត្យតំបន់ដែលបានកប់ខ្សែកាបរួចឱ្យបានញឹកញាប់ជៀសវៀងមានហេតុការណ៍កើតឡើងដាយថាហេតុ

៦.៣.១៦ ការពិគ្រោះយោបល់ជាមួយប្រជាជននៅភូមិកំពង់ពពិល ឃុំកំពង់ពពិល ស្រុកពារាំង ខេត្តព្រៃវែង

នៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៥ វេលាម៉ោង១០និង៣០នាទី នៅភូមិកំពង់ពពិល ក្រុមការងារវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង បានជួបពិភាក្សា និងពិគ្រោះយោបល់ជាមួយលោក ..... ជាមេភូមិកំពង់ពពិល និងប្រជាជនចំនួន ០៦នាក់ (មានភ្ជាប់ជូនបញ្ជីវត្តមានក្នុងតារាងឧបសម្ព័ន្ធទី...) លើគម្រោងបញ្ចប់ការសាងសង់ខ្សែកាប្លីអុបអិក (CFOCN)។ ការប្រជុំនេះបានលើកឡើងជាមតិ និងសំណូមពរមួយចំនួនដូចខាងក្រោម៖

↳ មតិ និងសំណូមពររបស់ប្រជាជន

តាមមតិរួមរបស់ប្រជាជននៅក្នុងភូមិមិនបានដឹងពីវត្តមាននៃការវិនិយោគរបស់ ក្រុមហ៊ុនខ្សែកាប្លីអុបទិក (CFOCN) ដែលបានបញ្ចប់ការសាងសង់នោះទេ ហើយមិនបានដឹងពីសារៈប្រយោជន៍នៃខ្សែកាប្លីអុបទិកនេះដែរ។ ពួកគាត់មិនមានការជំទាស់ទេ ព្រោះការសាងសង់បានបញ្ចប់ទៅយូរឆ្នាំហើយ និងមិនឃើញមានផលប៉ះពាល់អ្វីនោះទេ បន្ទាប់ពីបញ្ចប់ការសាងសង់នេះ។ ប្រជាជនបានគាំទ្រ និងពេញចិត្តចំពោះគម្រោងសាងសង់ខ្សែកាប្លីអុបទិកព្រោះគម្រោងនេះ នឹងធ្វើឱ្យមានការរីកចំរើនធ្វើឱ្យមានការងាយស្រួលដល់ប្រជាជននៅតាមជនបទក្នុងការទំនាក់ទំន ដឹងពីព័ត៌មាន និងសេវាផ្សេងៗជាច្រើន ។

↳ មតិ និងសំណូមពររបស់ប្រជាជន

- សូមឱ្យក្រុមហ៊ុនធ្វើការផ្សព្វផ្សាយពីពត៌មានគុណសម្បត្តិ និងគុណវិបត្តិនៃការវិនិយោគ ដើម្បីឱ្យប្រជាជនមានការទុកចិត្តចំពោះគម្រោងវិនិយោគនេះ ។
- សូមឱ្យក្រុមហ៊ុនមានការផ្សព្វផ្សាយពីព័ត៌មាននៃការប្រើប្រាស់ដល់ប្រជាជន

៦.៣.១៧ ការពិគ្រោះយោបល់ជាមួយអាជ្ញាធរមូលដ្ឋានស្រុកក្រគរ ខេត្តពោធិ៍សាត់

នៅថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៥ វេលាម៉ោង១០ និង០០នាទី នៅសាលាស្រុកក្រគរ ក្រុមការងារវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង បានជួបពិភាក្សា និងពិគ្រោះយោបល់ជាមួយ លោក **ញ៉ែម ហុង** អភិបាលរងស្រុក និងលោកស្រី **សុិន សៅរ៉ែន** អនុប្រធានអង្គភាពលទ្ធកម្មស្រុក លើគម្រោងកំពុងសាងសង់ខ្សែកាប្លីអ៊ុបអិក(CFOCN)។ នៅក្នុងកិច្ចប្រជុំនេះលោកនាយកបានលើកឡើងពីមតិយោបល់ និងសំណូមពររបស់អាជ្ញាធរដូចខាងក្រោមដូចខាងក្រោម៖

សាលាស្រុកបានដឹងពីវត្តមាននៃការវិនិយោគរបស់ក្រុមហ៊ុនបណ្តាញខ្សែកាប្លីអុបទិកកម្ពុជា(CFOCN) តាមរយៈការជូនដំណឹង និងសុំការអនុញ្ញាតពីក្រុមហ៊ុនផ្ទាល់។ ហើយក្រុមហ៊ុនបានជូនដំណឹងមកសាលាស្រុកពីការវិនិយោគ និងសុំការអនុញ្ញាតការសាងសង់បង្កប់បណ្តាញខ្សែកាប្លី។ អាជ្ញាធរស្រុកពិនិត្យឃើញថា ការវិនិយោគលើបណ្តាញខ្សែកាប្លីនេះវានឹងធ្វើឱ្យមានការរីកចំរើនច្រើនជាងផលប៉ះពាល់ដែលបានកើតមានកន្លងមក ដោយភាគីក្រុមហ៊ុនបានធ្វើការសម្រួល និងជួសជុលទៅលើចំណុចដែលបានប៉ះពាល់ជាមួយប្រជាជនរួចរាល់ផងដែរ។ អាជ្ញាធរស្រុកសូមគាំទ្រ និងពេញចិត្តចំពោះគម្រោងវិនិយោគនេះដែលនាំឱ្យមានការរីកចំរើនធ្វើឱ្យមានការងាយស្រួលដល់ប្រជាជននៅតាមជនបទក្នុងការទំនាក់ទំនង ដឹងពីព័ត៌មាន និងសេវាផ្សេងៗជាច្រើន ។

- **សមាសភាពអ្នកចូលរួមពិភាក្សា** (សូមរូបថតក្នុងឧបសម្ព័ន្ធទី)៖
  ១. លោក **ញ៉ែម ហុង** ជាអភិបាលរងស្រុកក្រគរ ខេត្តពោធិសាត់
  ២. សុិន សៅរ៉ែន ជាអនុប្រធានអង្គភាពលទ្ធកម្មនៃសាលាស្រុកក្រគរ
  ៣. ក្រុមការងាររបស់ក្រុមហ៊ុនPPIC
- **អង្គប្រជុំខាងលើមានខ្លឹមសារទាំងមូលដូចខាងក្រោម៖**

- លោកបានមានប្រសាសន៍ថា បានជ្រាបពីគម្រោងតាមរយៈរបស់ក្រុមហ៊ុន Cambodia Fiber Optic Cable Network Co., Ltd (CFOCN) នេះផ្ទាល់ដោយបង្ហាញលិខិតផ្លូវច្បាប់ពីរាជរដ្ឋាភិបាល។
- សំណូមពរ

– សូមឱ្យក្រុមហ៊ុនមកបំពេញបែបបទរដ្ឋបាល ក្នុងការទំនាក់ទំនងជាមួយអាជ្ញាធរស្រុក ឃុំ ភូមិ ក៏ដូចជាអាជ្ញាធរជំនាញដើម្បីឱ្យដំណើរការនៃការងារមានរលូន និងបានល្អ ។

៦.៣.១៨ ការពិគ្រោះយោបល់ជាមួយអាជ្ញាធរមូលដ្ឋានសាលាក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់

នៅថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៥ វេលាម៉ោង១៥ និង០០នាទី នៅសាលាក្រុងពោធិ៍សាត់ ក្រុមការងារវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង បានជួបពិភាក្សានិងពិគ្រោះយោបល់ជាមួយ លោកស្រី **ម៉ែន ផល្លី** អភិបាលរងក្រុងលើគម្រោងបញ្ចប់ការសាងសង់ខ្សែកាប្លីអុបអិក(CFOCN)។ នៅក្នុងកិច្ចប្រជុំនេះ អាជ្ញាធរឃុំបានលើកឡើងជាយោបល់ពីមតិយោបល់ និងសំណូមពរ និងចំណាប់អារម្មណ៍ដូចខាងក្រោម៖

- **សមាសភាពអ្នកចូលរួមពិភាក្សា** (សូមរូបថតក្នុងឧបសម្ព័ន្ធទី)៖

  ១. លោកស្រី ម៉ែន ផល្លី ជាអភិបាលរងក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់

  ២. ក្រុមការងាររបស់ក្រុមហ៊ុនPPIC
- **អង្គប្រជុំខាងលើមានខ្លឹមសារទាំងមូលដូចខាងក្រោម៖**
  - អង្គប្រជុំបានលើកឡើងថា បានដឹងពីគម្រោងតាមរយៈរបស់ក្រុមហ៊ុន Cambodia Fiber Optic Cable Network Co., Ltd (CFOCN) នេះផ្ទាល់តាមរយៈសាលាស្រុក។
  - **មតិ សំណូមពរ និងចំណាប់អារម្មណ៍ធរភូមិឃុំ**

សាលាក្រុងពោធិ៍សាត់បានដឹងពីវត្តមាននៃការវិនិយោគរបស់ក្រុមហ៊ុនបណ្តាញខ្សែកាប្លីអុបទិកកម្ពុជា (CFOCN) ដោយក្រុមហ៊ុនមកជូនដំណឹងដល់សាលាក្រុងពីការវិនិយោគ និងការសុំការអនុញ្ញាតការសាងសង់បង្កប់បណ្តាញខ្សែកាប្លី។ អាជ្ញាធរក្រុងពិនិត្យឃើញថា ការវិនិយោគលើបណ្តាញខ្សែកាប្លីនេះ វាធ្វើឱ្យមានការរីក ចំរើនច្រើនជាងផលប៉ះពាល់ដែលបានកើតមានកន្លងមក ដោយភាគីក្រុមហ៊ុនបានធ្វើការសម្របសម្រួលនិង ជួសជុលឡើងវិញទៅលើចំណុចដែលបានប៉ះពាល់ជាមួយប្រជាជនរួចរាល់ផងដែរ។ អាជ្ញាធរក្រុងសូមគាំទ្រ និងពេញចិត្តចំពោះគម្រោងវិនិយោគនេះដែលនាំឱ្យមានការរីកចំរើន ធ្វើឱ្យមានការងាយស្រួលដល់ប្រជាជននៅតាមជនបទក្នុងការទំនាក់ទំនង ដឹងពីព័ត៌មាន និងសេវាផ្សេងៗជាច្រើន ។

- សំណូមពរផ្ទាល់អាជ្ញាធរឃុំ៖

– សូមឱ្យក្រុមហ៊ុនធ្វើការផ្សព្វផ្សាយដល់ប្រជាជន និងអាជ្ញាធរមូលដ្ឋានឱ្យបានដឹងពីដំណើរការឱ្យបានច្បាស់ ដូចជាខិតប័ណ្ណផ្សព្វផ្សាយព័ត៌មាននៅតាមទីសាធារណៈ ។

– សូមឱ្យមានតម្លៃសមរម្យទៅលើសេវាកម្មដែលនឹងត្រូវដាក់លក់ ឱ្យសមស្របជាមួយនឹងជីវភាពប្រជាជន។

៦.៣.១៩ ការពិគ្រោះយោបល់ជាមួយអាជ្ញាធរសង្កាត់ព្រៃញី ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់

នៅថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៥ វេលាម៉ោង១៥ និង៣០នាទី នៅសាលាសង្កាត់ព្រៃញី ក្រុមការងារវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមដំបូង បានជួបពិភាក្សា និងពិគ្រោះយោបល់ជាមួយលោក **មុិល បេន** ចៅសង្កាត់ព្រៃញី និងលោក **ញ៉ឹក គឹមហ៊ន** ចៅសង្កាត់រង លើគម្រោងបញ្ចប់ការសាងសង់ខ្សែកាប្លីអុបអិក (CFOCN)។ ការប្រជុំនេះបានលើកឡើងជាមតិ និង សំណូមពរមួយចំនួនដូចខាងក្រោម៖

✍ មតិ និងសំណូមពររបស់ប្រជាជន

មតិរួមរបស់ឃុំបានដឹងពីដំណឹងនៃការវិនិយោគរបស់ក្រុមខ្សែកាប្លីអុបទិក (CFOCN) នៅតំបន់របស់គាត់ តាមរយៈក្រុមហ៊ុន ហើយនៅពេលដែលចាប់ផ្តើមសាងសង់ក្រុមហ៊ុនក៏បានជូនដំណឹងមកសាលាឃុំផងដែរ។ ផ្ទៃដីដែលមានការប៉ះពាល់នៅក្នុងឃុំ គឺជាដីស្រែ ដីលំនៅដ្ឋាន និងផ្លូវជាតិ ហើយផលប៉ះពាល់ដែលកើតមាន នៅពេលសាងសង់មិនសូវមានទេ ដោយសារការសាងសង់កាត់ស្រែរបស់ពួកគាត់នៅរដូវប្រាំងមិនមានការធ្វើស្រែទេ គឺភាគច្រើនសង់កាត់នៅលើដីចំណីផ្លូវ អាជ្ញាធរឃុំសូមឯកភាព និងគាំទ្រចំពោះគម្រោង ព្រោះថាគម្រោងនេះនឹងធ្វើឱ្យមានការរីកចំរើន មានការអភិវឌ្ឍន៍ និងមានការងាយស្រួលក្នុងការប្រើប្រាស់ ។

✍ សំណូមពរផ្ទាល់របស់ប្រជាពលរដ្ឋ៖

- សូមឱ្យក្រុមហ៊ុន (CFOCN) ធ្វើការផ្សព្វផ្សាយព័ត៌មាននៃការប្រើប្រាស់ និងសូមឱ្យតម្លៃសេវាកម្មមានតម្លៃថោកសមរម្យដែលប្រជាជនអាចប្រើប្រាស់បាន ។

៦.៣.២០ ការពិគ្រោះយោបល់ជាមួយប្រជាជននៅភូមិមាន់ចែ និងភូមិសាលាគំរូ សង្កាត់ព្រៃញី ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់

នៅថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៥ វេលាម៉ោង១៦និ ង៣០នាទី នៅសាលាសង្កាត់ព្រៃញី ក្រុមការងារវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង បានជួបពិភាក្សា និងពិគ្រោះយោបល់ជាមួយប្រធានភូមិទាំងពីរ និងប្រជាជនចំនួន ១៥នាក់ (មានភ្ជាប់ជូនបញ្ជីវត្តមានក្នុងតារាងឧបសម្ព័ន្ធទី លើគម្រោងបញ្ចប់ការសាងសង់ខ្សែកាប្លីអុបទិក(CFOCN) ។ ការប្រជុំនេះបានលើកឡើងជាមតិ និង សំណូមពរមួយចំនួនដូចខាងក្រោម៖

✍ មតិ និងសំណូមពររបស់ប្រជាជន

មតិរួមរបស់ប្រជាជននៅក្នុងភូមិមិនបានដឹងពីវត្តមាននៃការវិនិយោគរបស់ក្រុមហ៊ុនខ្សែកាប្លីអុបទិក (CFOCN) ដែលបានសាងសង់កន្លងមកនៅក្នុងភូមិរបស់ពួកគាត់ទេហើយពួកគាត់ក៏មិនបានដឹងអំពីសារៈប្រយោជន៍នៃខ្សែកាប្លីអុបទិកនេះដែរ។ ពួកគាត់ក៏មិនដំទាស់លើគម្រោងនេះទេ ទោះបីជាការដំណើរការនៃការសាងសង់គម្រោងបានបញ្ចប់ទៅដោយធ្វើឱ្យមានការខូចខាតដល់ដីស្រែ និងដីលំនៅដ្ឋានរបស់ពួកគាត់ក៏ដោយ។ ពួកគាត់ពេញចិត្តចំពោះគម្រោងសាងសង់ខ្សែកាប្លីអុបទិក ព្រោះគម្រោងនេះនឹងធ្វើឱ្យមានការរីកចំរើនមានការងាយស្រួលដល់ប្រជាជននៅតាមដងបទក្នុងការទំនាក់ទំនង ដឹងពីព័ត៌មាន និងសេវាផ្សេងៗជាច្រើន ។

៦ សំណូមពរផ្ទាល់របស់ប្រជាពលរដ្ឋ៖

– សូមឱ្យក្រុមហ៊ុនធ្វើការសាងសង់ដោយមានការសម្របសម្រួលជាមួយប្រជាជនឱ្យបានល្អ និងបង្កឱ្យមានភាពងាយស្រួលជាមួយប្រជាជនផង ។

៦.៤.១ លទ្ធផលនៃការជួបពិគ្រោះយោបល់ជាមួយស្ថាប័នដំណាក់កាលពាក់ព័ន្ធខេត្តកំពត

៦.៤.១.១ មន្ទីរបរិស្ថានខេត្តកំពត

នៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៥ វេលាម៉ោង០៩ និង៥០នាទី ព្រឹក នៅមន្ទីរបរិស្ថាន ខេត្តកំពត ក្នុងសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន របស់ក្រុមហ៊ុន ភី ភី អាយស៊ី បានជួបពិភាក្សា ពិគ្រោះយោបល់ជាមួយលោកអនុប្រធានមន្ទីរបរិស្ថានខេត្តកំពត និង ប្រធានការិយាល័យវាយតម្លៃផលប៉ះពាល់បរិស្ថានខេត្តកំពង់ធំ លើគម្រោងបញ្ចប់ការសាងសង់បណ្តាញខ្សែកាប្លីអុបទិករបស់ក្រុមហ៊ុន Cambodia Fiber Optic Communication Network Co.,LTD។ការពិភាក្សានេះធ្វើឡើងដើម្បីទទួលបាននូវមតិយោបល់ ការិះគន់ ការព្រួយបារម្ភ និងសំណូមពរក៏ដូចជាការគាំទ្ររបស់ស្ថាប័នពាក់ព័ន្ធ និងអជ្ញាធរមូលដ្ឋានទៅនឹងវត្តមានគម្រោងខាងលើ។

- សមាសភាពអ្នកចូលរួមពិភក្សា៖
  - លោក ស៊ុយ ធា អនុប្រធានមន្ទីរបរិស្ថានខេត្តកំពត
  - ក្រុមការងាររបស់ក្រុមហ៊ុនភីភីអាយស៊ី
- អង្គប្រជុំខាងលើមានខ្លឹមសារទាំងមូលដូចខាងក្រោម៖

លោកមានប្រសាសន៍ថា លោកបានជ្រាបពីគម្រោងតាមរយៈក្រុមហ៊ុន Cambodia Fiber Optic Communication Network Co.,LTD នោះផ្ទាល់តាមរយៈទូរសព្ទដៃ និងបានដឹងពីវត្តមានគម្រោងវិនិយោគខ្សែកាប្លីនេះផងដែរ។ លោកមានការឯកភាព និងគាំទ្រយ៉ាងខ្លាំងលើការអភិវឌ្ឍន៍មួយនេះ។

☞ជាចុងក្រោយ លោកធ្វើការសំណូមពរដូចខាងក្រោម៖

- ឯកភាពទៅតាមក្រសួងសាធារណៈការថា
  សូមឲ្យគម្រោងធ្វើការសាងសង់ខ្សែកាប្លីអុបទិកក្នុងតំបន់គោលដៅ (៣០ម-២៥ម=៥ម ឬ២៥ម-២០ម=៥ម)និងដោះស្រាយសំណងជាមួយប្រជាពលរដ្ឋឲ្យដាច់ស្រេចសិនមុននិងធ្វើការកប់ខ្សែកាប្លីអុបទិក។
- សូមគម្រោងត្រូវដោះស្រាយគោលនយោបាយជាមួយប្រជាពលរដ្ឋតាមភាពជាក់ស្តែង
- សូមគម្រោងពេលចុះកប់បណ្តាញនៅខេត្តណា ឬស្រុកណា ត្រូវទាក់ទងជាមួយអាជ្ញាធរ និងមន្ទីរពាក់ព័ន្ធ
- សូមគម្រោងចូលរួមចំណែកក្នុងការថែទាំធនធានបរិស្ថានដូចជាដាំដើមឈើនៅតាមដងផ្លូវដែលកប់បណ្តាញខ្សែកាប្លីអុបទិកនេះដើម្បីជារបាំងមួយដើម្បីបង្កើនភាពបៃតងនៅតាមដងផ្លូវ។
- សូមគម្រោងជួយចូលជាមូលនិធិបរិស្ថានសង្គម

Draft

៦.៨.១.២ សាលាខេត្តកំពត

នៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៥ វេលាម៉ោង០៣ និង២៣នាទី រសៀល នៅសាលាខេត្តកំពត ក្នុងការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន របស់ក្រុមហ៊ុន ភី ភី អាយស៊ី បានជួបពិភាក្សា ពិគ្រោះយោបល់ជាមួយលោកនាយករងរដ្ឋបាលសាលាខេត្តកំពត លើគម្រោងបញ្ចប់ការសាងសង់បណ្តាញ ខ្សែកាប្លីអុបទិករបស់ក្រុមហ៊ុន Cambodia Fiber Optic Communication Network Co.,LTD ។ ការពិភាក្សានេះធ្វើឡើងដើម្បីទទួលបាននូវមតិយោបល់ ការរិះគន់ ការព្រួយបារម្ភ និងសំណូមពរក៏ដូចជាការគាំទ្ររបស់ស្ថាប័នពាក់ព័ន្ធ និងអជ្ញាធរមូលដ្ឋានទៅនឹងវត្តមានគម្រោងខាងលើ។

- សមាសភាពអ្នកចូលរួមពិភក្សា:
  - លោក ឡេង វិបុល នាយករងរដ្ឋបាលសាលាខេត្តកំពត
  - ក្រុមការងាររបស់ក្រុមហ៊ុនភីភីអាយស៊ី
- អង្គប្រជុំខាងលើមានខ្លឹមសារទាំងមូលដូចខាងក្រោម:

លោកមានប្រសាសន៍ថា លោកបានជ្រាបពីគម្រោងតាមរយៈ ក្រុមហ៊ុន Cambodia Fiber Optic Communication Network Co.,LTD នោះផ្ទាល់ដោយបានយោងលិខិតរបស់ក្រសួងបរិស្ថានដើម្បីទាក់ទងជាមួយសាលាខេត្តងាយស្រួលក្នុងការសិក្សា និងពិភាក្សាពិគ្រោះយោបល់។

លោកក៏បានមានយោបល់បន្ថែមថាលោកមានការគាំទ្រ១០០%នៅគម្រោងវិនិយោគនេះ ព្រោះវាមានផលប្រយោជន៍ច្រើនដល់ប្រជាពលរដ្ឋដូចជាសេវាកម្មប្រព័ន្ធទូរស័ព្ទ ទូរទស្សន៍ អ៊ីនធើណេត ការម៉ាសុវត្ថិភាព ។ល។

៦.៨.១.៣ មន្ទីរប្រៃសនីយ៍ និងទូរគមនាគមន៍ខេត្តកំពត

នៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៥ វេលាម៉ោង០៩ និង០០នាទី ព្រឹក នៅមន្ទីប៉ុស្តិ៍ប្រៃសនីយ៍ និងទូរគមនាគមន៍ខេត្តកំពត ក្នុងសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន របស់ក្រុមហ៊ុន ភី ភី អាយស៊ី បានជួបពិភាក្សា ពិគ្រោះយោបល់ជាមួយលោកអនុប្រធានមន្ទីរប៉ុស្តិ៍ប្រៃសនីយ៍ និងទូរគមនាគមន៍ខេត្តកំពតលើគម្រោងបញ្ចប់ការសាងសង់បណ្តាញខ្សែកាប្លីអុបទិករបស់ក្រុមហ៊ុន Cambodia Fiber Optic Communication Network Co.,LTD។ការពិភាក្សានេះធ្វើឡើងដើម្បីទទួលបាននូវមតិយោបល់ ការរិះគន់ ការព្រួយបារម្ភ និងសំណូមពរក៏ដូចជាការគាំទ្ររបស់ស្ថាប័នពាក់ព័ន្ធ និងអជ្ញាធរមូលដ្ឋានទៅនឹងវត្តមានគម្រោងខាងលើ។

- សមាសភាពអ្នកចូលរួមពិភក្សា:
  - លោក ម៉ែង រតនា អនុប្រធានមន្ទីរប៉ុស្តិ៍ប្រៃសនីយ៍ និងទូរគមនាគមន៍ខេត្តកំពត
  - ក្រុមការងាររបស់ក្រុមហ៊ុនភីភីអាយស៊ី
- អង្គប្រជុំខាងលើមានខ្លឹមសារទាំងមូលដូចខាងក្រោម:

លោកមានប្រសាសន៍ថា លោកបានជ្រាបពីគម្រោងតាមរយៈ ក្រុមហ៊ុន Cambodia Fiber Optic Communication Network Co.,LTD នោះផ្ទាល់ដោយបង្ហាញលិខិតផ្លូវច្បាប់ចេញពីសាលាខេត្តកំពត។

លោកក៏បានមានយោបល់ទៅលើផលប៉ះពាល់របស់គម្រោងសាងសង់មកលើប្រជាពលរដ្ឋ និងបរិស្ថានថាមិនមានអ្វីជាធំដុំនោះទេ។ ហើយលោកក៏មានការពេញចិត្តនឹងគម្រោងសាងសង់មួយនេះខ្លាំងណាស់ដែរ។

ចំពោះមន្ទីរប៉ុស្តិ៍ប្រៃសនីយ៍ និងទូរគមនាគមន៍ខេត្តកំពតគឺ សូមធ្វើការគាំទ្រ១០០% លើគម្រោងវិនិយោគបណ្តាញខ្សែកាប្លីអុបទិកទាំងស្រុង។

☞ជាចុងក្រោយ លោកធ្វើការសំណូមពរដូចខាងក្រោម៖

- សូមឲ្យសាលាខេត្តដាក់បញ្ចូលវិស័យទូគមនាគមន៍នេះចូលក្នុងគម្រោងសំខាន់ៗរបស់វិស័យទូគមនាគមន៍ បច្ចេកវិទ្យទូគមនាគមន៍ និងព័ត៌មាន។

៦.៤.១.៤ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពត

នៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៥ វេលាម៉ោង០៤ និង០០នាទី រសៀល នៅមន្ទីមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពត ក្នុងសិក្ខាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន របស់ក្រុមហ៊ុន កីកី អាយស៊ី បានជួបពិភាក្សា ពិគ្រោះយោបល់ជាមួយលោកអនុប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពត លើគម្រោងបញ្ចប់ការសាងសង់បណ្តាញខ្សែកាប្លីអុបទិករបស់ក្រុមហ៊ុន Cambodia Fiber Optic Communication Network Co.,LTD។ការពិភាក្សានេះធ្វើឡើងដើម្បីទទួលបាននូវមតិយោបល់ ការរិះគន់ ការព្រួយបារម្ភ និងសំណូមពរក៏ដូចជាការគាំទ្ររបស់ស្ថាប័នពាក់ព័ន្ធ និងអជ្ញាធរមូលដ្ឋានទៅនឹងវត្តមានគម្រោងខាងលើ។

- សមាសភាពអ្នកចូលរួមពិភក្សា៖
  - លោក ជាញ់ សារី អនុប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពត
  - ក្រុមការងាររបស់ក្រុមហ៊ុនកីកីអាយស៊ី

- អង្គប្រជុំខាងលើមានខ្លឹមសារទាំងមូលដូចខាងក្រោម៖

លោកមានប្រសាសន៍ថា ការពាក់ព័ន្ធជាមួយគម្រោងនេះការប៉ះពាល់គឺមានកម្រិតតិចតួចទេ។ ហើយលោកក៏បន្ថែមថាខ្ញុំមានការពេញចិត្ត និងគាំទ្រគម្រោងនេះ១០០% នៅព្រះរាជាណាចក្រកម្ពុជា ជាពិសេសក្នុងខេត្តកំពតព្រោះគម្រោងនេះ នឹងផ្តល់សេវាកម្មប្រព័ន្ធទូរស័ព្ទ ទូរទស្សន៍ អ៊ីនធើណេត ការម៉ាស៊ុវត្ថិភាព។ល។ ប៉ុន្តែគម្រោងនេះមិនទាន់មានលិខិតស្នាមរបស់ក្រុមហ៊ុន មកទាក់ទងជាមួយមន្ទីរនោះឡើយទេ។ មិនតែប៉ណ្ណោះមានការជីកកាំង និងមិនត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេសទេធ្វើឲ្យមានផលប៉ះពាល់ដល់ក្រុមហ៊ុនទៅថ្ងៃអនាគត។

☞ជាចុងក្រោយ លោកធ្វើការសំណូមពរដូចខាងក្រោម៖

- ក្រុមហ៊ុនត្រូវដាក់ខ្សែកាប្លីអុបទិកនេះ ដោយផ្តល់ដំណឹងដល់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពតឲ្យបានជ្រាបជាដំណឹងផង។

- សូមឲ្យក្រុមហ៊ុនមុននឹងធ្វើការកប់ខ្សែកាប្លីអុបទិកនេះ ត្រូវផ្តល់និយាមកាម ឬបន្ទាត់ជាសេពហ្វាល់ឲ្យមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពត ជួយផ្ទៀងផ្ទាត់ជាក់ខ្សែកាប្លីឲ្យត្រឹមត្រូវក្នុងតំបន់គោលដៅ។
- គម្រោងនេះមានសារៈសំខាន់ណាស់សម្រាប់ប្រទេសកម្ពុជាយើងទាំងមូល។

៦.៤.២ លទ្ធផលនៃការជួបពិគ្រោះយោបល់ជាមួយស្ថាប័នដំណាញ់ពាក់ព័ន្ធខេត្តព្រៃវែងរួមគ្នា

៦.៤.២.១ ការប្រជុំរួមនៅមន្ទីរបរិស្ថានខេត្តព្រៃវែង

នៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៥ វេលាម៉ោង០៩ និង១៥នាទី ព្រឹក នៅមន្ទីរបរិស្ថាន ខេត្តព្រៃវែង ក្នុងការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន របស់ក្រុមហ៊ុន ភី ភី អាយស៊ី បានជួបពិភាក្សា ពិគ្រោះយោបល់ជាមួយមន្ទីរពាក់ព័ន្ធនានាក្នុងខេត្តព្រៃវែង ជាមួយលោកប្រធានការិយាល័យវាយតម្លៃបរិស្ថាន លោកប្រធានការិយាល័យបរិស្ថាន, លោកប្រធានការិយាល័យអភិរក្ស, អ្នកស្រីមន្ត្រីរដ្ឋបាល តំណាងមន្ទីរប្រៃសនីយ៍និងទូរគមនាគមន៍, លោកប្រធានរដ្ឋបាល និងហរិញ្ញវត្ថុ, លោកអនុប្រធានការិយាល័យសាលាខេត្តព្រៃវែង និងលោកប្រធានមន្ទីរធនធានទឹក លើគម្រោងបញ្ចប់ការសាងសង់បណ្តាញខ្សែកាប្លីអុបទិករបស់ក្រុមហ៊ុន Cambodia Fiber Optic Communication Network Co.,LTD។ការពិភាក្សានេះធ្វើឡើងដើម្បីទទួលបាននូវមតិយោបល់ ការរិះគន់ ការព្រួយបារម្ភ និងសំណូមពរក៏ដូចជាការគាំទ្ររបស់ស្ថាប័នពាក់ព័ន្ធនិងអជ្ញាធរមូលដ្ឋានទៅនឹងវត្តមានគម្រោងខាងលើ។

- សមាសភាពអ្នកចូលរួមពិភក្សា៖
  - លោក ប៊ិន សុភី ប្រធានការិយាល័យវាយតម្លៃបរិស្ថាននៃខេត្តព្រៃវែង
  - លោក ទុយ សារឿន ប្រធានការិយាល័យមន្ទីរបរិស្ថានខេត្តព្រៃវែង
  - លោក ហេង សុាំងហ៊ី ប្រធានការិយាល័យអភិរក្សសត្វព្រៃនៃមន្ទីរបរិស្ថានខេត្តព្រៃវែង
  - កញ្ញា ហេង បញ្ញាវី មន្ត្រីរដ្ឋបាលនៃមន្ទីរប៉ុស្តិ៍ប្រៃសនីយ៍ និងទូរគមនាគមន៍ខេត្តព្រៃវែង
  - លោក ប៊ិន សំភា ប្រធានរដ្ឋបាលនៃមន្ទីរបរិស្ថានខេត្តព្រៃវែង
  - លោក កង កាណាដា អនុប្រធានការិយាល័យសាលាខេត្តព្រៃវែង
  - លោក អ៊ុន ដារិទ្ធ មន្ទីរធនធានទឹកខេត្តព្រៃវែង
  - ក្រុមការងាររបស់ក្រុមហ៊ុនភីភីអាយស៊ី

- អង្គប្រជុំខាងលើមានខ្លឹមសារទាំងមូលដូចខាងក្រោម៖

តាមអង្គប្រជុំបានលើកឡើងថា បានជ្រាបពីគម្រោងតាមរយៈ ក្រុមហ៊ុន Cambodia Fiber Optic Communication Network Co.,LTD នោះផ្ទាល់ដោយឃើញជាក់ស្តែងពេលកំពុងធ្វើការសាងសង់ដំណើរការ និងមានលិខិតកាន់ពេលធ្វើការសាងសង់។

អង្គប្រជុំទាំងមូលគឺ មានការគាំទ្រ១០០% ចំពោះគម្រោងវិនិយោគខ្សែកាប្លីអុបទិកនេះ ប៉ុន្តែការសិក្សារកផលប៉ះពាល់ធ្វើឡើងមានការយឺតយ៉ាវបន្តិចក្រោយពេលបញ្ចប់គម្រោង។

អង្គប្រជុំក៏បានមានយោបល់ទៅលើផលប៉ះពាល់របស់គម្រោងសាងសង់មកលើប្រជាពលរដ្ឋថាមានផលប៉ះពាល់ខ្លះៗដែរព្រោះខ្សែកាប្លីត្រូវកប់នៅក្រោមដីដែលធ្វើឲ្យមានការប៉ះពាល់ដល់ការឆ្លងកាត់ផ្ទះរបស់ពួកគាត់បន្តិចបន្តួច។ ប្រជាជនមានការអន់ចិត្តនឹងការមិនផ្តល់ដំណឹងដល់ពួកគាត់ខ្លះៗដែរ តែដោយមានការសម្របសម្រួលពីអាជ្ញាធរ ឃើញថាគាត់ក៏មិនមានថាអ្វី។

អង្គប្រជុំបានផ្តល់នូវវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថានខ្លះៗដូចខាងក្រោម៖

- ត្រូវមានបំពង់ដាក់ខ្សែកាប្លី មានដាក់សញ្ញាសំគាល់បង្ហាញពីបង្គោលខ្សែកាប្លីរបស់ក្រុមហ៊ុន និងមានសំណងសមរម្យជាមួយប្រជាពលរដ្ឋ ។
- ត្រូវដាក់បង្គោលសំគាល់ឲ្យបានញឹកបន្តិចដើម្បីជៀសវាងការផ្តាច់ខ្សែកាប្លី ដោយហេតុចៃដន្យណាមួយពីម្ចាស់ដី។

☞ជាចុងក្រោយ លោកធ្វើការសំណូមពរដូចខាងក្រោម៖

- សូមឲ្យមានការដោះស្រាយចំពោះបញ្ហាដែលប៉ះពាល់ចំប្រឡាយមួយកន្លែងនៅ ឃុំល្វាស្រុកព្រះស្តេច ខេត្តព្រៃវែង ឲ្យក្រុមហ៊ុនរកវិធីដោះស្រាយកុំឲ្យមានផលប៉ះពាល់ និងឲ្យបានឆាប់រហ័ស។
- ចំពោះព្រៃឈើអាចមានការប៉ះពាល់មួយចំនួនក្នុងរយៈពេល ៤-១០ឆ្នាំ ខាងមុខត្រូវមានវិធានការត្រឹមត្រូវទៅលើធនធានមួយចំនួនដូចជា ទឹក, ដី, រុក្ខជាតិ និងមច្ឆា។
- ត្រូវមានការចុះត្រួតពិនិត្យតាមដានជាប្រចាំ។
- ត្រូវដាក់សេចក្តីជូនដំណឹងដល់ប្រជាពលរដ្ឋ និងរៀបចំឲ្យបានត្រឹមត្រូវ។
- នៅរាល់ការសាងសង់ត្រូវជូនដំណឹងដល់មន្ទីរប៉ុស្តិ៍ប្រៃសនីយ៍ និងទូរគមនាគមន៍ឲ្យបានដឹងផង។

៦.៤.៣ លទ្ធផលនៃការជួបពិគ្រោះយោបល់ជាមួយស្ថាប័នដំណាក់ពាក់ព័ន្ធក្នុងខេត្តត្បូងឃ្មុំ

៦.៤.៣.១ មន្ទីរបរិស្ថានខេត្តត្បូងឃ្មុំ

នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៥ វេលាម៉ោង០៣ និង២៥នាទី រសៀល នៅមន្ទីរបរិស្ថាន ខេត្តត្បូងឃ្មុំក្នុងការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន របស់ក្រុមហ៊ុន ភី ភី អាយស៊ី បានជួបពិភាក្សាពិគ្រោះយោបល់ ជាមួយលោកអនុប្រធានមន្ទីរបរិស្ថានខេត្តត្បូងឃ្មុំលើគម្រោងបញ្ចប់ការសាងសង់បណ្តាញខ្សែកាប្លីអុបទិករបស់ក្រុមហ៊ុន Cambodia Fiber Optic Communication Network Co.,LTD។ ការពិភាក្សានេះធ្វើឡើងដើម្បីទទួលបាននូវមតិយោបល់ ការរិះគន់ ការព្រួយបារម្ភ និងសំណូមពរក៏ដូចជាការគាំទ្ររបស់ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋានទៅនឹងវត្តមានគម្រោងខាងលើ។

- សមាសភាពអ្នកចូលរួមពិភក្សា៖

- លោក នី សុធី អនុប្រធានមន្ទីរបរិស្ថានខេត្តត្បូងឃ្មុំ
- ក្រុមការងាររបស់ក្រុមហ៊ុនភីភីអាយស៊ី

- អង្គប្រជុំខាងលើមានខ្លឹមសារទាំងមូលដូចខាងក្រោម៖

លោកមានប្រសាសន៍ថា លោកមិនបានជ្រាបពីគម្រោងតាមរយៈ ក្រុមហ៊ុន Cambodia Fiber Optic Communication Network Co.,LTD នេះទេពីព្រោះខេត្តត្បូងឃ្មុំទើបតែបង្កើតឡើងនៅក្នុងឆ្នាំ២០១៤ ប៉ុណ្ណោះ។ ហេតុនេះមន្ទីរនានា និងមន្ទីរបរិស្ថានខេត្តត្បូងឃ្មុំមិនមានឯកសារទាក់ទងនឹងក្រុមហ៊ុនខ្សែកាប្លីអុបទិកខាងលើទេ។ ដូចនេះក្រុមការងារ មិនបានទទួលព័ត៌មានពីអាជ្ញាធរនៅក្នុងខេត្តនេះទេ។

៦.៤.៤ លទ្ធផលនៃការជួបពិគ្រោះយោបល់ជាមួយស្ថាប័នដំណាញ់ពាក់ព័ន្ធក្នុងខេត្តកំពង់ធំ

៦.៤.៤.១ មន្ទីរបរិស្ថានខេត្តកំពង់ធំ

នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៥ វេលាម៉ោង០៨ និង៣០នាទី ព្រឹក នៅមន្ទីរបរិស្ថានខេត្តកំពង់ធំ ក្នុងការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន របស់ក្រុមហ៊ុន ភី ភី អាយស៊ី បានជួបពិភាក្សា ពិគ្រោះយោបល់ជាមួយលោកអនុប្រធានមន្ទីរបរិស្ថានខេត្តកំពង់ធំ និង ប្រធានការិយាល័យវាយតម្លៃផលប៉ះពាល់បរិស្ថានខេត្តកំពង់ធំ លើគម្រោងបញ្ចប់ការសាងសង់បណ្តាញខ្សែកាប្លីអុបទិករបស់ក្រុមហ៊ុន Cambodia Fiber Optic Communication Network Co.,LTD។ការពិភាក្សានេះធ្វើឡើងដើម្បីទទួលបាននូវមតិយោបល់ ការរិះគន់ ការព្រួយបារម្ភ និងសំណូមពរក៏ដូចជាការគាំទ្ររបស់ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋានទៅនឹងវត្តមានគម្រោងខាងលើ។

- សមាសភាពអ្នកចូលរួមពិភក្សា៖
  - លោក ជៅ ប៊ុនធឿន អនុប្រធានមន្ទីរបរិស្ថានខេត្តកំពង់ធំ
  - លោក ស៊ន ពិជាត ប្រធានការិយាល័យវាយតម្លៃផលប៉ះពាល់បរិស្ថាននៃមន្ទីរបរិស្ថានខេត្តកំពង់ធំ
  - ក្រុមការងាររបស់ក្រុមហ៊ុនភីភីអាយស៊ី

- អង្គប្រជុំខាងលើមានខ្លឹមសារទាំងមូលដូចខាងក្រោម៖

លោកមានប្រសាសន៍ថា លោកបានជ្រាបពីគម្រោងតាមរយៈ ក្រុមហ៊ុន Cambodia Fiber Optic Communication Network Co.,LTD នោះផ្ទាល់ដោយបង្ហាញលិខិតផ្លូវច្បាប់ចេញពីរដ្ឋាភិបាល។

លោកក៏បានមានយោបល់ទៅលើផលប៉ះពាល់របស់ គម្រោងសាងសង់មកលើប្រជាពលរដ្ឋថាមានផលប៉ះពាល់ខ្លះៗដែរ ព្រោះខ្សែកាប្លីត្រូវកប់នៅក្រោមដីដែលធ្វើឲ្យប្រជាជនមានការយល់ច្រលំថាជាការរំលោភបំពានទៅលើដីធ្លីរបស់ពួកគាត់។ ប៉ុន្តែកន្លងមកក្រសួងបរិស្ថានក៏ដូចជាអាជ្ញាធរមូលដ្ឋានបានចូលរួមសម្របសម្រួល និងដោះស្រាយពន្យល់ដល់ប្រជាជនអំពីគម្រោងវិនិយោគរបស់ក្រុមហ៊ុននៃផលប៉ះពាល់រវាងក្រុមហ៊ុនវិនិយោគ ជាមួយប្រជាពលរដ្ឋនៅពេលដែលមានការផ្តឹងផ្តល់ពីសំណាក់ប្រជាពលរដ្ឋមកកាន់ក្រសួង។ ការដោះស្រាយមានភាពរលូនរវាងក្រុមហ៊ុន និងប្រជាពលរដ្ឋផ្ទាល់ ដោយក្រុមហ៊ុនមានជូនជា

សំណងទៅលើដីដែលមានប៉ះពាល់របស់ប្រជាពលរដ្ឋ។ ចំណែកឯផលប៉ះពាល់បរិស្ថានមិនមានអ្វីធ្ងន់ធ្ងរនោះឡើយ ដោយមានក្រុមការងារប្រចាំរបស់ក្រុមហ៊ុនបានចុះថែទាំជាប្រចាំ។

☞ជាចុងក្រោយ លោកធ្វើការសំណូមពរដូចខាងក្រោម៖

- សំណូមពរជាចុងក្រោយរបស់លោកគឺសុំឲ្យក្រុមហ៊ុនធ្វើការផ្សព្វផ្សាយអំពីគម្រោងការសាងសង់ទៅដល់ប្រជាជនឲ្យបានជ្រាបពីវត្តមាននៃក្រុមការងារ ក៏ដូចជាឲ្យបានយល់ដឹងពីខ្សែកាប្លីអុបទិក។
- សំណូមពរឲ្យសេវាកម្មខ្សែកាប្លីអុបទិកមានតម្លៃថោកសមរម្យដើម្បីឲ្យប្រជាពលរដ្ឋគ្រប់គ្នាមានលទ្ធភាពប្រើប្រាស់។

៦.៤.៤.២ មន្ទីរប្រៃសនីយ៍ និងទូរគមនាគមន៍ខេត្តកំពង់ធំ

នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៥ វេលាម៉ោង០៩ និង៣០នាទី ព្រឹក នៅមន្ទីរប្រៃសនីយន៍ និងទូរគមនាគមន៍ ខេត្តកំពង់ធំ ក្នុងការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន របស់ក្រុមហ៊ុន កី កី អាយស៊ី បានជួបពិភាក្សា ពិគ្រោះយោបល់ជាមួយលោកប្រធានមន្ទីរប្រៃសនីយន៍ និងទូរគមនាគមន៍ខេត្តកំពង់ធំ លើគម្រោងបញ្ចប់ការសាងសង់បណ្តាញខ្សែកាប្លីអុបទិករបស់ក្រុមហ៊ុន Cambodia Fiber Optic Communication Network Co.,LTD ។ ការពិភាក្សានេះធ្វើឡើងដើម្បីទទួលបាននូវមតិយោបល់ ការរិះគន់ ការព្រួយបារម្ភ និងសំណូមពរក៏ដូចជាការគាំទ្ររបស់ស្ថាប័នពាក់ព័ន្ធ និងអជ្ញាធរមូលដ្ឋានទៅនឹងវត្តមានគម្រោងខាងលើ។

- សមាសភាពអ្នកចូលរួមពិភក្សា៖
  - លោក សាល់ ស៊ីថារិទ្ធ ប្រធានមន្ទីរប៉ុស្តិ៍ប្រៃសនីយ៍ និងទូរគមនាគមន៍ខេត្តកំពង់ធំ
  - ក្រុមការងាររបស់ក្រុមហ៊ុនកីកីអាយស៊ី

អង្គប្រជុំខាងលើមានខ្លឹមសារទាំងមូលដូចខាងក្រោម៖

លោកមានប្រសាសន៍ថា លោកបានជ្រាបពីគម្រោងតាមរយៈ ក្រុមហ៊ុន Cambodia Fiber Optic Communication Network Co.,LTD នោះផ្ទាល់ដោយបង្ហាញលិខិតផ្លូវច្បាប់ចេញពីរដ្ឋាភិបាល។

លោកក៏បានមានយោបល់ទៅលើផលប៉ះពាល់របស់គម្រោងសាងសង់មកលើប្រជាពលរដ្ឋថាមានផលប៉ះពាល់ខ្លះៗដែរដោយប្រជាជនមានការភ័យខ្លាចចំពោះសុវត្ថិភាពរបស់ពួកគាត់ដែលជៈឥទ្ធិពលពីការកប់ខ្សែកាប្លីអុបទិក ដូចជាស្រូបរន្ទះ និងជាតិវិទ្យុសកម្មជាដើម។ លោកមានប្រសាសន៍បន្ថែមទៀតថា ប្រជាជនមានការខឹងសម្បារព្រោះក្រុមហ៊ុនបានធ្វើការសាងសង់ដោយមិនបានផ្តល់ដំណឹងជាមុនដល់ពួកគាត់ជាហេតុធ្វើឲ្យពួកគាត់មិនយល់ដឹងពីវត្តមានរបស់ខ្សែកាប្លីអុបទិកនេះសោះឡើយ។

លោកក៏មានលើកឡើងដែរថា លោកមានការពេញចិត្តជាខ្លាំងចំពោះគម្រោងសាងសង់ខ្សែកាប្លីអុបទិកនេះ ព្រោះបណ្តាញខ្សែកាប្លីនេះផ្តល់សេវាកម្មទូទាំងប្រទេស ដែលត្រូវនឹងតំរូវការរបស់មនុស្សសព្វថ្ងៃដូចជា អ៊ីនធើណេត ទឹក ភ្លើង ធនធានមនុស្ស និងផ្លូវ។

☞ជាចុងក្រោយ លោកធ្វើការសំណូមពរដូចខាងក្រោម៖

- សំណូមពរជាចុងក្រោយរបស់លោកគឺសុំឲ្យក្រុមហ៊ុនធ្វើការផ្សព្វផ្សាយអំពីសេវាកម្មដល់ប្រជាជនបានយល់ដឹង ដៀសវៀងភាពកាំរកូសនៅពេលក្រោយ។

៦.៤.៤.៣ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពង់ធំ

នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៥ វេលាម៉ោង១០ និង៥០នាទី ព្រឹក នៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពង់ធំ ក្នុងការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន របស់ក្រុមហ៊ុន ភី ភី អាយស៊ី បានជួបពិភាក្សា ពិគ្រោះយោបល់ជាមួយលោកអនុប្រធានមន្ទីរដែនដីខេត្តកំពង់ធំលើគម្រោងបញ្ចប់ការសាងសង់បណ្តាញខ្សែកាប្លីអុបទិករបស់ក្រុមហ៊ុន Cambodia Fiber Optic Communication Network Co.,LTD។ការពិភាក្សានេះធ្វើឡើងដើម្បីទទួលបាននូវមតិយោបល់ ការរិះគន់ ការព្រួយបារម្ភ និងសំណូមពរក៏ដូចជាការគាំទ្ររបស់ស្ថាប័នពាក់ព័ន្ធ និងអជ្ញាធរមូលដ្ឋានទៅនឹងវត្តមានគម្រោងខាងលើ។

- សមាសភាពអ្នកចូលរួមពិភក្សា៖
  - លោក ផៅ ប៊ុនធឿន អនុប្រធានមន្ទីរបរិស្ថានខេត្តកំពង់ធំ
  - លោក ស៊ឹង ជីមហុង អនុប្រធានមន្ទីរដែនដី និងរូបនីយកម្ម
  - ក្រុមការងាររបស់ក្រុមហ៊ុនភីភីអាយស៊ី
- អង្គប្រជុំខាងលើមានខ្លឹមសារទាំងមូលដូចខាងក្រោម៖

លោកមានប្រសាសន៍ថា លោកបានជ្រាបពីគម្រោងតាមរយៈ ក្រុមហ៊ុន Cambodia Fiber Optic Communication Network Co.,LTD នោះផ្ទាល់ដោយបង្ហាញលិខិតផ្លូវច្បាប់ចេញពីរដ្ឋាភិបាល។

លោកក៏បានមានយោបល់ទៅលើផលប៉ះពាល់របស់ គម្រោងសាងសង់មកលើប្រជាពលរដ្ឋថាមានផលប៉ះពាល់ខ្លះៗទៅលើប្រជាពលរដ្ឋ។ លោកបានលើកឡើងថាជាទូទៅគោលការណ៍របស់ក្រុមហ៊ុនសាងសង់នីមួយៗគឺមានសិទ្ធអភិវឌ្ឍន៍នៅត្រឹមចំណីដីដែលជាកម្មសិទ្ធរបស់រដ្ឋតែប៉ុណ្ណោះ ប៉ុន្តែដោយឡែកសំរាប់ក្រុមហ៊ុនសាងសង់ខ្សែកាប្លីអុបទិករបស់ក្រុមហ៊ុនស៊ីហ្វុន គឺសាងសង់ប៉ះដល់ដីកម្មសិទ្ធរបស់ប្រជាពលរដ្ឋដែលវាខុសនឹងគោលការណ៍ច្បាប់ ធ្វើឲ្យប្រជាជនមានការខឹងសម្បារ។ ប៉ុន្តែខាងក្រុមហ៊ុនក៏បានសម្របសម្រួលជាមួយប្រជាជនដោយមានធ្វើការសុំអនុគ្រោះ និងសងជាសំណងរួចរាល់អស់ហើយ។ ចំពោះយោបល់របស់លោកផ្ទាល់ គឺលោកមានការពេញចិត្តជាខ្លាំងលើគម្រោងសាងសង់ខ្សែកាប្លីអុបទិកនេះព្រោះលោកចង់ឃើញមានការអភិវឌ្ឍន៍នៅក្នុងភូមិឃុំឲ្យបានគ្រប់វិស័យទាំងអស់។

☞ជាចុងក្រោយ លោកធ្វើការសំណូមពរដូចខាងក្រោម៖

- សំណូមពរជាចុងក្រោយរបស់លោកគឺ សុំឲ្យក្រុមហ៊ុនធ្វើការសាងសង់ដោយឲ្យដៀសផលប៉ះពាល់ដល់ប្រជាពលរដ្ឋកាន់តែតិចកាន់តែល្អ និងធ្វើការដោះស្រាយឲ្យពួកគាត់ឲ្យបានត្រឹមត្រូវតាមច្បាប់។

៦.៤.៥ លទ្ធផលនៃការជួបពិគ្រោះយោបល់ជាមួយស្ថាប័នជំនាញពាក់ព័ន្ធខេត្តពោធិ៍សាត់

៦.៤.៥.១ សាលាខេត្តពោធិ៍សាត់

នៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៥ វេលាម៉ោង០៩ និង៣០នាទី ព្រឹក នៅសាលាខេត្តពោធិ៍សាត់ក្នុងការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន របស់ក្រុមហ៊ុន ភី ភី អាយស៊ី បានជួបពិភាក្សា ពិគ្រោះយោបល់ជាមួយលោកតំណាងសាលាខេត្តពោធិ៍សាត់ លើគម្រោងបញ្ចប់ការសាងសង់បណ្តាញខ្សែកាប្លីអុបទិករបស់ក្រុមហ៊ុន Cambodia Fiber Optic Communication Network Co.,LTD។ ការពិភាក្សានេះធ្វើឡើងដើម្បីទទួលបាននូវមតិយោបល់ ការរិះគន់ ការព្រួយបារម្ភ និងសំណូមពរក៏ដូចជាការគាំទ្ររបស់ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋានទៅនឹងវត្តមានគម្រោងខាងលើ។

- សមាសភាពអ្នកចូលរួមពិភក្សា៖
  - លោក ឯម ភូវិបុទ្ធ តំណាងសាលាខេត្តពោធិ៍សាត់
  - ក្រុមការងាររបស់ក្រុមហ៊ុនភីភីអាយស៊ី

- អង្គប្រជុំខាងលើមានខ្លឹមសារទាំងមូលដូចខាងក្រោម៖

លោកមានប្រសាសន៍ថា លោកបានជ្រាបពីគម្រោងតាមរយៈ ក្រុមហ៊ុន Cambodia Fiber Optic Communication Network Co.,LTD នោះប៉ុន្តែក្រុមហ៊ុនមិនមានឯកសារគ្រប់គ្រាន់នោះទេ។

☞ជាចុងក្រោយ លោកធ្វើការសំណូមពរដូចខាងក្រោម៖

- សំណូមពរឲ្យក្រុមហ៊ុនសាងស់ប៉ុស្តិ៍បែងចែកឲ្យបានត្រឹមត្រូវ

៦.៤.៥.២ មន្ទីរប៉ុស្តិ៍ប្រៃសនីយ៍ និងទូរគមនាគមន៍ខេត្តពោធិ៍សាត់

នៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៥ វេលាម៉ោង១០ និង០៤នាទី ព្រឹក នៅមន្ទីរប៉ុស្តិ៍ប្រៃសនីយន៍ និងទូរគមនាគមន៍ខេត្តពោធិ៍សាត់ ក្នុងការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន របស់ក្រុមហ៊ុន ភី ភី អាយស៊ី បានជួបពិភាក្សាពិគ្រោះយោបល់ជាមួយលោកប្រធានមន្ទីរប៉ុស្តិ៍ប្រៃសនីយន៍ និងទូរគមនាគមន៍ខេត្តពោធិ៍សាត់ លើគម្រោងបញ្ចប់ការសាងសង់បណ្តាញខ្សែកាប្លីអុបទិករបស់ក្រុមហ៊ុន Cambodia Fiber Optic Communication Network Co.,LTD ។ ការពិភាក្សានេះធ្វើឡើងដើម្បីទទួលបាននូវមតិយោបល់ ការរិះគន់ ការព្រួយបារម្ភ និងសំណូមពរក៏ដូចជាការគាំទ្ររបស់ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋានទៅនឹងវត្តមានគម្រោងខាងលើ។

- សមាសភាពអ្នកចូលរួមពិភក្សា៖
  - លោក អ៊ូ ឆៃ ប្រធានមន្ទីរប៉ុស្តិ៍ប្រៃសនីយន៍ និងទូរគមនាគមន៍ខេត្តពោធិ៍សាត់
  - លោក ប៉ាង សុខា អនុប្រធានមន្ទីរប៉ុស្តិ៍ប្រៃសនីយន៍ និងទូរគមនាគមន៍ខេត្តពោធិ៍សាត់
  - លោក ម៉ែន អាន ប្រធានការិយាល័យមន្ទីរប៉ុស្តិ៍ប្រៃសនីយន៍ និងទូរគមនាគមន៍ខេត្តពោធិ៍សាត់
  - ក្រុមការងាររបស់ក្រុមហ៊ុនភីភីអាយស៊ី

- អង្គប្រជុំខាងលើមានខ្លឹមសារទាំងមូលដូចខាងក្រោម៖

លោកមានប្រសាសន៍ថា លោកបានជ្រាបពីគម្រោងតាមរយៈ ក្រុមហ៊ុន Cambodia Fiber Optic Communication Network Co.,LTD តែក្រុមហ៊ុនមិនបានឆ្លងយោបល់ពីមន្ទីរលោកទេ ប៉ុន្តែក្រុមហ៊ុនបានស្នើរសុំសាលាខេត្ត ដែលមានរយៈពេលខ្លី។

លោកក៏បានមានយោបល់ទៅលើផលប៉ះពាល់របស់គម្រោងសាងសង់មានខ្លះៗដែរដូចជា ប៉ះពាល់ដីចំណីផ្លូវ ប៉ះស្រែកំពុងស្ទូង និងសំណាប់ដែលកំពុងលូតលាស់ ប៉ុន្តែក្រោយមកក៏មានការសម្របសម្រួលពីអាជ្ញាធរ។ លោកបានបន្ថែមថា មានលិខិតមួយដែលបានសុំអនុញ្ញាតពីសាលាខេត្ត ក្នុងការជីក ប៉ុន្តែសាលាខេត្តមិនទាន់អនុញ្ញាតទេ ព្រោះមិនទាន់មានឯកសារត្រឹមត្រូវ។ ចំពោះផលប៉ះពាល់សុខភាព និងវិទ្យុសកម្មមានតិចតួច។ វាមិនមានចរន្តធក់ទេនៅពេលជាច់ខ្សែកាប្លី។ លោកអនុប្រធានបានមានប្រសាសន៍ថា មានប៉ះពាល់លើចំណីផ្លូវ ប៉ះបាល់ស្រែកំពុងស្ទូង, សំណាបកំពុងលូតលាស់, នៅរាល់ការប៉ះពាល់ត្រូវបានអាជ្ញាធរជាអ្នកសម្របសម្រួល។ ជាចុងក្រោយលោកប្រធានបានមានប្រសាសន៍ថា ជាផ្លូវការគាត់ដីកកប់តែលើដីចំណីផ្លូវទេ ហើយប្រជាពលរដ្ឋគាត់មិនមានសិទ្ធសង់លំនៅដ្ឋាន នៅលើដីចំណីផ្លូវទេ។ បើក្រុមហ៊ុនមិនសង់តាមតំបន់គោលដៅទេនោះ ការប៉ះពាល់ទៅលើក្រុមហ៊ុនខ្លួនង នៅពេលខាងមុខ ឬពេលរុះរើឡើងវិញ។

លោកក៏មានលើកឡើងដែរថា លោកមានការពេញចិត្តជាខ្លាំងចំពោះគម្រោងសាងសង់ខ្សែកាប្លីអុបទិកនេះ។

☞ជាចុងក្រោយ លោកធ្វើការសំណូមពរដូចខាងក្រោម៖

- សំណូមពរជាចុងក្រោយរបស់លោកគឺសុំឲ្យក្រុមហ៊ុនធ្វើការផ្សព្វផ្សាយអំពីសេវាកម្មដល់ប្រជាជនបានយល់ដឹង ដៀសវៀងភាពរកាំរកូសនៅពេលក្រោយ។

៦.៤.៤.៣ មន្ទីរបរិស្ថានខេត្តពោធិ៍សាត់

នៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៥ វេលាម៉ោង០២ និង១៤នាទី រសៀល នៅមន្ទីរបរិស្ថានខេត្តពោធិ៍សាត់ ក្នុងការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន របស់ក្រុមហ៊ុន ភី ភី អាយស៊ី បានជួបពិភាក្សាពិគ្រោះយោបល់ជាមួយលោកប្រធានមន្ទីរបរិស្ថានខេត្តពោធិ៍សាត់លើគម្រោងបញ្ចប់ការសាងសង់បណ្តាញខ្សែកាប្លីអុបទិករបស់ក្រុមហ៊ុន Cambodia Fiber Optic Communication Network Co.,LTD។ ការពិភាក្សានេះធ្វើឡើងដើម្បីទទួលបាននូវមតិយោបល់ ការរិះគន់ ការព្រួយបារម្ភ និងសំណូមពរក៏ដូចជាការគាំទ្ររបស់ស្ថាប័នពាក់ព័ន្ធ និងអជ្ញាធរមូលដ្ឋានទៅនឹងវត្តមានគម្រោងខាងលើ។

- សមាសភាពអ្នកចូលរួមពិភក្សា៖
  - លោក ប៉ាន់ មរកត ប្រធានមន្ទីរបរិស្ថានខេត្តពោធិ៍សាត់
  - ក្រុមការងាររបស់ក្រុមហ៊ុនភីភីអាយស៊ី

-អង្គប្រជុំខាងលើមានខ្លឹមសារទាំងមូលដូចខាងក្រោម៖

លោកមានប្រសាសន៍ថា លោកបានជ្រាបពីប្រវត្តិគម្រោងតាមរយៈ ក្រុមហ៊ុន Cambodia Fiber Optic Communication Network Co.,LTD នោះ ប៉ុន្តែមិនបានជូនដំណឹងដល់ប្រជាពលរដ្ឋ ហើយបានស្នើសុំការអនុញ្ញាតទៅសាលាខេត្ត។

លោកក៏បានមានយោបល់ទៅលើការពាក់ព័ន្ធ និងការពិនិត្យលើ ធនធានព្រៃឈើ និងសត្វព្រៃខ្លាចបាត់បង់ធនធានធម្មជាតិ។ មិនតែប៉ុណ្ណោះក៏មានការប៉ះពាល់ នៅពេលប្រជាពលរដ្ឋធ្វើស្រែ និងធ្វើចំការ ហើយគម្រោងមិនបានពិគ្រោះយោបល់ជាមុនទេ។

លោកបានបន្ថែមថា លោកមានការគាំទ្រ១០០%ទៅលើគម្រោងខ្សែកាប្លីអុបទិកនេះ។

☞ជាចុងក្រោយ លោកធ្វើការសំណូមពរដូចខាងក្រោម៖

- ដោះស្រាយផលប៉ះពាល់ជូនប្រជាពលរដ្ឋ។

៦.៤.៤.៤ មន្ទីរសាធារណៈការ និងដឹកជញ្ជូនខេត្តពោធិ៍សាត់

នៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៥ វេលាម៉ោង០៣ និង៣០នាទី រសៀល នៅមន្ទីរសាធារណៈការ និងដឹកជញ្ជូនខេត្តពោធិ៍សាត់ ក្នុងការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន របស់ក្រុមហ៊ុន កី កី អាយស៊ី បានជួបពិភាក្សា ពិគ្រោះយោបល់ជាមួយលោកប្រធានមន្ទីរសាធារណៈការ និងដឹកជញ្ជូនខេត្តពោធិ៍សាត់ លើគម្រោងបញ្ចប់ការសាងសង់បណ្តាញខ្សែកាប្លីអុបទិករបស់ក្រុមហ៊ុន Cambodia Fiber Optic Communication Network Co.,LTD។ការពិភាក្សានេះធ្វើឡើងដើម្បីទទួលបាននូវមតិយោបល់ ការរិះគន់ ការព្រួយបារម្ភ និងសំណូមពរក៏ដូចជាការគាំទ្ររបស់ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋានទៅនឹងវត្តមានគម្រោងខាងលើ។

- សមាសភាពអ្នកចូលរួមពិភក្សា៖
  - លោក កាង ប៉េងហាក់ ប្រធានមន្ទីរសាធារណៈការ និងដឹកជញ្ជូនខេត្តពោធិ៍សាត់
  - ក្រុមការងាររបស់ក្រុមហ៊ុនកីកីអាយស៊ី

- អង្គប្រជុំខាងលើមានខ្លឹមសារទាំងមូលដូចខាងក្រោម៖

លោកមានប្រសាសន៍ថា លោកបានជ្រាបពីគម្រោងតាមរយៈ ក្រុមហ៊ុន Cambodia Fiber Optic Communication Network Co.,LTD នោះផ្ទាល់ពីក្រុមហ៊ុន តែក្រុមហ៊ុនបានដាក់ខុសគោលដៅដែលមន្ទីរបានដាក់ជូន ហើយប្រាប់ថាដាក់បណ្តោះអាសន្នសិននៅកៀនចិញ្ចើមថ្នល់។

លោកក៏បានមានយោបល់ទៅលើផលប៉ះពាល់របស់គម្រោងសាងសង់គឺ ការជីកកប់នៅក្បែរចិញ្ចើមថ្នល់ពេកមិនបង្ហាប់ឲ្យបានត្រឹមត្រូវ អាចបណ្តាលឲ្យដីនៅចិញ្ចើមថ្នល់រាជ្រាយធ្វើឲ្យបាក់ស្រុតដី។ ហើយវាបានផ្តល់ផលពិបាកក្នុងការពង្រីកផ្លូវនៅថ្ងៃក្រោយ។

លោកបានបន្ថែមថា លោកគាំទ្រ១០០%ទៅលើគម្រោងវិនិយោគខ្សែកាប្លីអុបទិកនេះ។

Draft

☞ជាចុងក្រោយ លោកធ្វើការសំណូមពរដូចខាងក្រោម៖

- ចង់ឲ្យក្រុមហ៊ុនដាក់ឲ្យបានគ្រប់គោលដៅឲ្យអស់តាមដែលមន្ទីរបានដាក់ចុះ និងតាមច្បាប់ដែលបានអនុញ្ញាតឲ្យក្រុមហ៊ុនខ្សែកាប្លីអុបទិកនេះ ។

៦.៥ សន្ទេបមតិ សំណូមពររបស់ អាជ្ញាធរពាក់ព័ន្ធ ប្រជាពលរដ្ឋ និងដំណោះស្រាយម្ចាស់គម្រោង

តារាង ៦.១៖ សង្ខេបមតិ សំណូមពរ របស់ អាជ្ញាធរពាក់ព័ន្ធ និងប្រជាជន និងដំណោះស្រាយម្ចាស់ គម្រោង

មតិដែលបាននិងបញ្ហាលើកឡើង	សំណូមពរដែលបានលើកឡើង	ដំណោះស្រាយរួមរបស់គម្រោង
គាំទ្រ១០០ភាគរយ ព្រោះថា៖ – គម្រោងបានបញ្ចប់ទៅដោយរលូន ដោយពុំមានបញ្ហាទំនាស់ជាមួយនឹងប្រជាជន។ – គម្រោងនឹងជួយធ្វើអោយប្រជាជនទទួលបាននូវពត៌មានចំណេះដឹង និងចំណេះធ្វើសំរាប់កសាងជីវភាពគ្រួសារអោយកាន់តែធូរធារ – ធ្វើអោយភូមិ ឃុំមានការរីកចម្រើន – ការសាងសង់មិនមានផលប៉ះពាល់ធំដុំដល់ការបង្កើនផលរបស់ប្រជាជនទេព្រោះការកប់ខ្សែកាប្លីទៅក្នុងដីមានជម្រៅប្រមាណជា ១,២ ម៉ែត្រប៉ុណ្ណោះ	– សូមអោយក្រុមហ៊ុនផ្តល់ដំណឹងជាមុន មុននឹងធ្វើការសាងសង់នៅលើកក្រោយទៀត – សូមឲ្យក្រុមហ៊ុនជួយបំពេញបែបបទរដ្ឋបាលក្នុងការទំនាក់ទំនងជាមួយអាជ្ញាធរ ឲ្យបានគ្រប់តំរូវការនៃបែបបទរដ្ឋបាល – សូមអោយក្រុមហ៊ុនធ្វើការបោះបង្គោលចំណាំត្រង់ចំណុចដែលខ្សែកាប្លីរត់ឆ្លងកាត់ផ្លូវ – សូមអោយក្រុមហ៊ុនមកធ្វើការដោះស្រាយអោយបានឆាប់រហ័ស នៅពេលមានការទំនាក់ទំនងពីអាជ្ញាធរមូលដ្ឋាន – សូមអោយក្រុមហ៊ុនធ្វើការសងសំណងទៅកាន់ប្រជាជនដែលរងផលប៉ះពាល់ពីគម្រោងអោយបានសមស្រប – សូមអោយក្រុមហ៊ុនធ្វើការសាងសង់ នូវកន្លែងដែលមានផលប៉ះពាល់ឡើងវិញអោយបានល្អដូចដើម – សូមអោយក្រុមហ៊ុនដំណើរការខ្សែកាប្លីអោយបានកាន់តែឆាប់ប្រើប្រាស់ – សូមអោយក្រុមហ៊ុនធ្វើការផ្សព្វផ្សាយពីគុណសម្បត្តិគុណវិបត្តិ សេវាកម្ម និងតម្លៃរបស់ខ្សែកាប្លីអុបទិកទៅដល់ប្រជាពលរដ្ឋ និងអាជ្ញាធរ។ – សំណូមពរអោយតម្លៃនៃសេវាកម្មខ្សែកាប្លីអុបទិកមានតម្លៃថោកសមរម្យ – សូមក្រុមហ៊ុនសហការណ៍ជាមួយមន្ទីរដំនាញសង់ខ្សែកាប្លីអុបទិកឲ្យដល់តំបន់គោលដៅនិង	– គម្រោងនឹងចាប់ផ្តើមដំណើរការសេវាកម្មខ្សែកាប្លីអុបទិកអោយបានប្រើប្រាស់នៅ២ឆ្នាំបន្ទាប់ពីសាងសង់រួចរាល់ – គម្រោងនឹងចែកចាយ Collendar អោយម្ចាស់ក្បាលដីនៅរៀងរាល់១ឆ្នាំម្តង – គម្រោងនឹងធ្វើការទូទាត់សំណងទៅកាន់ប្រជាពលរដ្ឋដែលមានការប៉ះពាល់អោយបានសមស្របទៅនឹងលក្ខខណ្ឌនៃគោលការណ៍នយោបាយច្បាប់។

– ខ្សែកាប្លឺអុបទិកមានប្រយោជន៍ច្រើនដល់ប្រជាពលរដ្ឋ ព្រោះវាអាចភ្ជាប់បានជាមួយទាំងទូរទស្សន៍ ទូរស័ព្ទដៃ កាម៉េរ៉ាសុវត្ថិភាព និងអ៊ីនធើណេត ភ្ជាប់ជាមួយនឹងសេវាកម្មដែលមានល្បឿនលឿន។	ដោះស្រាយសំណងឲ្យដាច់ស្រាច់ចាំសង់។	
ការលើកឡើងផលប៉ះពាល់អវិជ្ជមានដោយសារគម្រោង៖ – នៅកន្លែងខ្លះការថែទាំខ្សែកាប្លឺអុបទិកធ្វើឡើងដោយមិនមានការម៉ត់ចត់ ដែលធ្វើអោយប៉ះពាល់ដល់ដីស្រែរបស់ប្រជាពលរដ្ឋ ជាហេតុដែលពួកគាត់ពិបាកនឹងធ្វើការស្នូង រាស់ – មិនបានធ្វើការផ្សព្វផ្សាយដល់ប្រជាជនមូលដ្ឋានធ្វើអោយគាត់មិនមានការយល់ដឹងអំពីគម្រោង – ក្រុមហ៊ុនមិនមានផ្តល់ជាសំណងដល់ប្រជាពលរដ្ឋដែល	– សូមឲ្យការសិក្សានេះមានការចូលរួមពីអាជ្ញាធរភូមិឃុំ/សង្កាត់ និងអ្នកប៉ះពាល់ ។ – សូមឲ្យកត់ត្រានូវសំណូមពរអ្នកប៉ះពាល់មកពិចារណា និងដោះស្រាយឲ្យបានសមស្រប។ – សូមឲ្យក្រុមហ៊ុនសាងសង់ត្រូវអនុវត្តន៍តាមបទដ្ឋានបច្ចេកទេសទំនើប ។ – សូមឲ្យមានការត្រួតពិនិត្យឲ្យបានត្រឹមត្រូវពីអ្នកជំនាញកម្ពុជា ។ – សូមឲ្យមានការកំណត់អាយុកាលរបស់សំណង់នេះ – សូមឲ្យមានផែនការថែទាំ និងជួសជុល ។ – សូមឲ្យមានប្រព័ន្ធការពារសុវត្ថិភាពឲ្យបានគ្រប់គ្រាន់ ។ – សុំអោយមានការការពារការស្រូបរន្ធះ ព្រោះការកប់ភាគច្រើនកប់នៅលើដីស្រែ	ក្រុមការងារ CFOCN ដែលមានបទពិសោធន៍គ្រប់គ្រាន់ប្រាជ្ញកជាមានទំនាក់ទំនងក្នុងការស្នើរសុំឲ្យមានការចូលរួមពីសំណាក់អ្នកពាក់ព័ន្ធក្នុងការប្រជុំពិភាក្សាទទួលជោគជ័យ ៖ – កំណត់ត្រាដែលទទួលបានពីការសិក្សានិងលើកយកមកពិភាក្សាកម្រិតថ្នាក់ខេត្ត ស្រុក ឃុំ និងជាមួយប្រជាជនផ្ទាល់ ។ – មានត្រួតពិនិត្យដោយទីប្រឹក្សាបច្ចេកទេសឯករាជ្យមួយដែលមានគុណភាព ។ – ក្រុមហ៊ុនសាងសង់និងធានាគុណភាពទៅតាមប្លង់រចនាគម្រោងដែលអាចទប់ទល់នូវកម្រិតខ្ពស់ពីការស្រូបរន្ធះ – ក្រុមហ៊ុនសម្របសម្រួលជាមួយអាជ្ញាធរ និងដោះស្រាយសំណងជាក់ស្តែងជាមួយម្ចាស់ដី ។

មានការប៉ះពាល់ពីគម្រោង – មិនមានដំណោះស្រាយណាមួយច្បាស់លាស់ជាមួយប្រជាពលរដ្ឋបន្ទាប់ពីធ្វើការសាងសង់រួចរាល់ – ការត្រួតពិនិត្យបច្ចេកទេសសាង់សង់របស់កម្ពុជានៅមានកម្រឹត ។ – ខ្លាចមានការប៉ះពាល់ពីរន្ទះព្រោះការកប់ភាគច្រើននៅលើដីស្រែរបស់ប្រជាជន – ផលប៉ះពាល់បរិស្ថានធនធានធម្មជាតិមានតិចតួច ។		
– ការប៉ះពាល់ត្រូវមានសំណងសមស្របនិងតាមសំណូមពរ។ – ការប៉ះពាល់ត្រូវមានសំណងតាមតម្លៃទីផ្សារ ។ – ការប៉ះពាល់ត្រូវមានសំណងតាមគោលនយោបាយ។	– សូមឲ្យម្ចាស់គម្រោងពិនិត្យ និងដោះស្រាយសំណងឲ្យបានសមស្រប/តាមការព្រមព្រៀងជាមួយអ្នកប៉ះពាល់ និងតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ។	សំណងប៉ះពាល់មាន៣ប្រភេទដូចខាងក្រោម៖ ប្រភេទសំណងដីសម្រាប់សាងសង់ – តម្លៃដីតាមតំបន់ – ប្រភេទដី – ច្បាប់របស់ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់

៦.៦ សេចក្តីសន្និដ្ឋាន លើលទ្ធផលពីគ្រោះយោបល់សាធារណៈ

តាមយោបល់ និងសំណូមពរខាងលើអំពីផលឆ្លងតាមលទ្ធផលនៃការផ្តល់មតិបរិស្ថាន និងសង្គមដំបូងនៃគម្រោងបណ្តាញទំនាក់ទំនងខ្សែកាប្លីអុបទិកទូទាំងប្រទេសកម្ពុជានេះ បានបង្ហាញថាឥទ្ធិពលនៃគម្រោងមាន២គឺវិជ្ជមាន និងអវិជ្ជមាន។ ការសន្និដ្ឋានលើឥទ្ធិពលវិជ្ជមាន និងអវិជ្ជមានមានដូចខាងក្រោម៖

Draft

៦.៦.១ ឥទ្ធិពលវិជ្ជមាននៃគម្រោង

អំពីផលប៉ះពាល់វិជ្ជមានដោយសារគម្រោង

- មានការចូលរួមសហការល្អជាមួយអាជ្ញាធរមូលដ្ឋានចំនួន ៧ឃុំ ៥ស្រុក/ក្រុង និងមានប្រជាពលរដ្ឋដែលចូលផ្តល់មតិសរុប៧៨នាក់ ដោយមានការគាំទ្រលើគម្រោងសាងសង់១០០% ប៉ន្តែពួកគាត់មានសំណូមពរឲ្យមានការកប់លប់ដី និងមានសងសំណងឲ្យបានត្រឹមត្រូវដល់ពួកគាត់។
- ប្រជាពលរដ្ឋសង្ឃឹមថា នឹងបានទទួលបានខ្សែកាប្លីអុបទិកប្រើប្រាស់ឆាប់រហ័ស ល្បឿនលឿន និងតម្លៃថោកសមរម្យ ។
- ប្រជាពលរដ្ឋអាចនឹងមានភាពងាយស្រួលក្នុងការប្រើប្រាស់សេវាកម្មតែមួយប្រភេទតែអាចភ្ជាប់ទៅនឹងសម្ភារៈគ្រប់ប្រភេទដូចជា ទូរទស្សន៍ ទូរសព្ទដៃ កាមេរ៉ាសុវត្ថិភាព និងអ៊ីនធើណេត។
- ការប្រើប្រាស់សម្ភារៈ-ឧបករណ៍អេឡិចត្រូនិចទំនើបៗ នៅតាមលំនៅដ្ឋាន នឹងមានការកើនឡើង ។
- ប្រជាពលរដ្ឋមានការរីកចម្រើនខាងចំណេះដឹងទូទៅ និងពត៌មានបានយ៉ាងឆាប់រហ័សដោយសារមានសេវាកម្មអេឡិចត្រូនិចប្រើប្រាស់គ្រប់គ្រាន់ ហើយមានតម្លៃថោក ។
- ប្រជាពលរដ្ឋមានភាពត្រេកអរដោយមានខ្សែកាប្លីប្រើប្រាស់គ្រប់គ្រាន់ជាពិសេសប្រជាពលរដ្ឋនៅតាមស្រុកស្រែពុំសូវមានជីភាពធូរធារ ដែលត្រូវការខ្សែកាប្លីសំរាប់ប្រើប្រាស់ ។
- ធ្វើអោយភូមិ ឃុំមានការរីកចម្រើន
- ការសាងសង់នៅក្នុងតំបន់គោលដៅ និងដោះស្រាយសំណងឲ្យហើយមុននឹងការសាងសង់ខ្សែកាប្លីអុបទិក។

៦.៦.២ ឥទ្ធិពលអវិជ្ជមាននៃគម្រោង

អំពីផលប៉ះពាល់អវិជ្ជមានដោយសារគម្រោង៖

- ប៉ះពាល់ដល់សតិអារម្មណ៍របស់ប្រជាជននៅក្បែរគម្រោង ដោយមានការព្រួយបារម្ភអំពីគ្រោះថ្នាក់ដែលអាចកើតមានឡើងដោយសារគម្រោង ។
- អាចនឹងប៉ះពាល់ដីស្រែ ចំការ និងលំនៅដ្ឋានរបស់ប្រជាពលរដ្ឋដែលរស់នៅតាមបណ្តាយផ្លូវដែលត្រូវធ្វើការសាងសង់។
- ការប៉ះពាល់អវិជ្ជមានលើធនធានបរិស្ថានរូបសាស្ត្រ និងធនធានជីវសាស្ត្រដោយសារគម្រោងនេះ មានកំរិតតិចតួច ។
- សិក្សាឲ្យបានច្បាស់លាស់ពីឧតុនិយមរបស់ទីតាំងគម្រោង ជាក់ស្តែងដូចជាគម្រោងខ្យល់ និងកម្រិតសីតុណ្ហភាព បរិយាកាសដែលអាចនិងមានការកើតឡើង និងបង្កបញ្ហាដល់គម្រោង ។
- គម្រោងត្រូវដ្ឋាកនៅរដូវវស្សា ព្រោះមានភ្លៀងធ្លាក់ច្រើនពិបាកនឹងធ្វើការជីកកប់ខ្សែកាប្លី។ ណាមួយជារដូវដែលប្រជាពលរដ្ឋត្រូវធ្វើការ ស្ទូង រាស់។
- កន្លែងខ្លះសាងសង់ដោយមានការធ្វេសប្រហែសធ្វើអោយផុងដីស្រែរបស់ប្រជាពលរដ្ឋ ជាហេតុប៉ះពាល់ដល់ដីស្រែ និងដីលំនៅដ្ឋានរបស់ពួកគាត់។

- ប្រជាពលរដ្ឋភាគច្រើនមិនមានការយល់ដឹងពីគម្រោង ព្រោះក្រុមហ៊ុនមិនចុះធ្វើការផ្សព្វផ្សាយជាមុន។
- ការផ្តល់សំណងដល់ប្រជាពលរដ្ឋទៅលើទ្រព្យសម្បត្តិរបស់ពួកគាត់នៅមានកម្រិត ធ្វើអោយពួកគាត់មានភាពមិនសប្បាយចិត្តខ្លះៗទៅលើគម្រោងសាងសង់
- ការត្រួតពិនិត្យបច្ចេកទេសនៅមានកម្រិតនៅឡើយ

៦.៦.៣ ដំណោះស្រាយលើផលប៉ះពាល់អវិជ្ជមាននៃគម្រោង

អំពីដំណោះស្រាយ

- ជៀសវៀងការប៉ះពាល់ដល់ធនធានបរិស្ថានរូបសាស្ត្រ និងជីវសាស្ត្រអោយមានកំរិតតិចតួចបំផុត។
- ធ្វើការដោះស្រាយដល់ប្រជាពលរដ្ឋ និងអាជ្ញាធរមូលដ្ឋាននៅពេលដែលមានការប្តឹងមកក្រុមហ៊ុន។
- ម្ចាស់គម្រោងត្រូវមានការសិក្សាកំណត់នូវបទដ្ឋានបច្ចេកទេសមួយត្រឹមត្រូវ ចំពោះការការពារន្ទះ ហើយការសាងសង់ត្រូវមានការគ្រប់គ្រងឲ្យបានល្អ
  ដើម្បីធានាដល់ការសាងសង់តាមបទដ្ឋានបច្ចេកទេស ។
- ត្រៀមកញ្ចប់ថវិការសម្រាប់ផលប៉ះពាល់ខ្សែឆ្លងកាត់ផ្លូវមួយចំនួន និងការដឹកជញ្ជូនសម្ភារៈធ្ងន់ៗ នៅពេលសាងសង់គម្រោងដែលអាច និងមានការខូចខាតពេលដឹកសម្ភារៈឬឧបករណ៍សំណង់ទាំងនោះ ។
- ត្រូវមានកញ្ចប់ថវិការសម្រាប់ជួសជុល និងថែទាំ ពេលការសាងសង់ត្រូវបានបញ្ចប់ គឺជាត្រូវការចាំបាច់ ដើម្បីធានាមិនបង្កឲ្យមានគ្រោះថ្នាក់ផ្សេងៗដល់បរិស្ថាន និងសង្គម ។
- ម្ចាស់គម្រោងត្រូវមានគោលការណ៍រួមដើម្បីដោះស្រាយសំណងដល់អ្នកប៉ះពាល់ឲ្យបានយុត្តិធម៌ និងសមរម្យ ។
- ស្វែងរកដំណោះស្រាយ នៅពេលដែលមានផលប៉ះពាល់ ដោយមានការចូលរួមពីអាជ្ញាធរតាមមូលដ្ឋាន និងមន្ទីរដែលពាក់ព័ន្ធដើម្បីកាត់បន្ថយឲ្យនៅកម្រិតអប្បបរិមា ។
- ការផ្សព្វផ្សាយពីគម្រោងដើម្បីអោយប្រជាជនមានការយល់ដឹង និងមិនមានការព្រួយបារម្ភចំពោះការកប់ខ្សែកាប្លឺ
- សហការជាមួយអាជ្ញាធរមូលដ្ឋានភូមិ ឃុំ ស្រុក ក្នុងការសាងសង់

Draft

ជំពូក ៧
ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង និង វិធានការកាត់បន្ថយ

Draft

ជំពូក ៧
ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង និងវិធានការកាត់បន្ថយ

៧.១ វិធីសាស្ត្រ

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម គឺជាអង្កេត សិក្សាស្រាវជ្រាវ និងការប្រជុំពិភាក្សាជាមួយសហគមន៍/ប្រជាជន អាជ្ញាធរថ្នាក់ក្រោមជាតិ អាជ្ញាធរមូលដ្ឋាន លើទីតាំងគម្រោង សមាសភាពគម្រោង ការងារសាងសង់គម្រោង និងកិច្ចដំណើរការរបស់វា ដើម្បីកំណត់រកហេតុប៉ះពាល់បរិស្ថានធម្មជាតិ និងសង្គម នៅក្នុងដំណាក់ប្រតិបត្តិ និងថែទាំគម្រោង (Project Operation & Maintenance) និងដំណាក់កាលបញ្ចប់គម្រោង (Project Closure)។

ហេតុប៉ះពាល់បរិស្ថាន និងសង្គមទាំងនោះត្រូវបានរកវិធានការកាត់បន្ថយឱ្យកម្រិតអប្បបរមា និងធ្វើផែនការគ្រប់គ្រងបរិស្ថានទៅតាមដំណាក់កាលនីមួយៗរបស់គម្រោងដោយមានការអនុវត្តន៍ពីម្ចាស់គម្រោង រួមទាំងកិច្ចសហការត្រួតពិនិត្យពីបណ្តាស្ថាប័នជំនាញពាក់ព័ន្ធថ្នាក់ជាតិដូចជា ក្រសួងបរិស្ថាន ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយការត្រួតពិនិត្យនេះក៏មានការចូលរួមពីស្ថាប័នថ្នាក់ក្រោមជាតិផងដែរ។

ក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ក្រុមការងារបានប្រើប្រាស់តារាង Check List និងប្រកាសលេខ ៣៧៦ ប្រកបស្ដ ស្តីពីគោលការណ៍ណែនាំទូទៅក្នុងការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញ ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០០៩។ ដើម្បីកំណត់ទំហំនៃការប៉ះពាល់បរិស្ថានរួចជ្រើសយកហេតុប៉ះពាល់បរិស្ថានអវិជ្ជមានណាដែលមានកម្រិតមធ្យម និងខ្លាំងមកធ្វើវិធានការកាត់បន្ថយហេតុប៉ះពាល់ឱ្យដល់កម្រិតអប្បបរមា ដូចមានបង្ហាញក្នុងតារាង Checklist ខាងក្រោម។

តារាងទី៧.១៖ តារាង Checklist ទីតាំង និងស្ថានភាពប៉ះពាល់នៃគម្រោងសាងសង់បណ្តាញខ្សែកាប្លីអុបទិក

ទីតាំងប៉ះពាល់ និងការប៉ះពាល់	មាន	គ្មាន	កំណត់សំគាល់
ទីតាំងមរតកវប្បធម៌		√	
តំបន់ការពារ/អភិរក្ស		√	
តំបន់ដីសើម		√	
ព្រៃលិចទឹក		√	
តំបន់ពិសេសសម្រាប់ការពារ/អភិរក្សជីវចំរុះ		√	
ធ្វើឱ្យបាត់បង់សោភ័ណ្ឌភាព ទេសភាព ហើយមានការញ្ចេញសំណល់ច្រើនដែរឬទេ?		√	
ការទន្ទ្រានចូលតំបន់ប្រព័ន្ធអេកូឡូស៊ីសំខាន់ៗដែរឬទេ?		√	

ការសាងសង់មានការប៉ះពាល់ផ្លូវទឹកសំខាន់ៗ ដែលធ្វើឱ្យប្រែប្រួលដល់ប្រព័ន្ធជលសាស្ត្រដោយបង្កើនល្បាប់ដោយសារការហូរច្រោះនៅកន្លែងសាងសង់ដែរឬទេ?	√		អាចមានការហូរច្រោះនៅពេលជីកដីដើម្បីកប់ខ្សែកាប្លឺចូលទៅក្នុងដី
មានការខូចខាតដល់គុណភាពទឹកលើដី/ក្រោមដីដោយសារកាកសំណល់រឹង/រាវដែលបញ្ចេញពីកន្លែងសាងសង់ដែរឬទេ?	√		អាចមានការប៉ះពាល់ដល់គុណភាពទឹកលើដី/ក្រោមដីដោយសារការគ្រប់គ្រងសំណល់រឹង/រាវមិនបានត្រឹមត្រូវ ឬខ្វះបង្គន់អនាម័យ និងសកម្មភាពដែលបង្កឱ្យមានការហូរច្រោះ
ការបង្កើនការបំពុលខ្យល់ដោយសារការងារជីកដីដែលឬទេ?		√	
តើមានការបំពុលដោយសារធាតុគីមីដោយសារការប្រើប្រាស់សារធាតុនេះសម្រាប់ការសម្អាតរុក្ខជាតិដែរឬទេ?		√	
តើមានការបញ្ចេញសំឡេង និងរំញ័រដោយសារការងារជីកកាយដីដែរទេ?	√		អាចមានការរំខានដោយសម្លេង និងរំញ័រដែលការកើតពីគ្រឿងម៉ាស៊ីនក្នុងដំណើរការការសាងសង់
តើមានការបំណាស់ប្តូរលំនៅដ្ឋានដោយមិនស្ម័គ្រចិត្តរបស់ប្រជាពលរដ្ឋដែរឬទេ?		√	
តើមានទំនាស់សង្គមដែលទាក់ទងទៅនឹងកម្រិតជីវភាពរស់នៅធម្មតារបស់ប្រជាពលរដ្ឋដោយសារការរាំងស្ទះផ្លូវឆ្លាប់ធ្វើចរាចរដែរឬទេ?	√		អាចមានកករស្ទះចរាចរតិចតួចនៅការដ្ឋានជីកកាយដីដាក់ខ្សែកាប្លឺអុបទិក
តើអាចកើតមានគ្រោះថ្នាក់ចរាចរដោយសារការបើកបរដឹកជញ្ជូនសម្ភារៈក្នុងការងារសាងសង់ដែរឬទេ?	√		អាចកើតមានគ្រោះថ្នាក់ចរាចរដោយសារការធ្វេសប្រហែសក្នុងការបើកបរដឹកជញ្ជូនសម្ភារៈសំណង់ និងសម្ភារៈរបស់គម្រោង
តើមានការខ្វះអនាម័យ និងខ្វះការគ្រប់គ្រងសំណល់រឹង/រាវនៅកន្លែងការដ្ឋានសាងសង់ដែលធ្វើឱ្យប៉ះពាល់ដល់សុខភាពកម្មករដែរឬទេ?	√		អាចនឹងកើតមានការប៉ះពាល់ដល់សុខភាពកម្មករ ឬប្រជាពលរដ្ឋក្នុងតំបន់គម្រោងដោយសារការមិនយកចិត្តទុក ឬធ្វេសប្រហែសពីក្រុមហ៊ុនក្នុងការអប់រំអនាម័យការត្រួតពិនិត្យសុខភាព
តើមានការប៉ះពាល់ដល់បរិស្ថានដែលទាក់ទងទៅនឹងការថែទាំខ្សែកាប្លឺអុបទិកដែរឬទេ?		√	
តើមានគ្រោះថ្នាក់ដល់សុខភាពប្រជាពលរដ្ឋដោយសារដែនអេឡិចត្រូម៉ាញ៉េទិក ដែរឬទេ?		√	

Draft

ការប៉ះពាល់ដីលំនៅដ្ឋាន ដីស្រែ ដីចំការ ដីសាធារណៈ ដែលស្ថិតនៅក្នុងដីចំណីផ្លូវ	√		
ការប៉ះពាល់ដីលំនៅដ្ឋាន ដីស្រែ ដីចំការ ដីសាធារណៈ កាត់ផ្លូវ របងផ្ទះ ផ្ទះ ។ល។ ដែលស្ថិតនៅក្នុងដីចំណីផ្លូវ	√		ប៉ះពាល់ដំណាំ កាត់បេតុង ខួងក្រោមផ្ទះ របង កាត់ផ្ទះ។ល។ ប៉ះពាល់សតិអារម្មណ៍របស់ប្រជាពលរដ្ឋលើដីលំនៅដ្ឋាន ដីស្រែ ដីចំការ ដីសាធារណៈ កាត់ផ្លូវ របងផ្ទះ ផ្ទះ ។ល។
ការប៉ះពាល់រុក្ខជាតិ ដែលស្ថិតនៅក្នុងដីចំណីផ្លូវ	√		ការដឹកកប់ខ្សែកាប្លីប៉ះពាល់ដោយយកចេញខាមិនបាន
ការប៉ះពាល់សត្វ ដែលស្ថិតនៅក្បែរៗក្នុងដីចំណីផ្លូវ		√	ករណីកម្មករសាងសង់ខ្សែកាប្លីអុបទិកចូលទៅបរបាញ់ ឬទិញសត្វ

៧.២ ហេតុប៉ះពាល់អវិជ្ជមានសំខាន់ៗ និងវិធានការកាត់បន្ថយ

គម្រោងកំពុងសាងសង់បណ្តាញខ្សែកាប្លីអុបទិក បានផ្តោតយកចិត្តទុកដាក់ទៅលើបរិស្ថានរូបសាស្ត្រ ជីវសាស្ត្រ និងសង្គម។ ហេតុប៉ះពាល់ធនធានរូបសាស្ត្រ ជីវសាស្ត្រ និងសង្គម ត្រូវបានកំណត់ដោយផ្អែកលើការសិក្សាស្រាវជ្រាវនៅមូលដ្ឋាន ព័ត៌មានលម្អិតពីគម្រោង និងព័ត៌មានជាមូលដ្ឋានមួយចំនួនទៀត។ ផ្អែកតាមការចុះអង្កេតសិក្សាលើធនធានបរិស្ថានរូបសាស្ត្រ ជីវសាស្ត្រ និងសង្គម នៅក្នុងតំបន់គម្រោងឃើញថា សក្តានុពលនៃហេតុប៉ះពាល់បរិស្ថានត្រូវបានរំពឹងទុកថា នឹងកើតមានឡើងដោយសារសកម្មភាពពេលប្រតិបត្តិ និងពេលបញ្ចប់គម្រោង។ វិធានការកាត់បន្ថយសម្រាប់ហេតុប៉ះពាល់អវិជ្ជមានត្រូវបានរៀបចំតាមសមាសភាពបរិស្ថាននីមួយៗតាមលំដាប់លំដោយដូចតទៅ៖

៧.២.១ ដំណាក់កាលប្រតិបត្តិ និងថៃទាំគម្រោង

ក. ធនធានរូបសាស្ត្រ

- ❖ ការហូរច្រោះដី

<u>ហេតុប៉ះពាល់អវិជ្ជមាន</u>

- នៅក្នុងដំណាក់កាលនេះ អាចនឹងមានការដឹកកាយដីដើម្បីរំកិល ឬជួសជុលខ្សែកាប្លីអុបទិក ដែលសកម្មភាពនេះ នឹងធ្វើឱ្យមានការហូរច្រោះដី ជាពិសេស សកម្មភាពអនុវត្តនៅរដូវវស្សា។

<u>វិធានការកាត់បន្ថយ</u>

- អនុវត្តសកម្មភាពដឹករំកិលខ្សែកាប្លីនៅក្នុងរដូវប្រាំង ឬថ្ងៃដែលមិនមានភ្លៀងធ្លាក់ ហើយនឹងការលុបដីដោយបង្គាប់វិញភ្លាមៗ។

- ❖ ការបំពុលខ្យល់

នៅក្នុងដំណាក់កាលនេះមិនអាចនឹងមានផលប៉ះពាល់ដល់គុណភាពខ្យល់នោះទេ។

❖ ការបំពុលទឹក

ហេតុប៉ះពាល់អវិជ្ជមាន

- នៅក្នុងដំណាក់កាលនេះ អាចមានការបំពុលទឹកតិចតួច ក្នុងករណីដែលមានការជីកកាយដី ដើម្បីរំកិលខ្សែកាប្លី។

វិធានការកាត់បន្ថយ

- អនុវត្តតាមវិធានការកាត់បន្ថយការហូរច្រោះដី។

❖ សំណល់រឹង

នៅក្នុងដំណាក់កាលនេះ មិនមានការបង្កើតជាសំណល់រឹងដោយសារសកម្មភាពគម្រោងទេ។

❖ ការបំពុលដី

នៅក្នុងដំណាក់កាលនេះ មិនមានការបង្កើតជាសំណល់រឹងដោយសារសកម្មភាពគម្រោងទេ។

❖ សម្លេង និងរំញ័រ

ហេតុប៉ះពាល់អវិជ្ជមាន

នៅក្នុងដំណាក់កាលនេះ មិនមានការបង្កើតជាសំណល់រឹងដោយសារសកម្មភាពគម្រោងទេ។

ខ. ធនធានជីវសាស្ត្រ

នៅក្នុងដំណាក់កាលនេះ ការប៉ះពាល់ទៅលើធនធានជីវសាស្ត្រនឹងមិនត្រូវកើតមានទៀតនោះទេ ដោយការប្រតិបត្តិរបស់គម្រោង គឺត្រូវបានធ្វើឡើងតែនៅតំបន់ទីប្រជុំតែប៉ុណ្ណោះ។

គ. ធនធានសង្គម

❖ ប្រពៃណី វប្បធម៌ និងសាសនា

ហេតុប៉ះពាល់អវិជ្ជមាន

- ក្នុងដំណាក់កាលនេះ អាចនឹងមានការប៉ះពាល់ដល់ទំនៀមទំលាប់ប្រពៃណីរបស់ ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់ដែលក្រុមហ៊ុនយកបុគ្គលិក/កម្មកពីតំបន់ផ្សេង ឬជនបរទេសមកធ្វើការ។

វិធានការកាត់បន្ថយ

- ក្រុមហ៊ុនត្រូវធ្វើការណែនាំអប់រំដល់បុគ្គលិក/កម្មកររបស់គម្រោងឱ្យមានការគោរពទំនៀមទំលាប់ប្រពៃណី និងជំនឿរបស់ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់គម្រោង។
- ក្រុមហ៊ុនត្រូវដាក់ពិន័យដល់បុគ្គលិ/កម្មកគម្រោងដែលបំពានលើទំនៀមទំលាប់ប្រពៃណី វប្បធម៌ និងជំនឿសាសនារបស់ប្រជាពលរដ្ឋក្នុងតំបន់។

❖ ផ្លូវគមនាគមន៍

ហេតុប៉ះពាល់អវិជ្ជមាន

- អាចនឹងមានការខូចផ្លូវតិចតួច ដោយសារសកម្មភាពជីកកាយដើម្បីធ្វើការជួសជុល និងការរំកិលខ្សែកាប្លី។

Draft

<u>វិធានការកាត់បន្ថយ</u>

- ក្រុមហ៊ុននឹងជូនដំណឹងទៅអាជ្ញាធរមូលដ្ឋាន និងស្ថាប័នជំនាញនៅពេលមានសកម្មភាពជួសជុល ឬរំកិលខ្សែកាប្ល៏។
- ក្រុមហ៊ុននឹងជួសជុលផ្លូវ ឬចិញ្ចើមផ្លូវភ្លាមៗ ឱ្យដូច ឬល្អជាងសភាពដើមវិញ ក្រោមពីការជួសជុល ឬរំកិលខ្សែកាប្ល៏រួច។

❖ សុខភាពសាធារណៈ:

<u>ហេតុប៉ះពាល់អវិជ្ជមាន</u>

- នៅក្នុងដំណាក់កាលនេះ អាចបង្កឱ្យមានការប៉ះពាល់ដល់សុខុមាលភាពរបស់ប្រជាពលរដ្ឋក្នុងតំបន់ ដោយសារបុគ្គលិក/កម្មករ របស់ក្រុមហ៊ុនអាចចម្លងជំងឺផ្សេងៗ ដល់អ្នកភូមិដូចជា ជំងឺអេដស៍ កាមរោគ។ល។

<u>វិធានការកាត់បន្ថយ</u>

- ក្រុមហ៊ុននឹងធ្វើការអប់រំសុខភាពអនាម័យដល់បុគ្គលិក/កម្មករ ដើម្បីទប់ស្កាត់ជំងឺទាំងនោះកុំឱ្យកើតមាន និងឆ្លងទៅប្រជាពលរដ្ឋក្នុងតំបន់គម្រោង។
- ក្រុមហ៊ុននឹងសហការជាមួយស្ថាប័នសុខាភិបាល ដើម្បីទប់ស្កាត់ជំងឺឆ្លង ដែលកើតឡើងជាយថាហេតុ។

៧.៣ ផលប៉ះពាល់វិជ្ជមាន

គម្រោងវិនិយោគដែលបានស្នើឡើងនេះនឹងផ្តល់នូវផលប្រយោជន៍ជាច្រើនទាំងផ្នែកបរិស្ថាន និងសេដ្ឋកិច្ចសង្គម ដល់បុគ្គលម្នាក់ៗ សហគមន៍ ក៏ដូចជាប្រទេសជាតិទាំងមូល។

៧.៣.១ ការបង្កើតការងារ

គម្រោងនឹងបង្កើតឱកាសការងារដោយផ្ទាល់ជូនដល់ប្រជាជនមូលដ្ឋានក្នុងតំបន់សាងសង់ ដែលនឹងផ្តល់ឱកាសការងារសំខាន់ៗដល់អ្នកដែលមានជំនាញផ្សេងៗ និងអ្នកគ្មានជំនាញ។ ប្រាក់ចំណូលដែលរកបានដោយប្រជាជនមូលដ្ឋាន និងមានឥទ្ធិពលដោយផ្ទាល់ចំពោះសេដ្ឋកិច្ចក្នុងតំបន់ តាមរយៈការផ្តល់ការងារយៈពេលខ្លី ភាគច្រើនដល់កម្មករសំណង់ ហើយក៏អាចកាត់បន្ថយការធ្វើចំណាកស្រុកតាមរដូវកាលរបស់ប្រជាពលរដ្ឋ។ ដើម្បីបង្កើននូវផលប្រយោជន៍ អាទិភាពការងារ និងត្រូវផ្តល់ជូនកម្លាំងពលកម្មក្នុងតំបន់តាមដែលអាចធ្វើទៅបាន។

៧.៣.២ ការពង្រឹងជំនាញ

គម្រោងនេះ មិនត្រឹមតែផ្តល់នូវឱកាសការងារដោយផ្ទាល់ប៉ុណ្ណោះទេ វាថែមទាំងធានាផ្តល់នូវជំនាញបច្ចេកទេស ដល់កម្លាំងពលកម្មក្នុងតំបន់ទៀតផង។ នាពេលអនាគត ជំនាញទាំងអស់នេះអាចជួយបំពេញបន្ថែមដល់ប្រជាពលរដ្ឋ និងអាចឱ្យពួកគាត់ធ្វើការងារដែលពាក់ព័ន្ធផ្សេងៗទៀតបានផងដែរ។

៧.៣.៣ ឱកាសពាណិជ្ជកម្ម និងមុខជំនួញក្នុងតំបន់

គម្រោងនឹងបន្ថែមនូវឱកាសធ្វើជំនួញនៅក្នុងតំបន់សាងសង់បណ្តាញខ្សែកាប្លីអុបទិក ដែលអាចនឹងធ្វើឱ្យមានកំណើនតម្រូវការអាហារ និងវត្ថុប្រើប្រាស់ផ្សេងៗ នៅជុំវិញការដ្ឋានសាងសង់។ ទាំងនឹងសបញ្ជាក់ឱ្យឃើញថា គម្រោងនេះជួយឱ្យបានកំណើនពាណិជ្ជកម្ម និងផ្នែកមុខជំនួញ។

Draft

តារាងទី៧.២ ៖ សង្ខេបទំហំនៃហេតុប៉ះពាល់អវិជ្ជមាន និងវិធានការកាត់បន្ថយ

ធនធានបរិស្ថាន និងសង្គម	ហេតុប៉ះពាល់អវិជ្ជមាន	កម្រិតនៃការប៉ះពាល់			វិធានការកាត់បន្ថយ
		តិច	មធ្យម	ខ្លាំង	
ដំណាក់កាលប្រតិបត្តិ និងថែទាំគម្រោង					
ធនធានរូបសាស្ត្រ					
ការហូរច្រោះដី	– នៅក្នុងដំណាក់កាលនេះ អាចនឹងមាន ការជីកកកាយដីដើម្បីរំកិល ឬជួសជុល ខ្សែកាប្លីអុបទិក ដែលសកម្មភាពនេះ នឹងធ្វើឱ្យមានការហូរច្រោះដី ជាពិសេស សកម្មភាពអនុវត្តនៅរដូវវស្សា។	√			– អនុវត្តសកម្មភាពជីករំកិលខ្សែកាប្លីនៅក្នុងរដូវប្រាំង ឬថ្ងៃដែលមិនមានភ្លៀងធ្លាក់ ហើយនឹងការលុបដីដោយបង្ហាប់វិញភ្លាមៗ។
ការបំពុលទឹក	– នៅក្នុងដំណាក់កាលនេះ អាចមានការ បំពុលទឹកតិចតួច ក្នុងករណីដែលមាន ការជីកកាយដី ដើម្បីរំកិលខ្សែកាប្លី។	√			– អនុវត្តសកម្មភាពជីករំកិលខ្សែកាប្លីនៅក្នុងរដូវប្រាំង ឬថ្ងៃដែលមិនមានភ្លៀងធ្លាក់ ហើយនឹងការលុបដីដោយបង្ហាប់វិញភ្លាមៗ។
ធនធានសង្គម					
ប្រពៃណី វប្បធម៌ និងសាសនា	– ក្នុងដំណាក់កាលនេះ អាចនឹងមានការ ប៉ះពាល់ដល់ទំនៀមទំលាប់ប្រពៃណី របស់ប្រជាពលរដ្ឋដែលរស់នៅក្នុង តំបន់ដែលក្រុមហ៊ុនយកបុគ្គលិក/ កម្មករពីតំបន់ផ្សេង ឬជន បរទេសមក	√			– ក្រុមហ៊ុនត្រូវធ្វើការណែនាំអប់រំដល់បុគ្គលិក/កម្មកររបស់គម្រោងឱ្យមានការគោរពទំនៀមទំលាប់ ប្រពៃណី និងជំនឿរបស់ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់គម្រោង។ – ក្រុមហ៊ុនត្រូវដាក់ពិន័យដល់បុគ្គលិ/កម្មករគម្រោងដែលបំពានលើទំនៀមទំលាប់ប្រពៃណី វប្បធម៌ និងជំនឿសាសនារបស់ប្រជាពលរដ្ឋក្នុងតំបន់។

	ធ្វើការ។				
ផ្លូវគមនាគមន៍	– អាចនឹងមានការខូចផ្លូវតិចតួច ដោយសារសកម្មភាពជីកកាយដើម្បីធ្វើការជួសជុល និងការរំកិលខ្សែកាប្លី។	√			– ក្រុមហ៊ុននឹងជូនដំណឹងទៅអាជ្ញាធរមូលដ្ឋាន និងស្ថាប័នជំនាញនៅពេលមានសកម្មភាពជួសជុល ឬរំកិលខ្សែកាប្លី។ – ក្រុមហ៊ុននឹងជួសជុលផ្លូវ ឬចិញ្ចើមផ្លូវភ្លាមៗ ឱ្យដូចឬល្អជាង សភាពដើមវិញ ក្រោមពីការជួសជុល ឬរំកិលខ្សែកាប្លីរួច។
សុខភាពសាធារណៈ	– នៅក្នុងដំណាក់កាលនេះ អាចបង្កឱ្យមានការប៉ះពាល់ដល់សុខុមាលភាពរបស់ប្រជាពលរដ្ឋក្នុងតំបន់ ដោយសារបុគ្គលិក/កម្មករ របស់ក្រុមហ៊ុនអាចបម្លងជំងឺផ្សេងៗ ដល់អ្នកភូមិដូចជា ជំងឺអេដស៍ កាមរោគ។ល។				– ក្រុមហ៊ុននឹងធ្វើការអប់រំសុខភាពអនាម័យដល់បុគ្គលិក/កម្មករ ដើម្បីទប់ស្កាត់ជំងឺទាំងនោះកុំឱ្យកើតមាន និងឆ្លងទៅប្រជាពលរដ្ឋក្នុងតំបន់គម្រោង។ – ក្រុមហ៊ុននឹងសហការជាមួយស្ថាប័នសុខាភិបាល ដើម្បីទប់ស្កាត់ជំងឺឆ្លង ដែលកើតឡើងជាយថាហេតុ។

ជំពូក ៨
ផែនការគ្រប់គ្រងបរិស្ថាន

Draft

ជំពូក ៨
ផែនការគ្រប់គ្រងបរិស្ថាន

៨.១ ផែនការគ្រប់គ្រងបរិស្ថាន

ផែនការគ្រប់គ្រងបរិស្ថាន ផ្តល់នូវការរៀបចំស្ថាប័នទទួលខុសត្រូវក្នុងការអនុវត្តផែនការគ្រប់គ្រងបរិស្ថានក្នុងពេលសាងសង់ ពេលដំណើរការ។ គោលបំណងនៃផែនការនេះគឺ ដើម្បីបង្ហាញពីភារៈកិច្ចដែលនឹងត្រូវអនុវត្តដោយស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល នៅថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ ព្រមទាំងផ្តល់ជាយោបល់ ថាតើប៉ារ៉ាម៉ែត្រណាខ្លះដែលនឹងត្រូវអង្កេតតាមដានតាមដំណាក់កាលនីមួយៗរបស់គម្រោង។ គួរកត់សម្គាល់ផងដែរថា ផែនការគ្រប់គ្រងបរិស្ថានត្រូវបានគេចាត់ទុកថា ជាឯកសារប្រតិបត្តិដែលនឹងត្រូវគេធ្វើបច្ចុប្បន្នភាពញឹកញាប់ដោយម្ចាស់គម្រោងក្រោមការពិនិត្យ និងវាយតម្លៃពីក្រសួង/ស្ថាប័នជំនាញ។

ផែនការគ្រប់គ្រងបរិស្ថាន គឺជាដំណើរការមួយក្នុងចំណោមដំណើរការសំខាន់ៗ នៃផែនការគ្រប់គ្រងបរិស្ថាន ដោយរួមបញ្ចូលនូវអ្វីដែលនឹងត្រូវធ្វើការត្រួតពិនិត្យទៅតាមដំណាក់កាលគម្រោង និងអ្នកទទួលខុសត្រូវក្នុងអនុវត្ត។ ផែនការគ្រប់គ្រងបរិស្ថានអាចជួយកែតម្រូវបញ្ហាទាំងឡាយដែលជាលទ្ធផលនៃសកម្មភាពគម្រោង និងអនុញ្ញាតដល់ការអនុវត្តដោយស្ថាបស្ថង់នូវវិធាការត្រឹមត្រូវដែលមានប្រសិទ្ធភាព។ ផែនការនេះមានគោលបំណងក្នុងការវាយតម្លៃលក្ខខណ្ឌអង្កេតតាមដាន និងការអនុវត្តដ៏មានប្រសិទ្ធភាពនូវវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថានដោយឱ្យមានការប្រុងប្រយ័ត្នចំពោះការធ្លាក់ចុះនៃគុណភាពបរិស្ថាន។ លទ្ធផលនៃការអង្កេតតាមដាននឹងក្លាយជាឯកសារអនុវត្តជាក់ស្តែងសម្រាប់ម្ចាស់គម្រោង ដើម្បីការពារការគោរពតាមច្បាប់បរិស្ថានទាំងឡាយ សុវត្ថិភាពការងារ និងការអនុវត្តដ៏សមស្របនៃវិធានការបន្ធូរបន្ថយ។

៨.២ សមាសភាពនៃក្រុមត្រួតពិនិត្យ និងការឃ្លាំមើលវិធានការការពារបរិស្ថាន

សមាសភាពក្រុមការងារអង្កេតតាមដាន និងឃ្លាំមើលលើគម្រោងសាងសង់បណ្តាញខ្សែកាប្លីអុបទិក នេះមានដូចតទៅ៖

១. ក្រសួងបរិស្ថានរួមមាន មន្ត្រីជំនាញតំណាងឱ្យនាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន នាយកដ្ឋានពាក់ព័ន្ធ
២. មន្ត្រីជំនាញតំណាងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
៣. មន្ត្រីជំនាញតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
៤. មន្ត្រីជំនាញតំណាងមន្ទីរបរិស្ថានខេត្តពាក់ព័ន្ធ
៥. មន្ត្រីជំនាញតំណាងមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍
៦. មន្ត្រីតំណាងមន្ទីរធនធានទឹក និងឧតុនិយម
៧. មន្ត្រីតំណាងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
៨. មន្ត្រីតំណាងមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់
៩. អាជ្ញាធរដែនដីខេត្តពាក់ព័ន្ធ

១០. មន្ត្រីតំណាងមន្ទីរសោធាណៈការ និងដឹកជញ្ជូន

សមាសភាពក្រុមការងារខាងលើ មានតួនាទីពិនិត្យតាមដានដោយផ្ទាល់ និងដោយប្រយោល ដើម្បីជួយតំរែតំរង់ និងកែលម្អរាល់ការខ្វះខាតរបស់ម្ចាស់គម្រោងក្នុង ការអនុវត្តន៍វិធានការការពារបរិស្ថានរបស់គម្រោង។

៨.៣ វិធានការសំខាន់ៗសម្រាប់ការពារបរិស្ថាន

យោងតាមអនុក្រឹត្យស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងយោងតាមលទ្ធផលនៃការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថានធម្មជាតិ និងសង្គមជំបូង ដែលបង្កឡើងដោយសារសកម្មភាពនៅដំណាក់កាលសាងសង់ និង ដំណាក់កាលប្រតិបត្តិ និថែទាំ គម្រោងដូចបានរៀបរាប់ក្នុងជំពូកទី៧ ម្ចាស់គម្រោងនឹងរៀបចំកំណត់នូវវិធានការសំខាន់ៗមួយចំនួនសម្រាប់ធ្វើការទប់ស្កាត់ និងកាត់បន្ថយនូវរាល់ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន ដើម្បីធានាបានការគ្រប់គ្រងធនធានបរិស្ថានតំបន់នោះដោយប្រសិទ្ធភាពស្របទៅតាមលក្ខណៈបច្ចេកទេស និងបទដ្ឋានបរិស្ថាន ព្រមទាំងធានាឱ្យគម្រោងអភិវឌ្ឍប្រកបដោយស្ថេរភាពដែលក្នុងនោះរួមមាន៖

- ការរៀបចំផ្នែក ឬក្រុមទទួលខុសត្រូវសម្រាប់ការអនុវត្តផែនការការងារ ដូចជាការចាត់តាំងប្រធានគម្រោង ការជ្រើសរើសទីប្រឹក្សាបច្ចេកទេស ការជ្រើសរើសអ្នកម៉ៅការ ការចាត់តាំងវិស្វករត្រួតពិនិត្យអ្នកម៉ៅការ។
- ពិភាក្សាជាមួយផ្នែកវិស្វកម្មគម្រោងក្នុងការគ្រប់គ្រងប្លង់លម្អិត យោងទៅតាមវិធានការកាត់បន្ថយហេតុប៉ះពាល់អវិជ្ជមាន។
- ការរៀបចំធ្វើផែនការដោះស្រាយជាបន្ទាន់នូវបញ្ហាដែលកើតជាយថាហេតុ។
- កំណត់ពេលវេលាធ្វើការងារឱ្យច្បាស់លាស់ក្នុងកិច្ចការការពារបរិស្ថាន។
- បំពាក់ឧបករណ៍ការពារសុខភាព គ្រោះថ្នាក់ និងគ្រឿងចក្រទំនើបៗតាមបែបផែនបច្ចេកទេស។
- ការពារ និងបង្ការជម្ងឺរាតត្បាតផ្សេងៗ ដោយមានកន្លែងសង្គ្រោះបឋម និងរថយន្តសង្គ្រោះបន្ទាន់។
- ការគ្រប់គ្រងសំណល់រឹងរាវ និងសំណល់សារធាតុពុល។
- ជំរុញឱ្យមានការដាំដើមឈើនៅទីសាធារណៈ ឬតំបន់ជុំវិញតំបន់ការពារទាំងនោះ។
- ធ្វើកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នជំនាញក្នុងការត្រួតពិនិត្យមើលទីតាំងបច្ចេកទេស និងទទួលយកនូវការកែប្រែបច្ចេកទេសណាមួយដែលជំនាញតម្រូវឱ្យធ្វើ។
- ធ្វើការផ្សព្វផ្សាយ និងអប់រំណែនាំអំពីវិធីសាស្ត្រការពារសុខភាពអនាម័យសុវត្ថិភាពការងារដល់បុគ្គលិក/កម្មករគម្រោង។
- ត្រៀមថវិកាបំរុងទុកសម្រាប់ប្រតិបត្តិផែនការគ្រប់គ្រងបរិស្ថាន។

៨.៤ កម្មវិធីអង្កេតតាមដានការអនុវត្តន៍វិធានការការពារបរិស្ថាន

កម្មវិធីអង្កេតតាមដានត្រួតពិនិត្យការអនុវត្តន៍វិធានការការពារបរិស្ថាន (វិធានការកាត់បន្ថយការប៉ះពាល់បរិស្ថានដែលបានចែងក្នុងជំពូក៧ ឬក្នុងទំហំនៃការប៉ះពាល់អវិជ្ជមាន និងវិធានការកាត់បន្ថយ)នេះ និងបញ្ជាក់អំពីកិច្ចការដែលត្រូវអង្កេតតាមដាន និងត្រួតពិនិត្យគម្រោងផងដែរ។ ម៉្យាងទៀត កម្មវិធីនេះនឹងប្រមើលឃ្លាំមើលសកម្មភាព ការអនុវត្តន៍គម្រោងដោយម្ចាស់គម្រោងនៅក្នុងគ្រប់ដំណាក់កាលគម្រោង។ កម្មវិធីនេះ មានដូចក្នុងតារាងខាងក្រោម៖

តារាងទី៨.១៖ ផែនការត្រួតពិនិត្យតាមដានការអនុវត្តន៍ផែនការគ្រប់គ្រងបរិស្ថាន

ធនធានបរិស្ថាន	សកម្មភាពត្រួតពិនិត្យ	ពេលវេលា	ស្ថាប័នទទួលខុសត្រូវ
ធនធានរូបសាស្ត្រ			
ការហូរច្រោះ	– ពិនិត្យមើលការដ្ឋានជីកដីបង្កប់ខ្សែកាប៊្ល តើបានកប់រណ្តៅវិញភ្លាមៗ ដោយមានការបបង្ហាប់ដីដែរឬទេ? – ពិនិត្យនៅតាមការដ្ឋានជីកដី ថាតើមានការជីកដីវាងទីតាំងប្រភពទឹក និងទីតាំងដែលមានជម្រាលចោទដែរឬទេ?	– ក្រុមហ៊ុន – ក្រសួងបរិស្ថាន – ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ – ក្រសួងធនធានទឹក និងឧតុនិយម – អាជ្ញាធរដែនដី	ដំណាក់កាលសាងសង់ ០៣ខែម្តង ដំណាក់កាលប្រតិបត្តិ ០៦ខែម្តង
ប្រព័ន្ធជលសាស្ត្រទឹកលើដី	– ពិនិត្យមើលទីតាំងជាប់ ឬក្បែរប្រភពទឹក ថាតើមានការជីកលុប ឬធ្វើឱ្យខូចទ្រង់ទ្រាយប្រភពទឹកដែរឬទេ?	– ក្រុមហ៊ុន – ក្រសួងបរិស្ថាន – ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ – ក្រសួងធនធានទឹក និងឧតុនិយម – អាជ្ញាធរដែនដី	ដំណាក់កាលសាងសង់ ០៣ខែម្តង ដំណាក់កាលប្រតិបត្តិ ០៦ខែម្តង
ការបំពុលខ្យល់	– ពិនិត្យមើលគុណភាពខ្យល់នៅការដ្ឋានជីកដី តើមានការស្រោចទឹកដែរឬទេ? – ត្រួតពិនិត្យមើលការបញ្ចេញផ្សែងរបស់គ្រឿងចក្រ	– ក្រុមហ៊ុន – ក្រសួងបរិស្ថាន – ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ – អាជ្ញាធរដែនដី	ដំណាក់កាលសាងសង់ ០៣ខែម្តង ដំណាក់កាលប្រតិបត្តិ ០៦ខែម្តង
ការបំពុលទឹក	– ពិនិត្យមើលសំណល់រឹង-រាវនៅការដ្ឋានសាងសង់ និងពិនិត្យកន្លែងចតគ្រឿងចក្រ មានការលេច ឬសាយភាយទៅក្នុងប្រភពទឹកដែរឬទេ?	– ក្រុមហ៊ុន – ក្រសួងបរិស្ថាន – ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ – អាជ្ញាធរដែនដី	ដំណាក់កាលសាងសង់ ០៣ខែម្តង ដំណាក់កាលប្រតិបត្តិ ០៦ខែម្តង

Draft

ការបំពុលដី	– ពិនិត្យមើលសំណល់រឹង-រាវ របស់គម្រោង តើមានការទុកដាក់ត្រឹមដែរទេ? ជាពិសេស សំណល់រឹងមានវេចខ្ចប់ទុកដើម្បីប្រគល់ឱ្យក្រុមហ៊ុនប្រមូលសំណល់ដែរឬទេ?	– ក្រុមហ៊ុន – ក្រសួងបរិស្ថាន – ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ – អាជ្ញាធរដែនដី	ដំណាក់កាលសាងសង់ ០៣ខែម្តង ដំណាក់កាលប្រតិបត្តិ ០៦ខែម្តង
សំឡេង និងរំញ័រ	– ពិនិត្យមើលសំឡេង និងរំញ័រ របស់រថយន្ត គ្រឿងចក្រ និងម៉ាស៊ីនកាត់បេតុង។ – ពិនិត្យពេលវេលាធ្វើការរបស់គម្រោង។	– ក្រុមហ៊ុន – ក្រសួងបរិស្ថាន – ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ – អាជ្ញាធរដែនដី	ដំណាក់កាលសាងសង់ ០៣ខែម្តង ដំណាក់កាលប្រតិបត្តិ ០៦ខែម្តង
ធនធានជីវសាស្ត្រ			
ព្រៃឈើ	– ពិនិត្យមើល តើមានការសហការជាមួយឧទ្យានុរក្ស ឬរដ្ឋបាលព្រៃឈើនៅតំបន់មានព្រៃឈើដែរឬទេ? – ពិនិត្យមើល តើមានការកាប់ដើមឈើដែរឬទេ? ហើយមានការដាំដើមឈើឡើងវិញដែរឬទេ?	– ក្រុមហ៊ុន – ក្រសួងបរិស្ថាន – ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ – រដ្ឋបាលព្រៃឈើ – អាជ្ញាធរដែនដី	ដំណាក់កាលសាងសង់ ០៣ខែម្តង ដំណាក់កាលប្រតិបត្តិ ០៦ខែម្តង
ជីវសាស្ត្រសត្វព្រៃ	– ពិនិត្យមើលសកម្មភាពបរបាញ់សត្វព្រៃពីសំណាក់បុគ្គលិក/កម្មកររដែរឬទេ?	– ក្រុមហ៊ុន – ក្រសួងបរិស្ថាន – ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ – រដ្ឋបាលព្រៃឈើ – អាជ្ញាធរដែនដី	ដំណាក់កាលសាងសង់ ០៣ខែម្តង ដំណាក់កាលប្រតិបត្តិ ០៦ខែម្តង
ជីវសាស្ត្រក្នុងទឹក/មច្ឆជាតិ	– ពិនិត្យមើលសកម្មភាពនេសាទរបស់កម្មករគម្រោង។ – ពិនិត្យមើល តើមានការកាប់រានព្រៃលិចទឹកនៅទីតាំងគម្រោងដែរឬទេ?	– ក្រុមហ៊ុន – ក្រសួងបរិស្ថាន – ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ – រដ្ឋបាលជលផល – អាជ្ញាធរដែនដី	ដំណាក់កាលសាងសង់ ០៣ខែម្តង ដំណាក់កាលប្រតិបត្តិ ០៦ខែម្តង
ធនធានសង្គម			
ការទូទាត់សំណង	– ពិនិត្យមើលទ្រព្យឯកជន/សាធារណៈ: មានការស្តារបនាឡើងវិញ ឬសងដល់ប្រជាពលរដ្ឋ	– ក្រុមហ៊ុន – ក្រសួងបរិស្ថាន – ក្រសួងប្រៃសណីយ៍	ដំណាក់កាលសាងសង់ ០៣ខែម្តង ដំណាក់កាលប្រតិ

Draft

	ដែរឬទេ? – ពិនិត្យនៅការដ្ឋានដែលសាងសង់រួច តើមានការតវ៉ាពីសំណាក់ប្រជាជនដែរឬទេ?	និងទូរគមនាគមន៍ – អាជ្ញាធរដែនដី	បត្តិ ០៦ខែម្តង
ហេដ្ឋារចនាសម្ព័ន្ធ និងសេវា កម្ម ដែលមានស្រាប់	– ពិនិត្យប្រព័ន្ធទឹកស្អាតមានស្រាប់ លូរ បេតុង របងផ្ទះ។ល។ តើមានការខូចខាត ឬបាក់បែកដែរឬទេ?	– ក្រុមហ៊ុន – ក្រសួងបរិស្ថាន – ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ – អាជ្ញាធរដែនដី	ដំណាក់កាលសាងសង់ ០៣ខែម្តង ដំណាក់កាលប្រតិបត្តិ ០៦ខែម្តង
ផ្លូវគមនាគមន៍	– ពិនិត្យការធ្វើចរាចរ ស្លាកសញ្ញានៅតាមការដ្ឋានសាងសង់។ – ពិនិត្យមើលសំឡេង និងរំញ័ររបស់គ្រឿងចក្រ និងយានយន្ត។	– ក្រុមហ៊ុន – ក្រសួងបរិស្ថាន – ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ – មន្ទីរសាធារណៈការ និងដឹកជញ្ជូនខេត្ត – រដ្ឋាករទឹក – អាជ្ញាធរដែនដី	ដំណាក់កាលសាងសង់ ០៣ខែម្តង ដំណាក់កាលប្រតិបត្តិ ០៦ខែម្តង
ទេសភាព	– ពិនិត្យមើលអាចម៍ដីនៅការដ្ឋាន តើមានប្រមូល ឬសម្អាតរួចរាល់ហើយឬនៅ។ – ពិនិត្យមើលនៅការដ្ឋាន តើមានការកាប់ដើមឈើ ឬធ្វើឱ្យខូចសួនច្បារដែរឬទេ?	– ក្រុមហ៊ុន – ក្រសួងបរិស្ថាន – ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ – អាជ្ញាធរដែនដី	ដំណាក់កាលសាងសង់ ០៣ខែម្តង ដំណាក់កាលប្រតិបត្តិ ០៦ខែម្តង
យេនឌ័រ	– ពិនិត្យមើលតើមានការរុះរើអាជីវកម្មរបស់ប្រជាពលរដ្ឋដោយមិនស្ម័គ្រចិត្តដែរទេ? – ជួបសម្ភាសន៍ជាមួយអាជីវកម្ម តើមានប៉ះពាល់ដល់ការប្រកបរបរដែរឬទេ? – ពិនិត្យតើមានការរើសអើងលើស្ត្រីភេទនៅតំបន់គម្រោងដែរឬទេ?	– ក្រុមហ៊ុន – ក្រសួងបរិស្ថាន – ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ – អាជ្ញាធរដែនដី	ដំណាក់កាលសាងសង់ ០៣ខែម្តង ដំណាក់កាលប្រតិបត្តិ ០៦ខែម្តង
ជម្ងឺឆ្លង	– ពិនិត្យមើលលទ្ធផលពិនិត្យសុខភាពរបស់បុគ្គលិក/កម្មករគម្រោង តើតមានជម្ងឺដែលអាចឆ្លងដល់ប្រជាជនក្នុងតំបន់ដែរឬទេ?	– ក្រុមហ៊ុន – ក្រសួងបរិស្ថាន – ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍	ដំណាក់កាលសាងសង់ ០៣ខែម្តង ដំណាក់កាលប្រតិបត្តិ ០៦ខែម្តង

Draft

		– មន្ទីរសុខាភិបាលខេត្ត – អាជ្ញាធរដែនដី	
ស្ថានភាពការងារ	– ត្រួតពិនិត្យការថែរក្សាសុវត្ថិភាពនៅក្នុងតំបន់គម្រោង។ – ត្រួតពិនិត្យការថែទាំសុខភាពរបស់បុគ្គលិក/កម្មករគម្រោង។ – ត្រួតពិនិត្យការជ្រើសរើសបុគ្គលិកកម្មកររបស់ក្រុមហ៊ុន តើមានការផ្តល់អាទិភាពដល់ប្រជាពលរដ្ឋក្នុងតំបន់ដែរឬទេ? – ត្រួតពិនិត្យមើលបរិក្ខារ និងថ្នាំពេទ្យ។ – ត្រួតពិនិត្យការទុកដាក់សំណល់រឹង/រាវ។ – ត្រួតពិនិត្យគុណភាពឧបករណ៍ និងគ្រឿងចក្ររបស់គម្រោង។	– ក្រុមហ៊ុន – ក្រសួងបរិស្ថាន – ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ – ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ – អាជ្ញាធរដែនដី	ដំណាក់កាលសាងសង់ ០៣ខែម្តង ដំណាក់កាលប្រតិបត្តិ ០៦ខែម្តង
ប្រពៃណី វប្បធម៌ និងសាសនា	– ពិនិត្យតាមដានរាល់ការខុសឆ្គង និងអំពើល្មើសរបស់បុគ្គលិក/កម្មករក្រុមហ៊ុនទៅលើប្រពៃណីទំនៀមទំលាប់ និងវប្បធម៌របស់ប្រទេសជាតិ និងប្រជាជនមូលដ្ឋាន។	– ក្រុមហ៊ុន – ក្រសួងបរិស្ថាន – ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ – អាជ្ញាធរដែនដី	ដំណាក់កាលសាងសង់ ០៣ខែម្តង ដំណាក់កាលប្រតិបត្តិ ០៦ខែម្តង

៨.៥ កម្មវិធីបណ្តុះបណ្តាល

កម្មវិធីបណ្តុះបណ្តាល/បំពាក់បំប៉នជាកត្តាមួយសំខាន់នៅក្នុងផែនការគ្រប់គ្រងបរិស្ថានដែលម្ចាស់គម្រោងត្រូវយកចិត្តទុកដាក់ ដើម្បីអនុវត្តផែនការរបស់គម្រោងឱ្យបានជោគជ័យ។ ម្យ៉ាងទៀត ដើម្បីធ្វើឱ្យគម្រោងនេះ មានការអភិវឌ្ឍន៍ប្រកបដោយចីរភាពចាំបាច់ត្រូវមានធនធានមនុស្ស ដែលមានសមត្ថភាពគ្រប់គ្រាន់សម្រាប់បំពេញការងារឱ្យបានរីកចំរើន និងសុក្រឹត្យត្រឹមត្រូវទាំងការងារបច្ចេកទេស និងការងារបរិស្ថាន ដូច្នេះ ម្ចាស់គម្រោងនឹងរៀបចំឱ្យមានវគ្គអប់រំបំពាក់បំប៉នដល់បុគ្គលិក និងកម្មករមានដូចជា:

- ចំណេះដឹងបច្ចេកទេសក្នុងការប្រើ ឬបញ្ជាគ្រឿងម៉ាស៊ីនគ្រប់ប្រភេទក្នុងពេលសាងសង់ និងប្រតិបត្តិគម្រោង។
- ចំណេះដឹងស្តីពីការសង្គ្រោះបឋមដល់បុគ្គលិក/កម្មករគម្រោង។
- បំពាក់បំប៉ន និងផ្សព្វផ្សាយពីជំនាញបច្ចេកទេសច្បាប់ និងលិខិតបទដ្ឋានផ្សេងៗដែលពាក់ព័ន្ធការបង្កឱ្យមានគ្រោះថ្នាក់ជាយថាហេតុពីសកម្មភាពគម្រោងទៅលើធនធានធម្មជាតិ និងសង្គម។

- អប់រំ និងផ្សព្វផ្សាយពីវិធីសាស្ត្រការពារជម្ងឺរាតត្បាតផ្សេងៗ ជាពិសេសជម្ងឺអេដស៍ជាដើម។
- បំពាក់បំប៉នដល់កម្មករក្នុងការគ្រប់គ្រងសំណល់រឹង/រាវ
- អប់រំពីអត្ថប្រយោជន៍នៃធនធានបរិស្ថានសំខាន់ៗ ដែលមាននៅក្នុងតំបន់សម្រាប់តម្រូវការសង្គម ដូចជាទឹក ដី ខ្យល់ ព្រៃឈើ សត្វព្រៃ ជាពិសេសធនធានធម្មជាតិនៃអភិរក្សព្រៃឈើ
- អប់រំពីវិធីសាស្ត្រជួយការពារបរិស្ថានក្នុង/ជុំវិញតំបន់គម្រោង និងចំណេះដឹងពីការអង្កេតតាមដានគម្រោងដែលទាក់ទងទៅនឹងបរិមាណ និងគុណភាពបរិស្ថានមានស្រាប់ ដែលនឹងត្រូវការប៉ះពាល់ដោយសារសកម្មភាពគម្រោង។
- ផ្សព្វផ្សាយពីវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថានដែលមានលើកឡើងក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដល់បុគ្គលិក/កម្មកគម្រោង។
- ការបំពាក់បំប៉នទាំងនេះក្រុមហ៊ុន និងទទួលបន្ទុកចំណាយទាំងស្រុង មិនតែប៉ុណ្ណោះក្រុមហ៊ុននឹងជ្រើសរើសបុគ្គលិកដែលមានសមត្ថភាពជំនាញខ្ពស់នៅប្រទេសចិន ហើយក្រុមហ៊ុននឹងផ្លាស់ប្តូរបទពិសោធន៍គ្នាទៅវិញទៅមកវាងប្រទេសចិន និងកម្ពុជា ដោយបញ្ជូនគណៈប្រតិភូទៅទស្សនកិច្ចសិក្សានៅប្រទេសដែលក្រុមហ៊ុនបានធ្វើកន្លងមក។

៨.៦ ការប៉ាន់ស្មានចំណាយសម្រាប់ផែនការគ្រប់គ្រងបរិស្ថាន

ការគណនាដំបូងសម្រាប់ថវិកាកិច្ចការពារបរិស្ថានត្រូវបានធ្វើឡើង សម្រាប់គម្រោងនេះដោយមានការចូលរួមយោបល់ពីស្ថាប័ន និងអង្គភាពពាក់ព័ន្ធមួយចំនួន ក្រុមការងារបានធ្វើផែនការចំណាយលើកិច្ចការពារបរិស្ថាន រួមមាន៖ កិច្ចការពារទឹក និងដី កិច្ចការពារបរិយាកាស និងខ្យល់ កិច្ចការពារសុខភាពមនុស្ស ការត្រួតពិនិត្យបរិស្ថាន ការបណ្តុះបណ្តាលពង្រឹងសមត្ថភាព និងការអភិវឌ្ឍន៍ និងចំណាយផ្សេងៗ សរុបមានចំនួន..... សម្រាប់ការងារគ្រប់គ្រង និងការពារបរិស្ថាន សម្រាប់រយៈពេលមួយឆ្នាំៗរបស់គម្រោង។

Draft

ជំពូក ៩
សេចក្តីសន្និដ្ឋាន និង អនុសាសន៍

Draft

ជំពូក ៩
សេចក្តីសន្និដ្ឋាន និងអនុសាសន៍

៩.១ សេចក្តីសន្និដ្ឋាន

ការសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង លើគម្រោងវិនិយោគអភិវឌ្ឍន៍លើវិស័យវិនិយោគលើបណ្តាញទំនាក់ទំនងខ្សែកាប្លីអុបទិករបស់ក្រុមហ៊ុន (ខេមបូឌា) ហ្វីប៊ឺរ អុបទិច ខមញ្ញូនីខេសិនណេតវើក (Cambodia Fiber Optic Communication Network) ដែលក្រុមហ៊ុនបានឲ្យក្រុមហ៊ុន PPIC Co.LTDធ្វើការសិក្សាស្រាវជ្រាវរៀបចំរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូងនេះ មានការសន្និដ្ឋានដូចខាងក្រោម៖

តំបន់គម្រោងដែលបានចែកចេញជា៥ក្រុមគោលដៅដូចខាងក្រោម៖

- ក្រុមគោលដៅទី១មាន៥ខេត្ត ដែលមានខ្សែកាប្លីអុបទិកប្រវែងសរុប១,៤៥២គម ដែលស្ថិតនៅក្នុងខេត្តកំពង់ស្ពឺខេត្តកែប ខេត្តកំពត ខេត្តព្រះសីហនុនិង ខេត្តកោះកុង។
- ក្រុមគោលដៅទី២មាន៤ខេត្ត ដែលមានខ្សែកាប្លីអុបទិកប្រវែងសរុប៩៩៥គម ដែលស្ថិតនៅក្នុងខេត្តតាកែវ ខេត្តកណ្តាល ខេត្តព្រៃវែងនិងខេត្តស្វាយរៀង។
- ក្រុមគោលដៅទី៣មាន៥ខេត្ត ដែលមានខ្សែកាប្លីអុបទិកប្រវែងសរុប២,០៨៤គម ដែលស្ថិតនៅក្នុងខេត្តកំពង់ចាម ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តរតនគិរី និង ខេត្តមណ្ឌលគិរី។
- ក្រុមគោលដៅទី៤មាន៥ខេត្ត ដែលមានខ្សែកាប្លីអុបទិកប្រវែងសរុប១,៥២៧គម ដែលស្ថិតនៅក្នុងរាជធានីភ្នំពេញខេត្តកំពង់ធំ ខេត្តសៀមរាបខេត្តឧត្តរមានជ័យ និងខេត្តព្រះវិហារ។
- ក្រុមគោលដៅទី៥មាន៥ខេត្ត ដែលមានខ្សែកាប្លីអុបទិកប្រវែងសរុប១,៥២៧គម ដែលស្ថិតនៅក្នុងខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ និង ខេត្តប៉ៃលិន។
- ដូចនេះ គម្រោងបញ្ចប់ការសាងសង់បណ្តាញខ្សែកាប្លីអុបទិកសរុបមានប្រវែង ៧,៤២៩គម សំរាប់ដំណាក់កាលទី១ ពីឆ្នាំ២០០៧-២០១៤។
- នៅខេត្តគោលដៅទាំង៥ដោយសិក្សាសំណាកផ្លូវតាមបណ្តាយផ្លូវលេខ ១៣៥មានប្រវែង ៦,៨គម ក្នុងឃុំដូនយ៉ុយ និងឃុំសត្វ ស្រុកឈូកខេត្តកំពតផ្លូវ ,លេខ៨មានប្រវែង ៣,៤គម ក្នុងឃុំកំពង់ពពិលស្រុកពារាំង ខេត្តព្រៃវែងផ្លូវ ,លេខ ៣០៨មានប្រវែង ២,២៦គម ក្នុងស្រុកក្រូចឆ្មារខេត្តត្បូងឃ្មុំផ្លូវ ,លេខ ២១៩មានប្រវែង ៣,៥គមក្នុងឃុំសណ្តាន់ និងឃុំមាន រិទ្ធ ស្រុកសណ្តាន់ខេត្តកំពង់ធំផ្លូវ ,ជាតិ ៧លេខ៥មានប្រវែង ៧,៧គមក្នុងសង្កាត់ព្រៃញី សាលាក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់។

តាមរយៈការសិក្សាស្រាវជ្រាវវាយតម្លៃហេតុប៉ះពាល់បរិស្ថានរបស់ក្រុមការងារ PPIC Co.LTDទៅលើគម្រោងវិនិយោគខាងលើ ទទួលបានលទ្ធផលបញ្ជាក់ឲ្យបានដឹងថា៖

- ក្រុមហ៊ុនCFOCN បានវិនិយោគនៅក្នុងគម្រោងសាងសង់បណ្តាញទំនាក់ទំនងខ្សែកាប្លីអុបទិកនៅកម្ពុជា។ ប្រាក់វិនិយោគសរុបរបស់គម្រោងនេះមានចំនួនយ៉ាងហោច១១០លានដុល្លារអាមេរិច។ ក្រុមហ៊ុនបានធ្វើការវិនិយោគសរុបលើផ្ទៃដី ៨,៥១៤គម ដែលក្នុងនោះគម្រោងបានបញ្ចប់ការសាងសង់

៧,៤២៩គម (ឆ្នាំ២០០៧-២០១៤) និងគម្រោងកំពុងសាងសង់មានប្រវែង ១,០៨៥គម (ចាប់ពីឆ្នាំ ២០១៥)។

- គម្រោងអភិវឌ្ឍន៍ទាំងឡាយត្រូវគោរពតាមច្បាប់បញ្ញត្តិដែលពាក់ព័ន្ធ ដើម្បីឲ្យដំណើរការមានសភាពរលូន និងប្រកបដោយចីរភាព។ តួយ៉ាងការអនុវត្តន៍គម្រោងនេះមានការពាក់ព័ន្ធទៅនឹងច្បាប់ អនុក្រឹត្យ ប្រកាសជាតិសំខាន់ៗដែលពាក់ព័ន្ធមួយចំនួនដូចជា៖
  - រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (១៩៩៣)។
  - ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា(១៩៩៤) និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា (២០០៣)។
  - ច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ (១៩៩៦)។
  - ច្បាប់ស្តីពីអស្សាមិករណ៍ (២០១០)។
  - ច្បាប់ការងារ(១៩៩៧) និងច្បាប់ស្តីពីវិសោធនកម្មមាត្រា១៣៩ និងមាត្រា១៤៤ នៃច្បាប់ស្តីពីការងារ (២០០៧)។
  - ច្បាប់ស្តីពីជលផល (២០០៦)។
  - ច្បាប់ស្តីពីកិច្ចការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា (២០០៧)។
  - ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់។
  - អនុក្រឹត្យស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (១៩៩៩)។
  - អនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់រឹង (១៩៩៩)។
  - អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេង (២០០០)។
  - អនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់។
  - អនុក្រឹត្យស្តីពីការបំពុលទឹក។
  - ប្រកាសអន្តរក្រសួងមហាផ្ទៃ-បរិស្ថានស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងនៅក្នុងខេត្តក្រុងនៃ ព្រះរាជាណាចក្រកម្ពុជា (២០០៣)។
  - ប្រកាសស្តីពីគោលការណ៍ណែនាំទូទៅក្នុងការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញ (២០០៩)
- អាកាសធាតុ ជាស្ថានភាពបរិយាកាសរបស់តំបន់មួយក្នុងពេលវេលាមួយជាក់លាក់។ អាកាសធាតុប្រទេសកម្ពុជាយើង ក៏ដូចជាប្រទេសជិតខាងនៅអាស៊ីអាគ្នេយ៍ដែរ គឺទទួលរងនូវឥទ្ធិពលពីរបបខ្យល់មូសុង និងអាកាសធាតុតំបន់ត្រូពិក ដែលជាអាកាសធាតុក្តៅហើយសើម ហើយមានពន្លឺព្រះអាទិត្យពេញលេញ និងភ្លៀងធ្លាក់គ្រប់គ្រាន់ លក្ខណៈល្អនេះបានអំណោយផលដល់ការរស់នៅរបស់មនុស្ស សត្វ និងរុក្ខជាតិ។ តាមលទ្ធផលខាងលើអាកាសធាតុរបស់បណ្តាខេត្តក្នុងតំបន់គម្រោងក្នុងគោលដៅទាំង៥ គឺ មានសីតុណ្ហភាពអប្បរមា ២១ ° C និងសីតុណ្ហភាពអតិបរមា ៣៦ ° C (ពីឆ្នាំ២០១២ ដល់ឆ្នាំ ២០១៤)។

- លទ្ធផលសរុបនៃប្រភេទរុក្ខជាតិក្នុងតំបន់សិក្សាសរុបមាន ៤១ប្រភេទក្នុងនោះមានរុក្ខជាតិដាំជាដំណាំហូបផ្លែនៅលើចំណីផ្លូវ ១០ប្រភេទ, រុក្ខជាតិដាំជាដំណែ្ការលើចំណីផ្លូវ ១០ប្រភេទ, រុក្ខជាតិដាំលំអតាមផ្លូវ ឬទប់ការហូរច្រោះផ្លូវនៅលើចំណីផ្លូវ ១២ប្រភេទ និងរុក្ខជាតិដុះលើចំណីផ្លូវ ៩ប្រភេទ ដែលមាន LC ៤ប្រភេទស្ថិតក្នុង IUCN RED LIST, មាន Vu ៣ប្រភេទស្ថិតក្នុង IUCN RED LIST, មាន DD ១ ប្រភេទស្ថិតក្នុង IUCN RED LIST, មាន En ១ប្រភេទស្ថិតក្នុង IUCN RED LIST ហើយក្នុងនោះមានឈើលេខ១ ចំនួន១ប្រភេទ, ឈើលេខ២ ចំនួន១ប្រភេទ នងឈើលេខ៣ ចំនួន២ប្រភេទ។
- លទ្ធផលសរុបនៃប្រភេទសត្វក្នុងតំបន់សិក្សាសរុបមាន ៦២ប្រភេទ ក្នុងនោះមានថ្នាក់បក្សីសត្វ ចំនួន ២១ប្រភេទ, ថ្នាក់ល្មូនសត្វ ១៤ចំនួនប្រភេទ, ថ្នាក់ថនិកសត្វ ៦ចំនួនប្រភេទ, ថ្នាក់មណ្ឌុកសត្វ ៦ ចំនួនប្រភេទ, ថ្នាក់កុម្ភសត្វ ១ចំនួនប្រភេទ និងថ្នាក់មច្ឆាសត្វ ១៤ចំនួនប្រភេទ ដែលក្នុងនោះមាន LC ៣៥ចំនួនប្រភេទស្ថិតក្នុង IUCN RED LIST, Vu ៤ចំនួនប្រភេទស្ថិតក្នុង IUCN RED LIST, En ២ចំនួនប្រភេទស្ថិតក្នុង IUCN RED LIST, NT ចំនួន២ប្រភេទស្ថិតក្នុង IUCN RED LISTនិងDD ៣ ចំនួនប្រភេទស្ថិតក្នុង IUCN RED LIST។
- ស្ថានភាពសេដ្ឋកិច្ចទូទៅនៃតំបន់សិក្សាទាំងប្រាំដែលប្រជាជនអាចរកចំណូលបានខ្ពស់បំផុតគឺនៅស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ ៣៩៣.៩៣ ដុល្លារ/ខែ ក្នុងម្នាក់។ ចំណែកឯចំណូលដែលទាបបំផុតគឺនៅក្នុងស្រុកសណ្តាន់ ខេត្តកំពង់ធំ ដែលប្រជាជនម្នាក់អាចរកចំណូលបាន ១៥៨.៨១ ដុល្លារ/ខែ។ សំរាប់ការចំណាយប្រចាំខែដែលប្រជាជនចំណាយអស់ខ្ពស់បំផុតនៅក្នុងតំបន់គម្រោងកំពុងសាងសង់ខ្សែកាប្លីអុបទិកគឺនៅក្នុងស្រុកពារាំង ខេត្តព្រៃវែង ៤៤៣.៥៦ដុល្លារ ក្នុងមួយខែ ។ រីឯឃុំព្រៃញី ស្រុកក្រគរ ខេត្តពោធិសាត់ ប្រជាជនមានអត្រាចំណាយទាបបំផុត១៧៨.៣៩ ដុល្លារ ក្នុងមួយខែ។
- ផលប៉ះពាល់នៃគម្រោងបណ្តាញទំនាក់ទំនងខ្សែកាប្លីអុបទិក មាន២គឺ វិជ្ជមាននិងអវិជ្ជមាន៖ ឥទ្ធិពលវិជ្ជាមានមានដូចជាប្រជាជនសង្ឃឹមថានឹងបានទទួលបានខ្សែកាប្លីអុបទិក ប្រើប្រាស់ធាប់រហ័សល្បឿនលឿន និងតម្លៃថោកសមរម្យ, ការប្រើប្រាស់សម្ភារៈ ឧបករណ៍អេឡិចត្រូនិចទំនើបៗ នៅតាមលំនៅដ្ឋាននឹងមានការកើនឡើង, ប្រជាពលរដ្ឋមានការរីកចម្រើនខាងចំណេះដឹងទូទៅ និងពត៌មានបានយ៉ាងធាប់រហ័សដោយសារមានសេវាកម្មអេឡិចត្រូនិចប្រើប្រាស់គ្រប់គ្រាន់ ជាពិសេសបង្កើតការងារពង្រឹងជំនាញ និងឱកាសពាណិជ្ជកម្ម និងមុខជំនួញក្នុងតំបន់។ ឯឥទ្ធិពលអវិជ្ជមានដោយ សារគម្រោងមានដូចជា៖ ប៉ះពាល់ដល់សតិអារម្មណ៍របស់ប្រជាជននៅក្បែរគម្រោង ដោយមានការព្រួយបារម្ភអំពីគ្រោះថ្នាក់ដែលអាចកើតមានឡើងដោយសារគម្រោង, អាចនឹងប៉ះពាល់ដីស្រែ ចំការ និងលំនៅដ្ឋានរបស់ប្រជាពលរដ្ឋដែលរស់នៅតាមបណ្តាយផ្លូវដែលត្រូវធ្វើការសាងសង់, ប្រជាពលរដ្ឋភាគច្រើនមិនមានការយល់ដឹងពីគម្រោង ព្រោះក្រុមហ៊ុនមិនបានចុះធ្វើការផ្សព្វផ្សាយជាមុន និង កន្លែងខ្លះសាងសង់ដោយមានការធ្វេសប្រហែសធ្វើអោយផ្ទុងដីស្រែ ចំការរបស់ពួកគាត់ ។ ដូចនេះក្រុមហ៊ុនត្រូវយកវិធានការកាត់បន្ថយហេតុប៉ះពាល់តាមដំពូកទី៧ខាងលើសម្រាប់ក្នុងដំណាក់កាលប្រតិបត្តិបត្តិ និងថែទាំគម្រោងដោយអនុវត្តផែនការគ្រប់គ្រងបរិស្ថានត្រូវផ្តោតសំខាន់ទៅធនធាន៣គឺ ធនធានរូបសាស្ត្រ, ធនធានជីវសាស្ត្រ និងធនធានសេដ្ឋកិច្ច-សង្គម ដោយធ្វើយ៉ាងណាឲ្យមានផលប៉ះពាល់នៅកម្រិត

ទាបបំផុតដែលអាចទទួលយកបានដោយមិនមានការរំខានដល់ផលប្រយោជន៍ប្រជាជន និងការសាងសង់របស់គម្រោង ពិសេសការវិនិយោគគម្រោងដោយប្រើប្រាស់ តារាងផែនការត្រួតពិនិត្យតាមដានការអនុវត្តន៍ផែនការគ្រប់គ្រងបរិស្ថានលទ្ធផលខាងលើ។

- តាមលទ្ធផលពីការពិគ្រោះយោបល់ពីសាធារណៈជនបានបង្ហាញថា គម្រោងគួរតែផ្សព្វផ្សាយពីផលប្រយោជន៍ឲ្យបានជ្រួតជ្រាបដល់ស្រទាប់មហាជន ផ្តល់លិខិតបទដ្ឋានគ្រប់គ្រាន់ជាមួយអ្នកពាក់ព័ន្ធសហការណ៍ជាមួយជំនាញសង់ឲ្យតាមតំបន់គោលដៅ និងដោះស្រាយសំណងជាមួយប្រជាពលរដ្ឋក្នុងដំណាក់កាលទី១ ឲ្យបានចប់គ្រប់មុននឹងសង់ខ្សែកាប្លីអុបទិក។ គាំទ្រការវិនិយោគរបស់គម្រោងពីព្រោះវាផ្តល់បច្ចេកវិទ្យាទូរគមនាគមន៍ដូចជាប្រព័ន្ធទូរស័ព្ទគ្រប់ប្រភេទ អ៊ីនធើណេត ទូរទស្សន៍ ការ៉ែវ៉ាសុវត្ថិភាព។ល។

៩.២ អនុសាសន៍

ជាអនុសាសន៍ ដើម្បីធានាឲ្យបាននូវការអភិវឌ្ឍដែលប្រកបដោយនិរន្តរភាព និងមិនផ្តល់នូវផលប៉ះពាល់ដល់ធនធានរូបសាស្ត្រ ធនធានជីវសាស្ត្រ និងធនធានសេដ្ឋកិច្ច-សង្គម ក្រុមហ៊ុនវិនិយោគត្រូវ៖

- ក្រុមហ៊ុនត្រូវថែរក្សាឲ្យបាននូវសោភ័ណភាពដើមនៃបរិស្ថានដែលនៅតាមដងផ្លូវក្នុងតំបន់គម្រោងនៅពេលធ្វើការជីកកប់។
- ក្រុមហ៊ុនត្រូវសង់ខ្សែកាប្លីអុបទិកនៅក្នុងតំបន់គោលដៅ និងដោះស្រាយគោលនយោបាយសំណងក្នុងដំណាក់កាលទី១ ដើម្បីជៀសវាងការរុះរើ ឬមានបញ្ហាទៅថ្ងៃក្រោយ។
- ក្រុមហ៊ុនគួរតែចូលរួមផ្តល់មូលនិធិទ័យទាន។
- ក្រុមហ៊ុនត្រូវអនុវត្តតាមផែនការគ្រប់គ្រងបរិស្ថានឲ្យបានត្រឹមត្រូវ ដោយបង្កើតផែនការគ្រប់គ្រងបរិស្ថានមួយឲ្យត្រូវនឹងគោលផែនការគ្រប់គ្រងបរិស្ថានក្នុងរបាយការណ៍នេះ ដោយសហការជាមួយក្រសួងបរិស្ថាន និងក្រសួងពាក់ព័ន្ធ។
- ក្រុមហ៊ុនត្រូវត្រូវមានការទូទាត់សំណងឲ្យបានសមស្របនិងគោរពផលប្រយោជន៍ប្រជាជនមូលដ្ឋាន។
- ក្រុមហ៊ុនត្រូវត្រូវផ្សព្វផ្សាយពីសារប្រយោជន៍នៃការប្រើប្រាស់បច្ចេកវិទ្យាប្រើប្រាស់ប្រព័ន្ធខ្សែកាប្លីឲ្យបានទូលំទូលាយដល់សាធារណៈជន។
- ត្រូវសហការជាមួយ អាជ្ញាធរដែនដី មន្ទីរជំនាញដែលពាក់ព័ន្ធ សាលាស្រុក សាលាឃុំ និងជួបផ្ទាល់ជាមួយប្រជាជន ដើម្បីកាត់បន្ថយបញ្ហាផ្សេងៗដែលកើតមានឡើងនៅពេលធ្វើការជីកកប់ ជាពិសេសដើម្បីកុំឲ្យមានការរាំងស្ទះដល់ការវិនិយោគគម្រោង
- ក្រុមហ៊ុនត្រូវសហការជាមួយអាជ្ញាធរមូលដ្ឋាន ដែលនៅក្នុងតំបន់គម្រោង ដើម្បីជួយដោះស្រាយ និងទប់ស្កាត់នូវបញ្ហាដែលកើតមានក្នុងតំបន់គម្រោងវិនិយោគ
- ក្រុមហ៊ុនត្រូវគ្រប់គ្រងសំណល់រឹង រាវ ក្នុងតំបន់គម្រោងឲ្យបានត្រឹមត្រូវ ដើម្បីធានាបានថា បរិស្ថានមិនត្រូវបានពុល ដោយការហូរច្រោះ ការជ្រាបចូល ដីឬប្រភពទឹកលើដីនិងក្រោមដី ការសាយភាយ

ក្លិនចូលក្នុងខ្យល់ ដែលនាំឲ្យប៉ះពាល់ធនធានជីវៈចម្រុះក្នុងទឹក ខូចគុណភាពដី ព្រមទាំងប៉ះពាល់ដល់សុខភាពប្រជាជនមូលដ្ឋាន។

ជាពិសេសក្រុមហ៊ុនវិនិយោគ ត្រូវគោរពតាមឲ្យបានខ្ជាប់ខ្ជួននូវកិច្ចសន្យាជាមួយរាជរដ្ឋាភិបាល និងអនុវត្តឲ្យបាននូវផែនការគ្រប់គ្រងបរិស្ថាន ឲ្យមានប្រសិទ្ធភាព ព្រមទាំងសហការល្អជាមួយក្រសួង/ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ ជាពិសេសក្រសួងបរិស្ថាន ក្នុងការត្រួតពិនិត្យ សម្របសម្រួល និងដោះស្រាយបញ្ហាទៅតាមកម្មវិធីត្រួតពិនិត្យបរិស្ថាន ដែលមានក្នុងរបាយការណ៍នេះ។

ជាចុងក្រោយតាងនាមឲ្យក្រុមហ៊ុនទីប្រឹក្សា សំណូមពរដល់ក្រសួងបរិស្ថាន ដែលជាក្រសួងមានសមត្ថកិច្ច មេតាពិនិត្យ និងសម្រេច ដោយឡែកស្ថាប័នពាក់ព័ន្ធនានា មេត្តាចូលរួមជួយជ្រោមជ្រែង និងបង្កលក្ខណៈងាយស្រួលដល់ក្រុមហ៊ុនវិនិយោគ ដើម្បីអនុវត្តគម្រោងនេះប្រកបដោយចីរភាព ដោយក្តីអនុគ្រោះ។

រាជធានីភ្នំពេញ, ថ្ងៃទី 09 ខែតុលា ឆ្នាំ ២០១៥
ក្រុមហ៊ុន ភីភីអាយ ស៊ុ ខូ អិល ធីឌី
(PPiC Co., Ltd.)
នាយកក្រុមហ៊ុន

រាជធានីភ្នំពេញ, ថ្ងៃទី 22 ខែ តុលា ឆ្នាំ ២០១៥
ក្រុមហ៊ុន (ខេមបូឌា) ហ្វីប៊ើ អុបទិក ខមញ្ចូនីខេសិន ណេតវើក
(CAMBODIA) FIBER OPTIC COMMUNICATION NETWORKCo., Ltd)
នាយកក្រុមហ៊ុន

ជូន ទិចិត្រសីលា

Draft

ឯកសារយោង

Draft

ឯកសារយោង

Draft

ឯកសារយោង

ឯកសារយោង និងប្រភពទិន្នន័យមួយចំនួនដកស្រង់ចេញពីឯកសារដូចខាងក្រោមនេះ៖

- ច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- ព្រះរាជក្រមលេខនស/រកម/១២៩៦/៣៦ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើប្រាស់ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- ព្រះរាជាក្រមលេខ នសខែមី ១២ចុះថ្ងៃទី ០០៣/០២១០/រកម/នា ឆ្នាំ២០១០ ដែលប្រកាសឲ្យប្រើប្រាស់ច្បាប់ស្តីពីអស្សាមិករណ៍
- ព្រះរាជក្រមលេខនស/រកម/០៦០៧/០១៦ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៧ដែលប្រកាសឲ្យប្រើប្រាស់ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ព្រះរាជក្រមលេខនស/រកម/០២០៨/០០៧ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើប្រាស់ច្បាប់ស្តីពីដលផល
- ព្រះរាជក្រមលេខនស/រកម/០៨០២/០១៦/ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើប្រាស់ច្បាប់ស្តីពីព្រៃឈើ
- ព្រះរាជក្រមលេខនស/រកម/០៨០១/១៤/៧ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើប្រាស់ច្បាប់ស្តីពីភូមិបាលឆ្នាំ២០០១
- ព្រះរាជក្រមលេខនស/រកម/០៣៩៧/០១ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើប្រាស់ច្បាប់ស្តីពីការងារ
- ព្រះរាជក្រមលេខ០៤នស៩៤/ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើប្រាស់ច្បាប់ស្តីពីការរៀបចំទឹកដីនគរូបនីយកម្ម និងសំណង់ឆ្នាំ១៩៩៤
- អនុក្រឹត្យលេខ១៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣ ស្តីពីសម្បាទានដីសង្គមកិច្ច
- អនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន
- អនុក្រឹត្យលេខ៤២អនប្រ.បកបានអនុម័តនៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០ ស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេង
- អនុក្រឹត្យលេខ២៧ អនប្រ.បកចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការត្រួតពិនិត្យការបំពុលទឹក
- អនុក្រឹត្យលេខ៣៦ អនប្រ.បកចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការគ្រប់គ្រងសំណល់រឹង
- អនុក្រឹត្យលេខ១២៣ អនប្រ.បកចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ស្តីពីការកំណត់ប្រភេទដលផលផលិតផលដលផល ដែលកំពុងរងគ្រោះថ្នាក់
- គោលការណ៍ណែនាំទូទៅក្នុងការធ្វើរបាយការណ៍បរាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញ ឆ្នាំ២០០៩
- គោលនយោបាយជាតិស្តីពី ការអភិវឌ្ឍរបៃតង ឆ្នាំ២០១៣
- សៀវភៅសត្វស្លាបប្រទេសកម្ពុជាឆ្នាំ១៩៩៨(រៀបរៀងដោយលោក Colin Poole, លោកស៊ុន ហ៊ាន, លោកសេង គឹមហ៊ាត់, លោកកែវ សុម៉ាលីស្យ និងលោកហេង នាថមុនី)

Draft

- ឯកសារឈ្មោះព្រៃឈើរបស់អគ្គនាយកដ្ឋានរដ្ឋបាលព្រៃឈើនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ
- ឈ្មោះប្រភេទសត្វព្រៃនៅប្រទេសកម្ពុជាដែលមាននៅក្នុងបញ្ជីឧបសម្ព័ន្ធអនុសញ្ញាCITES, Year 2001
- របាយការណ៍ប្រចាំឆ្នាំ២០១៤ ស្តីពីការអនុវត្តការងាររបស់រដ្ឋបាលនៃសាលាខេត្តកណ្តាល
- លោក គ្រាន កាញ់ ឆ្នាំ២០១១ សៀវភៅសន្ទានុក្រមធរណីវិទ្យា
- សៀវភៅអត្តសញ្ញាណកម្មសត្វព្រៃសម្រាប់ពង្រឹងការអនុវត្តន៍ច្បាប់
- សៀវភៅថនិកសត្វប្រទេសកម្ពុជា ឆ្នាំ២០០៨
- Fish of the Cambodian Mekong, FAO Species Identification Field Guide of Fishery Purpose (1996)

Draft

ឧបសម្ព័ន្ធ ១
ឯកសារពាក់ព័ន្ធ និងគម្រោង

Draft

១. បទដ្ឋានគតិយុត្តិផ្តល់សិទ្ធដល់គម្រោងវិនិយោគ

១.១ វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម



ក្រសួងពាណិជ្ជកម្ម
លេខ ..... ពណ.ចបព
MINISTRY OF COMMERCE
No. ..... MOC/D/REG

ទិញ្ញាបនបត្រ
បញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម
CERTIFICATE OF INCORPORATION

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
NATION RELIGION KING

ឆាមការណ៍ : (ខេមបូឌា) ហ្វីប៊ើរ អុបទីច ខមញូនីខេសិន ណេតវើក
NAME : (CAMBODIA) FIBER OPTIC COMMUNICATION NETWORK CO., LTD.
ចុះបញ្ជីក្រោមលេខ : Inv. ១១៣៩ E/២០០៦ ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៦
REGISTRATION NUMBER : Inv. 1139 E/2006 Dated 08 December 2006
ត្រូវបានទទួលស្គាល់ថាជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត
IS ACKNOWLEDGED AS : PRIVATE LIMITED COMPANY

ស្ថិតក្រោមបទបញ្ជាត្តិនៃច្បាប់ស្តីពីនានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ក្រមរដ្ឋប្បវេណី និងក្រមព្រហ្មទណ្ឌ ដែលមានជាធរមាន នៃព្រះរាជាណាចក្រកម្ពុជា ។
UNDER THE REGULATIONS OF COMMERCIAL RULES AND REGISTER LAW, COMMERCIAL ENTERPRISES LAW, CIVIL CODE, AND PENAL CODE OF THE KINGDOM OF CAMBODIA

ភ្នំពេញ, ថ្ងៃទី ..... ខែ ..... ឆ្នាំ ..... ឆ្នាំ ..... ឆ្នាំ
PHNOM PENH

ជ. ធេសដ្ឋេមន្ត្រី
ដ្ឋេមន្ត្រីក្រសួងពាណិជ្ជកម្ម
SENIOR MINISTER
MINISTER OF COMMERCE

* វិញ្ញាបនបត្រមានសុពលភាពចាប់ពីថ្ងៃចុះហត្ថលេខាដល់ថ្ងៃទី ១៦ ខែ ...
ទ្រឹសរយៈពេលកំណត់នៃក្រោមនេះ
* THE CERTIFICATE IS VALID FROM THE SIGNING DATE TO 16 March 2015
IT WILL BE CONSIDERED INVALID AFTER THE STATED DATE
* វិញ្ញាបនបត្រនេះត្រូវមកប្តូរជាថ្មីក្នុងរយៈពេល ៣០ ថ្ងៃ មុនថ្ងៃផុតសុពលភាព
* THE RENEWAL OF THIS CERTIFICATE SHALL BE MADE IN 30 DAYS BEFORE THE EXPIRY DATE

Copy is invalid, only for ESIA Report

Unofficial

១.២ បណ្ណប៉ាតង់(របបស្ម័យប្រកាស)



១.៣ ការកិច្ចរបស់អាជីវកម្មដ្ឋាន



ការកិច្ចរបស់អាជីវកម្មដ្ឋាន

(ដកស្រង់ពីក្រឹត្យលេខ ២២ ក្រ.ន ចុះថ្ងៃទី ១៤.០៦.១៩៨៥)

មាត្រា១៣ : អាជីវកម្មដ្ឋានមានភារកិច្ចដូចតទៅ :

ក- ប្រកាសរោយស្នាះត្រង់ចំពោះអង្គការពន្ធដែលស្ថិតនៅកន្លែងប្រកបអាជីវកម្មយ៉ាងយឺតបំផុត ៣០ ថ្ងៃ មុនពេលចាប់ផ្តើមប្រកបអាជីវកម្ម ។

ខ- ប្រកាសរោយអង្គការពន្ធដឹង អំពីស្ថានភាពអាជីវកម្មតាមសំរួ ឱ្យ ឬបេះពេលដែលអង្គការពន្ធបានកំណត់ ។

គ- ប្រកាសរោយអង្គការពន្ធដឹង ក្នុងករណីមានការកែប្រែកិច្ចការប្រកបអាជីវកម្មផ្នែក : ផ្ទាស់ម្ចាស់, ប្តូរទីកន្លែង, ប្តូរមុខរបរ, ពង្រីកមុខរបរ។

ឃ- បង់រោយត្រង់ នូវចំនួនប្រាក់ពន្ធដ៏តិចតួចតាមរយៈពេលកំណត់របស់អង្គការពន្ធ ។ ក្នុងករណីដែលមានការតវ៉ាអំពីចំនួនប្រាក់ពន្ធដែលត្រូវបង់ អាជីវកម្មត្រូវតែបង់រោយត្រូវតាមចំនួន និងតាមកំណត់ពេលរបស់អង្គការពន្ធ ក្នុងពេលដំណាលជាមួយការប្តឹងតវ៉ា ។

មាត្រា១៤ : ក្រោយពេលបិទបញ្ជី អាជីវកម្មដ្ឋានត្រូវបានទទួលប័ណ្ណជូនដំណឹង ។ ប័ណ្ណជូនដំណឹងនេះមានតម្លៃចំពោះតែអ្នកដែលមានឈ្មោះក្នុងប័ណ្ណជូនដំណឹងតែប៉ុណ្ណោះ ។

អាជីវកម្មមិនអាចរោយប្តូរ ឬផ្ទេររោយឃ្លាតដែលដោយគ្មានការអនុញ្ញាតពីអង្គការពន្ធបានឡើយ ។

នៅពេលលុបប្រកបអាជីវកម្ម អាជីវកម្មត្រូវប្រគល់ប័ណ្ណជូនដំណឹងរោយអង្គការពន្ធវិញ ។

មាត្រា១៥ : អាជីវកម្មដ្ឋានអាចលក់ត្រូវប្រាប់ប័ណ្ណជូនដំណឹងនៅមាត់ទ្វារចូលនៃអាគារលក់ដូរ រោងចក្រ រោងជាងផលិត ។

ប្រសិនបើទោយលក់ដូរនៅក្រៅកន្លែងដែលបានសុំប្រកបអាជីវកម្ម អាជីវកម្មត្រូវសុំអង្គការពន្ធ រោយរាចញ្ជើនិងបញ្ជាក់ថា : បានបង់ពន្ធជូនដំណឹងហើយ ដើម្បីតាមចំនួន ។ លិខិតបញ្ជាក់នេះមានតំលៃតែមួយថ្ងៃ ឬក្នុងរយៈពេលមួយមានកំណត់ ។

ពេលស្នើសុំលិខិតបញ្ជាក់ អាជីវកម្មត្រូវបង់ប្រាក់ថ្លៃលិខិតចេញ តំលៃដោយក្រសួងសេដ្ឋកិច្ច

Copy is invalid, only for E.S.I.A Report

១.៤ អាជ្ញាប័ណ្ណ (License)

LICENSE

GRANTED AND ISSUED BY

THE MINISTRY OF POSTS AND
TELECOMMUNICATIONS
OF
THE KINGDOM OF CAMBODIA

TO

(CAMBODIA) FIBER OPTIC COMMUNICATION
NETWORKS Co., Ltd (CFOCN)

FOR THE

CONSTRUCTION AND OPERATION

OF

OPTICAL FIBER CABLE BACKBONE SYSTEM
AND RELATED INFRASTRUCTURE

IN

THE KINGDOM OF CAMBODIA

Draft

Copy is invalid, only
for ESIA Report

TABLE OF CONTENTS

Article 1	DEFINITIONS AND INTERPRETATION
	1.1 DEFINITION
	1.2 INTERPRETATION
Article 2	PROVISION OF NETWORKS
Article 3	COMMENCEMENT OF CONSTRUCTION
Article 4	SCOPE OF SERVICES
Article 5	INTERNATIONAL LINKAGES FOR OPTICAL FIBER CABLE SERVICES
Article 6	DOMESTIC LINKAGES
Article 7	RADIO REQUENCY
Article 8	PERFORMANCE GUARANTEES
Article 9	RELATIONSHIP WITH CUSTOMERS
Article 10	TARIFF AND BILLING
Article 11	PROVISION OF INFORMATION
Article 12	COVERAGE
Article13	LICENSE FEES
	13.1 VERIFICATION OF GROSS REVENUE
Article 14	FISCAL AND ADMINISTRATIVE MATTERS
	14.1 TAXES AND DUTIES
	14.2 BANK ACCOUNTS, REMITTANCE OF PROFIT AND WORKING PERMITS
Article 15	FINANCE, ACCOUNTING AND OTHER REPORTS
Article 16	SUNSET PRINCIPLE
Article 17	LICENSE TERMS
	17.1 DURATION
	17.2 EXTENSION
Article 18	ASSIGNMENT AND SUBCONTRACT
Article 19	CONFIDENTIALITY
Article 20	TERMINATION
Article 21	FORCE MAJEURE
Article 22	DISPUTE RESOLUTION
Article 23	APPLICABLE LEGISLATION
Article 24	GENERAL

Draft

Copy is invalid, only for ESIA Report

LICENSE

for the construction and operation of optical fiber cable backbone system and related infrastructure in the Kingdom of Cambodia

With reference to the annotation from Samdech Prime Minister, Chairman of CDC, dated February 27, 2007 written on the CDC's letter No 594/07 dated February 22, 2007;

Pursuant to the Agreement between the Royal Government of Cambodia and Cambodia Fiber Optic Communication Networks Co., Ltd (CFOCN) for the Investment on the construction of optical fiber cable backbone system and related infrastructure in the Kingdom of Cambodia, dated April 4, 2007;

The MINISTRY OF POSTS AND TELECOMMUNICATIONS OF THE KINGDOM OF CAMBODIA (hereinafter referred as "MPTC") hereby grants a License to construct and operate the optical fiber cable backbone system and related infrastructure in the Kingdom of Cambodia.

TO

"(CAMBODIA) FIBER OPTIC COMMUNICATION NETWORK CO., LTD." (hereinafter referred as "CFOCN"), being a company duly incorporated under the laws of the Kingdom of Cambodia and having its registered office at No. 199ABC, Phum 6, Street 245, Sangkat Toul Svay Prey I, Khan Chamkarmorn, Phnom Penh, Cambodia, ...

This License is granted on this 11th day of December 2007.

Draft

Copy is invalid, only for ESIA Report

OBJECTIVES

The objective of licensing telecommunications is to:

(a) Ensure that there is an open, fair and competitive market in telecommunications in the Kingdom of Cambodia;

(b) Support and encourage innovation and efficient investment in the telecommunication sector;

(c) Promote efficient use of scarce resources in the promotion of the best quality cost effective telecommunications in the Kingdom of Cambodia;

(d) ensure the integrity, security and reliability of the telecommunication network;

(e) ensure the seamless carriage of emergency calls over all networks.

THIS LICENSE IS GRANTED SUBJECT TO THE FOLLOWING TERMS AND CONDITIONS:

Article 1. DEFINITIONS AND INTERPRETATION

1.1 Definitions

In this License, unless the context otherwise indicates:

"**Service**" means lease, subscription, sale and maintenance on optical fiber cable system and related services to all customers;

"**Gross Revenue**" means the total gross revenue and other revenues derived from the operation of Optical Fiber cable system and other related services, before deduction of all expenses.

1.2 Interpretation

In this License, unless the context otherwise indicates:

(a) words denoting the singular shall include the plural and vice versa and words importing gender shall include every gender;

Copy is invalid, only for ESIA Report

Draft

(b) references to any document (including this License) shall be references to that document and its annexes and schedules;

(c) except where expressly indicated to the contrary, references to clauses and schedules shall be references to clauses and schedules of this License;

(d) headings are for convenience in outlining the substance of the articles and shall not affect the interpretation or meaning of this License;

(e) references to any party in this License shall include references to its successors and permitted assignees;

(f) references to any person shall include individuals, firms, companies, bodies, corporations, associations, partnerships, joint ventures, trusts and governments and governmental, semi governmental and local authorities and agencies;

(g) except where expressly indicated to the contrary, all dollar amounts referred to shall be the United States currency; and

(h) references to payment paid or paid in full, shall mean that the funds made on that payment, paid or paid in full, are available for immediate use by the payee.

Article 2. PROVISION OF NETWORKS

CTOCN is authorized, at their own costs and expenses, to construct the Optical Fiber Cable Backbone System, from the non existing fiber optic system area and the area located for the same project of the Royal Government of Cambodia through Grant Aid and loan, in accordance with the Master Plan and working schedule approved by the MPTC, in the following two phases:

Draft

Copy is invalid, only for ESIA Report

a Phase 1 3,103 Km of Optical Cable, including the optical transmission systems, power supply system, building and related infrastructure such as radio communication system, within two and half (2.5) years

b Phase 2 5,480 km of Optical Cable, optical transmission system, power supply system, building and related infrastructure such as radio communication system, within five (5) years

Article 3. COMMENCEMENT OF CONSTRUCTION

The construction of the optical fiber cable system and related infrastructure shall be commenced within 6 (six) months after the signing of this License.

Article 4. SCOPE OF SERVICES

4.1 CFOCN shall offer (Sale and Lease) a standard range of basic services of optical fiber system and related infrastructure, such as radio communication system to all customers such as residential, governmental, and business sectors in the Kingdom of Cambodia

4.2 CFOCN is authorized to establish its branches in the nationwide and access to any public or private residents or install the optical fibre cable, metropolitan communication dust system and related equipment/ system, in accordance with the applicable laws and regulations

4.3 CFOCN is authorized to provide the following related services of optical fiber cable system, in accordance with the applicable law and regulations:

- Lease and sale of the core of optical fibre cable;

Draft

Copy is invalid, only for FSCA Report

- Lease and sale of the circuit via optical fiber cable system;
- Lease and Sale of the Private Leased Circuit (PLC);
- Lease and Sale of the optical fiber cable capacities to all customers and
- Lease and Sale of the communication duct pipe systems to all customers.

Article 5. INTERNATIONAL LINKAGES FOR OPTICAL FIBER CABLE SERVICES

International linkages can be connected through direct network and facilities of CFOCN or other transmission technologies that may become available during the term of this License, in accordance with the laws and related regulations of the Kingdom of Cambodia.

Article 6. DOMESTIC LINKAGES

Domestic links to the Optical Fiber Cable Network can be provided through optical fiber facilities, direct access dial up, the PSTN or mobile networks, wireless broadband links and other new telecommunication networks, established for that purpose or through any other means suitable for providing access between the Optical Fiber Network and the subscribers, as deemed appropriate, to maintain a high quality and high capacity service for subscribers.

CFOCN has the right to provide direct telecommunication connections between any of its customers and the Network through personal license.

Article 7. RADIO FREQUENCY

Assignment of required radio frequencies needed for the authorized services shall be granted under the terms and conditions as defined by MPTC.

Draft

Copy is invalid, only for ESIA Report

Article 8. PERFORMANCE GUARANTEES

8.1 CFOCN will undertake to establish a reliable control and quality measurement system for its services to ensure compliance with ITU and other established standards and practices, or developing technology that may become commercially available, to the reasonable satisfaction of MPTC.

8.2 CFOCN shall demonstrate its ability to comply with the following requirements:

i) The network operation must be designed to operate 24 hours a day, 365 days a year, except the planned down time that is expected in maintenance and development of services and failures that are encountered in the operation of the network;

ii) CFOCN will have an obligation to ensure that all failures in the network will be rectified and service restored without undue delay;

iii) General service quality shall be acceptable in accordance with ITU standards;

iv) CFOCN will use its best efforts to minimize down time for external maintenance and network development.

Article 9. RELATIONSHIP WITH CUSTOMERS

CFOCN shall make its services available to all licensed telecommunications operators on the same fair and reasonable terms.

CFOCN shall offer service agreements to all duly licensed telecommunications service providers, establishing a full set of terms and conditions of service in accordance with this license and applicable laws.

Draft

Copy is invalid, only for ESCA Report

Article 10. TARIFF AND BILLING

10.1 Tariffs for services provided in the Network will be determined by CFOCN, in compliance with the minimum tariff guidelines established by the MPTC, as telecommunications regulator

10.2 CFOCN shall keep its customers informed of the tariff rates and any changes to such tariff rates.

Article 11. PROVISION OF INFORMATION

11.1 CFOCN will provide to MPTC with technical, administrative and financial information reasonably required for the control of and compliance with the terms of the License

11.2 CFOCN shall produce a yearly audited report in accordance with international accounting practices and shall submit such report to the MPTC every year

Article 12. COVERAGE

This License covers the entire territory of the Kingdom of Cambodia

Article 13. LICENSE FEES

CFOCN shall pay annually within 90 (ninety) days from the end of each relevant year, to the Royal Government of Cambodia (MPTC), as License fees, the following percentage of the Gross Revenue, derived from the services and operation of the Optical Fiber Cable system and other related infrastructure, as detailed below

Year 1 to Year 5	1% (One per cent) of Gross Revenue
Year 6 to Year 10	2% (Two per cent) of Gross Revenue
From year 11 to year 35	3% (Three per cent) of Gross Revenue

Copy is invalid, only for ESIA Report

Draft

The payment of licence fees for the 1st (first) year shall be applied from the date of commercial operation of the optical fiber cable system.

CFOCN is to maintain true and accurate financial records, particularly of revenue collected.

13.1 **VERIFICATION OF GROSS REVENUE**

For the purposes of verification of gross revenue, the data records kept at the Network Management Centre of CFOCN shall be made available to the Ministry of Posts and Telecommunications and/or the Ministry of Economy and Finances quarterly subject to the confidentiality obligations set out in clause of this license.

CFOCN shall cause no hindrance to MPTC staff in accessing to the above records and make their pro rata share of the payment of fees that will be reviewed from time to time by the MPTC or Royal Telecommunication Regulator of Cambodia, in accordance with the applicable law and regulations.

Article 14 . **FISCAL AND ADMINISTRATIVE MATTERS**

14.1 **TAXES AND DUTIES**

CFOCN shall pay taxes and duties to the Ministry of Economy and Finance, in accordance with the investment law, other applicable Laws, rules and regulations.

14.2 **BANKS ACCOUNTS, REMITTANCE OF PROFIT AND WORKING PERMITS**

Draft

Copy is invalid, only for ESIA Report

CFOCN shall be permitted to operate onshore and offshore banks accounts as the operating bank accounts for the services, and

CFOCN is permitted to remit any profits to overseas in accordance with the applicable laws, regulations and through proper procedure.

CFOCN shall have the right to bring to Cambodia, the foreign staff for the project requirement, in accordance with the laws and regulations.

Article 15. **FINANCE, ACCOUNTING AND OTHER REPORTS**

The financial year of CFOCN shall start on January 1st and end on 31st December. Annual financial statement prepared in accordance with international accounting standard (IAS) shall be prepared and delivered to the Ministry of Posts and Telecommunications of Cambodia and to the Ministry of Economy and Finance within 90 days from the end of each year.

An annual audit shall be conducted by an internationally recognized accounting firm approved by both parties, the results of which shall comply with the Ministry of Economy & Finance guidelines and shall be supplied to the Ministry of Posts and Telecommunications of Cambodia and to the Ministry of Economy and Finance.

Article 16. **SUNSET PRINCIPLE**

In accordance with the Sunset Principle of Royal Government of Cambodia, CFOCN shall implement the Sunset Principle of 05 (five) years from the signature of the Agreement dated April 6, 2002, in which MPTC will not allow any private investment project on the construction of Optical Fiber Cable Backbone System in the Kingdom of Cambodia. The

Copy is invalid, only for ESIA Report

Draft

Sun Set Principle shall not cover the State Projects or other State investment projects through Grant Aid or Loans.

CFOCN shall hold the right to cooperate with other potential partner to implement this investment project.

Article 17. **LICENSE TERMS**

17.1 **DURATION**

The duration of this license shall be thirty-five (35) years commencing from the issuance date of this license, which may be extended to CFOCN under new Term of Reference, through additional Agreement.

17.2 **EXTENSION**

At least 01 (one) year, before the expiry date of this license, CFOCN may write to the MPTC to request the approval for an extension to the license.

Article 18. **ASSIGNMENT AND SUBCONTRACT**

CFOCN shall not be allowed to assign, partly or wholly this license to any third party, unless CFOCN has implemented at least 30% of the project and with prior written consent of the MPTC.

However, CFOCN has the right to cooperate with any other potential partner to implement this project through the prior written consent of the MPTC.

The assignment in part or in whole to any third party or the cooperation with any other partner to the same extent as assignment, shall not release CFOCN from its obligations under the Agreement and this License, unless

Copy is invalid, only for ESIA Report

Draft

the third party directly signs an Agreement with CFOCN, in which case, the third party shall be directly liable to CFOCN.

CFOCN may, at its discretion, subcontract to other parties for the provision of Services and/or operation of the Network, which may be otherwise provided for under this License.

MPTC may, at any time and subject to the reasonable notice, modify, revoke and add the special or additional conditions to this license, in accordance with the applicable laws and regulations.

Article 19. CONFIDENTIALITY

19.1 CFOCN shall assure confidentiality of confidential information received from or about its customers as well as any third parties, and shall not disclose such information without explicit agreement from those concerned.

19.2 Confidential information shall be used exclusively for the purpose for which it was disclosed, unless otherwise agreed by those concerned.

19.3 In the event that any confidential information, as mentioned above, is required in accordance with Cambodian law, such information will be disclosed to relevant authority(ies) following due formal procedures.

Article 20. TERMINATION

MPTC may terminate this license upon 90 (ninety) days notice to CFOCN, if CFOCN has committed a material breach of this license and, if such a breach, has not been remedied by CFOCN, within 30 (thirty) days of receiving notice to remedy from MPTC.

Draft

Copy is invalid, only for ESIA Report

Article 21. **FORCE MAJEURE**

Neither party shall be liable for any breach of any terms and conditions this License that are caused by act of God, insurrection or civil disorder, war or military operations, national or local emergency, compliance with any statutory obligation, industrial disputes of any kind, fire, lightning, explosion, flood, subsistence, weather of exceptional severity, acts or omissions of persons for whom neither party to this License is responsible or any other cause whether similar or dissimilar outside its reasonable control.

Article 22. **DISPUTE RESOLUTION**

The MPTC and the CFOCN agree to use their best endeavors to resolve any dispute by negotiation. Where the parties are unable to resolve any negotiation within thirty (30) days, the dispute shall be resolved under the Rules of Reconciliation and Arbitration of the International Chamber of Commerce by one or more arbitrators appointed in accordance with the said rules. The place of the arbitration shall be Singapore and the proceedings shall be conducted in the English language. The award shall be final and binding upon the parties.

Article 23. **APPLICABLE LEGISLATION**

23.1 CFOCN's activities determined by the conditions of this License are governed by Cambodian legislation and by the terms of this License, as well as by any pacts, agreements and treaties subscribed and ratified by the Royal Government of Cambodia.

23.2 In the event of new laws or changes of interpretation of existing laws that in any way adversely affect the commercial or operating

Draft

Copy is invalid, only for ESIA Report

conditions under this License, MPTC shall cause the Royal Government of Cambodia to make the necessary adjustment to enable a smooth continuation of the operation of the Network and the provisions of the Services.

Article 24. GENERAL

This License is made in English and Khmer language provided that, in case of conflict, the parties hereto agree that the English language version is the official and definitive text of this License.

ISSUED BY:

THE MINISTRY OF POSTS AND TELECOMMUNICATIONS OF THE KINGDOM OF CAMBODIA (MPTC)

Name: ILE SO KHUN

Title: MINISTER

ACCEPTED BY:

Cambodia Fiber Optic Communication Network Co., Ltd. (CFOCN)

Name: Mr. Huang Xinghong

Title: Chairman of CFOCN

Draft

Copy is invalid, only for ESIA Report

១.៥ លិខិតឆ្លងដែននាយកក្រុមហ៊ុន



១.៦ លក្ខន្តិក: ក្រុមហ៊ុន (ខេមបូឌា) ហ្វីប៊ើរ អុបទិច ខមញ្ញូនីខេសិន

លក្ខន្តិក:

ក្រុមហ៊ុន (ខេមបូឌា) ហ្វីប៊ើរ អុបទិច ខមញ្ញូនីខេសិន

ណេតវើក

(ក្រុមហ៊ុនឯកជនដែលមានកម្រិត)

STATUTE

OF

(CAMBODIA) FIBER OPTIC COMMUNICATION NETWORK Co., Ltd.

(Private Limited Company)

Draft

ដើមទុនចុះបញ្ជី : ៣,000,000 ដុល្លារអាមេរិក

Registered Capital: USD 3,000,000

អាសយដ្ឋានស្នាក់ការរបស់ក្រុមហ៊ុន:

លេខ២៩ ផ្លូវលេខ៥៩២ សង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ

Copy is invalid, only for ESIA report

២០១៩

លក្ខន្តិកៈ

ក្រុមហ៊ុន (ខេមបូឌា) ហ្គីប៊ែរ អុបធិច ខមប្លិនខេសិន ឈែនហ៊ែក

(ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត)

ដើមទុនចុះបញ្ជី ៣,000,000 ដុល្លារអាមេរិក

***

យើងខ្ញុំមានឈ្មោះខាងក្រោម :

១- ក្រុមហ៊ុន CITIGOOD INTERNATIONAL LIMITED

តំណាងដោយ :

លោក HUANG XINGLONG ភេទប្រុស សញ្ជាតិ សិង្ហបុរី

ថ្ងៃ-ខែ-ឆ្នាំកំណើត ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ១៩៥៩

អាស័យដ្ឋាន BLK = 1, #101 ROAD SINGARA SI YOU, DONG SI AN DISTRICT, GUANG ZHOU, GUANG DONG.

អត្តសញ្ញាណប័ណ្ណលេខ E3636925D ចុះថ្ងៃទី១៧ ខែ មករា ឆ្នាំ២០១៣





២- ក្រុមហ៊ុន MAIN ASIA INVESTMENTS LIMITED

តំណាងដោយ :

លោក HUANG XINGLONG ភេទប្រុស សញ្ជាតិ សិង្ហបុរី

ថ្ងៃ-ខែ-ឆ្នាំកំណើត ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ១៩៥៩

អាស័យដ្ឋាន BLK = 1, #101 ROAD SINGARA SI YOU, DONG SHAN DISTRICT, GUANG ZHOU, GUANG DONG

អត្តសញ្ញាណប័ណ្ណលេខ E3636925D ចុះថ្ងៃទី១៧ ខែ មករា ឆ្នាំ២០១៣



បានរៀបចំលក្ខន្តិកៈនៃក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិតមួយ ទៅតាមការព្រមព្រៀងគ្នាដោយស្ម័គ្រចិត្ត និងតាមលក្ខណៈដូចតទៅ:

ផ្នែកទី ១

ទ្រង់ទ្រាយ កម្មវត្ថុ នាមករណ៍ ទីស្នាក់ការ ចំនួនភាគ

ប្រការ ១: ទ្រង់ទ្រាយក្រុមហ៊ុន

ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិតត្រូវបានបង្កើតឡើង នៃលក្ខណៈអាចមានម្ចាស់ប៉ុន្តែមួយមានចែងនៅប្រការខាងក្រោយ និងអាចមានបន្ថែមម្ចាស់ប៉ុន្មានទៀតក្រោយមកទៀត។

Copy is invalid, only for ESIA Report

ចាប់ពីថ្ងៃបានចុះបញ្ជីវិនិយោគ និង បញ្ជីពាណិជ្ជកម្ម តាមបញ្ញត្តិច្បាប់ ក្រុមហ៊ុនគឺចក្លាយទៅជានីតិបុគ្គលត្រឹមត្រូវ ស្ថិតក្រោមការគំរាមនៃបទបញ្ញត្តិទាំងឡាយដែលមានចែងក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុន និងក្រោមរដ្ឋាធម្មនុញ្ញរបស់ច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ។

